# ព្រះ

# ត្រៃបិដកបាលី

និង

## សេចក្ដីប្រែជាភាសាខ្មែរ

# វិនយបិដក

## មហាវិភង្គ ទុតិយភាគ

# ២

កោសេកកណ្ឌ និង អនិយតកណ្ឌ

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥៤៩

# វិនយបិដកមហាវគ្គ

## ទុតិយភាគ

## ២

## ភេសជ្ជខណ្ឌ ដល់ ចីវរខណ្ឌ

# តេរសកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ

## បឋមសង្ឃាទិសេសំ

[១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សេយ្យសកោ អនភិរតោ ព្រហ្មចរិយំ ចរតិ ។ សោ តេន កិសោ ហោតិ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ ។ អទ្ទសា ខោ អាយស្មា ឧទាយី អាយស្មន្តំ សេយ្យសកំ កិសំ លូខំ ទុព្ពណ្ណំ ឧប្បណ្ឌុប្បណ្ឌុកជាតំ ធមនិសន្ថតគត្តំ ទិស្វាន អាយស្មន្តំ សេយ្យសកំ ឯតទវោច កិស្ស ត្វំ អាវុសោ សេយ្យសក កិសោ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ កច្ចិ នោ ត្វំ អាវុសោ សេយ្យសក

# តេរសកណ្ឌំ

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះ សង្ឃាទិសេសទាំង ១៣ សិក្ខាបទនេះមកកាន់ឧទ្ទេស[១] ។

## សង្ឃាទិសេសទី ១

[១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ សេយ្យសកភិក្ខុដ៏មានអាយុ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ (បង់ស៊ឹក) ។ ដោយហេតុនោះ សេយ្យសកភិក្ខុក៏ទៅជាស្គាំងស្គមមានសម្បុរអាប់អន់ កើតមានពេកស្គមលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ ។ ឧទាយិភិក្ខុ[២] ដ៏មានអាយុ បានឃើញសេយ្យសកភិក្ខុដ៏មានអាយុស្គាំងស្គម មានសម្បុរអាប់អន់កើតមានពេកស្គមលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ លុះឃើញហើយ ទើបសួរសេយ្យសកភិក្ខុថា ម្នាលអាវុសោសេយ្យសក ហេតុអ្វី បានជាលោកស្គាំងស្គមមានសម្បុរអាប់អន់កើតមានពេកស្គមលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ (ដូច្នេះ) ម្នាលអាវុសោសេយ្យសក

១ បាឡីដែលសរសេរនៅខាងចុងខាងលើនៃសិក្ខាបទ ហៅថា ឧទ្ទេស ។ ២ អដ្ឋកថា ពន្យល់សេចក្តីថា ឧទាយិត្ថេរនេះជាឧបជ្ឈាយ៍របស់សេយ្យសកភិក្ខុ ។

អនភិរតោ ព្រហ្មចរិយំ ចរសីតិ ។ ឯវមាវុសោតិ ។ តេនហិ ត្វំ អាវុសោ សេយ្យសក យាវទត្ថំ ភុញ្ជ យាវទត្ថំ សុប យាវទត្ថំ នហាយ យាវទត្ថំ ភុញ្ជិត្វា យាវទត្ថំ សុបិត្វា យាវទត្ថំ នហាយិត្វា យទា តេ អនភិរតិ ឧប្បជ្ជតិ រាគោ ចិត្តំ អនុទ្ធំសេតិ តទា ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេហីតិ ។ កិន្នុ ខោ អាវុសោ កប្បតិ ឯវរូបំ កាតុន្តិ ។ អាមាវុសោ អហម្បិ ឯវរូបំ(១) ករោមីតិ ។ អថខោ អាយស្មា សេយ្យ-សកោ យាវទត្ថំ ភុញ្ជិ យាវទត្ថំ សុបិ យាវទត្ថំ នហាយិ យាវទត្ថំ ភុញ្ជិត្វា យាវទត្ថំ សុបិត្វា យាវទត្ថំ នហាយិត្វា យទា អនភិរតិ ឧប្បជ្ជតិ រាគោ ចិត្តំ អនុទ្ធំសេតិ តទា ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេតិ(២) ។ អថខោ អាយ-ស្មា សេយ្យសកោ អបរេន សមយេន វណ្ណវា អហោសិ បីណិន្ទ្រិយោ(៣) បសន្នមុខវណ្ណោ វិប្បសន្នឆវិវណ្ណោ ។ អ-ថខោ អាយស្មតោ សេយ្យសកស្ស សហាយកា ភិក្ខូ អាយស្មន្តំ សេយ្យសកំ ឯតទវោចុំ បុព្វេ ខោ ត្វំ អាវុ-សោ សេយ្យសក កិសោ អហោសិ លូខោ ទុព្វណ្ណោ

១ ឱ. ច. ឯវំ ។ ២ ឱ. ម. មោចេសិ ។ ៣ ម. បីណិន្ទ្រិយោ ។



លោកមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឬអ៊ី ។ សេយ្យសកភិក្ខុឆ្លើយថា ករុណា អាវុសោ ។ ឧទាយិភិក្ខុប្រាប់ថា ម្នាលអាវុសោសេយ្យសក បើដូច្នោះ លោកចូរឆាន់ឲ្យឆ្អែតសឹងឲ្យស្កប់ស្រង់ឲ្យពេញចំណង់ទៅ លុះឆាន់ឆ្អែតសឹងស្កប់ស្រង់ពេញចំណង់ហើយ កាលណាបើសេចក្ដីអផ្សុកកើតមានដល់លោក តម្រេកសង្កត់ចិត្តលោក លោកចូរព្យាយាមដោយដៃញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាលនោះចុះ ។ សេយ្យសក-ភិក្ខុសួរថា ម្នាលអាវុសោ កិរិយាដែលសមណៈធ្វើយ៉ាងនេះគួរដែរឬ ។ ឧទាយិឆ្លើយថា ករុណា អាវុសោ ខ្ញុំក៏ធ្វើយ៉ាងនេះដែរ ។ លំដាប់តពីនោះមក សេយ្យសកដ៏មានអាយុ ក៏ឆាន់ទាល់តែឆ្អែត សឹងទាល់តែស្កប់ស្រង់ទាល់តែពេញចំណង់ លុះឆាន់ឆ្អែត សឹងស្កប់ ស្រង់ពេញចំណង់ហើយ កាលណាសេចក្ដីអផ្សុកកើតឡើង តម្រេកសង្កត់ចិត្ត ក៏ព្យាយាមដោយដៃញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាលនោះ ។ គ្រាតមកសេយ្យ-សកភិក្ខុក៏ត្រឡប់ជាមានសម្បុរមានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ មានសម្បុរស្បែកដ៏ផូរផង់ឡើងវិញ ។ គ្រានោះពួកភិក្ខុដែលជាសំឡាញ់របស់សេយ្យសកដ៏មានអាយុ ក៏សួរសេយ្យសកដ៏មានអាយុថា ម្នាលអាវុសោសេយ្យសក កាលពីដើមលោកស្គាំងស្គម មានសម្បុរអាប់អួ

ទុព្វណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ សោ ទានិ ត្វំ ឯតរហិ វណ្ណវា បីនិន្ទ្រិយោ(១) បសន្នមុខវណ្ណោ វិប្បសន្នឆវិវណ្ណោ កិន្នុ ខោ ត្វំ អាវុសោ សេយ្យសក ភេសជ្ជំ ករោសីតិ ។ ន ខោ អហំ អាវុសោ ភេសជ្ជំ ករោមិ អបិចាហំ យាវទត្ថំ ភុញ្ជាមិ យាវទត្ថំ សុបាមិ យាវទត្ថំ នហាយាមិ យាវទត្ថំ ភុញ្ជិត្វា យាវទត្ថំ សុបិត្វា យាវទត្ថំ នហាយិត្វា យទា មេ អនភិរតិ ឧប្បជ្ជតិ រាគោ ចិត្តំ អនុទ្ធំសេតិ តទា ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេមីតិ ។ កឹ បន ត្វំ អាវុសោ សេយ្យសក យេនេវ ហត្ថេន សទ្ធាទេយ្យំ ភុញ្ជសិ តេនេវ ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេសីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំហិ នាម អាយស្មា សេយ្យសកោ ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេស្សតីតិ ។ អថខោ តេ ភិក្ខូ អាយស្មន្តំ សេយ្យសកំ អនេកបរិយាយេន វិគរហិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ

១ ម. បីណិន្ទ្រិយោ ។



កើតទៅជាពណ៌ស្លេកស្លាំង មានខ្លួនពេញដោយសរសៃ ឥឡូវនេះលោកមានសម្បុរ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់ស្រាយ មានសម្បុរស្បែកផូរផង់ឡើងវិញ លោកបានធ្វើថ្នាំអ្វី (ទេ) អាវុសោសេយ្យសក ។ សេយ្យសកភិក្ខុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ខ្ញុំគ្មានធ្វើថ្នាំអ្វី (ទេ) ទេ តែខ្ញុំបានឆាន់ឆ្អែតសិងស្កប់ស្រង់ទឹកពេញចំណង់ លុះបានឆាន់ឆ្អែតសិងស្កប់ស្រង់ទឹកពេញចំណង់ហើយ កាលណាសេចក្តីអផ្សុកកើតឡើង រាគក៏គ្របសង្កត់ចិត្តខ្ញុំ ៗ ព្យាយាមបញ្ចេញទឹកអសុចិដោយដៃក្នុងកាលនោះ ។ ទើបពួកភិក្ខុជាសំឡាញ់សួរថា ម្នាលអាវុសោសេយ្យសក លោកទទួលបរិភោគនូវរបស់ដែលគេឲ្យដោយសទ្ធា ដោយដៃណា លោកក៏ព្យាយាមបញ្ចេញទឹកអសុចិដោយដៃនោះឯង ឬអ្វី ។ សេយ្យសកឆ្លើយថា ម្នាលអាវុសោទាំងឡាយ ពិតដូច្នោះឯង ។ ភិក្ខុទាំងឡាយណាដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀលថា ហេតុអ្វីបានជាសេយ្យសកដ៏មានអាយុ ព្យាយាមបញ្ចេញទឹកអសុចិដោយដៃ (ដូច្នេះ) ។ គ្រានោះ ពួកភិក្ខុទាំងនោះតិះដៀលសេយ្យសកដ៏មានអាយុ ដោយអនេកបរិយាយហើយ បានក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ទើបព្រះដ៏មានព្រះភាគ អាស្រ័យហេតុនេះ

ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អា-
យស្មន្តំ សេយ្យសកំ បដិបុច្ឆិ សច្ចំ កិរ ត្វំ សេយ្យ-
សក ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេសីតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ
មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ
អកប្បិយំ អករណីយំ កថញ្ហិ នាម ត្វំ មោ-
ឃបុរិស ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេស្សសិ
ននុ មយា មោឃបុរិស អនេកបរិយាយេន វិរាគាយ
ធម្មោ ទេសិតោ នោ សរាគាយ វិសំយោគាយ ធម្មោ
ទេសិតោ នោ សំយោគាយ អនុបាទានាយ ធម្មោ
ទេសិតោ នោ សឧបាទានាយ តត្ថ នាម ត្វំ មោ-
ឃបុរិស មយា វិរាគាយ ធម្មេ ទេសិតេ សរាគាយ
ចេតេស្សសិ វិសំយោគាយ ធម្មេ ទេសិតេ សំយោ-
គាយ ចេតេស្សសិ អនុបាទានាយ ធម្មេ ទេសិតេ



កាប្រែយដំណើរនេះ ទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរចំពោះ
ទៅសេយ្យសកដ៏មានអាយុថា ម្នាលសេយ្យសក ឮថាអ្នកឯងព្យា-
យាមញ៉ាំងទឹកអសុចិឲ្យឃ្លាតចេញដោយដៃមែនឬ ។ សេយ្យសកទូលតប
ថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់
តិះដៀលថា ម្នាលបុរសឥតអំពើ កម្មនុះមិនសមគួរ មិនត្រូវទំនង មិនត្រូវ
ផ្លូវ មិនមែនជារបស់សមណ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលមោឃ-
បុរស ហេតុអ្វីក៏អ្នកឯងព្យាយាមបញ្ចេញទឹកអសុចិដោយដៃ (ដូច្នេះ)
ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយបរិយាយដ៏ច្រើន
(សព្វគ្រា) ដើម្បីឲ្យប្រាសចាកតម្រេក មិនមែនដើម្បីប្រកបដោយតម្រេកទេ ធម៌
ដែលតថាគតសំដែងហើយដើម្បីឲ្យប្រាសចាកគ្រឿងប្រកប មិនមែនដើម្បី
គ្រឿងប្រកបទេ ធម៌ដែលតថាគតសំដែងហើយដើម្បីឲ្យប្រាសចាកសេចក្តី
ប្រកាន់មាំ មិនមែនដើម្បីសេចក្តីប្រកាន់មាំទេ (ដូច្នេះ) មិនមែនឬ ម្នាល
មោឃបុរស កាលបើធម៌ដែលតថាគតសំដែងហើយ (សព្វគ្រា) ដើម្បីឲ្យ
ប្រាសចាកតម្រេក អ្នកឯងនៅតែរិះគិតត្រិះរិះដើម្បីប្រកបដោយតម្រេកទៅ
វិញ កាលបើធម៌ដែលតថាគតសំដែងហើយដើម្បីឲ្យប្រាសចាកគ្រឿងប្រ-
កប អ្នកឯងនៅតែរិះគិតដើម្បីគ្រឿងប្រកបវិញ កាលបើធម៌ដែលតថាគត

សឧបាទានាយ ចេតេស្សសិ ននុ មយា មោឃ-
បុរិស អនេកបរិយាយេន រាគវិរាគាយ ធម្មោ
ទេសិតោ មទនិម្មទនាយ បិបាសវិនយាយ អាលយ-
សមុគ្ឃាតាយ វដ្ដុបច្ឆេទាយ តណ្ហក្ខយាយ
វិរាគាយ និរោធាយ និព្វានាយ ធម្មោ ទេសិតោ
ននុ មយា មោឃបុរិស អនេកបរិយាយេន
កាមានំ បហានំ អក្ខាតំ កាមសញ្ញានំ បរិញ្ញា
អក្ខាតា កាមបិបាសានំ បដិវិនយោ អក្ខាតោ កាម
វិតក្កានំ សមុគ្ឃាតោ អក្ខាតោ កាមបរិឡាហានំ
វូបសមោ អក្ខាតោ នេតំ មោឃបុរិស អប្បសន្នានំ
វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថ-
ខ្វេតំ មោឃបុរិស អប្បសន្នានញ្ចេវ អប្បសាទាយ



សំដែងហើយ ដើម្បីឲ្យប្រាសចាកសេចក្ដីប្រកាន់ អ្នកឯងនឹងបែរជាគិត ដើម្បីប្រកបដោយសេចក្ដីប្រកាន់វិញ ម្នាលមោឃបុរស តើមិនមែន តថាគតសំដែងធម៌ហើយដោយបរិយាយដ៏ច្រើន (ស្គូក) ដើម្បីនឿយណាយចាករាគៈ ដើម្បីញាំញីនូវសេចក្ដីស្រវឹង ដើម្បីបន្ទោបង់នូវសេចក្ដីស្រេក ដើម្បីដករំលើងនូវសេចក្ដីអាល័យ ដើម្បីកាត់ផ្តាច់នូវវដ្ដ ដើម្បីឲ្យអស់ទៅនៃតណ្ហា ដើម្បីឲ្យប្រាសចាករាគៈ ដើម្បីកិរិយារលត់ ដើម្បីនិព្វាន (ផុតទុក្ខ) មិនមែនឬ ម្នាលមោឃបុរស កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយដោយអនេកបរិយាយ កិរិយាកំណត់ដឹងនូវសេចក្ដីសំគាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាបន្ទោបង់នូវសេចក្ដីស្រេកក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាដករំលើងនូវកាមវិតក្កទាំងឡាយ តថាគតបានសំដែងហើយ កិរិយារម្ងាប់បង់នូវសេចក្ដីក្ដៅក្រហាយព្រោះកាមទាំងឡាយ តថាគតបានសំដែងហើយ, មិនមែនឬ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនុ៎ះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា (នោះ) ទេ មិនមែននាំឲ្យរឹតតែជ្រះថ្លាឡើងដល់ជនទាំងឡាយដែលមានសេចក្ដីជ្រះថ្លាហើយ (នោះ) ទេ ម្នាលមោឃបុរស អំពើរបស់អ្នកឯងនុ៎ះ បាននាំតែមិនឲ្យជ្រះថ្លាដល់ពួកជនខ្លះដែលមិនទាន់

បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយ ហោតិ ។ អថខោ ភគវា អាយស្មន្តំ សេយ្យសកំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ទុប្បោសតាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សញ្ចេតនិកា សុក្កវិស្សដ្ឋិ សង្ឃាទិសេសោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២] តេន ខោ បន សមយេន ភិក្ខូ បណីតភោជនានិ ភុញ្ជិត្វា មុដ្ឋស្សតី អសម្បជានា និទ្ទំ ឱក្កមន្តិ ។ តេសំ មុដ្ឋស្សតីនំ អសម្បជានានំ និទ្ទំ ឱក្កមន្តានំ សុបិនន្តេន អសុចិ មុច្ចតិ ។ តេសំ កុក្កុច្ចំ អហោសិ ភគវតា សិក្ខាបទំ បញ្ញត្តំ សញ្ចេតនិកា សុក្កវិស្សដ្ឋិ សង្ឃាទិសេសោតិ អម្ហាកញ្ច សុបិនន្តេន អសុចិ មុច្ចតិ(១) អត្ថិ ចេត្ថ ចេតនា ឧបលព្ភតិ(២) កច្ចិ នុ ខោ មយំ សង្ឃាទិសេសំ អាបត្តឹ អាបន្នាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១។ មុច្ចិ ។ ២ ម. លព្ភ ។



មានសេចក្តីជ្រះថ្លា តែជាទីនាំឲ្យពួកជនដែលមិនទាន់មានសេចក្តីជ្រះថ្លា មិនជ្រះថ្លា ហើយពួកជនដែលមានសេចក្តីជ្រះថ្លាហើយ (ឲ្យ) ប្រែប្រួលប៉ុណ្ណោះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលលោកសេយ្យសកភិក្ខុដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃសេចក្តីដែលជាហេតុនាំឲ្យគេចិញ្ចឹមបីបាច់ក្រ ចិញ្ចឹមបានដោយក្រ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុមានចិត្តគិតញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង ។

[២] សម័យនោះ ភិក្ខុទាំងឡាយបានឆាន់បណីតភោជនទាំងឡាយ ហើយភ្លេចស្មារតីមិនដឹងខ្លួនសឹងលក់ទៅ ។ កាលបើភិក្ខុទាំងនោះកំពុងតែភ្លេចស្មារតីមិនដឹងខ្លួនសឹងលក់ ទឹកអសុចិក៏ឃ្លាតចេញដោយយល់សប្តិ ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យថា សិក្ខាបទព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយថា ភិក្ខុក្លែងញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស តែទឹកអសុចិរបស់យើងទាំងឡាយឃ្លាតចេញដោយយល់សប្តិ ឯចេតនាក៏មានក្នុងកាលដែលយល់សប្តិនោះដែរ យើងត្រូវអាបត្តិសង្ឃាទិសេសហើយឬ ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

នេតំ ភិក្ខវេ អប្បសន្នានំ វា ។ បេ ។ អញ្ញថត្តាយាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សញ្ចេតនិកា សុក្កវិស្សដ្ឋិ អញ្ញត្រ សុបិនន្តា សង្ឃាទិសេសោតិ ។

[៣] សញ្ចេតនិកាតិ ជានន្តោ សញ្ជានន្តោ ចេច្ច អភិវិតរិត្វា វីតិក្កមោ ។ សុក្កន្តិ ទស សុក្កានិ នីលំ បីតកំ លោហិតកំ ឱទាតំ តក្កវណ្ណំ ទកវណ្ណំ តេលវណ្ណំ ខីរវណ្ណំ ទធិវណ្ណំ សប្បិវណ្ណំ ។ វិស្សដ្ឋីតិ ឋានា[១] ចាវនា វុច្ចតិ វិស្សដ្ឋីតិ ។ អញ្ញត្រ សុបិនន្តាតិ ឋបេត្វា សុបិនន្តំ ។

១ ម. ឋានតោ ។



ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អំពើនុ៎ះមិនមែន ប៉ុន្តែអំពើនុ៎ះជាអញ្ញថាភាព[១] ។ ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យដំណើរនេះជាហេតុ អាស្រ័យដំណើរនេះជាទីតាំង ទើបទ្រង់សំដែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុក្លែងញ៉ាំងទឹកសុក្កឱ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស វៀរលែងតែយល់សប្តិ ។

[៣] ត្រង់ពាក្យថា ភិក្ខុក្លែង សេចក្ដីថា ភិក្ខុកំពុងដឹង ភិក្ខុដឹងច្បាស់ហើយក្លែងបំពានធ្វើឲ្យកន្លង ។ ត្រង់ពាក្យថា ទឹកសុក្ក សេចក្ដីថា ទឹកសុក្កមាន ១០ យ៉ាង គឺទឹកសុក្កពណ៌ខៀវ ១ ទឹកសុក្កពណ៌លឿង ១ ទឹកសុក្កពណ៌ក្រហម ១ ទឹកសុក្កពណ៌ស ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរទើបនឹងកូរ ១ ទឹកសុក្កពណ៌ដូចទឹក ១ ទឹកសុក្កពណ៌ដូចប្រេង ១ ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរ ១ ទឹកសុក្កពណ៌ដូចទឹកដោះថ្លា ១ ។ ត្រង់ពាក្យថា ឲ្យឃ្លាតចេញ សេចក្ដីថា ឲ្យកម្រើកឃ្លាតចេញចាកទីកន្លែង (ដើម) កំពុងតែហៅថា ឲ្យឃ្លាតចេញ ។ ត្រង់ពាក្យថា វៀរលែងតែយល់សប្តិ (នោះ) សេចក្ដីថា វៀរលែងតែយល់សប្តិ ។

១ អញ្ញថាភាព ប្រែថា មិនជ្រះថ្លាសព្វៗគ្នា គឺថា មិនជ្រះថ្លាដោយយកហេតុដែលខ្លួនធ្លាប់ឃើញនោះទៀតឡើយ ឬថា មិនមែនជាហេតុឲ្យកើតសេចក្ដីជ្រះថ្លាណាមួយឡើយ ។

សង្ឃាទិសេសោតិ សង្ឃោវ តស្សា អាបត្តិយា បរិវាសំ ទេតិ មូលាយ បដិកស្សតិ មានត្តំ ទេតិ អព្ភេតិ ន សម្ពហុលា ន ឯកបុគ្គលោ តេន វុច្ចតិ សង្ឃាទិសេសោតិ ។ តស្សេវ អាបត្តិនិកាយស្ស នាមកម្មំ អធិវចនំ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

[៤] អជ្ឈត្តរូបេ មោចេតិ ពហិទ្ធារូបេ មោចេតិ អជ្ឈត្តពហិទ្ធារូបេ មោចេតិ អាកាសេ កដិំ កម្បេន្តោ មោចេតិ រាគូបត្ថម្ភេ មោចេតិ វច្ចូបត្ថម្ភេ មោចេតិ បស្សាវូបត្ថម្ភេ មោចេតិ វាតូបត្ថម្ភេ មោចេតិ ឧច្ចាលិង្គបាណកទដ្ឋូបត្ថម្ភេ មោចេតិ អារោគ្យត្ថាយ មោចេតិ សុខត្ថាយ មោចេតិ



ត្រង់ពាក្យថា សង្ឃាទិសេស (នោះ) សេចក្តីថា សង្ឃតែម្យ៉ាងដែលឲ្យនូវបរិវាសព្រោះអាបត្តិនោះ ត្រឡប់សើរើទាញមកមូលាបត្តិ ឲ្យនូវមានត្ត ឲ្យនូវអព្ភាន មិនមែនភិក្ខុច្រើនរូប មិនមែនបុគ្គលតែ ១ រូប ព្រោះហេតុនោះ បានជាលោកហៅថា សង្ឃាទិសេស ។ ម្យ៉ាងទៀតថា ជានាមកម្ម គឺជាឈ្មោះរបស់កងអាបត្តិនោះឯង ព្រោះហេតុនោះ បានជាហៅថា សង្ឃាទិសេស ។

(៤) ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុង (អវយវៈខ្លួនឯង) ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្រៅ (អវយវៈអ្នកដទៃ) ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុងនិងរូបខាងក្រៅ ភិក្ខុញ៉ាំងចង្កេះឲ្យញ័រក្នុងអាកាសញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីតប្បត្ថម្ភដោយរាគ ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីតប្បត្ថម្ភដោយលាមក ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីតប្បត្ថម្ភដោយមូត្រ ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីតប្បត្ថម្ភដោយខ្យល់ ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីតប្បត្ថម្ភដោយដង្កូវរមាស់ពល ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍មិនឲ្យមានរោគ ភិក្ខុញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ

ភេសជ្ជត្ថាយ ហោតិ ទានត្ថាយ ហោតិ បុញ្ញត្ថាយ ហោតិ យញ្ញត្ថាយ ហោតិ សគ្គត្ថាយ ហោតិ ពីជត្ថាយ ហោតិ វីមំសត្ថាយ ហោតិ ទវត្ថាយ ហោតិ នីលំ ហោតិ បីតកំ ហោតិ លោហិតកំ ហោតិ ឱទាតំ ហោតិ តក្កវណ្ណំ ហោតិ ទកវណ្ណំ ហោតិ តេលវណ្ណំ ហោតិ ខីរវណ្ណំ ហោតិ ទធិវណ្ណំ ហោតិ សប្បិវណ្ណំ ហោតិ ។

[៥] អជ្ឈត្តរូបេតិ អជ្ឈត្តំ ឧបាទិន្នរូបេ ។ ពហិទ្ធារូបេតិ ពហិទ្ធា ឧបាទិន្នេ វា អនុបាទិន្នេ វា ។



កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីត្រូវការដោយភេសជ្ជៈ កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ទាន កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់បុណ្យ កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការបូជា កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ឋានសួគ៌ កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ពូជ កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការល្បងមើល កិច្ចញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការលេង កិច្ចញ៉ាំងទឹកសុក្កពណ៌ខៀវឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌លឿងឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ក្រហមឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌សឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះជូរលាយនឹងពុះឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចទឹកឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចប្រេងឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះជូរឲ្យឃ្លាតចេញ កិច្ចញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះថ្លាឲ្យឃ្លាតចេញ ។

[៥] ត្រង់ពាក្យថា ក្នុងរូបខាងក្នុង សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណ ចូលទៅកាន់ស្រើយនៅជាខាងក្នុង ។ ត្រង់ពាក្យថា ក្នុងរូបខាងក្រៅ សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណក្តី ក្នុងរូបដែលឥតវិញ្ញាណក្តី ជាខាងក្រៅ ។

អជ្ឈត្តពហិទ្ធារូបេហិ អនុករេយ្យ ។ អាកាសេ គមិ-កម្បេត្វាតិ អាកាសេ ភយមត្តស្ស អត្តជាតំ កម្ម-និយំ ហោតិ ។ ភយបច្ចយាតិ ភយេន បីឡិតស្ស អត្តជាតំ កម្មនិយំ ហោតិ ។ វាឡបច្ចយាតិ វាឡេន បីឡិតស្ស អត្តជាតំ កម្មនិយំ ហោតិ ។ មនុស្សបច្ចយាតិ មនុស្សេហិ បីឡិតស្ស អត្តជាតំ កម្មនិយំ ហោតិ ។ វាតបច្ចយាតិ វាតេន បីឡិតស្ស អត្តជាតំ កម្មនិយំ ហោតិ ។ ឧច្ចាលិង្គបាណកទដ្ឋបច្ចយាតិ ឧច្ចាលិង្គបា-ណកទដ្ឋេន បីឡិតស្ស អត្តជាតំ កម្មនិយំ ហោតិ ។ អារោគ្យត្ថាយាតិ អរោគោ ភវិស្សាមីតិ ។ សុខត្ថា-យាតិ សុខំ វេទនំ ឧប្បាទេស្សាមីតិ ។ ភេសជ្ជត្ថាយាតិ





ត្រង់ពាក្យថា គឺរូបខាងក្នុងនិងរូបខាងក្រៅ សេចក្តីថា គឺរូបទាំងនោះ ។ ត្រង់ពាក្យថា ដើរចង្ក្រមឡើងក្នុងអាកាស សេចក្តីថា អត្តជាតរបស់ភិក្ខុដែលដើរចង្ក្រមទៅក្នុងអាកាស គឺជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីចង្អៀតដោយភយៈ សេចក្តីថា អត្តជាតរបស់ភិក្ខុដែលភយៈបៀតបៀនហើយ ជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីចង្អៀតដោយលាមក សេចក្តីថា អត្តជាតរបស់ភិក្ខុដែលលាមកបៀតបៀនហើយ ជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីចង្អៀតដោយមនុស្ស សេចក្តីថា អត្តជាតរបស់ភិក្ខុដែលមនុស្សបៀតបៀនហើយ ជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីចង្អៀតដោយខ្យល់ សេចក្តីថា អត្តជាតរបស់ភិក្ខុដែលខ្យល់បក់ត្រូវហើយ ជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីចង្អៀតដោយដង្កូវរមាស់កោល សេចក្តីថា អត្តជាតរបស់ភិក្ខុដែលដង្កូវរមាស់កោលបៀតបៀនហើយ ជាអាយតនៈគួរដល់កម្ម ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍មិនឲ្យមានរោគ សេចក្តីថា គិតថា អញនឹងជាអ្នកមិនមានរោគ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ សេចក្តីថា គិតថា អញនឹងញ៉ាំងសុខវេទនាឲ្យកើតឡើង ។ ត្រង់ពាក្យថា ដើម្បីត្រេកអរដោយភេសជ្ជៈ សេចក្តីថា

ភេសជ្ជំ ភវិស្សតីតិ ។ ទានត្ថាយាតិ ទានំ ទស្សាមីតិ ។ បុញ្ញត្ថាយាតិ បុញ្ញំ ភវិស្សតីតិ ។ យញ្ញត្ថាយាតិ យញ្ញំ យជិស្សាមីតិ ។ សគ្គត្ថាយាតិ សគ្គំ គមិស្សាមីតិ ។ ពីជត្ថាយាតិ ពីជំ ភវិស្សតីតិ ។ វីមំសត្ថាយាតិ វីមំសិស្សាមិ[១] នីលំ ភវិស្សតិ បីតកំ ភវិស្សតិ លោហិតកំ ភវិស្សតិ ឱទាតំ ភវិស្សតិ ។ បេ ។ សប្បិវណ្ណំ ភវិស្សតីតិ ។ ទវត្ថាយាតិ ខិឌ្ឌាធិប្បាយោ ។

[៦] អជ្ឈត្តរូបេ មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ពហិទ្ធារូបេ មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អជ្ឈត្តពហិទ្ធារូបេ មោចេតិ ឧបក្កមតិ មុច្ចតិ

១ ឱ. ម. ពោត្ថកេសុ អយំ បាឋោ ន បញ្ញាយតិ ។



ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាឱសថ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ទាន សេចក្តីថា ភិក្ខុគិតថា អាត្មានឹងឲ្យទឹកសុក្កជាទាន ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់បុណ្យ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាបុណ្យ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការបូជា សេចក្តីថា ភិក្ខុគិតថា អាត្មានឹងបូជាទឹកសុក្កជាគ្រឿងយញ្ញ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ សេចក្តីថា ភិក្ខុគិតថា អាត្មានឹងទៅកាន់ស្ថានសួគ៌ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ពូជ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាពូជ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការល្បងមើល សេចក្តីថា ភិក្ខុគិតថា អាត្មានឹងល្បងមើល ទឹកសុក្កនេះនឹងជាពណ៌ខៀវ នឹងជាពណ៌លឿង នឹងជាពណ៌ក្រហម នឹងជាពណ៌ស ។ បេ ។ ទឹកសុក្កនេះនឹងជាពណ៌ដូចទឹកដោះថ្លា ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការលេង សេចក្តីថា ភិក្ខុមានបំណងនឹងការលេង ។

[៦] ភិក្ខុគិតចំពោះរូបខាងក្នុង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះរូបខាងក្រៅ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះរូបខាងក្នុងទាំងរូបខាងក្រៅ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ

អាបត្តិ សង្ឃាទិសេសស្ស ។ អាកាសេ កដឹ កម្បេន្តោ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ រាគូបត្ថម្ភេ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ វច្ចូបត្ថម្ភេ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បស្សាវូបត្ថម្ភេ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ វាតូបត្ថម្ភេ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ឧច្ចាលិង្គបាណកទដ្ឋូបត្ថម្ភេ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថាយ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សុខត្ថាយ ។បេ។ ភេសជ្ជត្ថាយ ទានត្ថាយ បុញ្ញត្ថាយ យញ្ញត្ថាយ សគ្គត្ថាយ ពីជត្ថាយ វីមំសត្ថាយ ទវត្ថាយ ចេតេតិ ឧបក្កមតិ មុច្ចតិ



ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតថានឹងញ៉ោចង្កេះឲ្យញ័រនៅក្នុងអាកាស ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតគំនិតសេចក្តីតម្កល់ដោយរាគៈ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតគំនិតសេចក្តីតម្កល់ដោយលាមក ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតគំនិតសេចក្តីតម្កល់ដោយមូត្រ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតគំនិតសេចក្តីតម្កល់ដោយខ្យល់ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតគំនិតសេចក្តីតម្កល់ដោយសត្វដង្កូវខាំលិង្គ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតដើម្បីប្រយោជន៍មិនឲ្យមានរោគ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ១ ភិក្ខុគិតដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ ។បេ។ ដើម្បីត្រូវការជាយាភេសជ្ជៈ ដើម្បីប្រយោជន៍ដល់ទាន ដើម្បីប្រយោជន៍ដល់បុណ្យ ដើម្បីប្រយោជន៍ដល់ការបូជា ដើម្បីប្រយោជន៍ដល់ឋានសួគ៌ ដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍ដល់ការល្បងមើល ដើម្បីប្រយោជន៍ដល់ការលេង ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ

អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បីតកំ លោហិតកំ ឱទាតំ តក្កវណ្ណំ ទកវណ្ណំ តេលវណ្ណំ ខីរវណ្ណំ ទធិវណ្ណំ សប្បិវណ្ណំ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

សុទ្ធិកំ និដ្ឋិតំ ។

[៣] អារោគ្យត្ថាយ សុខត្ថាយ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថាយ ភេសជ្ជត្ថាយ[១] ។ អារោគ្យត្ថាយ ទានត្ថាយ ។ អារោគ្យត្ថាយ បុញ្ញត្ថាយ ។ អារោគ្យត្ថាយ យញ្ញត្ថាយ ។ អារោគ្យត្ថាយ សគ្គត្ថាយ ។ អារោគ្យត្ថាយ ពីជត្ថាយ ។ អារោគ្យត្ថាយ វីមំសត្ថាយ ។ អារោគ្យត្ថាយ ទវត្ថាយ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

(៤)
ឯកមូលកំ ខណ្ឌចក្កំ និដ្ឋិតំ ។

១ ឱ. ម. ឯកត្ថាយស្ស ។



ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ព្រោះទឹកសុក្កៈណាទៀត ក៏ព្យាយាម បាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ព្រោះទឹកសុក្កៈណាលឿង ព្រោះទឹកសុក្កៈណាក្រហម ព្រោះទឹកសុក្កៈណាស ព្រោះទឹកសុក្កៈណាដូចទឹកដោះជូរទ្បើងទឹកក្ដុះ ព្រោះទឹកសុក្កៈណាដូចទឹក ព្រោះទឹកសុក្កៈណាដូចប្រេង ព្រោះទឹកសុក្កៈណាដូចទឹកដោះស្រស់ ព្រោះទឹកសុក្កៈណាដូចទឹកដោះជូរ ព្រោះទឹកសុក្កៈណាដូចទឹកដោះថ្លា ក៏ព្យាយាម បាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

បទភាជនីយសុទ្ធិក ចប់ ។

(៣) ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ និងដើម្បីសេចក្ដីសុខ ក៏ព្យាយាម បាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ និងដើម្បីជាភេសជ្ជ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាទាន ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាបុណ្យ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីស្ថានសួគ៌ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាពូជ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីល្បងមើល ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីការលេង ក៏ព្យាយាម បាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្កមានមូល១ ចប់ ។

[៨] សុខត្ថញ្ច ភេសជ្ជត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សុខត្ថញ្ច ទានត្ថញ្ច ។ សុខត្ថញ្ច បុញ្ញត្ថញ្ច ។ សុខត្ថញ្ច យញ្ញត្ថញ្ច ។ សុខត្ថញ្ច សគ្គត្ថញ្ច ។ សុខត្ថញ្ច ពីជត្ថញ្ច ។ សុខត្ថញ្ច វីមំសត្ថញ្ច ។ សុខត្ថញ្ច ទវត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សុខត្ថញ្ច អារោគ្យត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[៩] ភេសជ្ជត្ថញ្ច ទានត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ភេសជ្ជត្ថញ្ច បុញ្ញត្ថញ្ច ។ ភេសជ្ជត្ថញ្ច យញ្ញត្ថញ្ច ។ ភេសជ្ជត្ថញ្ច សគ្គត្ថញ្ច ។ ភេសជ្ជត្ថញ្ច ពីជត្ថញ្ច ។ ភេសជ្ជត្ថញ្ច វីមំសត្ថញ្ច ។ ភេសជ្ជត្ថញ្ច ទវត្ថញ្ច ។ ភេសជ្ជត្ថញ្ច អារោគ្យត្ថញ្ច ។ ភេសជ្ជត្ថញ្ច សុខត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។



[៨] ភិក្ខុគិត ដើម្បីសេចក្តីសុខ ផងដើម្បីជាភេសជ្ជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីសេចក្តីសុខ ផងដើម្បីជាទាន ។ ដើម្បីសេចក្តីសុខ ផងដើម្បីជាបុណ្យ ។ ដើម្បីសេចក្តីសុខ ផងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីសេចក្តីសុខ ផងដើម្បីស្ថានសួគ៌ ។ ដើម្បីសេចក្តីសុខ ផងដើម្បីជាពូជ ។ ដើម្បីសេចក្តីសុខ ផងដើម្បីល្បងមើល ។ ដើម្បីសេចក្តីសុខ ផងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីសេចក្តីសុខ ផងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[៩] ភិក្ខុគិត ដើម្បីជាភេសជ្ជ ផងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីជាភេសជ្ជ ផងដើម្បីជាបុណ្យ ។ ដើម្បីជាភេសជ្ជ ផងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាភេសជ្ជ ផងដើម្បីស្ថានសួគ៌ ។ ដើម្បីជាភេសជ្ជ ផងដើម្បីជាពូជ ។ ដើម្បីជាភេសជ្ជ ផងដើម្បីល្បងមើល ។ ដើម្បីជាភេសជ្ជ ផងដើម្បីការលេង ។ ដើម្បីជាភេសជ្ជ ផងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាភេសជ្ជ ផងដើម្បីសេចក្តីសុខ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១០] ទានត្ថញ្ច បុញ្ញត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ទានត្ថញ្ច យញ្ញត្ថញ្ច ។ ទានត្ថញ្ច សគ្គត្ថញ្ច ។ ទានត្ថញ្ច ពីជត្ថញ្ច ។ ទានត្ថញ្ច វីមំសត្ថញ្ច ។ ទានត្ថញ្ច ទវត្ថញ្ច ។ ទានត្ថញ្ច អារោគ្យត្ថញ្ច ។ ទានត្ថញ្ច សុខត្ថញ្ច ។ ទានត្ថញ្ច ភេសជ្ជត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១១] បុញ្ញត្ថញ្ច យញ្ញត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បុញ្ញត្ថញ្ច សគ្គត្ថញ្ច ។ បុញ្ញត្ថញ្ច ពីជត្ថញ្ច ។ បុញ្ញត្ថញ្ច វីមំសត្ថញ្ច ។ បុញ្ញត្ថញ្ច ទវត្ថញ្ច ។ បុញ្ញត្ថញ្ច អារោគ្យត្ថញ្ច ។ បុញ្ញត្ថញ្ច សុខត្ថញ្ច ។ បុញ្ញត្ថញ្ច ភេសជ្ជត្ថញ្ច ។ បុញ្ញត្ថញ្ច ទានត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១២] យញ្ញត្ថញ្ច សគ្គត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។



[១០] ភិក្ខុគិត ដើម្បីជាទាន នឹងដើម្បីជាបុណ្យ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីជាទាន នឹងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាទាន នឹងដើម្បីស្ថានសួគ៌ ។ ដើម្បីជាទាន នឹងដើម្បីជាពូជ ។ ដើម្បីជាទាន នឹងដើម្បីល្បងមើល ។ ដើម្បីជាទាន នឹងដើម្បីការលេង ។ ដើម្បីជាទាន នឹងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាទាន នឹងដើម្បីសេចក្ដីសុខ ។ ដើម្បីជាទាន នឹងដើម្បីជាភេសជ្ជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១១] ភិក្ខុគិត ដើម្បីជាបុណ្យ នឹងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីជាបុណ្យ នឹងដើម្បីស្ថានសួគ៌ ។ ដើម្បីជាបុណ្យ នឹងដើម្បីជាពូជ ។ ដើម្បីជាបុណ្យ នឹងដើម្បីល្បងមើល ។ ដើម្បីជាបុណ្យ នឹងដើម្បីការលេង ។ ដើម្បីជាបុណ្យ នឹងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាបុណ្យ នឹងដើម្បីសេចក្ដីសុខ ។ ដើម្បីជាបុណ្យ នឹងដើម្បីជាភេសជ្ជ ។ ដើម្បីជាបុណ្យ នឹងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១២] ភិក្ខុគិត ដើម្បីជាគ្រឿងយញ្ញ នឹងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

យញ្ញត្ថញ្ច ពីជត្ថញ្ច ។ យញ្ញត្ថញ្ច វីមំសត្ថញ្ច ។ យញ្ញត្ថញ្ច ទវត្ថញ្ច ។ យញ្ញត្ថញ្ច អារោគ្យត្ថញ្ច ។ យញ្ញត្ថញ្ច សុខត្ថញ្ច ។ យញ្ញត្ថញ្ច ភេសជ្ជត្ថញ្ច ។ យញ្ញត្ថញ្ច ទានត្ថញ្ច ។ យញ្ញត្ថញ្ច បុញ្ញត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១៣] សគ្គត្ថញ្ច ពីជត្ថញ្ច ។ សគ្គត្ថញ្ច វីមំសត្ថញ្ច ។ សគ្គត្ថញ្ច ទវត្ថញ្ច ។ សគ្គត្ថញ្ច អារោគ្យត្ថញ្ច ។ សគ្គត្ថញ្ច សុខត្ថញ្ច ។ សគ្គត្ថញ្ច ភេសជ្ជត្ថញ្ច ។ សគ្គត្ថញ្ច ទានត្ថញ្ច ។ សគ្គត្ថញ្ច បុញ្ញត្ថញ្ច ។ សគ្គត្ថញ្ច យញ្ញត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១៤] ពីជត្ថញ្ច វីមំសត្ថញ្ច ។ ពីជត្ថញ្ច ទវត្ថញ្ច ។ ពីជត្ថញ្ច អារោគ្យត្ថញ្ច ។ ពីជត្ថញ្ច សុខត្ថញ្ច ។ ពីជត្ថញ្ច ភេសជ្ជត្ថញ្ច ។



ភិក្ខុគិត ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាពូជ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីល្បងមើល ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីការលេង ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីសេចក្តីសុខ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាភេសជ្ជ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាទាន ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាបុណ្យ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១៣] ភិក្ខុគិត ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ ។ ដើម្បីស្ថានសួគ៌ និងដើម្បីល្បងមើល ។ ដើម្បីស្ថានសួគ៌ និងដើម្បីការលេង ។ ដើម្បីស្ថានសួគ៌ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីស្ថានសួគ៌ និងដើម្បីសេចក្តីសុខ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាភេសជ្ជ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាទាន ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាបុណ្យ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម លុះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១៤] ភិក្ខុគិត ដើម្បីជាពូជ និងដើម្បីល្បងមើល ។ ដើម្បីជាពូជ និងដើម្បីការលេង ។ ដើម្បីជាពូជ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាពូជ និងដើម្បីសេចក្តីសុខ ។ ដើម្បីជាពូជ និងដើម្បីជាភេសជ្ជ ។

ពីជត្ថញ្ច ទានត្ថញ្ច ។ ពីជត្ថញ្ច បុញ្ញត្ថញ្ច ។ ពីជត្ថញ្ច យញ្ញត្ថញ្ច ។ ពីជត្ថញ្ច សគ្គត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១៨] វីមំសត្ថញ្ច ទវត្ថញ្ច ។ វីមំសត្ថញ្ច អារោគ្យត្ថញ្ច ។ វីមំសត្ថញ្ច សុខត្ថញ្ច ។ វីមំសត្ថញ្ច ភេសជ្ជត្ថញ្ច ។ វីមំសត្ថញ្ច ទានត្ថញ្ច ។ វីមំសត្ថញ្ច បុញ្ញត្ថញ្ច ។ វីមំសត្ថញ្ច យញ្ញត្ថញ្ច ។ វីមំសត្ថញ្ច សគ្គត្ថញ្ច ។ វីមំសត្ថញ្ច ពីជត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

[១៩] ទវត្ថញ្ច អារោគ្យត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ទវត្ថញ្ច សុខត្ថញ្ច ។ ទវត្ថញ្ច ភេសជ្ជត្ថញ្ច ។ ទវត្ថញ្ច ទានត្ថញ្ច ។ ទវត្ថញ្ច បុញ្ញត្ថញ្ច ។ ទវត្ថញ្ច យញ្ញត្ថញ្ច ។ ទវត្ថញ្ច សគ្គត្ថញ្ច ។



ដើម្បីជាពូជ នឹងដើម្បីជាទាន ។ ដើម្បីជាពូជ នឹងដើម្បីជាបុណ្យ ។ ដើម្បីជាពូជ នឹងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាពូជ នឹងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ពាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១៨] ភិក្ខុគិត ដើម្បីល្បងមើល នឹងដើម្បីការលេង ។ ដើម្បីល្បងមើល នឹងដើម្បីមិនឲ្យមានរោគ ។ ដើម្បីល្បងមើល នឹងដើម្បីសេចក្តីសុខ ។ ដើម្បីល្បងមើល នឹងដើម្បីជាភេសជ្ជ ។ ដើម្បីល្បងមើល នឹងដើម្បីជាទាន ។ ដើម្បីល្បងមើល នឹងដើម្បីជាបុណ្យ ។ ដើម្បីល្បងមើល នឹងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីល្បងមើល នឹងដើម្បីស្ថានសួគ៌ ។ ដើម្បីល្បងមើល នឹងដើម្បីជាពូជ ក៏ព្យាយាម ពាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[១៩] ភិក្ខុគិត ដើម្បីការលេង នឹងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ពាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីការលេង នឹងដើម្បីសេចក្តីសុខ ។ ដើម្បីការលេង នឹងដើម្បីជាភេសជ្ជ ។ ដើម្បីការលេង នឹងដើម្បីជាទាន ។ ដើម្បីការលេង នឹងដើម្បីជាបុណ្យ ។ ដើម្បីការលេង នឹងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីការលេង នឹងដើម្បីស្ថានសួគ៌ ។

ទវត្ថញ្ច វីជត្ថញ្ច ។ ទវត្ថញ្ច វីមំសត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ឯកមូលកំ(*) ចតុក្កំ និដ្ឋិតំ ។

## ទុមូលកាទិបិ ឯវមេវ នេតព្វំ ។

[១៧] អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ទវត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ទុមូលកំ ខណ្ឌចក្កំ ។

[១៨] សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទវត្ថញ្ច ។ បេ ។ សុខត្ថញ្ច ភេសជ្ជត្ថញ្ច អារោគ្យត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ វីមំសត្ថញ្ច ទវត្ថញ្ច អារោគ្យត្ថញ្ច ចេតេតិ

---
១ ម. ឯកមូលកស្ស ។



ដើម្បីការលេង និងដើម្បីជាពូជ ។ ដើម្បីការលេង និងដើម្បីល្បងមើល ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ចតុក្កៈ មានមូលមួយ ចប់ ។

ឯចតុក្កៈមានទុមូលកៈជាដើម បណ្ឌិតគប្បីនាំមក (សំដែង) ដូចគ្នានេះចុះ ។

[១៧] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្ដីសុខ និងដើម្បីជាភេសជ្ជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្ដីសុខ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្ក មានមូលពីរ ។

[១៨] ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ និងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ និងដើម្បីការលេង ។ បេ ។ ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត ដើម្បីល្បងមើល ដើម្បីការលេង និងដើម្បីមិនឲ្យមានរោគ

ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ វីមំសត្ថញ្ច ទវត្ថញ្ច វីជត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ឆមូលកំ និដ្ឋិតំ ។

[១៩] ទ្វិមូលកំ តិមូលកំ ចតុមូលកំ បញ្ចមូលកំ ឆមូលកំ សត្តមូលកំ អដ្ឋមូលកំ នវមូលកំ ឯវមេវ កាតព្វំ ។

## ឥទំ សព្វមូលកំ ។

[២០] អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច សគ្គត្ថញ្ច វីជត្ថញ្ច វីមំសត្ថញ្ច ទវត្ថញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

សព្វមូលកំ និដ្ឋិតំ ។

[២១] នីលញ្ច បីតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលញ្ច លោហិតកញ្ច ។ បេ ។ នីលញ្ច ឱទាតញ្ច ។ នីលញ្ច តក្កវណ្ណញ្ច ។ នីលញ្ច



ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត ដើម្បីល្បងមើល ដើម្បីការលេង ផងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ឆក្កមានមូលកៈ ចប់ ។

[១៩] ឆក្កមានមូល ៣ មូល ៤ មូល ៥ មូល ៦ មូល ៧ មូល ៨ មូល ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះឯង ។

បក្ខមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្ដីតទៅខាងក្រោយនេះ) ។

[២០] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

បក្ខមានមូលគ្រប់ទាំងអស់ ចប់ ។

[២១] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌ក្រហម ។ បេ ។ ពណ៌ខៀវ និងពណ៌ស ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះជូរឬទឹកពុះ ។ ពណ៌ខៀវ

ទកវណ្ណញ្ច ។ នីលញ្ច តេលវណ្ណញ្ច ។ នីលញ្ច ខីរវណ្ណញ្ច ។ នីលញ្ច ទធិវណ្ណញ្ច ។ នីលញ្ច សប្បិវណ្ណញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

(១)
ឯកមូលកំ វណ្ណចក្កំ និដ្ឋិតំ ។

[៦២] បីតកញ្ច លោហិតកញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បីតកញ្ច ឱទាតញ្ច ។បេ។ បីតកញ្ច តក្កវណ្ណញ្ច ។ បីតកញ្ច ទកវណ្ណញ្ច ។ បីតកញ្ច តេលវណ្ណញ្ច ។ បីតកញ្ច ខីរវណ្ណញ្ច ។ បីតកញ្ច ទធិវណ្ណញ្ច ។ បីតកញ្ច សប្បិវណ្ណញ្ច ។ បីតកញ្ច នីលញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ លោហិតកញ្ច ឱទាតញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ លោហិតកញ្ច តក្កវណ្ណញ្ច ។ លោហិតកញ្ច ទកវណ្ណញ្ច ។ លោហិតកញ្ច តេលវណ្ណញ្ច ។ លោហិតកញ្ច ខីរវណ្ណញ្ច ។

---
១ ម. ឧ ឯកមូលកស្ស ។



នឹងពណ៌ដូចទឹក ១ ពណ៌ខៀវ នឹងពណ៌ដូចប្រេង ១ ពណ៌ខៀវ នឹងពណ៌ដូចទឹកដោះស្រស់ ១ ពណ៌ខៀវ នឹងពណ៌ដូចទឹកដោះជូរ ១ ពណ៌ខៀវ នឹងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

វណ្ណចក្កមានមូលមួយ ចប់ ។

[៦៦] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង នឹងពណ៌ក្រហម ក៏ព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង នឹងពណ៌ស ។បេ។ ពណ៌លឿង នឹងពណ៌ដូចទឹកដោះជូរលាយនឹងទឹក ១ ពណ៌លឿង នឹងពណ៌ដូចទឹក ១ ពណ៌លឿង នឹងពណ៌ដូចប្រេង ១ ពណ៌លឿង នឹងពណ៌ដូចទឹកដោះស្រស់ ១ ពណ៌លឿង នឹងពណ៌ដូចទឹកដោះជូរ ១ ពណ៌លឿង នឹងពណ៌ដូចទឹកដោះថ្លា ១ ពណ៌លឿង នឹងពណ៌ខៀវ ក៏ព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ក្រហម នឹងពណ៌ស ក៏ព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ក្រហម នឹងពណ៌ដូចទឹកដោះជូរលាយនឹងទឹក ១ ពណ៌ក្រហម នឹងពណ៌ដូចទឹក ១ ពណ៌ក្រហម នឹងពណ៌ដូចប្រេង ១ ពណ៌ក្រហម នឹងពណ៌ដូចទឹកដោះស្រស់ ១

លោហិតកញ្ច ទធិវណ្ណញ្ច ។ លោហិតកញ្ច សប្បិវណ្ណញ្ច ។ លោហិតកញ្ច នីលញ្ច ។ លោហិតកញ្ច បីតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ឱទាតញ្ច តក្កវណ្ណញ្ច ។ ឱទាតញ្ច ទកវណ្ណញ្ច ។ ឱទាតញ្ច តេលវណ្ណញ្ច ។ ឱទាតញ្ច ខីរវណ្ណញ្ច ។ ឱទាតញ្ច ទធិវណ្ណញ្ច ។ ឱទាតញ្ច សប្បិវណ្ណញ្ច ។ ឱទាតញ្ច នីលញ្ច ។ ឱទាតញ្ច បីតកញ្ច ។ ឱទាតញ្ច លោហិតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ តក្កវណ្ណញ្ច ទកវណ្ណញ្ច ។ តក្កវណ្ណញ្ច តេលវណ្ណញ្ច ។ តក្កវណ្ណញ្ច ខីរវណ្ណញ្ច ។ តក្កវណ្ណញ្ច ទធិវណ្ណញ្ច ។ តក្កវណ្ណញ្ច សប្បិវណ្ណញ្ច ។ តក្កវណ្ណញ្ច នីលញ្ច ។ តក្កវណ្ណញ្ច បីតកញ្ច ។ តក្កវណ្ណញ្ច លោហិតកញ្ច ។ តក្កវណ្ណញ្ច ឱទាតញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ .



ពណ៌ក្រហម នឹងពណ៌ដូចទឹកដោះជូរ ។ ពណ៌ក្រហម នឹងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ក្រហម នឹងពណ៌ខៀវ ។ ពណ៌ក្រហម នឹងពណ៌លឿង គិតព្យាយាម ឲ្យទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ស នឹងពណ៌ដូចទឹកដោះជូរទៀបកកុះ ។ ពណ៌ស នឹងពណ៌ដូចទឹក ។ ពណ៌ស នឹងពណ៌ដូចប្រេង ។ ពណ៌ស នឹងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ស នឹងពណ៌ដូចទឹកដោះជូរ ។ ពណ៌ស នឹងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ស នឹងពណ៌ខៀវ ។ ពណ៌ស នឹងពណ៌លឿង ។ ពណ៌ស នឹងពណ៌ក្រហម គិតព្យាយាម ឲ្យទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ខៀវ ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌លឿង ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ក្រហម ។ ពណ៌ដូចទឹកដោះជូរទៀបកកុះ នឹងពណ៌ស គិតព្យាយាម ឲ្យទឹកសុក្ក

អាបត្តិ សង្ឃាទិសេសស្ស ។ ទកវណ្ណញ្ច តេល-វណ្ណញ្ច ។ ទកវណ្ណញ្ច ខីរវណ្ណញ្ច ។ ទកវណ្ណញ្ច ទធិវណ្ណញ្ច ។ ទកវណ្ណញ្ច សប្បិវណ្ណញ្ច ។ ទក-វណ្ណញ្ច នីលញ្ច ។ ទកវណ្ណញ្ច បីតកញ្ច ។ ទកវណ្ណញ្ច លោហិតកញ្ច ។ ទកវណ្ណញ្ច ឱទាតញ្ច ។ ទកវណ្ណញ្ច តក្កវណ្ណញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ តេលវណ្ណញ្ច ខីរវណ្ណញ្ច ។ តេលវណ្ណញ្ច ទធិវណ្ណញ្ច ។ តេលវណ្ណញ្ច សប្បិវណ្ណញ្ច ។ តេលវណ្ណញ្ច នីលញ្ច ។ តេលវណ្ណញ្ច បីតកញ្ច ។ តេលវណ្ណញ្ច លោហិតកញ្ច ។ តេលវណ្ណញ្ច ឱទាតញ្ច ។ តេលវណ្ណញ្ច តក្កវណ្ណញ្ច ។ តេលវណ្ណញ្ច ទកវណ្ណញ្ច មោចេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេ-សស្ស ។ ខីរវណ្ណញ្ច ទធិវណ្ណញ្ច ។ ខីរវណ្ណញ្ច សប្បិវណ្ណញ្ច ។ ខីរវណ្ណញ្ច នីលញ្ច ។ ខីរវណ្ណញ្ច



ឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹក ទឹកពណ៌ដូចប្រេង ។ ពណ៌ដូចទឹក ទឹកពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹក ទឹកពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹក ទឹកពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹក ទឹកពណ៌ខៀវ ។ ពណ៌ដូចទឹក ទឹកពណ៌លឿង ។ ពណ៌ដូចទឹក ទឹកពណ៌ក្រហម ។ ពណ៌ដូចទឹក ទឹកពណ៌ស ។ ពណ៌ដូចទឹក ទឹកពណ៌ដូចទឹកដោះជូរមេឡើងពពុះ ក៏ព្យាយាម ត្រូវតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចប្រេង ទឹកពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចប្រេង ទឹកពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចប្រេង ទឹកពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចប្រេង ទឹកពណ៌ខៀវ ។ ពណ៌ដូចប្រេង ទឹកពណ៌លឿង ។ ពណ៌ដូចប្រេង ទឹកពណ៌ក្រហម ។ ពណ៌ដូចប្រេង ទឹកពណ៌ស ។ ពណ៌ដូចប្រេង ទឹកពណ៌ដូចទឹកដោះជូរមេឡើងពពុះ ។ ពណ៌ដូចប្រេង ទឹកពណ៌ដូចទឹក ក៏ព្យាយាម ត្រូវតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិ-សេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ខៀវ ។ ពណ៌ដូចទឹកដោះស្រស់

បីតកញ្ច ។ ខីរវណ្ណញ្ច លោហិតកញ្ច ។ ខីរវណ្ណញ្ច ឱទាតញ្ច ។ ខីរវណ្ណញ្ច តក្កវណ្ណញ្ច ។ ខីរវណ្ណញ្ច ទកវណ្ណញ្ច ។ ខីរវណ្ណញ្ច តេលវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ទធិវណ្ណញ្ច សប្បិវណ្ណញ្ច ។ ទធិវណ្ណញ្ច នីលញ្ច ។ ទធិវណ្ណញ្ច បីតកញ្ច ។ ទធិវណ្ណញ្ច លោហិតកញ្ច ។ ទធិវណ្ណញ្ច ឱទាតញ្ច ។ ទធិវណ្ណញ្ច តក្កវណ្ណញ្ច ។ ទធិវណ្ណញ្ច ទកវណ្ណញ្ច ។ ទធិវណ្ណញ្ច តេលវណ្ណញ្ច ។ ទធិវណ្ណញ្ច ខីរវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សប្បិវណ្ណញ្ច នីលញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សប្បិវណ្ណញ្ច បីតកញ្ច ។ សប្បិវណ្ណញ្ច លោហិតកញ្ច ។ សប្បិវណ្ណញ្ច ឱទាតញ្ច ។ សប្បិវណ្ណញ្ច តក្កវណ្ណញ្ច ។ សប្បិវណ្ណញ្ច ទកវណ្ណញ្ច ។ សប្បិវណ្ណញ្ច





ទឹកពណ៌លឿង ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ក្រហម ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ស ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះស្រស់ ទឹកពណ៌ដូចប្រេង គឺព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ខៀវ ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌លឿង ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ក្រហម ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ស ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចទឹកដោះស្រស់ គឺព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ខៀវ គឺព្យាយាម ព្រោះតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ទឹកពណ៌លឿង ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ក្រហម ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ស ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះថ្លា

តេលវណ្ណញ្ច ។ សប្បិវណ្ណញ្ច ខីរវណ្ណញ្ច ។ សប្បិវណ្ណញ្ច ទធិវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

(១)
ឯកមូលកំ ខណ្ឌចក្កំ និដ្ឋិតំ ។

## ទុមូលកាទិបិ ឯវមេវ នេតព្វំ ។

[២៣] នីលញ្ច បីតកញ្ច លោហិតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលញ្ច បីតកញ្ច ឱទាតញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ នីលញ្ច បីតកញ្ច សប្បិវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ទុមូលកំ ខណ្ឌចក្កំ និដ្ឋិតំ ។

[២៤] បីតកញ្ច លោហិតកញ្ច ឱទាតញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ បីតកញ្ច លោហិតកញ្ច នីលញ្ច ចេតេតិ

១ ម. ឆ. ឯកមូលកស្ស ។



ទឹកពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្កមានមូលមួយ ចប់ ។

ឯចក្កមានមូលពីរ ជាដើម បណ្ឌិតគប្បីនាំមក (សំដែង) ដូចគ្នានេះចុះ ។

[៦៣] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ទឹកពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ទឹកពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ទឹកពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្កមានមូលពីរ ចប់ ។

[៦៤] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម ទឹកពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម ទឹកពណ៌ខៀវ

ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ ទធិវណ្ណញ្ច សប្បិវណ្ណញ្ច ឥតរញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បេ ។ ទធិវណ្ណញ្ច សប្បិវណ្ណញ្ច ខីរវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ទុមូលកំ ខណ្ឌចក្កំ និដ្ឋិតំ ។

[២៥] តិមូលកំ ចតុមូលកំ បញ្ចមូលកំ ឆមូលកំ សត្តមូលកំ អដ្ឋមូលកំ នវមូលកំ ឯវមេវ កាតព្វំ ។

## ឥទំ សព្វមូលកំ ។

[២៦] នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទកវណ្ណញ្ច តេលវណ្ណញ្ច ខីរវណ្ណញ្ច ទធិវណ្ណញ្ច សប្បិវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

សព្វមូលកំ និដ្ឋិតំ ។



ក៏ព្យាយាម គ្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ទៀត ក៏ព្យាយាម គ្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ទឹកពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម គ្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្កមានមូលពីរ ចប់ ។

[២៧] ចក្កមានមូល ៣ មូល ៤ មូល ៥ មូល ៦ មូល ៧ មូល ៨ មូល ៩ បណ្ឌិតគប្បីធ្វើយ៉ាងនោះផងចុះ ។

នេះចក្កមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្តីខាងក្រោយនេះ) ។

[២៨] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ទឹកពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម គ្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ចក្កមានមូលគ្រប់ទាំងអស់ ចប់ ។

[៦៧] អារោគ្យត្ថញ្ច នីលញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច នីលញ្ច បីតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទកវណ្ណញ្ច ចេតេតិ





[៦៧] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវក៏ក្ដី ដើម្បីមិនឲ្យមានរោគក៏ក្ដី ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ នឹងពណ៌លឿង ដើម្បីមិនឲ្យមានរោគ នឹងដើម្បីឲ្យស្រួលខ្លួន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង នឹងពណ៌ក្រហម ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន នឹងដើម្បីជាភេសជ្ជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម នឹងពណ៌ស ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ នឹងដើម្បីជាទាន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស នឹងពណ៌ដូចទឹកដោះជូរឡើងពពុះ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ ដើម្បីជាទាន នឹងដើម្បីជាបុណ្យ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ នឹងពណ៌ដូចទឹក ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ ដើម្បីជាទាន ដើម្បីជាបុណ្យ នឹង

ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យ-ត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច សគ្គត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទកវណ្ណញ្ច តេលវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច សគ្គត្ថញ្ច ពីជត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទក-វណ្ណញ្ច តេលវណ្ណញ្ច ខីរវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច សគ្គត្ថញ្ច ពីជត្ថញ្ច វីមំសត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទកវណ្ណញ្ច តេលវណ្ណញ្ច ខីរវណ្ណញ្ច ទធិវណ្ណញ្ច ចេតេតិ ឧបក្កមតិ



ដើម្បីជាគ្រឿងបូជា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឈ្មោះតក្កៈ ពណ៌ដូចទឹក និងពណ៌ដូចប្រេង ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេ-សជ្ជ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឈ្មោះតក្កៈ ពណ៌ដូចទឹក ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះស្រស់ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឈ្មោះតក្កៈ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ និងដើម្បីល្បងមើល ក៏ព្យាយាម

មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ អារោគ្យត្ថញ្ច សុខត្ថញ្ច ភេសជ្ជត្ថញ្ច ទានត្ថញ្ច បុញ្ញត្ថញ្ច យញ្ញត្ថញ្ច សគ្គត្ថញ្ច ពីជត្ថញ្ច វីមំសត្ថញ្ច ទវត្ថញ្ច នីលញ្ច បីតកញ្ច លោហិតកញ្ច ឱទាតញ្ច តក្កវណ្ណញ្ច ទកវណ្ណញ្ច តេលវណ្ណញ្ច ខីរវណ្ណញ្ច ទធិវណ្ណញ្ច សប្បិវណ្ណញ្ច ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

មោចនទ្វយមិស្សកចក្កំ(១) និដ្ឋិតំ ។

[៦៤] នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ បីតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ លោហិតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ឱទាតំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ តក្កវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

១ ឱ. ម. មិស្សកចក្កំ ។



ស្រាប់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរម្យ៉ាងតក្ក ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាម ស្រាប់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ការដោះគូមិស្សកចក្ក ចប់ ។

[៦៨] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរម្យ៉ាងឈ្មោះតក្កៈឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ទកវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ តេលវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ខីរវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ទធិវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ នីលំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ សប្បិវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ខណ្ឌចក្កំ និដ្ឋិតំ ។

(៦៨) បីតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ លោហិតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ បីតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ឱទាតំ មុច្ចតិ ។ បេ ។ តក្កវណ្ណំ មុច្ចតិ ។



ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្ក ចប់ ។

[៦៨] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (ធ្វើ) ទឹកសុក្កពណ៌សឃ្លាតចេញទៅ ។ បេ ។ (ធ្វើ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញទៅ ។

ទកវណ្ណំ មុច្ចតិ ។ តេលវណ្ណំ មុច្ចតិ ។ ខីរវណ្ណំ មុច្ចតិ ។ ទធិវណ្ណំ មុច្ចតិ ។ សប្បិវណ្ណំ មុច្ចតិ ។ នីលំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ពទ្ធចក្កំ និដ្ឋិតំ ។

[៣០] លោហិតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ឱទាតំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ លោហិតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ តក្កវណ្ណំ មុច្ចតិ ។បេ។ ទកវណ្ណំ មុច្ចតិ ។ តេលវណ្ណំ មុច្ចតិ ។ ខីរវណ្ណំ មុច្ចតិ ។ ទធិវណ្ណំ មុច្ចតិ ។ សប្បិវណ្ណំ មុច្ចតិ ។ នីលំ មុច្ចតិ ។ បីតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ឱទាតំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ តក្កវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស



ពណ៌ដូចទឹកឃ្លាតចេញវិញ ១ ពណ៌ដូចប្រេងឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ១ ពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ពទ្ធចក្ក ចប់ ។

[៣០] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កៈពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កៈពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កៈពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កៈពណ៌ដូចទឹកដោះជូរលាយទឹកពុះឃ្លាតចេញវិញ ១ ។ល។ (បែរជា) ទឹកសុក្កៈពណ៌ដូចទឹកឃ្លាតចេញវិញ ១ ពណ៌ដូចប្រេងឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ១ ពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ១ ពណ៌ខៀវឃ្លាតចេញវិញ ១ ពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កៈពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កៈពណ៌ដូចទឹកដោះជូរលាយទឹកពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស

១ ។ បេ ។ លោហិតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ [ឯវំ ចក្កានិ ឋបេតព្វានិ] សប្បិវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ នីលំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ សប្បិវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ បីតកំ មុច្ចតិ ។ បេ ។ លោហិតកំ មុច្ចតិ ។ ឱទាតំ មុច្ចតិ ។ តក្កវណ្ណំ មុច្ចតិ ។ ទកវណ្ណំ មុច្ចតិ ។ តេលវណ្ណំ មុច្ចតិ ។ ខីរវណ្ណំ មុច្ចតិ ។ ទធិវណ្ណំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ខណ្ឌចក្កំ និដ្ឋិតំ ។

[៣១] បីតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ នីលំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ លោហិតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ នីលំ មុច្ចតិ ។ ឱទាតំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ នីលំ មុច្ចតិ ។



។ បេ ។ (បើចេញ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ (ត្រូវអាបត្តិសង្ឃាទិសេស ។ (ចក្កទាំងឡាយបណ្ឌិតគប្បីដឹងដោយអាការយ៉ាងនេះ) ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បើចេញ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ (ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បើចេញ) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ។ បេ ។ (បើចេញ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ។ ពណ៌សឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះជូររាវឡើងភក់ឃ្លាតចេញវិញ ។ ពណ៌ដូចទឹកឃ្លាតចេញវិញ ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ (ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្ក ចប់ ។

[៣១] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បើចេញ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ (ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បើចេញ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បើចេញ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។

តក្កវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ ។ ទកវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ ។ តេលវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ ។ ខីរវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ ។ ទធិវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ ។ សប្បិវណ្ណំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ ដល់ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ចក្កបេយ្យាលំ[១] បឋមំ គមនំ និដ្ឋិតំ ។

[៣៦] លោហិតកំ មោចេស្សាមីតិ ចេតេតិ ឧបក្កមតិ បីតកំ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ឱទាតំ[២] តក្កវណ្ណំ ទកវណ្ណំ តេលវណ្ណំ ខីរវណ្ណំ ទធិវណ្ណំ សប្បិវណ្ណំ ។

១ បាលិ បឋមចក្កគមនន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ មរម្មបោត្ថកេ ឯត្តកំ ទេហេក្វ ប៉េរ ទិស្សតិ តតោ បរំ គ្លិរកោ មន្តាបិ ទិស្សតិយេវ ។ តំ យុត្តំ ។



ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូររាវឡើងកកុះ ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌ទៀតឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ដំណើរនៃចក្កទី ១ ចប់ ។

[៣៦] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (ប្រឹង) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ស ពណ៌ដូចទឹកដោះជូររាវឡើងកកុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ។

នីលំ មោចេស្សាមីតិ ចេតេន្តោ ឧបក្កមន្តោ បីតកំ មុញ្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ពទ្ធចក្កស្ស ទុតិយំ គមនំ និដ្ឋិតំ ។

[៣៥] ឱទាតំ មោចេស្សាមីតិ ចេតេន្តោ ឧបក្កមន្តោ លោហិតកំ មុញ្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ តក្កវណ្ណំ ទកវណ្ណំ តេលវណ្ណំ ខីរវណ្ណំ ទធិវណ្ណំ សប្បិវណ្ណំ នីលំ ។ បីតកំ មោចេស្សាមីតិ ចេតេន្តោ ឧបក្កមន្តោ លោហិតកំ មុញ្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ពទ្ធចក្កស្ស តតិយំ គមនំ និដ្ឋិតំ ។

[៣៦] តក្កវណ្ណំ មោចេស្សាមីតិ ចេតេន្តោ ឧបក្កមន្តោ ឱទាតំ មុញ្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។ ទកវណ្ណំ តេលវណ្ណំ ខីរវណ្ណំ ទធិវណ្ណំ សប្បិវណ្ណំ នីលំ បីតកំ ។ លោហិតកំ មោចេស្សាមីតិ ចេតេន្តោ ឧបក្កមន្តោ ឱទាតំ មុញ្ចតិ អាបត្តិ សង្ឃាទិសេសស្ស ។

ពទ្ធចក្កស្ស ចតុត្ថំ គមនំ និដ្ឋិតំ ។



ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ដំណើរនៃពទ្ធចក្ក ទី ២ ចប់ ។

[៣៥] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ដំណើរនៃពទ្ធចក្ក ទី ៣ ចប់ ។

[៣៦] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ដំណើរនៃពទ្ធចក្ក ទី ៤ ចប់ ។

(១០៥) ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបន្ទាប់ក្ដី ។ បេ ។ ជេរក្ដី (ចំពោះកាយ)ខាងក្រោម ពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែ វច្ចមគ្គ បស្សាវមគ្គនៃស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាជាស្រី ។ បេ ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាជាស្រី ។ បេ ។ តិរច្ឆានពិតមែន ភិក្ខុសំគាល់ថាស្រី ។ បេ ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបន្ទាប់ក្ដី ។ បេ ។ ជេរក្ដី (ចំពោះកាយ) ខាងក្រោម ពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែង តែវច្ចមគ្គ និងបស្សាវមគ្គ នៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់នូវទាំងពីរថាជាស្រី ក៏មានសេចក្ដីត្រេកអរ

ទ្វិន្នំ វច្ចមគ្គំ បស្សាវមគ្គំ ឋបេត្វា អធក្ខកំ ឧព្ភជាណុមណ្ឌលំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។បេ។ អក្កោសតិបិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។

(១០៨) ឥត្ថី ច ហោតិ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឥត្ថិយា ឧព្ភក្ខកំ អធោជាណុមណ្ឌលំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។បេ។ អក្កោសតិបិ អាបត្តិ ទុក្កដស្ស ។ បណ្ឌកោ ច ហោតិ ឥត្ថីសញ្ញី ។បេ។ បុរិសោ ច ហោតិ ឥត្ថីសញ្ញី ។បេ។ តិរច្ឆានគតោ ច ហោតិ ឥត្ថីសញ្ញី ។បេ។ អាបត្តិ ទុក្កដស្ស ។ ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ ឥត្ថីនំ ឧព្ភក្ខកំ អធោជាណុមណ្ឌលំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។បេ។ អក្កោសតិបិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ឥត្ថី ច បណ្ឌកោ ច ឧភិន្នំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ ឧព្ភក្ខកំ អធោជាណុមណ្ឌលំ អាទិស្ស វណ្ណំបិ



ហៅសរសើរក្ដី ហៅបន្ទាប់ក្ដី ។បេ។ ជេរក្ដី (ចំពោះកាយ) ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ និងបស្សាវមគ្គ នៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។

(១០៨) ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្ដីត្រេកអរ ហៅសរសើរក្ដី ហៅបន្ទាប់ក្ដី ។បេ។ ជេរក្ដី (ចំពោះកាយ) ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលជង្គង់ចុះមកនៃស្រីនោះ ត្រូវអាបត្តិទុក្កដ ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាជាស្រី ។បេ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាជាស្រី ។បេ។ តិរច្ឆានពិតមែន ភិក្ខុសំគាល់ថាស្រី ។បេ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្ដីត្រេកអរ ហៅសរសើរក្ដី ហៅបន្ទាប់ក្ដី ។បេ។ ជេរក្ដី (ចំពោះកាយ) ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលជង្គង់ចុះមក នៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ទាំងពីរជាស្រី ក៏មានសេចក្ដីត្រេកអរ ហៅសរសើរក្ដី

ភណតិ អវណ្ណំបិ ភណតិ ។ បេ ។ អក្កោសតិបិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បេ ។ ឥត្ថី ច ហោតិ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឥត្ថិយា កាយប្បដិពទ្ធំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។ បេ ។ អក្កោសតិបិ អាបត្តិ ទុក្កដស្ស ។ បណ្ឌកោ ច ហោតិ ។ បេ ។ បុរិសោ ច ហោតិ ។ បេ ។ តិរច្ឆានគតោ ច ហោតិ ។ បេ ។ អាបត្តិ ទុក្កដស្ស ។ ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ ឥត្ថីនំ កាយប្បដិពទ្ធំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។ បេ ។ អក្កោសតិបិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ឥត្ថី ច បណ្ឌកោ ច ឧភិន្នំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ កាយប្បដិពទ្ធំ អាទិស្ស វណ្ណំបិ ភណតិ អវណ្ណំបិ ភណតិ ។ បេ ។ អក្កោសតិបិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។

(១០៦) អនាបត្តិ អត្ថបុរេក្ខារស្ស ធម្មបុរេក្ខារស្ស អនុសាសនីបុរេក្ខារស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ពោលបន្ទាប់ក្តី ។ បេ ។ ជេរក្តី (ចំពោះកាយ) ខាងលើពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹមមណ្ឌលជង្គង់ចុះមក វៀរលែងតែទីទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី គឺមានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយស្រីនោះ ត្រូវអាបត្តិទុក្កដ ។ ខ្ទើយពិតមែន ។ បេ ។ ប្រុសពិតមែន ។ បេ ។ តិរច្ឆានពិតមែន ។ បេ ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រី គឺមានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ទាំងពីរថាជាស្រី គឺមានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយ នៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។

(១០៦) អាបត្តិមិនមាន (ដល់ភិក្ខុ ៥ ពួក) គឺ ភិក្ខុដែលគិតនឹងអធិប្បាយសេចក្តី[1] ១ ភិក្ខុដែលគិតនឹងបង្រៀនធម៌[2] ១ ភិក្ខុដែលគិតនឹងប្រៀនប្រដៅ[3] ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

---

១ ភិក្ខុដែលគិតនឹងសំដែងនូវសេចក្តីពន្យល់ ឬដែលគិតនឹងស្វាធ្យាយនូវអដ្ឋកថា ដែលមានពាក្យថា ឯនិមិត្តមនុស្សស្រីនេះមិនល្អ ដូច្នេះជាដើម ។ ២ ភិក្ខុដែលគិតនឹងបង្ហាញ ឬគិតនឹងស្វាធ្យាយនូវបាលី ។ ៣ ភិក្ខុដែលគិតនឹងនិយាយប្រៀនប្រដៅមនុស្សស្រីថា ឥឡូវនេះឯងជាមនុស្សក្មេងចិត្ត ឯងជាមនុស្សកោតញ្ញូ ក៏ចាំងគិតឥឡូវនេះទៅ ឯងត្រូវកុំឲ្យមាន ទៅកាន់អបាយ

(១០៧) លោហិតកក្កសាកិណ្ណំ ឱរកំ ទីឃលោមកំបិចំ
ការក្ខំ សំសារត្តំ(១) មរក្ខោ សទ្ធាជាតេន កម្មជាតំ ។

(១០៨) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី នវកំ កម្ពលំ បារុតា ហោតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច លោហិតំ ខោ តេ ភគិនិ ។ សា ន បដិវិជានិ អាម អយ្យ នវកោ កម្ពលោតិ ។ តស្ស កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ អហំ សង្ឃាទិសេសំ អាបត្តឹ អាបន្នោតិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កក្ខសកម្ពលំ បារុតា ហោតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច កក្ខស-លោមំ ខោ តេ ភគិនិ ។ សា ន បដិវិជានិ

១ ឱ. ម. លិស្តិតំ ។





(បាលីកានុក្រម តិបញ្ជីរឿងតាមរបៀបឧទ្ទាន ដែលនឹងសំដែង តទៅដូចមានខាងក្រោយនេះ)

(១០៧) សម្ពត់កម្ពលក្រហម១ សម្ពត់កម្ពលមានរោមរឹង១ សម្ពត់កម្ពលមានរោមក្រញាញ់១ សម្ពត់កម្ពលមានរោមវែង១ សម្ពត់កម្ពលមានរោមរលើ១ ស្រីក្រោះស្រួ១ ភិក្ខុសួរថាស្រី ប្រពន្ធនៅស្រែរមយ១ សត្វ១ តាមធីប្រែសើ១ ស្រីកំពុងរើក្តីការលើ១ ។

(១០៨) សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់កម្ពលជ្រលក់ថ្មី ។ ភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងក្រហមឬ ។ ស្រីនោះមិនបានដឹងច្បាស់ ក៏ឆ្លើយថា ករុណា លោកម្ចាស់ សម្ពត់កម្ពលខ្ញុំជ្រលក់ថ្មី ។ ភិក្ខុនោះមានសេចក្តីសង្ស័យថាអាត្មាត្រូវអាបត្តិសង្ឃាទិសេសហើយឬដូចម្តេច ។ ទើបក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវត្រឹមតែអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ ដណ្តប់សម្ពត់កម្ពលមានរោមរឹង ។ ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមរឹងឬ ។ ស្រីនោះមិនបានដឹងច្បាស់ក៏ឆ្លើយថា

អាម អយ្យ កក្ខសកម្ពលោតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី នវធោតំ កម្ពលំ បារុតា ហោតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថិំ ឯតទវោច អាកិណ្ណលោមា ខោ តេ ភគិនីតិ ។ សា ន បដិវិជានាតិ អាម អយ្យ នវធោតោ កម្ពលោតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ខរកម្ពលំ បារុតា ហោតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថិំ ឯតទវោច ខរលោមា ខោ តេ ភគិនីតិ ។ សា ន បដិវិជានាតិ អាម អយ្យ ខរកម្ពលោតិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។





ករុណា លោកម្ចាស់ សម្ពត់កម្ពលខ្ញុំមានរោមគ្រើម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ ដណ្តប់សម្ពត់កម្ពលទើបតែនឹងលាងថ្មី ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមក្រញាញ់ឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណា លោកម្ចាស់ សម្ពត់កម្ពលខ្ញុំទើបតែនឹងលាងថ្មី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃា-ទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ ដណ្តប់សម្ពត់កម្ពលមានរោមរឹង ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមរឹងឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណា លោកម្ចាស់ សម្ពត់កម្ពលខ្ញុំមានរោមរឹង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

(១០៩) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ខរកម្ពលំ បារុតា ហោតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច ខរលោមំ ខោ តេ ភគិនីតិ ។ សា ន បដិវិជានិ អាម អយ្យ ខរកម្ពលកោតិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។

(១១០) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី ខេត្តំ វាបេត្វា អាគច្ឆតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច វុត្តំ ខោ តេ ភគិនីតិ ។ សា ន បដិវិជានិ អាម អយ្យ នោ ច ខោ បដិវុត្តន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។

(១១១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ បរិព្វាជិកំ បដិបថេ បស្សិត្វា សារត្តោ តំ បរិព្វាជិកំ ឯតទវោច កច្ចិ ភគិនិ តេ មគ្គោ សំសរតីតិ(១) ។ សា ន បដិវិជានិ អាម ភិក្ខុ

១ ឧ. ម. សំសប្បតីតិ ។



(១០៩) សម័យនោះឯង មានស្រីម្នាក់ ដណ្តប់សំពត់ចាប់រោមវែង ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី តើរបស់នាងមានរោមវែងឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សំពត់ចាប់ខ្ញុំមានរោមវែង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវត្រឹមអាបត្តិទុក្កដ ។

(១១០) សម័យនោះឯង មានស្រីម្នាក់ ប្រើគេឲ្យព្រោះស្រូវស្រែ រួចហើយត្រឡប់មកវិញ ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី តើរបស់នាងឲ្យគេព្រោះហើយឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ ស្រែខ្ញុំគេមិនទាន់ព្រោះទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវត្រឹមអាបត្តិទុក្កដ ។

(១១១) សម័យនោះឯង មានភិក្ខុ១រូប ប្រទះនឹងនាងបរិព្វាជិកាក្នុងផ្លូវជួបគ្នា មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងបរិព្វាជិកានោះថា ម្នាលប្អូនស្រី ផ្លូវរបស់នាងប្រព្រឹត្តទៅស្រួលទេឬ ។ នាងនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោក

បដិបដិស្សសីតិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។

[១០៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សារត្តោ អញ្ញតរំ ឥត្ថឹ ឯតទវោច សទ្ធាសិ ត្វំ ភគិនិ អបិច យំ សាមិកស្ស ទេសិ តំ អម្ហាកំ ន ទេសីតិ ។ កឹ ភន្តេតិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សារត្តោ អញ្ញតរំ ឥត្ថឹ ឯតទវោច សទ្ធាសិ ត្វំ ភគិនិ អបិច យំ អគ្គទានំ តំ អម្ហាកំ ន ទេសីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។បេ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។





លោកនឹងដេកផ្ងារទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[១០៦] សម័យនោះឯង មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែនាងឲ្យវត្ថុណាដល់ស្វាមី នាងមិនឲ្យវត្ថុនោះដល់ពួកអាត្មាទេ ។ ស្រីនោះសួរថា អ្វីលោកម្ចាស់ ។ ភិក្ខុនោះឆ្លើយថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែទានណាដ៏ប្រសើរ នាងមិនឲ្យទាននោះដល់ពួកអាត្មាទេ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះឆ្លើយថា ទានដ៏ប្រសើរនោះ គឺមេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

[១១៣] តេន ខោ បន សមយេន អញ្ញតរា ឥត្ថី វប្បំ ការេតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច តិដ្ឋ ភគិនិ អហំ ការាបេមីតិ ។ សា ន បដិវិជានិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី វប្បំ ការេតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច និសីទ ភគិនិ អហំ ការាបេមីតិ ។ សា ន បដិវិជានិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី វប្បំ ការេតិ ។ អញ្ញតរោ ភិក្ខុ សារត្តោ តំ ឥត្ថឹ ឯតទវោច និបជ្ជ ភគិនិ អហំ ការាបេមីតិ ។ សា ន បដិវិជានិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អនាបត្តិ ភិក្ខុ សង្ឃាទិសេសស្ស អាបត្តិ ទុក្កដស្សាតិ ។

តតិយសង្ឃាទិសេសំ និដ្ឋិតំ ។



[១១៣] សម័យនោះឯង មានស្រីម្នាក់ កំពុងធ្វើការស្រែ ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងឈប់ចុះចាំអាត្មាធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ កំពុងធ្វើការស្រែ ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី ចូរនាងអង្គុយទៅ អាត្មានឹងធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ កំពុងធ្វើការស្រែ ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងចូរដេកទៅ អាត្មានឹងធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

សង្ឃាទិសេសទី ៣ ចប់ ។

# បត្ថុសង្ឃាទិសេសំ

(១១៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយី សាវត្ថិយំ កុលូបកោ ហោតិ ពហុកានិ កុលានិ ឧបសង្ក-មតិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី មតបតិកា អភិរូបា ហោតិ ទស្សនីយា បាសាទិ-កា ។ អថខោ អាយស្មា ឧទាយី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្សា ឥត្ថិយា និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សា ឥត្ថី យេនាយស្មា ឧទាយី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ឥត្ថឹ អាយស្មា ឧទាយី ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំ-សេសិ ។ អថខោ សា ឥត្ថី អាយស្មតា ឧទាយិនា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេ-ជិតា សម្បហំសិតា អាយស្មន្តំ ឧទាយឹ ឯតទវោច

# សង្ឃាទិសេសទី ៤

(១១៤) សម័យនោះ ព្រះសម្ពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧទាយិត្ថេរមានអាយុជាអ្នកចូលទៅកាន់ត្រកូល(១) ក៏ចូលទៅរកត្រកូលបានប្រមាណច្រើន ក្នុងក្រុងសាវត្ថី ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមេម៉ាយស្លាប់ប្តី មានរូបល្អគួរពិតពិលរម៉ិលមើល ជាទីតាំងនៃសេចក្តីជ្រះថ្លា ។ គ្រានោះ ព្រះឧទាយិត្ថេរមានអាយុស្លៀកស្បង់ ទ្រង់បាត្រចីវរ ហើយចូលទៅកាន់លំនៅរបស់ស្រីនោះ ក្នុងវេលាព្រឹកព្រហាម លុះចូលទៅដល់ហើយក៏អង្គុយលើអាសនៈដែលគេក្រាលប្រគេន ។ ស្រីនោះក៏ចូលមករកព្រះឧទាយិត្ថេរមានអាយុក្នុងវេលានោះ លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំព្រះឧទាយិត្ថេរមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះឧទាយិត្ថេរមានអាយុក៏ញុំាងស្រីនោះ ដែលអង្គុយនៅក្នុងទីសមគួរ ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយ ដោយពាក្យដ៏ប្រកបដោយធម៌ ។ ឯស្រីនោះ លុះព្រះឧទាយិត្ថេរមានអាយុឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយដោយពាក្យដ៏ប្រកបដោយធម៌ ដូច្នោះហើយ ក៏ពោលនូវពាក្យនេះនឹងព្រះឧទាយិត្ថេរមានអាយុថា

១ [illegible] សំដៅភិក្ខុដែលជិតដិតស្និទ្ធស្នាលនឹងត្រកូល ។

វទេយ្យាថ ភន្តេ យេន អត្ថោ បដិពលោ អហំ អយ្យស្ស ទាតុំ យទិទំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារន្តិ(១) ។ ន ខោ តេ ភគិនិ អម្ហាកំ ទុល្លភា យទិទំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អបិច ខោ(២) យោ អម្ហាកំ ទុល្លភោ តំ អម្ហាកំ ទេហីតិ ។ កឹ ភន្តេតិ ។ មេថុនធម្មន្តិ ។ អត្ថោ ភន្តេតិ ។ អត្ថោ ភគិនីតិ ។ ឯហិ ភន្តេតិ ឱវរកំ បវិសិត្វា សាដកំ និក្ខិបិត្វា មញ្ចកេ ឧត្តានា និបជ្ជិ ។ អថខោ អាយស្មា ឧទាយី យេន សា ឥត្ថី តេនុបសង្កមិ ឧបសង្កមិត្វា កោ ឥមំ វសលំ ទុគ្គន្ធំ អាមសិស្សតីតិ និដ្ឋុហិត្វា បក្កាមិ ។ អថខោ សា ឥត្ថី ឧជ្ឈាយតិ ខីយតិ វិបាចេតិ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា មុសាវាទិនោ ឥមេហិ នាម សមចារិនោ

១ ម. ម. បរិក្ខារានន្តិ ។ ២ ម. ម. ហោត្ថុ ភេសុ កោលុទ្ធា ឥត្ថិ អចិរាគំ ទិស្សតិ ។



ថាគិត្រូវលោកម្ចាស់ លោកម្ចាស់ត្រូវការដោយវត្ថុណាដែលខ្ញុំព្រះករុណាល្មមនឹងប្រគេនលោកម្ចាស់បាន ដូចជាចីវរ បិណ្ឌបាត ទៀតសេនាសនៈ ទៀតបរិក្ខារគឺថ្នាំជាបច្ច័យដល់មនុស្សឈឺ នោះលោកម្ចាស់និមន្តប្រាប់មកចុះ ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចីវរ បិណ្ឌបាត ទៀតសេនាសនៈ ទៀតបរិក្ខារគឺថ្នាំជាបច្ច័យដល់មនុស្សមានជម្ងឺដែលជារបស់នាង យើងមិនមែនបានដោយកម្រទេ តែជារបស់ណាដែលយើងបានដោយកម្រ នាងចូរឲ្យរបស់នោះដល់យើងវិញចុះ ។ ស្រីនោះសួរថា ឲ្យអ្វីលោកម្ចាស់ ។ ឧទាយិភិក្ខុឆ្លើយថា ឲ្យមេថុនធម្ម ។ ស្រីនោះសួរថា លោកម្ចាស់ត្រូវការឬ ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី អាត្មាត្រូវការដែរ ។ ស្រីនោះឆ្លើយថា លោកម្ចាស់និមន្តមកចុះ ចាះហើយក៏ចូលទៅក្នុងបន្ទប់តូចដោះសំពត់សាដកចេញហើយដេកផ្ងារលើគ្រែ ។ ឧទាយិភិក្ខុមានអាយុ ក៏ចូលទៅជិតស្រីនោះក្នុងវេលានោះឯង លុះចូលទៅដល់ហើយក៏ស្តីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ថាហើយក៏ខាកស្តោះដើរចេញទៅ ។ គ្រានោះឯងស្រីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណទាំងនេះជាពួកពៅព្រះកូនសក្យបុត្តឥតសេចក្តីអៀនខ្មាស ទ្រុស្តសីល និយាយពាក្យកុហក ព្រោះថាសមណទាំងនេះប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ត្រូវ

ធម្មចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ កុតោ ឥមេសំ ព្រហ្មញ្ញំ អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញា កថំ ហិ នាម សមណោ ឧទាយី មំ សាមំ មេថុនធម្មំ យាចិស្សតិ កោ ឥមំ ឥសលំ ទុគ្គន្ធំ ការាសិស្សតិតិ បុច្ឆិតា បត្ថយិស្សតិ កិំ មេ បាបកំ កិំ មេ ទុក្កដំ កិស្សាហំ តេន ហាយាមីតិ ។ អញ្ញាបិ ឥត្ថិយោ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ អហិរិកា ឥមេ សមណា សក្យបុត្តិយា ទុស្សីលា មុសាវាទិនោ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ



ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ សាមញ្ញ-គុណរបស់សមណទាំងនេះមានតែណា ព្រហ្មញ្ញគុណរបស់សមណទាំងនេះមានតែណា សមណទាំងនេះព្រាត់ចាកសាមញ្ញគុណហើយ សមណទាំងនេះព្រាត់ចាកព្រហ្មញ្ញគុណហើយ មិនសមបើ សមណឈ្មោះឧទាយិសុំមេថុនធម្មនឹងអញដោយខ្លួនឯង ហើយស្តីថា អ្នកណាទីទៃហ៊ានស្វាមអន្ទិលស្រីគាគ្រក់មានខ្លួនស្អុយយ៉ាងនេះ ជាហើយពាក់ស្គុះគៀសចេញទៅ (ដូចឈ្មោះសោះ) ការណាមករបស់អញដូចម្តេច គុណអញអាក្រក់ដូច-ម្តេច អញខូចម្តេច អញអន់ (ថាមិនស្មើទៀត) ដោយគុណ ។ ស្រីទាំងឡាយឯទៀតក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណទាំងនេះជាកូនចៅព្រះពុទ្ធជាសក្យបុត្រ គ្មានសេចក្តីខ្មាសខ្មាស ទ្រុស្តសីល និយាយកុហក ព្រោះថា សមណទាំងនេះប្តេជ្ញាខ្លួនជាអ្នកប្រព្រឹត្តត្រឹមត្រូវ ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ

នដ្ឋំ ឥមស្ស ព្រហ្មញ្ញំ កុតោ ឥមស្ស សាមញ្ញំ កុតោ ឥមស្ស ព្រហ្មញ្ញំ អបគតោ ឥមោ សាមញ្ញា អបគតោ ឥមោ ព្រហ្មញ្ញា កថំ ហិ នាម សមណោ ឧទាយិ ឥមិស្សា សាមំ មេថុនធម្មំ យាចិត្វា កោ ឥមំ វសលំ ទុគ្គន្ធំ អាមសិស្សតីតិ និដ្ឋុភិត្វា បក្កមិំសុ កិំ ឥមិស្សា បាបកំ កិំ ឥមិស្សា ទុគ្គន្ធំ កិស្សាយំ កេន ហាយតីតិ ។ អស្សោសុំ ខោ ភិក្ខូ តាសំ ឥត្ថីនំ ឧជ្ឈាយន្តីនំ ខីយន្តីនំ វិបាចេន្តីនំ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុច្ចកា សិក្ខាកាមា តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយិ មាតុគាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ឧទាយឹ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឧទាយិ មាតុគាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសសីតិ ។



ព្រហ្មញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណទាំងនេះនៅពីណា ព្រហ្មញ្ញគុណរបស់សមណទាំងនេះមានពីណា សមណទាំងនេះឃ្លាតចាកសាមញ្ញគុណហើយ សមណទាំងនេះឃ្លាតចាកព្រហ្មញ្ញគុណហើយ មិនសមបើ សមណឈ្មោះឧទាយិសុំមេថុនធម្មនឹងស្រីនេះដោយខ្លួនឯងហើយទើបជាស្ដីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ហើយនាងស្ដោះទៀសចេញទៅ (ដូច្នេះសោះ) ការលាមករបស់ស្រីនេះដូចម្ដេច ក្លិនរបស់ស្រីនេះអាក្រក់ដូចម្ដេច ស្រីនេះដូចម្ដេច ស្រីនេះថោកថយ(ជាងស្រីឯទៀត)ដោយអ្វី ។ ភិក្ខុទាំងឡាយបានឮស្រីទាំងឡាយនោះពោលទោស តិះដៀលបន្ទុះបង្អាប់ (ដូច្នោះហើយ) ។ ភិក្ខុទាំងឡាយណាដែលមានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្ដោស មានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាតែការសិក្សា ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបើឧទាយិភិក្ខុដ៏មានអាយុពោលសរសើរការបម្រើខ្លួនដោយកាមគុណសំណាក់មាតុគ្រាមសោះ ។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគក្នុងពេលនោះ ។ គ្រានោះ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះថា ម្នាលឧទាយិ ឮថាឯងពោលសរសើរការបម្រើ

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស អននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស មាតុគាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសិស្សសិ ននុ មយា មោឃបុរិស អនេកបរិយាយេន វិរាគាយ ធម្មោ ទេសិតោ នោ សរាគាយ ។បេ។ កាមបរិឡាហានំ វូបសមោ អក្ខាតោ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន មាតុគាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសេយ្យ ឯតទគ្គំ ភគិនិ បារិចរិយានំ យា មាទិសំ សីលវន្តំ កល្យាណធម្មំ ព្រហ្មចារី ឯតេន ធម្មេន បរិចរេយ្យាតិ មេថុនុបសញ្ហិតេន សង្ឃាទិសេសោតិ ។



ខ្លួនដោយកាមគុណសំណាក់មាតុគ្រាមមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្ដីនុ៎ះពិតមែន ។ ព្រះសម្មាសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសាបសូន្យ អំពើនោះមិនសមទេ មិនសមគួរ មិនត្រូវទំនង មិនមែនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលមោឃបុរស មិនសមបីបើ អ្នកឯងពោលសរសើរការបម្រើខ្លួនដោយកាមគុណសំណាក់មាតុគ្រាម (ដូច្នេះ) ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ (សូត្រ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនសំដែងឲ្យប្រកបដោយរាគៈទេ ។បេ។ ការរម្ងាប់សេចក្ដីក្តៅក្រហាយក្រោះកាម តថាគតក៏បានសំដែងហើយ ម្នាលមោឃបុរស អំពើលាមករបស់អ្នកឯងនុ៎ះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ត្រេកត្រអាលហើយមានចិត្តប្រែប្រួល ពោលសរសើរការបម្រើជាកាមដើម្បីខ្លួនក្នុងសំណាក់នៃមាតុគ្រាម ដោយសំដីប្រកបដោយមេថុនធម្មថា ស្រីណាគប្បីបម្រើនូវភិក្ខុមានសីល មានធម៌ជាកុសល ជាអ្នកប្រព្រឹត្តធម៌ប្រសើរ ប្រហែលដូចអាត្មា ដោយធម៌នេះ ម្នាលប្អូនស្រី ការបម្រើនេះរបស់ស្រីនោះជាការប្រសើរជាងការបម្រើទាំងអស់ (ពោលពាក្យដូច្នេះ) ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

[១១៥] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឱតិណ្ណោ នាម សារត្តោ អបេក្ខវា បដិពទ្ធចិត្តោ ។ វិបរិណតន្តិ រត្តម្បិ ចិត្តំ វិបរិណតំ ទុដ្ឋម្បិ ចិត្តំ វិបរិណតំ មូឡ្ហម្បិ ចិត្តំ វិបរិណតំ អបិច រត្តំ ចិត្តំ ឥមស្មឹ អត្ថេ អធិប្បេតំ វិបរិណតន្តិ ។ មាតុគាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិតទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ មាតុគាមស្ស សន្តិកេតិ មាតុគាមស្ស សាមន្តា មាតុគាមស្ស អវិទូរេ ។ អត្តកាមន្តិ អត្តនោ កាមំ អត្តនោ ហេតុំ អត្តនោ អធិប្បាយំ អត្តនោ បារិចរិយំ ។ ឯតទគ្គន្តិ ឯតំ អគ្គំ ឯតំ សេដ្ឋំ ឯតំ មោក្ខំ ឯតំ ឧត្តមំ ឯតំ បវរំ ។ យាតិ ខត្តិយា វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វា ។



(១១៥) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ រួចហើយ ។ ភិក្ខុមានសេចក្តីត្រេកអរ ក្រឡេកសម្លឹងមើល មានចិត្តប្រតិព័ទ្ធ ហៅថាមានចិត្តជាប់ត្រង់សេចក្តីនោះហើយ ។ ត្រង់ពាក្យថា ប្រែប្រួល សេចក្តីថា ចិត្តត្រេកអរ ក៏ហៅថាប្រែប្រួល ចិត្តគិតប្រទូស្ត ក៏ហៅថាប្រែប្រួល ចិត្តវង្វេង ក៏ហៅថាប្រែប្រួល តែថាព្រះដ៏មានព្រះភាគសំដៅយកចិត្ត ដែលត្រេកអរថាជាចិត្តប្រែប្រួល ក្នុងអត្ថនេះ ។ មនុស្សស្រីដែលដឹងសេចក្តី ឆ្លៀវឆ្លាស អាចដឹងច្បាស់នូវពាក្យដែលគេនិយាយល្អនឹងអាក្រក់ សំដីគួរនឹងមិនគួរ ហៅថាមាតុគ្រាម (ក្នុងសិក្ខាបទនេះ) ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថាមាតុគ្រាមទេ ។ ត្រង់ពាក្យថា ក្នុងសំណាក់នៃមាតុគ្រាម សេចក្តីថាជិតខាងនៃមាតុគ្រាម គឺមិនឆ្ងាយអំពីមាតុគ្រាម ។ ត្រង់ពាក្យថា កាមដើម្បីខ្លួន សេចក្តីថាបំណងដើម្បីខ្លួន ហេតុដើម្បីខ្លួន សេចក្តីត្រូវការដើម្បីខ្លួន ការបម្រើដើម្បីខ្លួន ។ ត្រង់ពាក្យថា ការបម្រើនេះប្រសើរ សេចក្តីថា ការបម្រើនេះប្រសើរ ការបម្រើនេះប្រសើរបំផុត ការបម្រើនេះជាគ្រឿងរំដោះខ្លួនឲ្យរួចចាកទុក្ខ ការបម្រើនេះខ្ពង់ខ្ពស់ ការបម្រើនេះគួរប្រាថ្នាណាស់ ។ ត្រង់ពាក្យថា ស្រីណា សេចក្តីថា ស្រីក្សត្រិយ៍ក្តី ស្រីព្រាហ្មណ៍ក្តី ស្រីអ្នកលក់ជួញក្តី ស្រីអ្នកស្រែក្តី ។

មាទិសន្តិ ខត្តិយំ ច ព្រាហ្មណំ ច វេស្សំ ច សុទ្ទំ ច ។ សីលវន្តន្តិ បាណាតិបាតា បដិវិរតំ អទិន្នាទានា បដិវិរតំ មុសាវាទា បដិវិរតំ ។ ព្រហ្មចារិន្តិ មេថុនធម្មា បដិវិរតំ ។ កល្យាណធម្មោ នាម តេន ច សីលេន តេន ច ព្រហ្មចរិយេន កល្យាណធម្មោ ហោតិ ។ ឯតេន ធម្មេនាតិ មេថុនធម្មេន ។ បរិចរេយ្យាតិ អភិរមេយ្យ ។ មេថុនុបសំហិតេនាតិ មេថុនធម្មប្បដិសំយុត្តេន ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(១១២) ឥត្ថី ច ហោតិ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឥត្ថិយា សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិសេសស្ស ។ ឥត្ថី ច ហោតិ វេមតិកោ បណ្ឌកសញ្ញី បុរិសសញ្ញី តិរច្ឆានគតសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឥត្ថិយា សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយស្ស ។ បណ្ឌកោ ច ហោតិ បណ្ឌកសញ្ញី សារត្តោ ច ភិក្ខុ ច នំ បណ្ឌកស្ស សន្តិកេ



ត្រង់ពាក្យថា ប្រហែលដូចអាត្មា សេចក្តីថា ក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកឈ្មួញក្តី អ្នកស្រែក្តី ។ ត្រង់ពាក្យថា មានសីល សេចក្តីថា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកមុសាវាទ ។ ត្រង់ពាក្យថា ប្រព្រឹត្តធម៌ដ៏ប្រសើរ គឺវៀរចាកមេថុនធម្ម ។ មានធម៌ជាកុសលដោយសីលនោះផង ដោយព្រហ្មចរិយនោះផង ហៅថា មានធម៌ជាកុសល ។ ត្រង់ពាក្យថា ដោយធម៌នេះ គឺដោយមេថុនធម្ម ។ ត្រង់ពាក្យថា គប្បីបម្រើ គឺគប្បីត្រេកអរចំពោះ ។ ត្រង់ពាក្យថា ប្រកបដោយមេថុន គឺប្រកបព្រមចំពោះដោយមេថុនធម្ម ។ ត្រង់ពាក្យថា ត្រូវអាបត្តិសង្ឃាទិសេស នោះមានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ ។

(១១២) ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដល់ខ្លួន ក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីពិតមែន ភិក្ខុមានសេចក្តីសង្ស័យក្តី សំគាល់ថាខ្ទើយក្តី សំគាល់ថាប្រុសក្តី សំគាល់ថាតិរច្ឆានក្តី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដល់ខ្លួនក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដល់ខ្លួន ក្នុងសំណាក់នៃខ្ទើយនោះ

អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយស្ស ។ បណ្ឌកោ ច ហោតិ វេមតិកោ បុរិសសញ្ញី តិរច្ឆានគតសញ្ញី ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ បណ្ឌកស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទុក្កដស្ស ។ បុរិសោ ច ហោតិ បុរិសសញ្ញី វេមតិកោ តិរច្ឆានគតសញ្ញី ឥត្ថីសញ្ញី បណ្ឌកសញ្ញី សារត្តោ ច ភិក្ខុ ច នំ បុរិសស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទុក្កដស្ស ។ តិរច្ឆានគតោ ច ហោតិ តិរច្ឆានគតសញ្ញី វេមតិកោ ឥត្ថីសញ្ញី បណ្ឌកសញ្ញី បុរិសសញ្ញី សារត្តោ ច ភិក្ខុ ច នំ តិរច្ឆានគតស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទុក្កដស្ស ។

(១១៧) ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ ឥត្ថីនំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ សង្ឃាទិសេសានំ ។ ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ



ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយពិតមែន ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) គឺមានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់ខ្ទើយនោះ ត្រូវអាបត្តិទុក្កដ ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាប្រុស (ក្ដី) មានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) គឺមានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់ប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ តិរច្ឆានពិតមែន ភិក្ខុសំគាល់ថាតិរច្ឆាន (ក្ដី) មានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាស្រី (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) គឺមានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់តិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ ។

(១១៧) ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រី គឺមានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ស្រីពីរនាក់ ភិក្ខុមាន

វេមតិកោ បណ្ឌកសញ្ញី បុរិសសញ្ញី តិរច្ឆានគតសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ ឥត្ថីនំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ថុល្លច្ចយានំ ។ ទ្វេ បណ្ឌកា ទ្វិន្នំ បណ្ឌកានំ បណ្ឌកសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ បណ្ឌកានំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ថុល្លច្ចយានំ ។ ទ្វេ បណ្ឌកា ទ្វិន្នំ បណ្ឌកានំ វេមតិកោ បុរិសសញ្ញី តិរច្ឆានគតសញ្ញី ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ បណ្ឌកានំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ទ្វេ បុរិសា ទ្វិន្នំ បុរិសានំ ។ បេ ។ ទ្វេ តិរច្ឆានគតា ទ្វិន្នំ តិរច្ឆានគតានំ តិរច្ឆានគតសញ្ញី វេមតិកោ ឥត្ថីសញ្ញី បណ្ឌកសញ្ញី បុរិសសញ្ញី សារត្តោ ច ភិក្ខុ ច នំ ទ្វិន្នំ តិរច្ឆានគតានំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ឥត្ថី ច បណ្ឌកោ ច ឧភិន្នំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ





សេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) ចំពោះស្រីទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ខ្ទើយពីរនាក់ ភិក្ខុសំគាល់ខ្ទើយទាំងពីរថាជាខ្ទើយ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ខ្ទើយពីរនាក់ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) ចំពោះខ្ទើយទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរ ។ បេ ។ តិរច្ឆានពីរ ភិក្ខុសំគាល់ថាតិរច្ឆាន (ក្ដី) មានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាស្រី (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) ចំពោះតិរច្ឆានទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់តិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ

វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ ឥត្ថី ច បណ្ឌកោ ច ឧភិន្នំ វេមតិកោ ។បេ។ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។បេ។ បណ្ឌកសញ្ញី ។បេ។ អាបត្តិ ទ្វិន្នំ ថុល្លច្ចយានំ ។បេ។ បុរិសសញ្ញី ។បេ។ តិរច្ឆានគតសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។ ឥត្ថី ច បុរិសោ ច ឧភិន្នំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ ឥត្ថី ច បុរិសោ ច ឧភិន្នំ វេមតិកោ បណ្ឌកសញ្ញី បុរិសសញ្ញី តិរច្ឆានគតសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។ ឥត្ថី ច តិរច្ឆានគតោ ច ឧភិន្នំ ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។



ត្រូវអាបត្តិសង្ឃាទិសេសនឹងអាបត្តិទុក្កដ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុមានសេចក្តីសង្ស័យចំពោះជនទាំងពីរនាក់ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យនឹងអាបត្តិទុក្កដ ។បេ។ ភិក្ខុសំគាល់ថាខ្ទើយ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យពីរ ។បេ។ ភិក្ខុសំគាល់ថាប្រុស ។បេ។ ភិក្ខុសំគាល់ថាតិរច្ឆាន គឺមានសេចក្តីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួនក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនឹងអាបត្តិទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាស្រី គឺមានសេចក្តីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេសនឹងទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាខ្ទើយ (ក្តី) សំគាល់ថាប្រុស (ក្តី) សំគាល់ថាតិរច្ឆាន (ក្តី) ចំពោះជនទាំងពីរនាក់ គឺមានសេចក្តីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនឹងទុក្កដ ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ជនទាំងពីរថាស្រី គឺមានសេចក្តីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេសនឹងទុក្កដ ។

ឥត្ថី ច ឧភតោព្យញ្ជនកោ ច ឧភិន្នំ វេមតិកោ បណ្ឌកសញ្ញី បុរិសសញ្ញី ឧភតោព្យញ្ជនកសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។ បណ្ឌកោ ច បុរិសោ ច ឧភិន្នំ បណ្ឌកសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។ បណ្ឌកោ ច បុរិសោ ច ឧភិន្នំ វេមតិកោ បុរិសសញ្ញី ឧភតោព្យញ្ជនកសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បណ្ឌកោ ច ឧភតោព្យញ្ជនកោ ច ឧភិន្នំ បណ្ឌកសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយេន ទុក្កដស្ស ។ បណ្ឌកោ ច ឧភតោព្យញ្ជនកោ ច ឧភិន្នំ វេមតិកោ បុរិសសញ្ញី ឧភតោព្យញ្ជនកសញ្ញី ឥត្ថីសញ្ញី សារត្តោ ច ភិក្ខុ ច នំ ឧភិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ





ស្រីម្នាក់ ឧភតោព្យញ្ជនៈមួយ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាខ្ទើយ (ក្តី) សំគាល់ថាប្រុស (ក្តី) សំគាល់ថាឧភតោព្យញ្ជនៈ (ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យនឹងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនឹងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាប្រុស (ក្តី) សំគាល់ថាឧភតោព្យញ្ជនៈ (ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ខ្ទើយម្នាក់ ឧភតោព្យញ្ជនៈមួយ ភិក្ខុសំគាល់ជនទាំងពីរនោះថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនឹងទុក្កដ ។ ខ្ទើយម្នាក់ ឧភតោព្យញ្ជនៈមួយ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាប្រុស (ក្តី) សំគាល់ថាឧភតោព្យញ្ជនៈ (ក្តី) សំគាល់ថាស្រី (ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ

អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បុរិសោ ច ឥត្ថីព្យញ្ជនកោ ច ទុវិន្នំ បុរិសសញ្ញី វេមតិកោ ឥត្ថីព្យញ្ជនកសញ្ញី ឥត្ថីសញ្ញី បណ្ឌកសញ្ញី សោភគ្គា ច ភិក្ខុ ច ទំ ទុវិន្នំ សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។

(១១៨) អនាបត្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ឧបដ្ឋហាតិ គណនំ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[១១៩] គាចំ វញ្ញា(១) លោកេ ចុត្តិ
បិយា ច សុភគា ភវេ(២)
កឹ ទជ្ជំ កេនុបដ្ឋេយ្យំ
គាមំ គច្ឆេយ្យ សុគ្គតិន្តិ(៣) ។

[១២០] តេន ខោ បន សមយេន អញ្ញតរា វញ្ញា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កថាហំ ភន្តេ វិជាយេយ្យន្តិ ។ តេនហិ ភគិនិ

១ វញ្ញាតិបិ ឈ.ម. ។ ២ ម. ភវេ ។ ៣ ... សិក្ខាយោ ភាគ ១



ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសម្នាក់ ស្ត្រីខ្ទើយមួយ ភិក្ខុសំគាល់ថាប្រុស (ក្តី) មានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាស្ត្រីខ្ទើយ (ក្តី) សំគាល់ថាស្រី (ក្តី) សំគាល់ថាខ្ទើយ (ក្តី) ជាអ្នកពោលនូវគុណ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

(១១៨) អាបត្តិមិនមាន (ដល់ភិក្ខុ ៣ ពួក) គឺ ភិក្ខុពោលថា នាងចូរបម្រើអាត្មាដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកមានជម្ងឺ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

(មាតិកានុក្រម និបញ្ញើរឿងតាមលំដាប់ហួសហៅដែលនឹងសំដែងតទៅ ដូចមានក្នុងក្រោយនេះ គឺ)

(១១៩) ស្រីអារ ស្រីបានកូន ស្រីឲ្យគុណស្រីសំឡាញ់ ស្រី
ឲ្យបានរូបល្អ សួរភិក្ខុថាធ្វើដូចម្តេច ស្រីឲ្យទាន ស្រី
ចង់បម្រើ សួរភិក្ខុថាធ្វើដូចម្តេច ស្រីចង់ទៅសុគតិ សួរភិក្ខុ
ថាធ្វើដូចម្តេច ។

(១២០) សម័យនោះឯង មានស្រីម្នាក់ជាស្រីអារ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំគួរណាន់នឹងធ្វើដូចម្តេចឲ្យមានកូន ។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី

អគ្គទានំ ទេហីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរា វិជាយិនី ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កថាហំ ភន្តេ បុត្តំ ច(១) លភេយ្យន្តិ ។ តេនហិ ភគិនិ អគ្គទានំ ទេហីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កថាហំ ភន្តេ សាមិកស្ស បិយា អស្សន្តិ ។ តេនហិ ភគិនិ អគ្គទានំ ទេហីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។

១ ឱ. ម. បោត្ថកេសុ ចសទ្ទោ នត្ថិ ។



បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ទើបយកសេចក្តីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូនបានទំលាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចក៏ឲ្យបានកូន ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ បានទំលាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចឲ្យជាទីស្រឡាញ់នៃប្តី ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កថាហំ ភន្តេ សុភគា អស្សន្តិ ។ តេនហិ ភគិនិ អគ្គទានំ ទេហីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច ក្យាហំ ភន្តេ អយ្យស្ស ទទាមីតិ ។ អគ្គទានំ ភគិនីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កេនាហំ ភន្តេ អយ្យំ ឧបដ្ឋាមីតិ ។ អគ្គទានេន ភគិនីតិ ។ កឹ ភន្តេ អគ្គទានន្តិ ។

១១៨
វិនយបិដក មហាវិភង្គ

សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលចូលទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចឲ្យជាស្រីមានបុណ្យ ។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះឆ្លើយថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណានឹងឲ្យទានដូចម្តេចដល់លោកម្ចាស់ ។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះឆ្លើយថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាផ្គត់ផ្គង់លោកម្ចាស់ដោយទានដូចម្តេច ។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី ចូរនាងផ្គត់ផ្គង់ដោយទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។

មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ ។ បេ ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។ តេន ខោ បន សមយេន អញ្ញតរា ឥត្ថី កុលូបកំ ភិក្ខុំ ឯតទវោច កថាហំ ភន្តេ សុគតិំ គច្ឆេយ្យន្តិ ។ តេនហិ ភគិនិ អគ្គទានំ ទេហីតិ ។ កឹ បន ភន្តេ អគ្គទានន្តិ ។ មេថុនធម្មន្តិ ។ តស្ស កុក្កុច្ចំ អហោសិ កច្ចិ នុ ខោ អហំ សង្ឃាទិសេសំ អាបត្តិ អាបន្នោតិ ។ ភគវតោ ឯតមត្ថំ អារោចេសិ ។ អាបត្តិ ត្វំ ភិក្ខុ អាបន្នោ សង្ឃាទិសេសន្តិ ។

បញ្ចមសង្ឃាទិសេសំ និដ្ឋិតំ ។





ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណា គប្បីទៅកាន់សុគតិដោយកុសលដូចម្តេច ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយឬមិន ។ ទើបយកសេចក្តីនោះក្រាបទូលបង្គំព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

សង្ឃាទិសេសទី ៥ចប់ ។

# បញ្ចមសង្ឃាទិសេសំ

(១៦១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ សាវត្ថិយំ កុលូបកោ ហោតិ ពហុកានិ កុលានិ ឧបសង្កមតិ យត្ថ បស្សតិ កុមារកំ វា អបជាបតិកំ កុមារិកំ វា អបតិកំ កុមារកស្ស មាតាបិតូនំ សន្តិកេ កុមារិកាយ វណ្ណំ ភណតិ អមុកស្ស កុលស្ស កុមារិកា អភិរូបា ទស្សនីយា បាសាទិកា បណ្ឌិតា ព្យត្តា មេធាវិនី ទក្ខា អនលសា ឆន្នា សា កុមារិកា ឥមស្ស កុមារកស្សាតិ ។ តេ ឯវំ វទន្តិ[1] ឯតេ ខោ អយ្យ អម្ហេ ន ជានន្តិ កេ វា ឥមេ កស្ស វាតិ សចេ អយ្យ អយ្យោ ទាបេយ្យ អានេយ្យាម មយំ តំ កុមារិកំ ឥមស្ស កុមារកស្សាតិ ។ កុមារិកាយ មាតាបិតូនំ សន្តិកេ កុមារកស្ស វណ្ណំ ភណតិ អមុកស្ស កុលស្ស កុមារកោ អភិរូបោ ទស្សនីយោ

[1] ម. ម. វទន្តិ ។

# សង្ឃាទិសេស ទី៥

(១៦១) សម័យនោះឯង ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧទាយិត្ថេរដ៏មានអាយុជាអ្នកចូលទៅកាន់ត្រកូលក្នុងក្រុងសាវត្ថី តែងចូលទៅកាន់ត្រកូលទាំងឡាយមានប្រមាណច្រើន ឃើញកុមារដែលគ្មានប្រពន្ធក្តី ឃើញនាងកុមារីដែលគ្មានប្តីក្តី ក្នុងទីណា គឺនិយាយសរសើរនាងកុមារីក្នុងសំណាក់នៃមាតាបិតារបស់កុមារ (ក្នុងទីនោះ) ថា នាងកុមារីរបស់ត្រកូលឯណោះ មានរូបល្អគួរគយគន់មើល ល្មមជ្រះថ្លា ជាស្រីមានប្រាជ្ញាមធ្យម ខ្លៀវខ្លាស វាងវៃ មិនខ្ជិលច្រអូស នាងកុមារីនោះ សមគួរដល់កុមារនេះណាស់ ។ មាតាបិតារបស់កុមារនោះ គឺនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកអស់នោះគេមិនធ្លាប់ស្គាល់យើងខ្ញុំថា ពួកអស់ទាំងនុះជានរណាក្តី ជាកូនរបស់អ្នកណាក្តី ដូច្នេះឡើយ បពិត្រលោកដ៏ចំរើន ប្រសិនបើលោកម្ចាស់ឲ្យគេឲ្យ យើងខ្ញុំនឹងនាំនាងកុមារីនោះមកឲ្យកុមារនេះដែរ ។ ព្រះឧទាយិត្ថេរដ៏មានអាយុ តែងសរសើរកុមារក្នុងសំណាក់មាតាបិតារបស់នាងកុមារីថា កុមាររបស់ត្រកូលឯណោះ មានរូបល្អគួរគយគន់មើល

ទាសាគតោ ចណ្ឌាលោ ព្យគ្ឃោ មេណ្ឌី ធនត្ថា អធលាសោ ឥន្ទ្រោ សោ កុមារកោ វតិស្សា កុមារិកាយាតិ(១) ។ តេ បរំ កតន្តិ បរោ តោ កដ្ឋ អម្ហ ច ជាតន្តិ តេ ក សំ តេស្ស ភត្តិ ឥតិ ស្មឹ រំយ កុមារិកាយ វត្ថុំ សាតេ កដ្ឋ អយ្យោ យាជាតេយ្យ ធជ្ជេយ្យាថ មយំ សំ កុមារិកំ តស្ស កុមារកស្សាតិ ។ បរោ តេ ទុតាយេន អភិមានិបិ កាលបេតិ វិភហានិបិ កាលបេតិ ភយេយ្យានិបិ វត្តាបេតិ ។

(១៦៦) តេន ខោ បន សមយេន អញ្ញតរិស្សា បុរាណគណកិយា ធីតា អភិរូបា ហោតិ ទស្សនីយា បាសាទិកា ។ តិរោគាមកា ច អាជីវកសាវកា អាគន្ត្វា តំ គណកឹ ឯតទវោចុំ ទេហាយ្យេ ឥមំ កុមារិកំ អម្ហាកំ កុមារកស្សាតិ ។ សា ឯវមាហ អហំ ខោ អយ្យា តុម្ហេ ន ជានាមិ តេ ក សំ តេស្ស ភតិ អយញ្ច មេ ឯកធីតិកា តិរោគាមោ ច គន្តព្វោ





ល្អបព្រៃផ្កា ជាស្រែសមានប្រាប់អត់លាជ ទៀតទ្ធរ ករ៉ារ រំពន្ធិល ប្រែរូបកុមារនោះសម្គាល់ថាជាកុមារីនេះណាស់ ។ ម្តាយរកកុំកូនបាន កុមារីនោះរឿយថា បពិត្រលោកម្ចាស់ អ្នកអស់នោះមិនធ្លាប់ស្គាល់យើងថា អ្នកអស់នុះតាមអ្វី ជាគូទៅម្នាក់ណាក្តី ការផលយើងនិយាយព្រោះតាម កុមារីជួបជាមៀនមាត់គេណាស់ បពិត្រលោកដ៏ចំរើន បើលោកម្ចាស់ ឲ្យគេយកផ្ការដ៏យើង ខ្ញុំឲ្យតាន់កុមារីនេះជល់កុមារនោះផង ។ ទោះបើ កំគួតតនឲ្យគ្រូលរៀបចំរាក់ហាមទ្ធិលផង រៃហាមទ្ធិលផង ឲ្យស្ត្រីផល្កានិទ្ធ ទំងគ្នាផង ស្តូវតែជាយខ្មោយនេះឯង ។

(១៦៦) សម័យនោះឯង មានកូនស្រី នៃស្រីបម្រើយម្នាក់ជាបែកខ្ទ ហោកបាស់ មានរូបឆោមស្រស់បស់គួរគេបត់មើលមាំឲ្យព្រែង ។ កូន សាគេរបស់កេដ៏តែទៅស្រែគ្រាប់ធុនចូលមកនិយាយថា បែកខ្ទហោក នោះថា ហ្លាលស្ត្រី អ្នកចូរឲ្យតាន់កុមារីនេះមកកុមាររបស់យើងទៅ ។ បែកខ្ទហោកក៏និយាយថា នេះថា បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំឯងមិន ធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វី មកជាគូទៅអ្នកណាទេ ម្យ៉ាង ទៀតត្តនាន់នេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយជាត្រូវទៅស្រែគ្រាប់ផងទៀត

ញាតេ ទស្សាមីតិ ។ មនុស្សា តេ អាជីវកសាវកេ
ឯតទវោចុំ កិស្ស តុម្ហេ អយ្យា អាគតត្ថាតិ ។ ឥធ
មយំ អយ្យា អមុកំ នាម គណកឹ ធីតរំ យាចិម្ហា
អម្ហាកំ កុមារកស្ស សា ឯវមាហ នាហំ អយ្យា
តុម្ហេ ច ជានាមិ កេ វា ឥមេ កស្ស វាតិ មយ្ហញ្ច
មេ ឯកធីតិកា គាមន្តរោ ច គន្តព្វោ នាហំ
ទស្សាមីតិ ។ កិស្ស តុម្ហេ អយ្យា តំ គណកឹ
ធីតរំ យាចិត្ថ ននុ អយ្យោ ឧទាយិ វត្តព្វោ អយ្យោ
ឧទាយិ ទាបេស្សតីតិ ។ អថខោ តេ អាជីវកសាវកា
យេនាយស្មា ឧទាយិ តេនុបសង្កមិំសុ ឧបសង្កមិត្វា
អាយស្មន្តំ ឧទាយឹ ឯតទវោចុំ ឥធ មយំ ភន្តេ អមុកំ
នាម គណកឹ ធីតរំ យាចិម្ហា អម្ហាកំ កុមារកស្ស
សា ឯវមាហ នាហំ អយ្យា តុម្ហេ ច ជានាមិ កេ វា
ឥមេ កស្ស វាតិ មយ្ហញ្ច មេ ឯកធីតិកា គាមន្ត-
រោ ច គន្តព្វោ នាហំ ទស្សាមីតិ ឥង្ឃ ភន្តេ



ខ្ញុំមិនឲ្យទេ ។ មនុស្សទាំងឡាយសួរទៅពួកសាវករបស់អាជីវកនោះថា
បពិត្រអ្នកម្ចាស់ទាំងឡាយ អស់អ្នកមកនេះដោយហេតុអ្វី ។ ពួកសាវករបស់
អាជីវកនោះប្រាប់ថា យើងមកដណ្តឹងធីតារបស់អ្នកស្រីប្រពន្ធហោរ
ឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយថា
បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយ
ជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀតធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ
ហើយត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ ។ មនុស្សទាំងឡាយ
នោះប្រាប់ទៅពួកសាវករបស់អាជីវកវិញថា បពិត្រអ្នកម្ចាស់ទាំងឡាយ
ម្តេចក៏អស់អ្នកទៅដណ្តឹងធីតារបស់ប្រពន្ធហោរនោះ ក៏គួរតែអ្នកទាំង-
ឡាយពឹងលោកម្ចាស់ឧទាយិ លោកម្ចាស់ឧទាយិនឹងបង្គាប់ឲ្យគេឲ្យទេមុខ ។
គ្រានោះឯង ពួកសាវករបស់អាជីវក ក៏ចូលទៅឯទីដែលព្រះឧទាយិគង់
នៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងព្រះឧទាយិដ៏មាន
អាយុថា បពិត្រលោកដ៏ចំរើន យើងមកដណ្តឹងធីតារបស់ប្រពន្ធហោរ
ឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយ
យ៉ាងនេះថា ខ្ញុំមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ
ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀតធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ
ហើយត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ បពិត្រលោកដ៏ចំរើន

អយ្យោ តំ គណកឹ ធីតរំ ទាបេតុ អម្ហាកំ កុមារកស្សាតិ ។ អថខោ អាយស្មា ឧទាយី យេន សា គណកី តេនុបសង្កមិ ឧបសង្កមិត្វា តំ គណកឹ ឯតទវោច កិស្ស ឥមេសំ ធីតរំ ន ទេសីតិ ។ អហំ ខ្វយ្យ ឥមេ ន ជានាមិ កេ ឥមេ កស្ស វាតិ អយញ្ច មេ ឯកធីតិកា តិរោគាមោ ច គន្តព្វោ នាហំ ទស្សាមីតិ ។ ទេហិ ឥមេសំ អហំ ឥមេ ជានាមីតិ ។ សចេ ភន្តេ អយ្យោ ជានាតិ ទស្សាមីតិ ។ អថខោ សា គណកី តេសំ អាជីវកសាវកានំ ធីតរំ អទាសិ ។ អថខោ តេ អាជីវកសាវកា តំ កុមារិកំ នេត្វា មាសំយេវ សុណិសាភោគេន ភុញ្ជិំសុ តតោ អបរេន ទាសីភោគេន ភុញ្ជិំសុ ។

(១៦៣) អថខោ សា កុមារិកា មាតុយា សន្តិកេ ទូតំ បាហេសិ អហំ ហិ ទុក្ខិតា ទុក្ខិតា ន សុខំ លភាមិ មាសំយេវ មំ សុណិសាភោគេន



យើងសូមពឹងលោកម្ចាស់ សូមលោកម្ចាស់និយាយនឹងប្រពន្ធហោរា ឲ្យកូនស្រីមកកាន់ផ្ទះរបស់យើងទៅ ។ គ្រានោះឯង ព្រះឧទាយិដ៏មានអាយុ ក៏ចូលទៅរកទីដែលប្រពន្ធហោរានៅ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងប្រពន្ធហោរានោះថា ហេតុអ្វីបានជានាងមិនឲ្យធីតាដល់អ្នកទាំងនេះ ។ ប្រពន្ធហោរាក៏ឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមិនធ្លាប់ស្គាល់អ្នកទាំងនេះថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះជាធីតាតែមួយរបស់ខ្ញុំ ហើយជាស្រីទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ ។ ព្រះឧទាយិក៏និយាយថា នាងចូរឲ្យទៅអ្នកទាំងនេះចុះ អាត្មាធ្លាប់ស្គាល់គេដែរ ។ ប្រពន្ធហោរានិយាយថា បពិត្រលោកដ៏ចំរើន បើលោកម្ចាស់ស្គាល់ ខ្ញុំព្រះករុណានឹងឲ្យ ។ គ្រានោះឯង ប្រពន្ធហោរានោះ ក៏បានឲ្យធីតាទៅពួកសាវ័ករបស់អាជីវកនោះ ។ លំដាប់នោះ ពួកសាវ័ករបស់អាជីវកនោះឯង ក៏បាននាំនាងកុមារីនោះទៅ ហើយប្រើប្រាស់នាងដោយការបម្រើជាកូនប្រសាបានតែត្រឹមមួយខែ តពីនោះមកប្រើប្រាស់នាងដោយការបម្រើជាទាសីទៅវិញ ។

(១៦៣) គ្រានោះឯង នាងកុមារីនោះក៏ប្រើបម្រើទៅឯសំណាក់ម្ដាយដោយពាក្យថា ខ្ញុំនេះដល់នូវសេចក្ដីក្រលំបាក មិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវក ប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសា

ភុញ្ជិំសុ តតោ អបរំ ទាសីភោគេន ភុញ្ជន្តិ អាគច្ឆតុ មេ មាតា មំ[១] នេស្សតូតិ ។ អថខោ សា ឥត្ថី យេន តេ អាជីវកសាវកា តេនុបសង្កមិ ឧបសង្កមិត្វា តេ អាជីវកសាវកេ ឯតទវោច មា អយ្យោ ឥមំ កុមារិកំ ទាសីភោគេន ភុញ្ជិត្ថ សុណិសាភោគេន ឥមំ កុមារិកំ ភុញ្ជថាតិ ។ តេ ឯវមាហំសុ អម្ហាកំ តយា សទ្ធិំ អាហារូបហារោ នត្ថិ សមណេន សទ្ធិំ អាហារូបហារោ គច្ឆ ត្វំ ន មយំ តំ ជានាមាតិ ។ អថខោ សា ឥត្ថី អាជីវកសាវកេហិ អបសាទិតា បុនទេវ សាវត្ថិំ បច្ចាគញ្ឆិ ។ ទុតិយម្បិ ខោ សា កុមារិកា មាតុយា សន្តិកេ ទូតំ បាហេសិ អហម្ហិ ទុគ្គតា ទុក្ខិតា ន សុខំ លភាមិ មាសំយេវ មំ សុណិសាភោគេន ភុញ្ជិំសុ តតោ អបរំ ទាសីភោគេន ភុញ្ជន្តិ អាគច្ឆតុ មេ មាតា មំ នេស្សតូតិ ។ អថខោ សា ឥត្ថី

១ ម. ម [illegible]



បានត្រឹម ១ ខែ តពីនោះមកក៏ប្រើប្រាស់ខ្ញុំ ដោយការបម្រើជាទាសីទៅវិញ សូមអ្នកម្ដាយខ្ញុំ មកនាំយកខ្ញុំទៅផង ។ គ្រានោះឯង ស្ត្រីមាតានោះ ក៏ចូលទៅរកទីដែលពួកសាវ័ករបស់អាជីវកនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងពួកសាវ័ករបស់អាជីវកនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ អ្នកទាំងឡាយកុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ ។ ពួកសាវ័ករបស់អាជីវកក៏និយាយថា យើងគ្មានទាក់ទងជាមួយនឹងនាងឯងទេ យើងមានទាក់ទងតែនឹងសមណរបស់យើងទេតើ នាងឯងទៅៗ យើងមិនស្គាល់នាងឯងទេ ។ ឯស្ត្រីមាតានោះ កាលបើពួកសាវ័ករបស់អាជីវកតិះដៀលធ្វើមិនឲ្យជ្រះថ្លាហើយ ក៏ត្រឡប់មកក្រុងសាវត្ថីវិញ ។ នាងកុមារីក៏ប្រើបម្រើទៅឯសំណាក់ម្ដាយ គម្រប់លើកទី ២ ទៀតថា ខ្ញុំដល់នូវសេចក្តីក្រីក្រលំបាកមិនបានសេចក្តីសុខទេ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់ខ្ញុំដោយការបម្រើជាកូនប្រសា បានត្រឹម ១ ខែ តពីនោះមកក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមអ្នកម្ដាយខ្ញុំ មកនាំយកខ្ញុំទៅផង ។ ឯស្ត្រីមាតា

យេនាយស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច សា កិរ ភន្តេ កុមារិកា ទុគ្គតា ទុក្ខិតា ន សុខំ លភតិ មាសំយេវ នំ សុណ្ហាភោគេន ភុញ្ជឹសុ តតោ អបរេន ទាសីភោគេន ភុញ្ជន្តិ វទេយ្យាថ ភន្តេ មា អយ្យោ ឥមំ កុមារិកំ ទាសីភោគេន ភុញ្ជិត្ថ សុណ្ហាភោគេន ឥមំ កុមារិកំ ភុញ្ជថាតិ ។ អថខោ អាយស្មា ឧទាយិ យេន តេ អាជីវកសាវកា តេនុបសង្កមិ ឧបសង្កមិត្វា តេ អាជីវកសាវកេ ឯតទវោច មា អយ្យោ ឥមំ កុមារិកំ ទាសីភោគេន ភុញ្ជិត្ថ សុណ្ហាភោគេន ឥមំ កុមារិកំ ភុញ្ជថាតិ ។ តេ ឯវមាហំសុ នត្ថម្ហាកំ តយា សទ្ធឹ អាហារូបហារោ ឥត្ថិយា សទ្ធឹ អម្ហាកំ អាហារូបហារោ សមណេន ភវិតព្វំ អព្យាវដេន សមណោ អស្ស សុសមណោ គច្ឆ ត្វំ ន មយំ តំ ជានាមាតិ ។ អថខោ អាយស្មា ឧទាយិ តេហិ អាជីវកសាវកេហិ អបសាទិតោ



ក៏ចូលទៅរកទីដែលឧទាយិភិក្ខុដ៏មានអាយុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ឮដំណឹងថា នាងកុមារីនោះ ជាស្ត្រីកំសត់ក្រីក្រលំបាក មិនបានសេចក្តីសុខសោះ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់ ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមក ក៏ប្រើប្រាស់ដោយការបម្រើជាទាសីទៅវិញ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និយាយនឹងគេផងចុះថា ម្នាលអ្នកដ៏ចំរើន អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាកូនប្រសាវិញ ។ គ្រានោះឯង ឧទាយិដ៏មានអាយុចូលទៅរកទីដែលពួកសាវករបស់អាជីវកនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងពួកសាវករបស់អាជីវកនោះថា ម្នាលអ្នកដ៏ចំរើន អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាកូនប្រសាវិញ ។ ពួកសាវករបស់អាជីវកនោះឆ្លើយថា យើងគ្មានទាក់ទងជាមួយនឹងលោកទេ យើងមានទាក់ទងនឹងតែនឹងប្រពន្ធប៉ុណ្ណោះទេតើ សមណៈមិនត្រូវខ្វល់ខ្វាយទេ សមណៈត្រូវតែជាសមណៈល្អ លោកចូរទៅវិញទៅ យើងមិនស្គាល់លោកទេ ។ ឯឧទាយិភិក្ខុដ៏មានអាយុ កាលដែលពួកសាវករបស់អាជីវកមិនឲ្យជ្រះថ្លា

ពុនទេវ សាវត្ថឹ បច្ចាគញ្ឆិ ។ ទុតិយម្បិ ខោ សា កុមារិកា មាតុយា សន្តិកេ ទូតំ បាហេសិ អហំ ហិ ទុក្ខិតា ទុម្មនា ន សុខំ លភាមិ មាសំយេវ មំ សុណិសាភោគេន ភុញ្ជិំសុ តតោ អបរេន ទាសីភោគេន ភុញ្ជន្តិ អាគច្ឆតុ មេ មាតា មំ នេស្សតូតិ ។ ទុតិយម្បិ ខោ សា កុមារិកាយ មាតា យេនាយស្មា ឧទាយី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច សា កិរ ភន្តេ កុមារិកា ទុក្ខិតា ទុម្មនា ន សុខំ លភតិ មាសំយេវ នំ សុណិសាភោគេន ភុញ្ជិំសុ តតោ អបរេន ទាសីភោគេន ភុញ្ជន្តិ វទេយ្យាថ ភន្តេ មា អយ្យា នំ កុមារិកំ ទាសីភោគេន ភុញ្ជន្តុ សុណិសាភោគេន នំ កុមារិកំ ភុញ្ជន្តូតិ ។ បឋមំ ខ្វាហំ តេហិ អាជីវកសាវកេហិ អបសាទិតោ គច្ឆ ត្វំ នាហំ គមិស្សាមីតិ ។



ហើយក៏ត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ នាងកុមារីនោះក៏ប្រើបម្រើទៅឯសំណាក់ម្ដាយគម្រប់ពីរលើកទៀតថា ខ្ញុំដល់នូវសេចក្ដីក្រៀមក្រំលំបាកណាស់ មិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមកគេប្រើប្រាស់ ដោយការបម្រើជាទាសីវិញ សូមឲ្យអ្នកម្ដាយប្រញាប់មកនាំយកខ្ញុំទៅផង ។ ម្ដាយនាងកុមារីនោះចូលទៅឯទីដែលព្រះឧទាយិត្ថេរនៅ លុះចូលទៅដល់ហើយក៏និយាយពាក្យនេះ នឹងព្រះឧទាយិត្ថេរជាគម្រប់លើកទី ២ ថា បពិត្រលោកម្ចាស់ ខ្ញុំបានឮដំណឹងថា នាងកុមារីនោះ ជាស្រីដល់នូវសេចក្ដីក្រៀមក្រំលំបាកណាស់ មិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់ ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមកក៏ប្រើប្រាស់ដោយការបម្រើជាទាសីវិញ បពិត្រលោកចំរើន សូមលោកម្ចាស់ទៅនិយាយនឹងគេថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយកុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាខ្ញុំស្រី ចូរប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ ។ ឧទាយិត្ថេរឆ្លើយថា កាលពីមុន ពួកសាវ័ករបស់អាជីវក ធ្វើអាត្មាមិនឲ្យជ្រះថ្លាទៅហើយ អ្នកឯងចូរទៅចុះ អាត្មាមិនទៅទៀតទេ ។

(១៦៥) អថខោ សា គណកី ឧជ្ឈាយតិ ខីយ្យតិ វិបាចេតិ ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ មា សុខំ លភតុ អយ្យោ ឧទាយី យថា មេ កុមារិកា ទុគ្គតា ទុក្ខិតា ន សុខំ លភតិ បាបិកាយ សស្សុយា បាបកេន សសុរេន បាបកេន សាមិកេនាតិ ។ សាបិ ខោ កុមារិកា ឧជ្ឈាយតិ ខីយ្យតិ វិបាចេតិ ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ មា សុខំ លភតុ អយ្យោ ឧទាយី យថាហំ ទុគ្គតា ទុក្ខិតា ន សុខំ លភាមិ បាបិកាយ សស្សុយា បាបកេន សសុរេន បាបកេន សាមិកេនាតិ ។ អញ្ញាបិ ឥត្ថិយោ អសន្តុដ្ឋា សស្សូហិ វា សសុរេហិ វា សាមិកេហិ វា តា ឯវំ ឱយាចន្តិ ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ ទុក្ខិតោ ហោតុ អយ្យោ ឧទាយី ឯវំ មា សុខំ លភតុ អយ្យោ ឧទាយី យថា មយំ ទុគ្គតា ទុក្ខិតា ន សុខំ លភាម បាបិកាហិ សស្សូហិ



[១៦៥] ស្រីពេស្យាចាស់ ប្រែកន្ទួរហាកនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ព្រះឧទាយីថា តាមដែលកូនអញ ដល់នូវសេចក្ដីក្រៀមក្រំលំបាក មិនបានសេចក្ដីសុខយ៉ាងណា ។ ក៏ព្រោះតែម្ដាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្ដីអាក្រក់ សូមឲ្យលោកម្ចាស់ឧទាយីក្រៀមក្រំដូចយ៉ាងនេះកូនអញ សូមឲ្យលោកម្ចាស់ឧទាយីលំបាកដូចយ៉ាងនេះកូនអញ សូមឲ្យលោកម្ចាស់ឧទាយីកុំបានសេចក្ដីសុខដូចយ៉ាងនេះកូនអញនៅចុះ ចំណែកកុមារីសោត ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ព្រះឧទាយីថា អញដល់នូវសេចក្ដីក្រៀមក្រំលំបាក មិនបានសេចក្ដីសុខយ៉ាងណា ។ ក៏ព្រោះតែម្ដាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្ដីអាក្រក់ សូមឲ្យលោកម្ចាស់ឧទាយីក្រៀមក្រំដូចយ៉ាងនេះអញ សូមឲ្យលោកម្ចាស់ឧទាយីលំបាកដូចយ៉ាងនេះអញ សូមឲ្យលោកម្ចាស់ឧទាយីកុំបានសេចក្ដីសុខដូចយ៉ាងនេះអញនៅចុះ ។ ចំណែកពួកស្រីដទៃ ដែលម្ដាយក្មេកក្ដី ឪពុកក្មេកក្ដី ប្ដីក្ដី មិនត្រេកអរ ស្រីទាំងនោះក៏ផ្ដាសាថា យើងដល់នូវសេចក្ដីក្រៀមក្រំលំបាក មិនបានសេចក្ដីសុខយ៉ាងណា ។ ក៏ព្រោះតែម្ដាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្ដីអាក្រក់ សូមឲ្យលោកម្ចាស់ឧទាយីក្រៀមក្រំដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយីលំបាកដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយី

តាបកេហិ សស្សុរេហិ តាបកេហិ សាមិកេហីតិ ។ យា បន កា ឥត្ថិយោ សទ្ធា សស្សូហិ ក សស្សុរេហិ ក សាមិកេហិ ក កា បរំ អាយាចន្តិ បរំ សុខិតោ ហោតុ អយ្យោ ឧទាយី បរំ សន្តិតោ ហោតុ អយ្យោ ឧទាយី បរំ សុខ-មេធតុ អយ្យោ ឧទាយី យថា មយំ សុខិតា សន្តិតា សុខមេធាម ក្ខកកាហិ សស្សូហិ ភទ្ទ-កេហិ សស្សុរេហិ ភទ្ទកេហិ សាមិកេហីតិ ។

[១៦៨] អស្សោសុំ ខោ ភិក្ខូ បរាភវាបំ ឥត្ថីនំ អាយាចន្តីនំ បរាភវាបំ ឥត្ថីនំ អាយាចន្តីនំ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយី សញ្ចរិត្តំ សមាបជ្ជិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុ-សង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ឧទាយឹ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឧទាយិ សញ្ចរិត្តំ សមាបជ្ជសីតិ ។



កុំទ្រានសេចក្តីសុខដូចយ៉ាងយើងទៅចុះ ។ ពួកស្រីណាដែលម្តាយក្មេកក្តី ឪពុកក្មេកក្តី ប្តីក្តី ត្រេកអរហើយ ពួកស្រីទាំងនោះក៏បន់ស្រន់យ៉ាងនេះថា យើងដល់នូវសេចក្តីសុខបរិបូណ៌ដោយគ្រឿងស្អិតស្អាង ដល់នូវសេចក្តីសប្បាយយ៉ាងណា ។ គឺព្រោះតែម្តាយក្មេកល្អ ព្រោះតែឪពុកក្មេកល្អ ព្រោះតែប្តីល្អ សូមឲ្យលោកម្ចាស់ៗ ទាំងឡាយដល់នូវសេចក្តីសុខដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ៗ ទាំងឡាយបរិបូណ៌ដោយគ្រឿងស្អិតស្អាងដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ៗ ទាំងឡាយដល់នូវសេចក្តីសប្បាយដូចយ៉ាងយើងចុះ ។

ពួកភិក្ខុណា ដែលមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀលថា ចុះហេតុអ្វី បានជាឆន្នភិក្ខុដ៏មានអាយុ ឲ្យមនុស្សកាប់ឈើដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុកគេបូជា ។បេ។ អ្នកដែនបានគោរពបូជា ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឆន្ន ឮថាអ្នកឯងឲ្យមនុស្សកាប់ឈើដែលគេសន្មតជាចេតិយ ដែលអ្នកស្រុកគេបូជា ។បេ។ អ្នកដែនបានគោរពបូជា មែនឬ ។ ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ។បេ។ នែបុរសទទេ ចុះហេតុអ្វីបានជាអ្នកឯងឲ្យមនុស្សកាប់ដើមឈើ ដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែនតែងគោរពបូជា (ដូច្នេះ) ម្នាលមោឃបុរស ព្រោះមនុស្សទាំងឡាយ មានសេចក្ដីសំគាល់ថា ឈើជាសត្វមានជីវិត នែបុរសសោះសូន្យ ហេតុនេះមិនទាន់ឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើវិហារ[១]មានម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន

១ ពាក្យដែលហៅថាវិហារនោះ តាមភាសាបាឡី សំដៅយកទីនៅដ៏ធំរបស់សង្ឃ គឺកុដិដែលធំ ៗ សម្រាប់សង្ឃនៅ ឬទីវត្តទាំងមូលនោះឯង ហៅថាវិហារ ។

ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ តេហិ ភិក្ខូហិ វត្ថុ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ មហល្លកំ វិហារំ ការេយ្យ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ សង្ឃាទិសេសោតិ ។

(៦៦២) មហល្លកោ នាម វិហារោ សស្សាមិកោ វុច្ចតិ ។ វិហារោ នាម ឧល្លិត្តោ វា ហោតិ អវលិត្តោ វា ឧល្លិត្តាវលិត្តោ វា ។ ការយមានេនាតិ ការេន្តោ វា ការាបេន្តោ វា ។ សស្សាមិកន្តិ អញ្ញោ កោចិ សាមិកោ ហោតិ ឥត្ថី វា បុរិសោ វា គហដ្ឋោ វា បព្វជិតោ វា ។ អត្តុទ្ទេសន្តិ អត្តនោ អត្ថាយ ។

(៦៦៣) ភិក្ខូ អភិនេតព្វា វត្ថុទេសនាយាតិ តេន វិហារការកេន ភិក្ខុនា វិហារវត្ថុំ សោធេត្វា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ វិហារវត្ថុឱលោកនំ យាចាមីតិ ។



ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីឲ្យ ភិក្ខុទាំងឡាយនោះ ត្រូវសំដែងទីដែលមិនមានសេចក្តីកន្ទ្រៀស មានឧបចារ បើទីដែលប្រកបដោយសេចក្តីកន្ទ្រៀស មិនមានឧបចារហើយ ភិក្ខុគប្បីឲ្យធ្វើវិហារធំ ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសំដែងទីឲ្យ ត្រូវអាបត្តិសង្ឃាទិសេស ។

(៦៦២) វិហារដែលមានម្ចាស់ គេហៅថាគ្រាស់ហៅថាវិហារធំ ។ (ទីនៅរបស់សង្ឃ) គឺទីដែលលាបតាំងក្នុងក្តី លាបតាំងក្រៅក្តី លាបទាំងខាងក្នុងទាំងខាងក្រៅក្តី ហៅថាវិហារ ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ សេចក្តីថាធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ។ ត្រង់ពាក្យថា មានម្ចាស់ គឺអ្នកណាមួយផ្សេង គឺស្រីក្តី ប្រុសក្តី គ្រហស្ថក្តី អ្នកបួសក្តី ជាម្ចាស់ ។ ត្រង់ពាក្យថា ចំពោះជាទីនៅរបស់ខ្លួន គឺដើម្បីជាប្រយោជន៍ដល់ខ្លួន ។

(៦៦៣) ត្រង់ពាក្យថា ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីឲ្យ គឺត្រូវភិក្ខុអ្នកធ្វើវិហារនោះជម្រះទីសម្រាប់ធ្វើវិហារ រួចហើយចូលទៅរកសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គ(១) ឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងរបស់ភិក្ខុចាស់ៗទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី ហើយពោលយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាមានសេចក្តីប្រាថ្នាធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមសង្ឃត្រួតត្រាមើលទីសម្រាប់

១ សំពត់សម្រាប់ដណ្តប់ខាងលើឈ្មោះថាឧត្តរាសង្គ (ចីពរ) ។

ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ សចេ សព្វោ សង្ឃោ ឧស្សហតិ វិហារវត្ថុំ ឱលោកេតុំ សព្វេន សង្ឃេន ឱលោកេតព្វំ ។ នោ ចេ សព្វោ សង្ឃោ ឧស្សហតិ វិហារវត្ថុំ ឱលោកេតុំ យេ តត្ថ ហោន្តិ ភិក្ខូ ព្យត្តា បដិពលា សារម្ភំ អនារម្ភំ សបរិក្កមនំ អបរិក្កមនំ ជានិតុំ តេ យាចិត្វា សម្មន្និតព្វា ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុឱលោកនំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខូ សម្មន្នេយ្យ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ឱលោកេតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ



ធ្វើវិហារធំ ។ ភិក្ខុអ្នកធ្វើវិហារត្រូវសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង ។ បើសង្ឃទាំងអស់អាចត្រួតត្រាមើលទីសម្រាប់សង់វិហារបាន ត្រូវសង្ឃទាំងអស់ត្រួតមើល ។ បើសង្ឃទាំងអស់មិនអាចត្រួតមើលទីសម្រាប់សង់វិហារបានទេ ហើយភិក្ខុទាំងនោះមានភិក្ខុទាំងឡាយណា ឈ្លាសប្រតិពល ដឹងទីដែលមានសេចក្តីក្តៀស[1] ទីដែលមិនមានសេចក្តីក្តៀស ទីមានឧបចារ ទីមិនមានឧបចារ ភិក្ខុសង្ឃត្រូវសូមភិក្ខុទាំងឡាយនោះហើយសន្មត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះសង្ឃត្រូវសន្មតយ៉ាងនេះ ។ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវឲ្យសង្ឃដឹងដោយវាចាថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនោះចង់ធ្វើវិហារធំ មានតាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមសង្ឃត្រួតមើលទីសម្រាប់សង់វិហារធំ ។ បើការត្រួតមើលទីសម្រាប់សង់វិហារមានកាលដ៏គួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលនូវទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ ពាក្យនេះជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន

---

១ សព្ទនេះប្រែបានពីរយ៉ាង សារម្ភ ។ នេះប្រែថាប្រកបដោយសេចក្តីអន្តរាយ ជាមានហេតុចាស់ ថាប្រកបដោយសេចក្តីក្តៀស ឬមានសេចក្តីក្តៀស ។

សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុឱលោកនំ យាចតិ ។ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខូ សម្មន្នតិ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ឱលោកេតុំ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច ភិក្ខូនំ សម្មុតិ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ឱលោកេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សង្ឃេន ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខូ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ឱលោកេតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៦៦៤) តេហិ សម្មតេហិ ភិក្ខូហិ តត្ថ គន្ត្វា វិហារវត្ថុំ ឱលោកេតព្វំ ។ សារម្ភំ អនារម្ភំ សបរិក្កមនំ អបរិក្កមនំ ជានិតព្វំ ។ សចេ សារម្ភំ ហោតិ អបរិក្កមនំ មា យិធ ករីតិ វត្តព្វោ ។ សចេ អនារម្ភំ ហោតិ សបរិក្កមនំ សង្ឃស្ស អារោចេតព្វំ



សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះប៉ងធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមការត្រួតមើលទីសម្រាប់ធ្វើវិហារនឹងសង្ឃ ។ ព្រះសង្ឃសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផងឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ ការសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផងឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ភិក្ខុទាំងឡាយឈ្មោះនេះផងឈ្មោះនេះផង សង្ឃបានសន្មតហើយ ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ (ការសន្មតដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ) គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំព្រះករុណាចាំទុកនូវដំណើរនេះដោយគតិយ៉ាងស្ងៀមយ៉ាងនេះ ។

(៦៦៤) ភិក្ខុទាំងឡាយដែលសង្ឃបានសន្មតហើយនោះ ត្រូវទៅកាន់ទីនោះ ហើយត្រូវមើលទីដីសម្រាប់សង់វិហារ ។ ភិក្ខុទាំងនោះត្រូវដឹងទីដែលមានសេចក្តីកន្ទ្រៀសនិងទីដែលមិនមានសេចក្តីកន្ទ្រៀស ទីមានឧបចារ ទីមិនមានឧបចារ ។ បើទីមានសេចក្តីកន្ទ្រៀស មិនមានឧបចារ គប្បីប្រាប់ថា លោកកុំធ្វើក្នុងទីនេះ ។ បើទីមិនមានសេចក្តីកន្ទ្រៀស មានឧបចារ គប្បីប្រាប់

អនារម្ភំ សបរិក្កមនន្តិ ។ តេន វិហារការកេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ វិហារវត្ថុទេសនំ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុទេសនំ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ទេសេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុទេសនំ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុំ ទេសេតិ ។



ដល់សង្ឃថាទីមិនមានសេចក្ដីក្តៀស មានចំហារ ។ ភិក្ខុអ្នកធ្វើវិហារនោះ គប្បីចូលទៅរកសង្ឃ ហើយធ្វើឲ្យបើកឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងនៃភិក្ខុចាស់ៗទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលី ពោលយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណា មានសេចក្ដីប្រាថ្នាធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមសង្ឃសំដែងទីសម្រាប់សង់វិហារឲ្យ ។ ភិក្ខុអ្នកធ្វើវិហារ ត្រូវសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង ។ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមឲ្យសង្ឃសំដែងទីសម្រាប់សង់វិហារឲ្យ ។ បើកាលសំដែងទីសម្រាប់សង់វិហារ មានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសំដែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ ។ ពាក្យនេះជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមសង្ឃសំដែងទីសម្រាប់ធ្វើវិហារឲ្យ ។ ព្រះសង្ឃសំដែងទីសម្រាប់ធ្វើវិហារ ដល់ភិក្ខុឈ្មោះនេះ ។

យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុ-ទេសនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតំ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ វិហារវត្ថុ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៦៦៤] សារម្ភំ នាម កិបិល្លិកានំ វា អាសយោ ហោតិ ឧបចិកានំ វា អាសយោ ហោតិ ឧន្ទូរានំ វា អាសយោ ហោតិ អហីនំ វា អាសយោ ហោតិ វិច្ឆិកានំ វា អាសយោ ហោតិ សតបទីនំ វា អាសយោ ហោតិ ហត្ថីនំ វា អាសយោ ហោតិ អស្សានំ វា អាសយោ ហោតិ សីហានំ វា អាសយោ ហោតិ ព្យគ្ឃានំ វា អាសយោ ហោតិ ទីបីនំ វា អាសយោ ហោតិ អច្ឆានំ វា អាសយោ ហោតិ តរច្ឆានំ វា អាសយោ ហោតិ យេសំ កេសញ្ចិ តិរច្ឆានគតានំ បាណានំ អាសយោ ហោតិ បុព្វណ្ណនិស្សិតំ វា ហោតិ អបរណ្ណនិស្សិតំ វា ហោតិ អព្ភាឃាតនិស្សិតំ វា ហោតិ សុសាននិស្សិតំ វា ហោតិ



ការដែលសង្ឃសំដែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម (ធ្វើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ សង្ឃបានសំដែងហើយ ។ ការសំដែងទីសម្រាប់សង់វិហារនេះ គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំព្រះករុណា ចាំទុកនូវសេចក្តីនេះដោយកិរិយាស្ងៀមយ៉ាងនេះ ។

(៦៦៤) ទីដែលហៅថា ប្រកបដោយសេចក្តីរង្កៀស (នោះ) គឺទីជាលំនៅនៃពួកស្រមោចក្រហមក្តី ជាលំនៅនៃពួកកណ្ដៀរក្តី ជាលំនៅនៃពួកកណ្ដុរក្តី ជាលំនៅនៃពួកពស់ក្តី ជាលំនៅនៃពួកខ្ទួយក្តី ជាលំនៅនៃពួកក្អែបក្តី ជាលំនៅនៃពួកដំរីក្តី ជាលំនៅនៃពួកសេះក្តី ជាលំនៅនៃពួកខ្លាធំក្តី ជាលំនៅនៃពួកខ្លាដំបងក្តី ជាលំនៅនៃពួកខ្លាឃ្មុំក្តី ជាលំនៅនៃពួកខ្លារខិន(១)ក្តី ជាលំនៅរបស់ពួកសត្វតិរច្ឆានឯណាមួយក្តី ទីសម្រាប់អាស្រ័យបុព្វណ្ណ(២)ជាតិក្តី ទីសម្រាប់អាស្រ័យអបរណ្ណ(៣)ជាតិក្តី កន្លែងសម្រាប់សម្លាប់ចោរក្តី កន្លែងសម្រាប់ផ្តាច់ទោស(៤)ក្តី កន្លែងទីព្រៃស្មសានក្តី

១ ពាក្យ ខ្លារខិន ប្រែថា ឆ្កែព្រៃ ។ ២ វត្ថុដែលត្រូវបរិភោគមុន បានដល់ស្រូវ ៧ យ៉ាង មានស្រូវសាលីជាដើម ហៅថា បុព្វណ្ណជាតិ ។ ៣ វត្ថុដែលត្រូវបរិភោគក្រោយ បានដល់សណ្តែកល្ងជាដើម ហៅថា អបរណ្ណជាតិ ។ ៤ ទីដែលគេចងកាត់ក ។

ឧយ្យាននិស្សិតំ វា ហោតិ រាជវត្ថុនិស្សិតំ វា ហោតិ ហត្ថិសាលានិស្សិតំ វា ហោតិ អស្សសាលានិស្សិតំ វា ហោតិ ពន្ធនាគារនិស្សិតំ វា ហោតិ បានាគារនិស្សិតំ វា ហោតិ សូននិស្សិតំ វា ហោតិ រច្ឆានិស្សិតំ វា ហោតិ ចច្ចរនិស្សិតំ វា ហោតិ សភានិស្សិតំ វា ហោតិ សំសរណនិស្សិតំ វា ហោតិ ឯតំ សារម្ភំ នាម ។

[៤៤៦] អបរិក្កមនំ នាម ន សក្កា ហោតិ យថាយុត្តេន សកដេន អនុបរិគន្តុំ សមន្តា និស្សេណិយា អនុបរិគន្តុំ ឯតំ អបរិក្កមនំ នាម ។

[៤៤៧] អនារម្ភំ នាម ន កិបិល្លិកានំ វា អាសយោ ហោតិ ។បេ។ ន សំសរណនិស្សិតំ វា ហោតិ ឯតំ អនារម្ភំ នាម ។

[៤៤៨] សបរិក្កមនំ នាម សក្កា ហោតិ យថាយុត្តេន សកដេន អនុបរិគន្តុំ សមន្តា និស្សេណិយា អនុបរិគន្តុំ ឯតំ សបរិក្កមនំ នាម ។



កន្លែងជិតឧទ្យានក្តី កន្លែងជិតប្រាសាទក្តី កន្លែងជិតរោងដំរីក្តី កន្លែងជិតរោងសេះក្តី កន្លែងជិតបន្ទប់ឃុំឃាំងមនុស្សទោសក្តី កន្លែងជិតរោងសុរាក្តី កន្លែងជិតផ្លូវលក់សាច់ក្តី កន្លែងជិតច្រកល្ហកក្តី កន្លែងជិតផ្លូវបែកក្តី កន្លែងជិតសាលាប្រជុំ-យាយក្តី កន្លែងផ្លូវជាទីដើរទៅមកក្តី ទីទាំងប៉ុន្មាននេះ ហៅថាទីប្រកបដោយសេចក្តីបៀតបៀន ។

[៤៤៦] ទីដែលហៅថា មិនមានឧបចារ(នោះ) គឺទីដែលរទេះគេទឹមស្រេចហើយបរមិនបាន ឬជណ្តើរបញ្ឈានជុំវិញមិនបាន ទីទាំងនេះ ហៅថាទីមិនមានឧបចារ ។

[៤៤៧] ទីដែលហៅថា មិនមានសេចក្តីបៀតបៀន(នោះ) គឺទីដែលមិនមែនជាលំនៅនៃពួកស្រមោចក្រហមក្តី ។បេ។ ទីមិនមែនជាផ្លូវដែលគេដើរទៅមកក្តី ទីទាំងនេះហៅថាទីមិនមានសេចក្តីបៀតបៀន ។

[៤៤៨] ទីដែលហៅថា មានឧបចារ(នោះ) គឺទីដែលរទេះគេទឹមស្រេចហើយបរបាន ឬជណ្តើរបញ្ឈានជុំវិញបាន ទីទាំងនេះហៅថាទីមានឧបចារ ។

(៦២៩) មហល្លកោ នាម វិហារោ សស្សាមិកោ វុច្ចតិ ។ វិហារោ នាម ឧល្លិត្តោ វា ហោតិ អវលិត្តោ វា ឧល្លិត្តាវលិត្តោ វា ។ ការាបេយ្យាតិ ការេតិ វា ការាបេតិ វា ។ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយាតិ ញត្តិចតុត្ថេន កម្មេន វិហារវត្ថុំ ន ទេសាបេត្វា ការេតិ វា ការាបេតិ វា បយោគេ ទុក្កដំ ឯកំ បិណ្ឌំ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មិំ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(៦៣០) ភិក្ខុ វិហារំ ការេតិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទ្វិន្នំ ទុក្កដានំ ។ ភិក្ខុ វិហារំ ការេតិ អទេសិតវត្ថុកំ សារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ ភិក្ខុ វិហារំ ការេតិ អទេសិតវត្ថុកំ អនារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ ភិក្ខុ វិហារំ ការេតិ អទេសិតវត្ថុកំ អនារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសស្ស ។



(៦២៩) វិហារដែលមានទាយកជាម្ចាស់ គេហៅថាវិហារធំ ។ ពាក្យថា វិហារ គឺវិហារដែលគេលាបខាងក្នុងក្តី លាបខាងក្រៅក្តី លាបទាំងខាងក្នុងទាំងខាងក្រៅក្តី ហៅថាវិហារ ។ ត្រង់ពាក្យថា កសាងឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ។ ត្រង់ពាក្យថា ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសំដែងទីឲ្យ សេចក្តីថា ភិក្ខុអ្នកធ្វើវិហារមិនឲ្យភិក្ខុទាំងឡាយសំដែងទីសម្រាប់សង់វិហារដោយកម្មមានញត្តិជាគំរប់បួន ហើយធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដព្រោះប្រយោគ នៅខ្វះ១ដុំទៀតនឹងសម្រេច ត្រូវអាបត្តិថុល្លច្ច័យ លុះយកដុំនោះមកសម្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ត្រង់ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ ។

(៦៣០) ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរនឹងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន តែជាទីមានឧបចារ ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីបៀតបៀន តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីបៀតបៀន មានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ។

ភិក្ខុ វិហារំ ការេតិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ ភិក្ខុ វិហារំ ការេតិ ទេសិតវត្ថុកំ សារម្ភំ សបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ ភិក្ខុ វិហារំ ការេតិ ទេសិតវត្ថុកំ អនារម្ភំ អបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ ភិក្ខុ វិហារំ ការេតិ ទេសិតវត្ថុកំ អនារម្ភំ សបរិក្កមនំ អនាបត្តិ ។

[៤៣១] ភិក្ខុ សមាទិសតិ វិហារំ មេ ការេថាតិ ។ តស្ស វិហារំ ការេន្តិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទ្វិន្នំ ទុក្កដានំ ។ បេ ។ សារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ សមាទិសតិ វិហារំ មេ ការេថាតិ ។ តស្ស វិហារំ ការេន្តិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បេ ។



ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរន្ធៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរន្ធៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរន្ធៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរន្ធៀស មានឧបចារ មិនត្រូវអាបត្តិឡើយ ។

៤៣១] ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរន្ធៀស មិនមានឧបចារ (ភិក្ខុអ្នកប្រើនោះ) ត្រូវអាបត្តិទុក្កដពីរនឹងសង្ឃាទិសេស ។ បេ ។ ប្រកបដោយសេចក្តីរន្ធៀស តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេសនឹងអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីរន្ធៀស មិនមានឧបចារ ត្រូវទុក្កដនឹងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីរន្ធៀស តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរន្ធៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។

សារម្ភំ សបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អនាបត្តិ ។

(២៣២) ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ ន ច សមាទិសតិ ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ការេន្តិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទ្វិន្នំ ទុក្កដានំ ។ បេ ។ សារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ ន ច សមាទិសតិ ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ការេន្តិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បេ ។



ប្រកបដោយសេចក្តីបៀតបៀន តែមានឧបចារ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីបៀតបៀន តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីបៀតបៀន មានឧបចារ មិនត្រូវអាបត្តិឡើយ ។

(២៣២) ភិក្ខុបង្គាប់ភិក្ខុទាំងឡាយថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយទៀសចេញទៅ តែមិនបានបង្គាប់ថា វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីបៀតបៀនផង មានទីឧបចារផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរនឹងសង្ឃាទិសេស ។ បេ ។ ប្រកបដោយសេចក្តីបៀតបៀន តែមានឧបចារ ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីបៀតបៀន តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីបៀតបៀន មានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុទាំងឡាយថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយទៀសចេញទៅ តែមិនបានបង្គាប់ថា វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីបៀតបៀនផង មានឧបចារផង ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។

សារម្ភំ សបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អនាបត្តិ ។

[២៣៣] ភិក្ខុ សមាទិសតិ វិហារំ មេ ករោថាតិ ។ សមាទិសតិ ច ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ករោន្តិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ ។ សោ សុណាតិ វិហារោ កិរ មេ កយិរតិ អទេសិតវត្ថុកោ សារម្ភោ អបរិក្កមនោតិ ។ តេន ភិក្ខុនា សាមំ វា គន្តព្វំ ទូតោ វា បាហេតព្វោ ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ នោ ចេ សាមំ វា គច្ឆេយ្យ ទូតំ វា បហិណេយ្យ អាបត្តិ ទុក្កដស្ស ។ បេ ។ ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ចាតិ ។ បេ ។ ទេសិតវត្ថុកោ ច ហោតុ សបរិក្ក-មនោ ចាតិ ។ បេ ។ ទេសិតវត្ថុកោ ហោតូតិ ។



ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ មិនត្រូវអាបត្តិឡើយ ។

[២៣៣] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះ គួរជាវិហារមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានឧបចារផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ។ ភិក្ខុនោះឮដំណឹងថា បានឮថាវិហារគេធ្វើឲ្យអាត្មាអញ សង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ។ ភិក្ខុនោះត្រូវទៅដោយខ្លួនឯងក្តី បញ្ជូនទូតឲ្យទៅក្តី ដោយពាក្យថា វិហារនោះគួរជាវិហារ ដែលមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារផង ។ បើភិក្ខុមិនទៅដោយខ្លួនឯងក្តី មិនបញ្ជូនទូតឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ បេ ។ វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង ។ បេ ។ វិហារនោះគួរជាវិហារដែលសង្ឃបានសំដែងទីឲ្យផង មិនមានឧបចារផង ។ បេ ។ វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង ។

នោ ចេ សាមំ វា គច្ឆេយ្យ ទូតំ វា បហិណេយ្យ អាបត្តិ ទុក្កដស្ស ។ ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ សមាទិសតិ ច ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ករោន្តិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ ។ សោ សុណាតិ វិហារោ កិរ មេ កយិរតិ ទេសិតវត្ថុកោ សារម្ភោ អបរិក្កមនោតិ ។ តេន ភិក្ខុនា សាមំ វា គន្តព្វំ ទូតោ វា បាហេតព្វោ អនារម្ភោ ច ហោតុ សបរិក្កមនោ ចាតិ ។ បេ ។ អនារម្ភោ ហោតូតិ ។ បេ ។ សបរិក្កមនោ ហោតូតិ ។ បេ ។ អនាបត្តិ ។

[២៣៦] ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ សមាទិសតិ ច ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ករោន្តិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ ការុកានំ តិណ្ណំ ទុក្កដានំ ។ បេ ។ សារម្ភំ



បើភិក្ខុមិនទៅដោយខ្លួនឯងក្តី មិនបញ្ជូនបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែភិក្ខុនោះបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃបានសំដែងទីឲ្យផង មិនមានសេចក្តីកង្វៀសផង មានទីចុះបោះផង ។ ភិក្ខុទាំងឡាយគឺធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ តែប្រកបដោយសេចក្តីកង្វៀស មិនមានទីចុះបោះ ។ ភិក្ខុនោះឮដំណឹងថាបានឮថា គេធ្វើវិហារឲ្យអាត្មាអញ ជាវិហារដែលសង្ឃបានសំដែងទីឲ្យតែប្រកបដោយសេចក្តីកង្វៀស មិនមានទីចុះបោះ ។ ភិក្ខុនោះគប្បីទៅដោយខ្លួនឯង ឬប្រើបម្រើឲ្យទៅដោយពាក្យថា វិហារនោះគួរជាវិហារមិនមានសេចក្តីកង្វៀសផង មានទីចុះបោះផង ។ បេ ។ គួរជាវិហារមិនមានសេចក្តីកង្វៀស ។ បេ ។ គួរជាវិហារមានទីចុះបោះ ។ បេ ។ មិនត្រូវអាបត្តិឡើយ ។

(៦៣៦) ភិក្ខុបង្គាប់ពួកភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនប្រកបដោយសេចក្តីកង្វៀសផង មានទីចុះបោះផង ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីកង្វៀស មិនមានទីចុះបោះ (ភិក្ខុទាំងឡាយអ្នកធ្វើ) ត្រូវអាបត្តិទុក្កដ ៣ ។ បេ ។ ប្រកបដោយសេចក្តីកង្វៀស

សបរិក្កមនំ អាបត្តិ ការុកានំ ទ្វិន្នំ ទុក្កដានំ ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ ការុកានំ ទ្វិន្នំ ទុក្កដានំ ។ បេ ។ អនារម្ភំ សបរិក្កមនំ អាបត្តិ ការុកានំ ទុក្កដស្ស ។ ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ សមាទិសតិ ច ទេសិតវត្ថុកោ ច ហោតុ អនារម្ភោ ច សបរិក្កមនោ ចាតិ ។ តស្ស វិហារំ ការេន្តិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ អាបត្តិ ការុកានំ ទ្វិន្នំ ទុក្កដានំ ។ បេ ។ សារម្ភំ សបរិក្កមនំ អាបត្តិ ការុកានំ ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ អាបត្តិ ការុកានំ ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អនាបត្តិ ។

[២៣៩] ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ ។ តស្ស វិហារំ ការេន្តិ អទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ សោ ច វិប្បកតេ អាគច្ឆតិ ។ តេន ភិក្ខុនា សោ វិហារោ អញ្ញស្ស វា ទាតព្វោ ភិន្ទិត្វា វា បុន កាតព្វោ ។ នោ ចេ អញ្ញស្ស វា



តែមានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ មិនមានសេចក្តីបៀតបៀន តែមិនមានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ មិនមានសេចក្តីបៀតបៀន មានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែផ្ដាំផងថា វិហារនោះគួរជាវិហារមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីបៀតបៀនផង មានទីប្រចារផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន មិនមានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ ប្រកបដោយសេចក្តីបៀតបៀន តែមានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីបៀតបៀន មិនមានទីប្រចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីបៀតបៀន មានទីប្រចារ មិនត្រូវអាបត្តិឡើយ ។

(២៣៩) ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីបៀតបៀន មិនមានទីប្រចារ បើវិហារនោះមិនទាន់ហើយ ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះគប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើវិហារនោះធ្វើជាថ្មីទៀត ។ បើភិក្ខុនោះ

ទទេយ្យ ភិន្ទិត្វា វា បុន ការេយ្យ អាបត្តិ សង្ឃាទិសេសេន ទ្វិន្នំ ទុក្កដានំ ។ បេ ។ សារម្ភំ សបរិក្កមនំ... អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ... អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ... អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ សមាទិសិត្វា បក្កមតិ វិហារំ មេ ការេថាតិ ។ តស្ស វិហារំ ការេន្តិ ទេសិតវត្ថុកំ សារម្ភំ អបរិក្កមនំ ។ សោ ចេ វិប្បកតេ អាគច្ឆតិ ។ តេន ភិក្ខុនា សោ វិហារោ អញ្ញស្ស វា ទាតព្វោ ភិន្ទិត្វា វា បុន កាតព្វោ ។ នោ ចេ អញ្ញស្ស វា ទទេយ្យ ភិន្ទិត្វា វា បុន ការេយ្យ អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ បេ ។ សារម្ភំ សបរិក្កមនំ... អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ អបរិក្កមនំ... អាបត្តិ ទុក្កដស្ស ។ បេ ។ អនារម្ភំ សបរិក្កមនំ អនាបត្តិ ។



មិនឲ្យវិហារនោះដល់ភិក្ខុដទៃទេ ឬមិនឲ្យគេរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរនិងសង្ឃាទិសេស ។ បេ ។ ប្រកបដោយសេចក្តីចង្អៀត តែមានទីចូលដល់ ត្រូវអាបត្តិទុក្កដនិងសង្ឃាទិសេស ។ បេ ។ មិនប្រកបដោយសេចក្តីចង្អៀត តែមិនមានទីចូលដល់ ត្រូវអាបត្តិទុក្កដនិងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីចង្អៀត មានទីចូលដល់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុដទៃថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ តែប្រកបដោយសេចក្តីចង្អៀត មិនមានទីចូលដល់ ។ បើភិក្ខុនោះមកដល់ក្នុងវេលាដែលវិហារមិនទាន់ហើយ ។ ភិក្ខុនោះគប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើធ្វើជាថ្មីទៀត ។ បើភិក្ខុនោះមិនឲ្យវិហារនោះទៅភិក្ខុដទៃទេ មិនឲ្យគេរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ ប្រកបដោយសេចក្តីចង្អៀត តែមានទីចូលដល់ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីចង្អៀត តែមិនមានទីចូលដល់ ត្រូវអាបត្តិទុក្កដ ។ បេ ។ មិនមានសេចក្តីចង្អៀត មានទីចូលដល់ មិនត្រូវអាបត្តិឡើយ ។

(៦៣៦) អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ សង្ឃាទិសេសស្ស ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ សង្ឃាទិសេសស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ សង្ឃាទិសេសស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ សង្ឃាទិសេសស្ស ។

(៦៣៧) អនាបត្តិ លេណេ គុហាយ តិណកុដិកាយ អញ្ញស្សត្ថាយ វាសាគារំ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសង្ឃាទិសេសំ និដ្ឋិតំ ។



(៦៣៦) ភិក្ខុធ្វើ (វិហារ) ដោយខ្លួនឯងមិនទាន់ហើយ (តក្រោយ) ក៏ធ្វើបញ្ចប់ឲ្យហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើ (វិហារ) ដោយខ្លួនឯងមិនទាន់ហើយ ឲ្យអ្នកដទៃធ្វើបញ្ចប់ឲ្យហើយ ត្រូវអាបត្តិសង្ឃាទិសេស ។ អ្នកដទៃធ្វើ (វិហារ) មិនទាន់ហើយ ភិក្ខុ (ម្ចាស់វិហារ) ធ្វើបញ្ចប់ឲ្យហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ អ្នកដទៃធ្វើ (វិហារ) មិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបញ្ចប់ឲ្យហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

(៦៣៧) ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើលេណ(១) (ទីសម្រាប់ដេកល្មមនៅបាន) គូហា(២) (ទីចង្អៀតល្មមនៅបាន) កុដិស្មៅ ទាំងកុដិសម្រាប់ភិក្ខុដទៃមានឧបជ្ឈាយ៍ជាដើម ម្យ៉ាងទៀត ដំណើរដែលមិនត្រូវអាបត្តិដល់ភិក្ខុអ្នកធ្វើសេនាសនៈបានក្នុងទីទាំងពួងជាដើម ទាំងភិក្ខុឆ្កួត ទាំងភិក្ខុដើមបញ្ញត្តិ វៀរលែងតែធ្វើផ្ទះសម្រាប់នៅរបស់ខ្លួនចេញ ។

សង្ឃាទិសេស ទី ៧ ចប់ ។

---

១-២ ពាក្យថា លេណ នឹងគូហានេះ ជាប់ទាំង គឺជាពាក្យនិយាយផ្លាស់ប្តូរគ្នា ជាធំទូលាយ បាន (អដ្ឋកថា) ។

# អដ្ឋមសង្ឃាទិសេសំ

(៦៣៨) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ទព្វោ មល្លបុត្តោ ជាតិយា សត្តវស្សោ អរហត្តំ សច្ឆិកតំ ហោតិ យំ កិញ្ចិ សាវកេន បត្តព្វំ សព្វំ តេន អនុប្បត្តំ ហោតិ នត្ថិ ចស្ស កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ ។

(៦៣៩) អថខោ អាយស្មតោ ទព្វស្ស មល្ល-បុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មយា ខោ ជាតិយា សត្ត-វស្សេន អរហត្តំ សច្ឆិកតំ យំ កិញ្ចិ សាវកេន បត្តព្វំ សព្វំ មយា អនុប្បត្តំ នត្ថិ ច មេ កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ កិំ នុ ខោ អហំ សង្ឃស្ស វេយ្យាវច្ចំ ករេយ្យន្តិ ។ អថខោ

# សង្ឃាទិសេស ទី ៨

(៦៣៨) សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះទព្វមល្លបុត្ត(១) ដ៏មានអាយុ មានអាយុ៧ឆ្នាំអំពីកំណើត បានសម្រេចព្រះអរហត្តផល គុណជាតណាមួយដែលសាវកគួរដល់ គុណជាតទាំងអស់ (នោះ) គឺព្រះទព្វមល្លបុត្តនោះបានដល់ដោយលំដាប់ហើយ កិច្ចអ្វីបន្តិចបន្តួច (សោឡសកិច្ច) ដែលព្រះទព្វមល្លបុត្តនោះគប្បីធ្វើតទៅទៀត ឬកិច្ចដែលព្រះទព្វមល្លបុត្តបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចំរើនឡើងទៅទៀត ក៏មិនមានឡើយ ។

(៦៣៩) លំដាប់នោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ទៅកាន់ទីស្ងាត់ សម្ងំនៅក្នុងទីកំបាំង មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អញកើតឡើងបាន៧ឆ្នាំ បានសម្រេចអរហត្តផល គុណជាតណាមួយដែលសាវកគួរដល់ គុណជាតទាំងអស់ (នោះ) គឺអញបានដល់ដោយលំដាប់ហើយ បើនឹងទៀត កិច្ចអ្វីមួយ ដែលអញត្រូវធ្វើតទៅទៀត ឬកិច្ចដែលអញបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចំរើនឡើងទៅទៀត ក៏មិនមានឡើយ (បើដូច្នោះ) អញគប្បីធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃដូចម្តេចហ្ន៎ ។ កាលនោះ

• ព្រះទព្វត្ថេរ ជាបុត្តស្តេចមល្ល ហៅជាឈ្មោះថា ទព្វមល្លបុត្ត ។

អាយស្មតោ ទព្វស្ស មល្លបុត្តស្ស ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យន្តិ ។ អថខោ អាយស្មា ទព្វោ មល្លបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នោ ខោ អាយស្មា ទព្វោ មល្លបុត្តោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ មយា ខោ ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ យំ កិញ្ចិ សាវកេន បត្តព្វំ សព្វំ មយា អនុប្បត្តំ នត្ថិ ច មេ កិញ្ចិ ឧត្តរិ ករណីយំ កតស្ស វា បតិចយោ កិន្នុ ខោ អហំ សង្ឃស្ស វេយ្យាវច្ចំ ករេយ្យន្តិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យន្តិ ឥច្ឆាមហំ ភន្តេ សង្ឃស្ស សេនាសនញ្ច



ព្រះទព្វមល្លបុត្តដ៏មានអាយុបានត្រិះរិះដូច្នេះថា បើដូច្នោះមានតែអញត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងនិមន្តភត្តទាំងឡាយផង ដល់ព្រះសង្ឃ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចេញអំពីទីសម្ងំនឹងកម្មដ្ឋាន នៅពេលសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងវេលានោះ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះព្រះទព្វមល្លបុត្តដ៏មានអាយុគង់ក្នុងទីដ៏សមគួរល្មមហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទៅក្នុងទីស្ងាត់ សម្ងំនៅក្នុងកម្មដ្ឋានក្នុងថ្ងៃនេះ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា កាលខ្ញុំកើតបាន៧ឆ្នាំបានសម្រេចអរហត្តផល គុណជាតឯណាមួយ ដែលសាវកត្រូវដល់ គុណជាតទាំងអស់ (នោះ) ក៏អាត្មាបានដល់ជាលំដាប់ហើយ ម្យ៉ាងទៀត កិច្ចអ្វីមួយដែលអាត្មាគប្បីធ្វើតទៅទៀត ឬកិច្ចដែលអាត្មាបានធ្វើរួចហើយ ដំរើនធ្វើកិច្ចនោះឲ្យចំរើនឡើងទៀតក៏មិនមានឡើយ (បើដូច្នោះ) អាត្មាគប្បីធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃ ឬអ្វីហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីត្រិះរិះនេះកើតមានដល់ខ្ញុំព្រះអង្គនោះថា បើដូច្នោះមានតែអាត្មាត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងនិមន្តភត្តទាំងឡាយផងដល់ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់រៀបចំសេនាសនៈផង

បញ្ញាបេតុំ ភត្តានិ ច ឧទ្ទិសិតុន្តិ ។ សាធុ សាធុ ទព្វ តេនហិ ត្វំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេហិ ភត្តានិ ច ឧទ្ទិសាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ទព្វោ មល្លបុត្តោ ភគវតោ បច្ចស្សោសិ ។

(៦៤០) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នតុ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ បឋមំ ទព្វោ យាចិតព្វោ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អាយស្មន្តំ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ អាយស្មន្តំ ទព្វំ មល្លបុត្តំ សេនាសនបញ្ញាបកញ្ច ភត្តុទ្ទេសកញ្ច សម្មន្នតិ ។ យស្សាយស្មតោ ខមតិ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស



ចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ ។ ព្រះបរមគ្រូទ្រង់ត្រាស់ថា ម្នាលទព្វ ប្រពៃណាស់ហើយៗ បើដូច្នោះអ្នកចូររៀបចំសេនាសនៈផង ចូរចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃចុះ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ដោយពាក្យថា ករុណាព្រះអង្គ ។

(៦៤០) គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងហេតុនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូរសម្មតិទព្វមល្លបុត្ត ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុត្រូវសង្ឃសម្មតិយ៉ាងនេះ មុនដំបូងត្រូវសង្ឃសួរទព្វភិក្ខុ លុះសួររួចហើយ ត្រូវភិក្ខុមួយរូបដែលឈ្លាសប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើការសម្មតិ មានកាលដ៏គួរដល់សង្ឃហើយ សូមព្រះសង្ឃសម្មតិទព្វមល្លបុត្តដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនផង ជាអ្នកចាត់ចែងចង្ហាន់ផង ។ ពាក្យនេះជាពាក្យសម្រាប់ប្រកាសសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ព្រះសង្ឃសម្មតិទព្វមល្លបុត្តដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនផង ជាអ្នកចាត់ចែងចង្ហាន់ផង ។ ការសម្មតិទព្វមល្លបុត្តដ៏មានអាយុ

សេនាសនបញ្ញាបកស្ស ច ភត្តុទ្ទេសកស្ស ច សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន អាយស្មា ទព្វោ មល្លបុត្តោ សេនាសនបញ្ញាបកោ ច ភត្តុទ្ទេសកោ ច ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៦៤៣) សម្មតោ ច បនាយស្មា ទព្វោ មល្លបុត្តោ សភាគានំ សភាគានំ(១) ភិក្ខូនំ ឯកជ្ជំ សេនាសនំ បញ្ញាបេតិ យេ តេ ភិក្ខូ សុត្តន្តិកា តេសំ ឯកជ្ជំ សេនាសនំ បញ្ញាបេតិ តេ អញ្ញមញ្ញំ សុត្តន្តំ សង្គាយិស្សន្តីតិ យេ តេ ភិក្ខូ វិនយធរា តេសំ ឯកជ្ជំ សេនាសនំ បញ្ញាបេតិ តេ អញ្ញមញ្ញំ វិនយំ វិនិច្ឆិនិស្សន្តីតិ(២) យេ តេ ភិក្ខូ អភិធម្មិកា(៣) តេសំ ឯកជ្ជំ សេនាសនំ បញ្ញាបេតិ តេ អញ្ញមញ្ញំ អភិធម្មំ(៤) សាកច្ឆិស្សន្តីតិ យេ តេ ភិក្ខូ

១ សព្វត្ថ អាចរិយេហិ អតិរេកោ ។ ២ ក្នុង វិនិច្ឆិនិស្សន្តីតិ ឱស្សរ ។ ៣ ឆ ម. ធម្មកថិកា ។ ៤ ឆ. ម. ធម្មំ ។



ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងភត្តផង គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម (បើ) មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ទព្វមល្លបុត្តដ៏មានអាយុ ជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងភត្តផង សង្ឃបានសន្មតរួចហើយ ។ ការសន្មតនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ព្រះសង្ឃទើបស្ងៀម ។ ខ្ញុំចាំទុកនូវសេចក្ដីស្ងៀមរបស់សង្ឃនេះយ៉ាងនេះ ។

(៦៤១) ទព្វមល្លបុត្តដ៏មានអាយុដែលសង្ឃបានសន្មតរួចហើយ ក៏រៀបចំសេនាសនៈទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយដែលមានគុណធម៌ស្មើគ្នា ភិក្ខុទាំងឡាយឯណា ជាអ្នករៀនព្រះសូត្រ ទព្វមល្លបុត្តដ៏មានអាយុក៏រៀបចំសេនាសនៈទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុទាំងឡាយនោះនឹងរួមគ្នាសូត្រសាធ្យាយនូវព្រះសូត្រ ។ ភិក្ខុទាំងឡាយឯណា ជាអ្នកទ្រទ្រង់វិន័យ ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកទ្រទ្រង់វិន័យទាំងឡាយនោះ នឹងវិនិច្ឆ័យវិន័យជាមួយគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណា ជាអ្នករៀនព្រះអភិធម្ម ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នករៀនព្រះអភិធម្ម នឹងសាកសួរព្រះអភិធម្មទៅវិញទៅមក ភិក្ខុទាំងឡាយឯណា

ឈាយិនោ តេសំ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ តេ អញ្ញមញ្ញំ ន ព្យាពាធិស្សន្តីតិ យេ តេ ភិក្ខូ តិរច្ឆានកថិកា កាយទឡ្ហិពហុលា វិហរន្តិ តេសំបិ ឯកជ្ឈំ សេនាសនំ បញ្ញបេតិ ឥមេបិមេ អាយស្មន្តោ[១] យថារតិយា អច្ឆិស្សន្តីតិ យេ តេ[២] ភិក្ខូ វិកាលេ អាគច្ឆន្តិ តេសំបិ តេជោធាតុំ សមាបជ្ជិត្វា តេនេវ អាលោកេន សេនាសនំ បញ្ញបេតិ ។ អបិស្សុ ភិក្ខូ សញ្ចិច្ច វិកាលេ អាគច្ឆន្តិ មយំ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស ឥទ្ធិបាដិហារិយំ បស្សិស្សាមាតិ ។ តេ អាយស្មន្តំ ទព្វំ មល្លបុត្តំ ឧបសង្កមិត្វា ឯវំ វទន្តិ អម្ហាកំ អាវុសោ ទព្វ សេនាសនំ បញ្ញបេហីតិ ។ តេ អាយស្មា ទព្វោ មល្លបុត្តោ ឯវំ វទេតិ កត្ថាយស្មន្តា[៣] ឥច្ឆន្តិ កត្ថ បញ្ញបេមីតិ ។ តេ សញ្ចិច្ច ទូរេ អបទិសន្តិ

១ ឧទ្ធំ អាយស្មន្តោតិ ទិស្សតិ ។ ២ ម. យេបិ តេ ។ ម. ឆ. យេបិ ។ ៣ ម. ឆ. កត្ថាយស្មន្តោ ។



ជាអ្នកចំរើនឈាន ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកចំរើនឈានទាំងឡាយនោះ មិនបៀតបៀនគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណា ជាអ្នកពោលតិរច្ឆានកថា[១] ច្រើនដោយការថែមខ្លួន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ដោយគិតថា លោកដ៏មានអាយុទាំងឡាយនេះ នឹងនៅតាមសេចក្ដីដោយពោលនូវតិរច្ឆានកថានេះ ភិក្ខុទាំងឡាយឯណា មកដល់ក្នុងវេលាដែលងងឹត ព្រះទព្វមល្លបុត្តក៏ចូលកាន់តេជោធាតុ[២] ហើយរៀបចំសេនាសនៈដោយពន្លឺនៃតេជោធាតុ ដើម្បីភិក្ខុទាំងឡាយនោះ ។ ជួនកាលមានភិក្ខុទាំងឡាយក្លែងក្លាយ ហើយមកក្នុងវេលាងងឹត ដោយគិតថា យើងទាំងឡាយ នឹងឃើញឥទ្ធិបាដិហារិយ៍ របស់ទព្វមល្លបុត្តដ៏មានអាយុ ។ ភិក្ខុទាំងនោះចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយពោលយ៉ាងនេះថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈដើម្បីយើងទាំងឡាយ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ពោលនូវពាក្យយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា លោកទាំងឡាយដ៏មានអាយុ ចង់បានក្នុងទីណា ខ្ញុំត្រូវរៀបចំក្នុងទីដូចម្ដេច ។ ភិក្ខុទាំងឡាយនោះ

១ ពាក្យពោលចំពោះពាក្យតិរច្ឆាន គឺនិយាយពាក្យទាក់ទងនឹងយោធ ជាពាក្យក្រៅធម៌វិន័យ ។
២ ព្រះទព្វមល្លបុត្តចូលឈានក្នុងវេលានោះយកភ្លើងជាអារម្មណ៍ ឬជាកសិណ ។

អម្ហាកំ អាវុសោ ទព្វ គិជ្ឈកូដេ បព្វតេ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ(១) ចោរប្បបាតេ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ ឥសិគិលិបស្សេ កាឡសិលាយំ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ វេភារបស្សេ សត្តបណ្ណិគុហាយំ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ សីតវនេ សប្បសោណ្ឌិកបព្ភារេ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ គោតមកកន្ទរាយំ(២) សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ តិន្ទុកកន្ទរាយំ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ តបោទកន្ទរាយំ(៣) សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ តបោទារាមេ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ ជីវកម្ពវនេ សេនាសនំ បញ្ញាបេហិ អម្ហាកំ អាវុសោ ទព្វ មទ្ទកុច្ឆិស្មឹ មិគទាយេ សេនាសនំ បញ្ញាបេហីតិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ តេជោធាតុំ សមាបជ្ជិត្វា

១ [illegible] ។ ២ [illegible] ។ ៣ [illegible] ។



(៦៩) ភិក្ខុទាំងនោះនាំគ្នាពោលយ៉ាងនេះថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈលើភ្នំគិជ្ឈកូដ ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈជិតជ្រោះប្រព្រឹត្តទម្លាក់ចោរ ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈលើកាឡសិលា ជាប់នឹងភ្នំឥសិគិលិ ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងសត្តបណ្ណគុហា ជាប់នឹងភ្នំវេភារ ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបជ្រកភ្នំឈ្មោះសប្បសោណ្ឌិក ក្នុងព្រៃត្រជាក់ (សីតវ័ន) ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបជ្រោះភ្នំឈ្មោះគោតមក ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបជ្រោះភ្នំឈ្មោះតិន្ទុក ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបជ្រោះភ្នំឈ្មោះតបោទក ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងតបោទារាម ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងជីវកម្ពវ័ន ដើម្បីយើងទាំងឡាយផង ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងព្រៃឈ្មោះមទ្ទកុច្ឆិ ជាទីឲ្យអភ័យដល់ម្រឹគ ដើម្បីយើងទាំងឡាយផង ។ ព្រះទព្វមល្លបុត្តមានអាយុ ក៏ចូលកាន់តេជោធាតុ

អង្គុលិយា ជលមានាយ បុរតោ បុរតោ គច្ឆតិ ។ តេបិ តេនេវ អាលោកេន អាយស្មតោ ទព្វស្ស មល្លបុត្តស្ស បិដ្ឋិតោ បិដ្ឋិតោ គច្ឆន្តិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ ឯវំ សេនាសនំ បញ្ញាបេតិ អយំ មញ្ចោ ឥទំ បីឋំ អយំ ភិសី ឥទំ ពិម្ពោហនំ ឥទំ វច្ចដ្ឋានំ ឥទំ បស្សាវដ្ឋានំ ឥទំ បានីយំ ឥទំ បរិភោជនីយំ អយំ កត្តរទណ្ឌោ ឥទំ សង្ឃស្ស កតិកសណ្ឋានំ ឥមំ កាលំ បវិសិតព្វំ ឥមំ កាលំ និក្ខមិតព្វន្តិ ។ តេសំ អាយស្មា ទព្វោ មល្លបុត្តោ ឯវំ សេនាសនំ បញ្ញាបេត្វា បុនទេវ វេឡុវនំ បច្ចាគច្ឆតិ ។

(៤៤៦) តេន ខោ បន សមយេន មេត្តិយភុម្មជកា ភិក្ខូ នវកា ចេវ ហោន្តិ អប្បបុញ្ញា ច យានិ សង្ឃស្ស លាមកានិ សេនាសនានិ តានិ តេសំ បាបុណន្តិ លាមកានិ ច ភត្តានិ ។ តេន ខោ បន សមយេន



(ចម្រើនតេជោកសិណ) ហើយមានម្រាមដៃបំភ្លឺរុងរឿង ដើរទៅកាន់ទីខាងមុខ ៗ ។ ភិក្ខុទាំងឡាយនោះក៏ដើរទៅតាមពីខាងក្រោយ ៗ នៃព្រះទព្វមល្លបុត្តដោយពន្លឺនោះឯង ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ រៀបចំក្រាលសេនាសនៈដល់ភិក្ខុទាំងឡាយនោះដោយរបៀបយ៉ាងនេះថា នេះគ្រែ នេះតាំង នេះពូក នេះខ្នើយ នេះទីសម្រាប់ជុះឧច្ចារៈ នេះទីសម្រាប់ជុះបស្សាវៈ នេះទឹកសម្រាប់ផឹក នេះទឹកសម្រាប់ប្រើប្រាស់ នេះឈើច្រត់ នេះកតិកសណ្ឋានរបស់សង្ឃ ពេលនេះត្រូវអ្នកទាំងឡាយចូល ពេលនេះត្រូវអ្នកទាំងឡាយចេញ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ រៀបចំសេនាសនៈយ៉ាងនេះដល់ភិក្ខុទាំងនោះ ហើយក៏វិលត្រឡប់មកកាន់វេឡុវនវិញ ។

[៤៤៦] សម័យនោះឯង ភិក្ខុមេត្តិយភុម្មជកៈ(១) ភិក្ខុទាំងឡាយ ជាអ្នកបួសថ្មីផង មានបុណ្យតិចផង សេនាសនៈទាំងឡាយណាដែលអាក្រក់ ជាសេនាសនៈរបស់សង្ឃ សេនាសនៈទាំងឡាយនោះក៏ដល់មកពួកភិក្ខុមេត្តិយភុម្មជកៈ ទាំងភត្តណាដែលអាក្រក់ ក៏ដល់ចាំមកភិក្ខុទាំងនោះដែរ ។ សម័យនោះឯង មនុស្សទាំងឡាយ

១ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ទាំងពីរអង្គនេះ ជាមេក្លោងមួយៗ ក្នុងពួកឆព្វគ្គិយភិក្ខុ ប៉ុន្តែភិក្ខុពីររូបនេះ ជាអ្នកទើបនឹងបួសថ្មីៗ ។

ភោជេត្វា មនុស្សា ឥទ្ធិ ចេតនំ ភិក្ខូនំ អច្ឆាទេស្សាមាតិ ។ ចោទិ សព្វំ នេសំ ឧក្កដ្ឋំ បេត្តិយ ក្ខន្ធ- កាលំ ឧទ ភិក្ខូនំ បាកតិកំ ទេតិ យថាវុត្ត- ការណា ជាតំ ចិត្តុប្បាទំ ។ បេ បព្ពាជិតំ បិណ្ឌបាត- ប្បដិញ្ញាតា ចេវ ភិក្ខុ បក្កន្តិ ទត្តាកំ រសាសេហ កត្វា ភត្ត- កំ អាហារំ ទត្តាកំ រសាសេហ កត្វា ភត្តកំ អាហារំ ទត្វា ។ បរតោ ចេវ ជំ ភត្តំ អញ្ញាតំ រសាសេហ សប្បិ អាហារំ ខេត្តំ អាហារំ ទត្តកំ អាហារំ ទត្វា ។ បត្តិយ កុម្មាសា បន ភិក្ខុ បរំ រសេតិ អញ្ញាតំ រសាសេហ ឧ ភិក្ខុ អាហារំ បាកតិកំ យថាវុត្ត- ការណា ជាតំ ចិត្តុប្បាទំ ។

[៤៤៣] តេន ខោ បន សមយេន កល្យាណភត្តិ- កោ គហបតិ សង្ឃស្ស ចតុក្កភត្តំ ទេតិ ។

១ ឱ. ម. បោត្ថកេសុ ឥតោ បរំ បិណ្ឌបាតគ្គំ ទិស្សតិ ។



ក៏ក្រែងកផ្ដើរ ចង់ឲ្យសម្បុរផង ព្រែងផង សម្មុខភ្នំកន្ត[1]ផង ដែលគេតាក់តែងដើម្បីភិក្ខុទាំងឡាយជាដើម ដែលមនុស្សទាំងឡាយនោះ ឲ្យបាយបុណ្យវត្ត មានទឹកជ្រលក់ជាតិរបស់ ដែលខ្លួនត្រៀមហើយ យកដំណាលប្រគេន សល់មេក្ខយភិក្ខុទាំងអម្បូតកភិក្ខុ ។ មេក្ខុយភិក្ខុទាំងអម្បូតកភិក្ខុ បាន បន្ថែមខ្លួនហើយក៏សួរភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុទាំងឡាយបានភត្តរបស់ពួកលោក មានអ្វីខ្លះ ម្នាលអាវុសោទាំងឡាយ តែអ្វីខ្លះ មានភិក្ខុទាំងឡាយបានភត្តរបស់លោកទាំងឡាយ ។ ព្រោះថាទាំងឡាយ ពួកខ្ញុំ ប្រាថ្នាយកនំនោះថា ម្នាលអាវុសោ ភិក្ខុទាំងឡាយមានសម្បុរ ភិក្ខុទាំងឡាយមានព្រែង ភិក្ខុទាំងឡាយមានសម្មុខភ្នំកន្ត ។ ឯមេក្ខុយភិក្ខុទាំងអម្បូតកភិក្ខុ និយាយប្រាប់យកនំនោះថា ម្នាលអាវុសោ យើងទាំងឡាយក្ដីបន្តិចបន្តួច មានតែបាយបុណ្យវត្តដែលទឹកជ្រលក់ជាតិរបស់ តាមដំណើរដែលគេត្រៀមទុកជាប្រក្រតីប៉ុណ្ណោះ ។

[៤៤៣] សម័យនោះឯង មានគហបតី (ម្នាក់) ឈ្មោះកល្យាណ- ភត្តិក[2]តែងប្រគេនចតុក្កភត្ត (ភត្តមួយថ្ងៃ) ដល់ព្រះសង្ឃ ។

១ ប្រែតាមលទ្ធិ សង្ឃាដិបរិក្ខារទាំងនៃកក់ពីព្រែង ។ ជាឈ្មោះសម្លៀកដែលអ្នកតម្បាញរបស់ប្រក្រតីដោយប្រាណ ។ ២ កល្យាណៈ មានពន្លឺដូចអ្វីៗ ធ្លាប់ ពិសេសណាស់ ។

សោ ភត្តគ្គេ សម្បត្តកាលេ ឧបតិដ្ឋិត្វា បរិវិសតិ ។ អញ្ញេ ឱទនេន បុច្ឆតិ អញ្ញេ សូបេន បុច្ឆតិ អញ្ញេ តេលេន បុច្ឆតិ អញ្ញេ ឧត្តរិភង្គេន បុច្ឆតិ ។ តេន ខោ បន សមយេន កល្យាណភត្តិកស្ស គហបតិនោ ភត្តំ ស្វាតនាយ មេត្តិយភុម្មជកានំ ភិក្ខូនំ ឧទ្ទិដ្ឋំ ហោតិ ។ អថ ខោ កល្យាណភត្តិកោ គហបតិ អារាមំ អគមាសិ កេនចិទេវ ករណីយេន ។ សោ យេនាយស្មា ទព្វោ មល្លបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ទព្វំ មល្លបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កល្យាណភត្តិកំ គហបតឹ អាយស្មា ទព្វោ មល្លបុត្តោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថ ខោ កល្យាណភត្តិកោ គហបតិ អាយស្មតា ទព្វេន មល្លបុត្តេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច កស្ស ភន្តេ អម្ហាកំ ឃរេ ស្វាតនាយ ភត្តំ ឧទ្ទិដ្ឋន្តិ ។ មេត្តិយភុម្មជកានំ ខោ គហបតិ ភិក្ខូនំ តុម្ហាកំ ឃរេ



គហបតីនោះ ក្រាបទាំងកូនប្រពន្ធ ចូលទៅបម្រើក្បែរ (ព្រះសង្ឃ) ក្នុងរោងភត្ត ។ គឺចូលទៅចំពោះភិក្ខុពួកខ្លះសួរនឹងបាយ ខ្លះសួរនឹងសម្ល ខ្លះសួរនឹងប្រេង ខ្លះសួរនឹងសម្លត្រួតភ័ក្ត្រ ។ សម័យនោះឯង មេត្តិយនឹងភុម្មជកភិក្ខុ ត្រូវនឹងទទួលបង្គាប់ភត្តដើម្បីថ្ងៃស្អែក របស់គហបតីឈ្មោះកល្យាណភត្តិក ដាច់ខ្ទង់ ដែលភត្តុទ្ទេសក(១)ភិក្ខុសំដែងឲ្យ ។ គ្រានោះ គហបតីឈ្មោះកល្យាណភត្តិក បានទៅកាន់អារាមដោយមានកិច្ចការអ្វីមួយដែលខ្លួនត្រូវធ្វើ ។ គហបតីនោះចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ បាននិយាយពន្យល់គហបតីឈ្មោះកល្យាណភត្តិកឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយក្រៃ ដោយពាក្យដ៏ប្រកបដោយធម៌ ។ លំដាប់នោះ គហបតីឈ្មោះកល្យាណភត្តិក កាលដែលព្រះទព្វមល្លបុត្តដ៏មានអាយុ បាននិយាយពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយក្រៃ ដោយពាក្យដ៏ប្រកបដោយធម៌ (ដូច្នេះ) ហើយ ក៏ពោលនូវពាក្យនេះនឹងព្រះទព្វមល្លបុត្តដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ភត្តក្នុងផ្ទះរបស់យើងខ្ញុំថ្ងៃស្អែក លោកម្ចាស់បានដាក់ឲ្យលោកអង្គណា ។ ព្រះទព្វមល្លបុត្តឆ្លើយថា ម្នាលគហបតី ភត្តក្នុងផ្ទះរបស់អ្នក

---

១ ភិក្ខុដែលសង្ឃសន្មតឲ្យធ្វើជាអ្នកចាត់ចែងភត្តដល់ភិក្ខុទាំងឡាយ ។

ស្វាតនាយ ភត្តំ ឧទ្ទិដ្ឋំ ។ អថខោ កល្យាណភត្តិកោ គហបតិ អនត្តមនោ អហោសិ កថំ ហិ នាម ចារ. ភិក្ខូ អស្នាតិ យេវ កុញ្ជិសុទ្ទិតំ យត់ តញ្ញា ធាសិ កណាជកំ យេ ជេ វេ ភត្តិកា អាកង្ខន្តិ តេ ភោជនេ អាសនំ បញ្ញាបេត្វា តានាជកេន ចំលង្ខំ-ទុតិយេន បរិវិសតិ ។ អថ អយ្យាតិ ទោ ភណ ធាសំ កល្យាណភត្តិកស្ស គហបតិនោ បត្តសេនាសិ ។ អថខោ ភេត្តិយភុម្មជកា ភិក្ខូ ហិយ្យោ ខោ អាវុសោ អម្ហាកំ កល្យាណភត្តិកស្ស គហបតិនោ យេវ ភត្តំ ឧទ្ទិដ្ឋំ វេ អម្ហេ កល្យាណភត្តិកោ គហបតិ សបុត្តទារោ ឧបតិដ្ឋិត្វា បរិវិសិស្សតិ អញ្ញេ ឱទនេន បរិវិស្សតិ អញ្ញេ សូបេន បរិវិស្សតិ អញ្ញេ តេលេន បរិវិស្សតិ អញ្ញេ ឧត្តរិភង្គេន បរិវិស្សតិ ។ តេ តេន សោមនស្សេន ឯ ចិត្តស្ស រត្តិយា សុបំសុ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កល្យាណភត្តិកស្ស គហបតិនោ





ញាតិម្នាស្តុក តាមបានចាត់ឲ្យដល់ភិក្ខុមិនកំណត់ភិក្ខុទាំងឡាយ ។ គ្រានោះគហបតីឈ្មោះកល្យាណភត្តិកនឹងមានសេចក្តីអាក់អន់ចិត្ត ដោយគិតថា ចុះហេតុអ្វីបានជាភិក្ខុក្រោកទាំងឡាយ នឹងត្រូវចាប់បញ្ចប់ភិក្ខុផ្ទះយើងដែរ (លុះគិតដូច្នេះហើយ) គឺទៅផ្ទះបន្តិចរួសរាល់ ដែលមាន ស្នេហ៍គ្រែក្លួរ លោកណាមកទទួលបញ្ចប់ ហើយនឹងឲ្យក្រាលអាសនៈក្នុងផ្ទះ ហើយអង្គាសលោកទាំងនោះដោយបាយចុចអង្ករនិងទឹកជ្រក់ជាគំរប់ពីរចុះ ។ ខ្ញុំព្រោះនោះ ទទួលស្លាប់ភោជនគហបតីឈ្មោះកល្យាណភត្តិកដោយពាក្យថាលោក ម្ចាស់ ។ កាលនោះមេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងឡាយគិតគ្នាថា ម្នាលអាវុសោ បញ្ញាប់គឺផ្ទះគហបតីឈ្មោះកល្យាណភត្តិក សម្រាប់យើងនឹងទៅដល់ពួកយើងទាំងឡាយ អំពីថ្ងៃម្សិលមិញហើយ ព្រោះត្រឹមស្អែកគហបតីឈ្មោះកល្យាណភត្តិកព្រមទាំងកូនប្រពន្ធ នឹងចូលមកជិតបម្រើបម្រាស់អង្គាសយើង ភិក្ខុទាំងឡាយខ្លះនឹងអង្គាសដោយបាយ ខ្លះនឹងអង្គាសដោយសម្ល ខ្លះនឹងអង្គាសដោយប្រេង ខ្លះនឹងអង្គាសដោយចំណីក្រៃកន្លែង ។ ដោយសេចក្តីសោមនស្សនោះឯង មេត្តិយភិក្ខុនិងភុម្មជកភិក្ខុនោះ មិនបានដេកលក់ពេញមួយយប់ ។ គ្រានោះ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ព្រឹកឡើងស្លៀកដណ្តប់ហើយប្រដាប់បាត្រនិងចីវរចូលទៅកាន់ទីលំនៅ

និវេសនំ តេនុបសង្កមឹសុ ។ អទ្ទសា ខោ សា ទាសី មេត្តិយភុម្មជកេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន កោដ្ឋកេ អាសនំ បញ្ញាបេត្វា មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច និសីទថ ភន្តេតិ ។ អថខោ មេត្តិយភុម្មជកានំ ភិក្ខូនំ ឯតទហោសិ និស្សំសយំ ខោ ន តាវ ភត្តំ សិទ្ធំ ភវិស្សតិ យថា មយំ កោដ្ឋកេ និសីទាបិយាមាតិ[១] ។ អថខោ សា ទាសី កាណាជកេន ពិលង្គទុតិយេន ឧបគញ្ឆិ ភុញ្ជថ ភន្តេតិ ។ មយំ ខោ ភគិនិ និច្ចភត្តិកាតិ ។ ជានាមិ អយ្យា និច្ចភត្តិកាតិ អបិចាហំ ហិយ្យោ វ គហបតិនា អាណត្តា យេ តេ ស្វេ ភត្តា អាគច្ឆន្តិ តេ កោដ្ឋកេ អាសនំ បញ្ញាបេត្វា កាណាជកេន ពិលង្គទុតិយេន បរិវិសាតិ ភុញ្ជថ ភន្តេតិ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ ហិយ្យោ ខោ អាវុសោ កល្យាណភត្តិកោ គហបតិ អារាមំ អគមាសិ ទព្ពស្ស មល្លបុត្តស្ស សន្តិកេ

១ សព្វត្ថ និសីទាបិយ្យាមាតិ ទិស្សតិ ។



របស់គហបតីឈ្មោះកល្យាណភត្តិក ។ ខ្ញុំស្រីនោះបានឃើញមេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងពីរនិមន្តមកពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈក្នុងជង្រុក ហើយបានពោលពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុ (ទាំងពីររូប) ថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយគង់ (ក្នុងទីនេះ) ចុះ ។ កាលនោះ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ មានសេចក្ដីត្រិះរិះថា ប្រហែលជាចង្ហាន់មិនទាន់ឆ្អិនទេដឹង បានជាគេឲ្យយើងអង្គុយក្នុងជង្រុក (នេះ) ។ ខ្ញុំស្រីនោះក៏លើកបាយចុងអង្ករជាគំរប់ពីរមួយនឹងទឹកជ្រក់ ហើយនិយាយនឹងមេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងពីរនោះថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី យើងទាំងឡាយសុទ្ធតែជាអ្នកត្រូវបានទទួលនិច្ចភត្ត ។ ខ្ញុំស្រីនោះឆ្លើយថា ខ្ញុំព្រះករុណាដឹងថា លោកម្ចាស់ទាំងឡាយជាអ្នកត្រូវបាននិច្ចភត្តហើយ តែថាម្សិលមិញ គហបតីបង្គាប់ខ្ញុំព្រះករុណាថា នែនាង លោកទាំងឡាយឯណាត្រូវការជាអ្នកនិមន្តមកក្នុងថ្ងៃស្អែក ហើយឯងចូរក្រាលអាសនៈក្នុងជង្រុកចុះ ហើយអង្គាសលោកទាំងនោះ ដោយបាយចុងអង្ករជាគំរប់ពីរនឹងទឹកជ្រក់ (ហេតុនោះ) បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកឆាន់ចុះ ។ លំដាប់នោះ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុតិះគ្នាថា ម្នាលអាវុសោ កាលពីថ្ងៃម្សិល គហបតីឈ្មោះកល្យាណភត្តិក បានទៅកាន់សំណាក់ព្រះទព្វមល្លបុត្ត

និស្សំសយំ ខោ មយំ ទព្វេន មល្លបុត្តេន គហបតិនោ សន្តិកេ បរិភិន្នាតិ ។ តេ តេន ទោមនស្សេន ន ចិត្តរូបំ ភុញ្ជិំសុ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា អារាមំ គន្ត្វា បត្តចីវរំ បដិសាមេត្វា ពហារាមកោដ្ឋកេ សង្ឃាដិបល្លត្ថិកាយ និសីទិំសុ តុណ្ហីភូតា មង្កុភូតា បត្តក្ខន្ធា អធោមុខា បជ្ឈាយន្តា អប្បដិភានា ។

[៤៤៤] អថខោ មេត្តិយា ភិក្ខុនី យេន មេត្តិយភុម្មជកា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។ ឯវំ វុត្តេ មេត្តិយភុម្មជកា ភិក្ខូ នាលបិំសុ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ មេត្តិយា ភិក្ខុនី មេត្តិយភុម្មជកេ ភិក្ខូ ឯតទវោច វន្ទាមិ អយ្យាតិ ។ តតិយម្បិ ខោ មេត្តិយភុម្មជកា ភិក្ខូ នាលបិំសុ ។ ក្យាហំ អយ្យានំ អបរជ្ឈាមិ កិស្ស មំ អយ្យា នាលបន្តីតិ ។ តថា ហិ បន ត្វំ ភគិនិ អម្ហេ ទព្វេន មល្លបុត្តេន វិហេឋិយមានេ អជ្ឈុបេក្ខសីតិ ។



ឯកាកមយើង ត្រូវលោកទព្វមល្លបុត្តបំបែកបំបាក់ក្នុងសំណាក់នៃគហបតីនោះហើយ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុទាំងនោះ ក៏ឆាន់ចង្ហាន់ឲ្យសមគួរដល់ចិត្តមិនបាន ព្រោះតែសេចក្ដីទោមនស្សនោះឯង ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ឆាន់ចង្ហាន់រួចហើយ ត្រឡប់មកអារាមក្នុងពេលនោះ ក៏រៀបចំទុកដាក់បាត្រនិងចីវរ ហើយអង្គុយបត់សង្ឃាដិ ខាងក្រៅខ្លោងទ្វារវត្ត នៅស្ងៀម មានសេចក្ដីអៀនខ្មាស់ ទំលាក់ស្មា ឱនមុខចុះ ដល់សំកុកខនិយាយតតាំងសោះ ។

(៤៤៤) គ្រានោះ មេត្តិយាភិក្ខុនីចូលទៅរកមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ ។ កាលបើមេត្តិយាភិក្ខុនី និយាយយ៉ាងនេះហើយ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិននិយាយតបសោះឡើយ ។ មេត្តិយាភិក្ខុនីបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុ ជាគំរប់ពីរដង ។បេ។ ជាគំរប់បីដងថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិននិយាយតបជាគំរប់បីដងដែរ ។ ទើបមេត្តិយាភិក្ខុនីសួរថា ខ្ញុំម្ចាស់បានប្រទូស្តដល់លោកម្ចាស់ទាំងឡាយ អ្វីដូចម្ដេចខ្លះ ទើបបានជាលោកម្ចាស់ទាំងឡាយមិននិយាយនឹងខ្ញុំម្ចាស់ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ព្រោះហេតុតែយើងត្រូវទព្វមល្លបុត្តគេបៀតបៀន ហើយនាងនៅតែធ្វើព្រងើយកន្តើយ ។

ត្យាហំ អយ្យោ ករោមីតិ ។ សចេ ខោ ត្វំ ភគិនិ ឧស្សហេយ្យាសិ អជ្ជេវ ភគវា ទព្វំ មល្លបុត្តំ នាសាបេយ្យាតិ ។ ត្យាហំ អយ្យោ ករោមិ កឹ មយា សក្កា កាតុន្តិ ។ ឯហិ ត្វំ ភគិនិ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា ភគវន្តំ ឯវំ វទេហិ ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា សឧបទ្ទវា យតោ និវាតំ តតោ បវាតំ ឧទកំ មញ្ញេ អាទិត្តំ អយ្យេនម្ហិ ទព្វេន មល្លបុត្តេន ទូសិតាតិ ។ ឯវំ អយ្យាតិ ខោ មេត្តិយា ភិក្ខុនី មេត្តិយភុម្មជកានំ ភិក្ខូនំ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ



មេត្តិយាភិក្ខុនីសួរថា (បើដូច្នេះ) លោកម្ចាស់ឲ្យខ្ញុំធ្វើដូចម្តេច ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បើនាងចង់ឲ្យព្រះដ៏មានព្រះភាគធ្វើឲ្យទព្វមល្លបុត្តវិនាស . (នោះ) ព្រះដ៏មានព្រះភាគគង់នឹងធ្វើទព្វមល្លបុត្តឲ្យវិនាសក្នុងថ្ងៃនេះពុំខាន ។ មេត្តិយាភិក្ខុនីសួរថា ចុះលោកម្ចាស់ករុណាឲ្យខ្ញុំធ្វើដូចម្តេច ខ្ញុំអាចធ្វើម្តេច ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចូរនាងមក ចូរនាងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅគាល់ហើយ ចូរនាងក្រាបទូលពាក្យយ៉ាងនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការបើចប៉ុន មិនមែនជាការសមគួរសោះឡើយ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់ទៅវិញ ដូចជាទឹកធ្លាប់ត្រជាក់ត្រឡប់ជាក្តៅ ខ្ញុំព្រះទព្វមល្លបុត្តជាម្ចាស់លោកប្រទូស្ត(១)ដល់ខ្ញុំម្ចាស់ហើយ ។ មេត្តិយាភិក្ខុនីទទួលស្តាប់ពាក្យមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ដោយពាក្យថា យ៉ាងហ្នឹងហើយលោកម្ចាស់ រួចហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ

១ ពាក្យប្រៀបធៀប សំដៅសេចក្តីផ្ទុយហេតុផល ។

ឯកមន្តំ ឋិតា ខោ មេត្តិយា ភិក្ខុនី ភគវន្តំ ឯតទវោច
ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យាយំ ភន្តេ ទិសា អភយា
អនីតិកា អនុបទ្ទវា សាយំ ទិសា សភយា សឦតិកា
សឧបទ្ទវា យតោ និវាតំ តតោ បវាតំ ឧទកំ មញ្ញេ
អាទិត្តំ អយ្យេនម្ហិ ទព្វេន មល្លបុត្តេន ទូសិតាតិ ។

[៦៤៨] អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ទព្វំ
មល្លបុត្តំ បដិបុច្ឆិ សរសិ ត្វំ ទព្វ ឯវរូបំ កត្តា
យថាយំ ភិក្ខុនី អាហាតិ ។ យថា មំ ភន្តេ ភគវា
ជានាតីតិ ។ ទុតិយម្បិ ខោ ភគវា ។បេ។ តតិយម្បិ
ខោ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច
សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថាយំ ភិក្ខុនី
អាហាតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។



ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។ មេត្តិយាភិក្ខុនីលុះស្ថិតនៅក្នុងទីដ៏សមគួរ
ហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះ
អង្គដ៏ចំរើន ការនេះមិនមែនជាការបិទបាំង មិនមែនជាការសមគួរសោះ
ឡើយ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនធ្លាប់មានភ័យ មិន
មានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ជាប្រកបដោយភ័យ ប្រកប
ដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មាន
ខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់ទៅវិញ ដូចជាទឹកធ្លាប់ត្រជាក់ប្រែ
ជាក្តៅ ខ្ញុំត្រូវព្រះទព្វមល្លបុត្តជាម្ចាស់លោកប្រទូស្តនឹងខ្ញុំព្រះអង្គហើយ ។

[៦៤៨] គ្រានោះ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់
ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ព្រះទព្វមល្លបុត្តដ៏មានអាយុក្នុង
ពេលនោះថា ម្នាលទព្វៈ អ្នករលឹកឃើញឬទេ នាងភិក្ខុនីនេះថាយ៉ាងណា
អ្នកឯងធ្លាប់ធ្វើយ៉ាងនោះមែនឬទេ ។ ព្រះទព្វមល្លបុត្តក្រាបទូលថា បពិត្រ
ព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិត
ហើយ ។ ព្រះដ៏មានព្រះភាគមានបន្ទូលសួរព្រះទព្វមល្លបុត្តដ៏មាន
អាយុជាគំរប់ពីរដង ។បេ។ ជាគំរប់បីដងថា ម្នាលទព្វៈ អ្នករលឹក
ឃើញឬទេ នាងភិក្ខុនីនេះថាយ៉ាងណា អ្នកឯងធ្លាប់ធ្វើយ៉ាងនោះ
មែនឬទេ ។ ព្រះទព្វមល្លបុត្តក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស

ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ សចេ តយា កតំ កតន្តិ វទេហិ សចេ តយា អកតំ អកតន្តិ វទេហីតិ ។ យតោហំ ភន្តេ ជាតោ នាភិជានាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតា បគេវ ជាគរោតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ មេត្តិយំ ភិក្ខុនឹ នាសេថ ឥមេ ច ភិក្ខូ អនុយុញ្ជថាតិ ។ ឥទំ វត្វា ភគវា ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេ ភិក្ខូ មេត្តិយំ ភិក្ខុនឹ នាសេសុំ ។ អថខោ មេត្តិយភុម្មជកា ភិក្ខូ តេ ភិក្ខូ ឯតទវោចុំ មា អាវុសោ មេត្តិយំ ភិក្ខុនឹ នាសេថ ន សា កិញ្ចិ អបរជ្ឈតិ អម្ហេហិ សា ឧស្សាហិតា កុបិតេហិ អនត្តមនេហិ ចាវនាធិប្បាយេហីតិ ។ កឹ បន តុម្ហេ អាវុសោ អាយស្មន្តំ ទព្វំ មល្លបុត្តំ



ព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវនុំព្រះអង្គដោយគតិហើយ ។ ព្រះបរមគ្រូត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិនពោលបណ្ដោះបណ្ដោយយ៉ាងនេះទេ បើអំពើដែលអ្នកបានធ្វើហើយ អ្នកចូរប្រាប់ថា ខ្ញុំធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរប្រាប់ថា ខ្ញុំមិនបានធ្វើទេ ។ ព្រះទព្វៈមល្លបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងពីកើតមក សូម្បីតែយល់សប្តិសេពមេថុនធម្មក៏មិនដែលស្គាល់សោះឡើយ ចាំបាច់ពោលទៅថ្វីដល់កាលភ្ញាក់ (នោះ) ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ ម្យ៉ាងទៀត អ្នកទាំងឡាយចូរសាកសួរភិក្ខុទាំងឡាយនេះមើល ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ក៏ក្រោកចាកអាសនៈចូលទៅកាន់វិហារវិញ ។ ភិក្ខុទាំងឡាយនោះក៏ឲ្យមេត្តិយាភិក្ខុនីសឹកក្នុងពេលនោះ ។ ទើបមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ និយាយពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា ម្នាលអាវុសោ ចូរលោកកុំឲ្យមេត្តិយាភិក្ខុនីសឹក ។ នាង មិនមានកំហុសសោះទេ (ហេតុដើមមកពី) យើងទាំងមិនសប្បាយចិត្ត (ខឹង) ចង់ឲ្យទព្វមល្លបុត្តឃ្លាតចាកសមណភេទ ទើបឲ្យមេត្តិយាភិក្ខុនីនោះប្រឹងប្រែងឡើង ។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកទាំងនោះចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិក

អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេថាតិ ។
ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម
មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ
អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេស្សន្តីតិ ។
អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។
អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ
ភិក្ខុសង្ឃំ សន្និបាតាបេត្វា មេត្តិយភុម្មជកេ ភិក្ខូ
បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ទព្វំ មល្លបុត្តំ
អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេថាតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ
នាម តុម្ហេ មោឃបុរិសា ទព្វំ មល្លបុត្តំ អមូលកេន
បារាជិកេន ធម្មេន អនុទ្ធំសេស្សថ នេតំ មោឃបុរិសា
អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ
សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ



មិនមានមូល(១)ឬ ។ មេត្តិយភិក្ខុនិងភុម្មជកភិក្ខុឆ្លើយថា ម្នាលអាវុសោ យ៉ាង
ហ្នឹងមែនហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។
ភិក្ខុទាំងឡាយនោះ ក៏ពោលទោស និន្ទា តិះដៀលថា ព្រោះហេតុអ្វីបានជា
មេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិ
បារាជិកមិនមានមូល (ដូច្នេះ) ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូល
សេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះ
ដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះមេត្តិយភិក្ខុ
និងភុម្មជកភិក្ខុក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកទាំង
ឡាយចោទព្រះទព្វមល្លបុត្តដោយអាបត្តិបារាជិកមិនមានមូល ពិតមែនឬ ។
មេត្តិយភិក្ខុនិងភុម្មជកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរ
នោះពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃ-
បុរសទាំងឡាយ ព្រោះហេតុអ្វីបានជា អ្នកទាំងឡាយ ចោទព្រះទព្វមល្លបុត្តដោយ
អាបត្តិបារាជិកមិនមានមូល (ដូច្នោះ) ម្នាលមោឃបុរសទាំងឡាយ ហេតុ
នេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លានោះទេ ។បេ។
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ
យ៉ាងនេះថា ភិក្ខុណាមួយ មានសេចក្តីក្រោធ ប្រទូស្ត មានចិត្តអាក់អន់

---

១ មិនបានឃើញ ឬមិនបានឮ ឬគិតរង្កៀសឡើយ ។

ទោសោ អប្បតីតោ អមូលកេន បារាជិកេន ធម្មេន អ-
នុទ្ធំសេយ្យ អប្បេវនាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ
តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អស-
មនុគ្គាហិយមានោ វា អមូលកញ្ចេវ តំ អធិករណំ
ហោតិ ភិក្ខុ ច ទោសំ បតិដ្ឋាតិ សង្ឃាទិសេសោតិ ។

(៦៤៦) យោ បនាតិ យោ យាទិសោ ។បេ។
ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។
ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ ទុដ្ឋោ ទោសោតិ កុបិតោ
អនត្តមនោ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។
អប្បតីតោតិ តេន ច កោបេន តេន ច ទោសេន តាយ
ច អនត្តមនតាយ តាយ ច អនភិរទ្ធិយា អប្បតីតោ
ហោតិ ។ អមូលកំ នាម អទិដ្ឋំ អសុតំ អបរិសង្កិតំ ។
បារាជិកេន ធម្មេនាតិ ចតុន្នំ អញ្ញតរេន ។ អនុទ្ធំសេ-
យ្យាតិ ចោទេតិ វា ចោទាបេតិ វា ។ អប្បេវនាម នំ
ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ ភិក្ខុភាវា ចាវេយ្យំ សម-
ណធម្មា ចាវេយ្យំ សីលក្ខន្ធា ចាវេយ្យំ តបោគុណា
ចាវេយ្យំ ។



ចោទភិក្ខុនឹងអាបត្តិបារាជិកមិនមានមូលដោយបំណងថា អាត្មា
ត្រូវធ្វើដូចម្ដេចឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌[១]នេះបាន លុះសម័យ
ខាងក្រោយតពីនោះមក ព្រោះគេសាកសួរក្ដី គេមិនសាកសួរក្ដី អធិករណ៍
នោះប្រាកដជាគ្មានមូល ភិក្ខុអ្នកចោទនោះក៏ប្ដេជ្ញាទោស (ដោយខ្លួនឯង)
ត្រូវអាបត្តិសង្ឃាទិសេស ។

(៦៤៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទខាង
ដើមរួចហើយ ។ ត្រង់ពាក្យថា មានសេចក្ដីក្រោធប្រទូស្ដ អធិប្បាយថា ទាំង
អន់ចិត្ត មិនត្រេកអរ មានចិត្តគឺពោសព្រោំខុប់ មានចិត្តចង្អៀតចង្អល់ ។
ត្រង់ពាក្យថា មានចិត្តតូចអន់ គឺមានចិត្តមិនរីករាយ ព្រោះសេចក្ដីខឹង
នោះផង ព្រោះទោសនោះផង ព្រោះសេចក្ដីអន់ចិត្តនោះផង ព្រោះសេចក្ដី
មិនត្រេកអរនោះផង ។ ដែលហៅថាមិនមានមូល គឺមិនឃើញ មិនឮ
មិនរង្កៀស ។ ត្រង់ពាក្យថា ដោយអាបត្តិបារាជិក គឺបណ្ដាអាបត្តិបារាជិក
ទាំង ៤ អាបត្តិបារាជិកណាមួយ ។ ត្រង់ពាក្យថា ចោទ គឺចោទខ្លួនឯងក្ដី
ឲ្យអ្នកដទៃចោទក្ដី ។ ពាក្យថា អាត្មាត្រូវធ្វើដូចម្ដេច ឲ្យភិក្ខុនោះឃ្លាតចាក
ព្រហ្មចរិយធម៌នេះបាន អធិប្បាយថា អាត្មាគប្បីឲ្យភិក្ខុនោះឃ្លាតចាកភិក្ខុ
ភាព ឃ្លាតចាកសមណធម៌ ឃ្លាតចាកកងសីល ឃ្លាតចាកតបោគុណ[២] ។

---

១ សាសនព្រហ្មចរិយ ។ ២ ក្នុងអដ្ឋកថាសមន្តបាសាទិកា មានសេចក្ដីថា "គុណធម៌ជា
គ្រឿងដុតកិលេសឲ្យវិនាសទៅ" ។

[៤៦៧] តតោ អបរេន សមយេនាតិ យស្មិំ ខណេ អនុទ្ធំសិតោ ហោតិ តំ ខណំ តំ លយំ តំ មុហុត្តំ វីតិវត្តេ ។ សមនុគ្គាហិយមានោតិ យេន វត្ថុនា អនុទ្ធំសិតោ ហោតិ តស្មិំ វត្ថុស្មិំ សមនុគ្គាហិយមានោ ។ អសមនុគ្គាហិយមានោតិ ន កេនចិ វុច្ចមានោ ។

[៤៦៨] អធិករណំ នាម ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។

[៤៦៩] ភិក្ខុ ច ទោសំ បតិដ្ឋាតីតិ តុច្ឆកំ មយា ភណិតំ មុសា មយា ភណិតំ អភូតំ មយា ភណិតំ អជានន្តេន មយា ភណិតំ ។ សង្ឃាទិសេសោតិ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

[៤៧០] អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ តញ្ចេ ចោទេតិ ទិដ្ឋោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធិំ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



[៤៦៧] ត្រង់ពាក្យថា លុះសម័យតទៅក្រោយតពីនោះមក សេចក្តីថា (ភិក្ខុនោះ) ត្រូវគេកំចាត់ក្នុងខណៈណា ក្នុងខណៈនោះ វេលានោះ ពេលនោះកន្លងទៅ ។ ត្រង់ពាក្យថា កាលគេសាកសួរក្តី សេចក្តីថា (ភិក្ខុនោះ) គេចោទដោយវត្ថុណា គេសាកសួរក្នុងវត្ថុនោះក្តី ។ ត្រង់ពាក្យថា គេមិនសាកសួរក្តី សេចក្តីថា ឥតមានអ្នកណាមួយសាកសួរ ។

[៤៦៨] ដែលហៅថា អធិករណៈ ។ នោះមាន ៤ យ៉ាងគឺ វិវាទាធិករណៈ ១ អនុវាទាធិករណៈ ១ អាបត្តាធិករណៈ ១ កិច្ចាធិករណៈ ១ ។

[៤៦៩] ត្រង់ពាក្យថា ភិក្ខុអ្នកចោទនោះតម្កល់ទោស (ដោយខ្លួនឯង) សេចក្តីថា អញពោលពាក្យទទេ អញពោលពាក្យកុហក អញពោលពាក្យមិនពិត អញមិនដឹងហើយពោល ។ ត្រង់ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ ។

[៤៧០] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញទេ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា ខ្ញុំបានឃើញអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុពោលដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេស

អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ សុតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ បរិសង្កិតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(២៥១) អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ ទិដ្ឋោ មយា សុតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ ទិដ្ឋោ មយា



គ្រប់ ១ មាត់ ១ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំបានឮថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្ដី បវារណាកម្មក្ដី សង្ឃកម្មក្ដី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ មាត់ ១ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនមានសេចក្ដីរង្កៀស បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំមានសេចក្ដីរង្កៀសថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្ដី បវារណាកម្មក្ដី សង្ឃកម្មក្ដី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ មាត់ ១ ។

[២៥១] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញហើយផង បានឮផង ។ បេ ។ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ មាត់ ១ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញហើយផង

បរិសង្កិតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ ។បេ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ ចោទេតិ ទិដ្ឋោ មយា សុតោ ច បរិសង្កិតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។បេ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នំ តញ្ចេ ចោទេតិ សុតោ មយា បរិសង្កិតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។បេ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នំ តញ្ចេ ចោទេតិ សុតោ មយា ទិដ្ឋោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។បេ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នំ តញ្ចេ ចោទេតិ សុតោ មយា បរិសង្កិតោ ច ទិដ្ឋោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។បេ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ



រង្កៀសហើយផង អ្នកឯងមិនមែនជាសមណៈ ។បេ។ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនបានឃើញ ទេ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយផង ឮហើយផង រង្កៀសហើយផង ។បេ។ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទមិនបានឮ ព្រោះហេតុនោះ ជាបើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ យើងបានឮផង រង្កៀសផង ។បេ។ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា យើងបានឮផង បានឃើញផងថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា ខ្ញុំឮហើយផង រង្កៀសហើយផង ឃើញហើយផងថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះ មិនបានរង្កៀស

ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ បរិសង្កិតោ មយា ទិដ្ឋោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ បរិសង្កិតោ មយា សុតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ បរិសង្កិតោ មយា ទិដ្ឋោ ច សុតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៦៨៦) ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ តញ្ចេ ចោទេតិ សុតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ តញ្ចេ ចោទេតិ បរិសង្កិតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ តញ្ចេ ចោទេតិ សុតោ មយា បរិសង្កិតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។



បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង ។ បេ ។ (ភិក្ខុចោទកនោះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះ មិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឮហើយផង ។ បេ ។ (ភិក្ខុចោទកនោះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង ។ បេ ។ (ភិក្ខុចោទកនោះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។

[៦៨៦] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះ បានឃើញមែន បើ(ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឮហើយ ។ បេ ។ (ភិក្ខុចោទកនោះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទបានឃើញមែន បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ

អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ សុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ បរិសង្កិតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ តញ្ចេ ចោទេតិ ទិដ្ឋោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ តញ្ចេ ចោទេតិ បរិសង្កិតោ មយា ទិដ្ឋោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ បរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទេតិ ទិដ្ឋោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ តញ្ចេ ចោទេតិ សុតោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ តញ្ចេ ចោទេតិ ទិដ្ឋោ មយា សុតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



ខ្ញុំឮហើយផង រង្កៀសហើយផង ។ បេ ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ (ភិក្ខុអ្នកចោទនោះ) បានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ឃើញហើយផង ។ បេ ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឮហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។

[៤៨៣] ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ ទិដ្ឋេ វេមតិកោ ទិដ្ឋំ នោកប្បេតិ ទិដ្ឋំ ន សរតិ ទិដ្ឋំ បមុដ្ឋោ(១) ហោតិ តញ្ចេ ចោទេតិ ទិដ្ឋោ មយា សុតោ ច ។ បេ ។ ទិដ្ឋោ មយា បរិសង្កិតោ ច ។ បេ ។ ទិដ្ឋោ មយា សុតោ ច បរិសង្កិតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ សុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ សុតេ វេមតិកោ សុតំ នោកប្បេតិ សុតំ ន សរតិ សុតំ បមុដ្ឋោ ហោតិ តញ្ចេ ចោទេតិ សុតោ មយា បរិសង្កិតោ ច ។ បេ ។ សុតោ មយា ទិដ្ឋោ ច ។ បេ ។ សុតោ មយា បរិសង្កិតោ ច ទិដ្ឋោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ បរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ បរិសង្កិតេ វេមតិកោ បរិសង្កិតំ នោកប្បេតិ បរិសង្កិតំ ន សរតិ បរិសង្កិតំ បមុដ្ឋោ ហោតិ តញ្ចេ ចោទេតិ បរិសង្កិតោ

១ ម. ប. សម្មុដ្ឋោ ។



[៤៨៣] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញមែន តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឃើញហើយ (គឺ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញផង ខ្ញុំបានឮផង ។ បេ ។ ខ្ញុំបានឃើញផង ខ្ញុំមានសេចក្តីរង្កៀសផង ។ បេ ។ ខ្ញុំបានឃើញផង ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ។ បេ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានឮ តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឮហើយ (គឺ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ។ បេ ។ ខ្ញុំបានឮផង ខ្ញុំបានឃើញផង ។ បេ ។ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង ។ បេ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមានសេចក្តីរង្កៀស តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនមានសេចក្តីរង្កៀសហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ

មយា ទិដ្ឋោ ច ។ បេ ។ បរិសង្កិតោ មយា សុតោ ច ។ បេ ។ បរិសង្កិតោ មយា ទិដ្ឋោ ច សុតោ ច បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធិំ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

[២៤៦] អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ ចោទាបេតិ ទិដ្ឋោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធិំ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ ចោទាបេតិ សុតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ ចោទាបេតិ បរិសង្កិតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



ខ្ញុំមានសេចក្ដីរង្កៀសផង ខ្ញុំបានឃើញផង ។ បេ ។ ខ្ញុំមានសេចក្ដីរង្កៀសផង ខ្ញុំបានឮផង ។ បេ ។ ខ្ញុំមានសេចក្ដីរង្កៀសផង ខ្ញុំបានឃើញផង ខ្ញុំបានឮផង អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូននៃព្រះពុទ្ធជាសក្យបុត្រ ឧបោសថកម្មក្ដី បវារណាកម្មក្ដី សង្ឃកម្មក្ដី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុពោលទោសគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[២៤៦] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកពោលទោសនោះមិនឃើញ បើ (ភិក្ខុអ្នកពោលទោស) ប្រើបុគ្គលដទៃឲ្យពោលថាភិក្ខុដែលត្រូវអាបត្តិបារាជិកនោះ ថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ឧបោសថកម្មក្ដី បវារណាកម្មក្ដី សង្ឃកម្មក្ដី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុអ្នកពោលទោសគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកពោលទោសមិនបានឮ បើភិក្ខុអ្នកពោលទោស ប្រើភិក្ខុដទៃឲ្យពោលទៅភិក្ខុនោះថា អ្នកឯងខ្ញុំបានឮថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុពោលទោសគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកពោលទោសមិនបានរង្កៀស បើភិក្ខុអ្នកពោលទោស ប្រើភិក្ខុដទៃឲ្យពោលទៅភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុពោលទោសគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។

(២៨៥) អទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តំ តញ្ចេ ចោទេតិ ទិដ្ឋោសិ សុតោសិ ។ បេ ។ ទិដ្ឋោសិ បរិសង្កិតោសិ ។ បេ ។ ទិដ្ឋោសិ សុតោសិ បរិសង្កិតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អសុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តំ តញ្ចេ ចោទេតិ សុតោសិ បរិសង្កិតោសិ ។ បេ ។ សុតោសិ ទិដ្ឋោសិ ។ បេ ។ សុតោសិ បរិសង្កិតោសិ ទិដ្ឋោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ អបរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តំ តញ្ចេ ចោទេតិ បរិសង្កិតោសិ ទិដ្ឋោសិ ។ បេ ។ បរិសង្កិតោសិ សុតោសិ ។ បេ ។ បរិសង្កិតោសិ ទិដ្ឋោសិ សុតោសិ បារាជិកំ



(២៨៥) ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទមិនឃើញទេ បើ (ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ ។ បេ ។ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ ។ បេ ។ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទគេថាដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ ។ បេ ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំបានឃើញហើយ ។ បេ ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទគេថាដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានរង្កៀស បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ ។ បេ ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឮហើយ ។ បេ ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ

ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

[២៨៦] ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ តញ្ចេ ចោទាបេតិ សុតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ បរិសង្កិតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ សុតោសិ បរិសង្កិតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ សុតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទាបេតិ បរិសង្កិតោសិ ។ បេ ។ តញ្ចេ ចោទាបេតិ ទិដ្ឋោសិ ។ បេ ។ តញ្ចេ ចោទាបេតិ បរិសង្កិតោសិ ទិដ្ឋោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ បរិសង្កិតស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបន្នោតិ តញ្ចេ ចោទាបេតិ ទិដ្ឋោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។



អ្នកឯងខ្ញុំបានឮហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទគេម្ដងៗ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។

(២៨៦) ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញហើយ បើ (ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុដែលត្រូវអាបត្តិបារាជិកនោះថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទគេម្ដងៗ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ (ភិក្ខុអ្នកចោទ) បានឮហើយ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយ ។ បេ ។ បើ (ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទគេម្ដងៗ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមានសេចក្តីរង្កៀស បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។

តញ្ចេ ចោទាបេតិ ទិដ្ឋោសិ សុតោសិ ។ បេ ។ តញ្ចេ ចោទាបេតិ ទិដ្ឋោសិ សុតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ ។ បេ ។ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៦៩៧) ទិដ្ឋស្ស ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ ទិដ្ឋេ វេមតិកោ ទិដ្ឋំ នោ កប្បេតិ ទិដ្ឋំ ន សរតិ ទិដ្ឋំ បម្មុដ្ឋោ ហោតិ ។ បេ ។ សុតេ វេមតិកោ សុតំ នោ កប្បេតិ សុតំ ន សរតិ សុតំ បម្មុដ្ឋោ ហោតិ ។ បេ ។ បរិសង្កិតេ វេមតិកោ បរិសង្កិតំ នោ កប្បេតិ បរិសង្កិតំ ន សរតិ បរិសង្កិតំ បម្មុដ្ឋោ ហោតិ តញ្ចេ ចោទាបេតិ បរិសង្កិតោសិ ទិដ្ឋោសិ ។ បេ ។ បរិសង្កិតោសិ សុតោសិ ។ បេ ។ បរិសង្កិតោសិ ទិដ្ឋោសិ សុតោសិ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ





បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយ ។ បេ ។ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ ៖ អ្នកឯងខ្ញុំឮហើយ ថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ (ភិក្ខុចោទកនោះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗមាត់ ។

(៦៩៧) ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះក៏ឃើញមែន (តែភិក្ខុអ្នកចោទ) មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឃើញហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ ។ បេ ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឮហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ ។ បេ ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនរង្កៀស កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទ ប្រើបុគ្គលដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ ។ បេ ។ អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឮហើយ ។ បេ ។ អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយ ថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណ

អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធិំ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(២៥៨) អសុទ្ធេ សុទ្ធទិដ្ឋិ សុទ្ធេ អសុទ្ធទិដ្ឋិ អសុទ្ធេ អសុទ្ធទិដ្ឋិ សុទ្ធេ សុទ្ធទិដ្ឋិ ។

(២៥៩) អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា ចាវនាធិប្បាយោ វទេតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា ចាវនាធិប្បាយោ



អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តឡើយ ។ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តីជាមួយនឹងអ្នកឯងគ្មានទេ ភិក្ខុពោលទៅគេដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ មាត់ ។

( មាតិកានុក្រម គឺបញ្ញើរឿងដែលនឹងត្រូវសំដែងតាមលំដាប់ហូរហែ ដូចមានខាងក្រោមនេះ )

(២៥៨) ភិក្ខុយល់ឃើញថាបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ១ យល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ១ យល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ១ យល់ឃើញថាបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ១ ។

(២៥៩) បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកឯណាមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានសេចក្តីប្រាថ្នាឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទភិក្ខុនោះ (ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ) ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌

វទតិ អាបត្តិ សង្ឃាទិសេសស្ស ។ អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទតិ អាបត្តិ ឱមសវាទេន ទុក្កដស្ស ។ អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទតិ អាបត្តិ ឱមសវាទស្ស ។

[២៦០] សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា ចាវនាធិប្បាយោ វទតិ អាបត្តិ ទុក្កដស្ស ។ សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា ចាវនាធិប្បាយោ វទតិ អនាបត្តិ ។



ទើបពោលចោទភិក្ខុនោះ (ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ (ភិក្ខុអ្នកជេរ) ត្រូវអាបត្តិទុក្កដនឹងបាចិត្តិយៈ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[២៦០] បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះមិនបរិសុទ្ធទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថាភិក្ខុនោះមិនបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ មិនត្រូវអាបត្តិ ។

សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទេន ទុក្កដស្ស ។ សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

(៦៦១) អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា ចាវនាធិប្បាយោ វទេតិ អាបត្តិ ទុក្កដស្ស ។ អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា ចាវនាធិប្បាយោ វទេតិ អនាបត្តិ ។ អសុទ្ធោ ហោតិ



បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដនឹងឱមសវាទ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិឱមសវាទ ។

(៦៦១) បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយ ភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ មិនត្រូវអាបត្តិឡើយ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ

បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទតិ អាបត្តិ ឱមសវាទេន ទុក្កដស្ស ។ អសុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អជ្ឈាបន្នោ តញ្ចេ អសុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទតិ អាបត្តិ ឱមសវាទស្ស ។

[៤០៦] សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ អនោកាសំ ការាបេត្វា ចាវនាធិប្បាយោ វទតិ អាបត្តិ សង្ឃាទិសេសេន ទុក្កដស្ស ។ សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា ចាវនាធិប្បាយោ វទតិ អាបត្តិ សង្ឃាទិសេសស្ស ។ សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ



ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកដទៃយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដនឹងបាចិត្តិយ ។ បុគ្គល ភិក្ខុដែលត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកមិនបរិសុទ្ធហើយភិក្ខុអ្នកដទៃយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[៦៦៦] បុគ្គល ភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកដទៃយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបដោទ ភិក្ខុអ្នកដោទ ត្រូវអាបត្តិទុក្កដនឹងសង្ឃាទិសេស ។ បុគ្គល ភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកដទៃយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អ ឲ្យភិក្ខុនោះធ្វើឱកាសដោយសេចក្តីជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលដោទ ភិក្ខុអ្នកដោទ ត្រូវអាបត្តិសង្ឃាទិសេស ។ បុគ្គល ភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកដទៃយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អ

សមានោ អនោកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទេន ទុក្កដស្ស ។ សុទ្ធោ ហោតិ បុគ្គលោ អញ្ញតរំ បារាជិកំ ធម្មំ អនជ្ឈាបន្នោ តញ្ចេ សុទ្ធទិដ្ឋិ សមានោ ឱកាសំ ការាបេត្វា អក្កោសាធិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

(៦៦៣) អនាបត្តិ សុទ្ធេ អសុទ្ធទិដ្ឋិស្ស អសុទ្ធេ អសុទ្ធទិដ្ឋិស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសង្ឃាទិសេសំ និដ្ឋិតំ ។



មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដនឹងបាចិត្តិយ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធដូច្នេះ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៣) អាបត្តិមិនមានដល់ភិក្ខុដែលយល់ឃើញថា មិនបរិសុទ្ធ ក្នុងបុគ្គលដែលបរិសុទ្ធ ដល់ភិក្ខុដែលយល់ឃើញថា មិនបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សង្ឃាទិសេស ទី ៨ ចប់ ។

# នវមសង្ឃាទិសេសំ

(៦៦៦) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន មេត្តិយភុម្មជកា ភិក្ខូ គិជ្ឈកូដា បព្វតា ឱរោហន្តា អទ្ទសំសុ ឆគលកំ អជិកាយ វិប្បដិបជ្ជន្តំ ទិស្វាន ឯវមាហំសុ ហន្ទ មយំ អាវុសោ ឥមំ ឆគលកំ ទព្វំ មល្លបុត្តំ នាម ករោម ឥមំ អជិកំ មេត្តិយំ នាម ភិក្ខុនឹ ករោម ឯវំ មយំ វោហរិស្សាម បុព្វេ មយំ អាវុសោ ទព្វំ មល្លបុត្តំ សុតេន អវោចុម្ហា ឥទានិ បន អម្ហេហិ សាមំ ទិដ្ឋោ មេត្តិយាយ ភិក្ខុនិយា វិប្បដិបជ្ជន្តោតិ ។

# សង្ឃាទិសេសទី៩

(៦៦៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន[*] ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ភិក្ខុពួកមេត្តិយភុម្មជកៈទាំងឡាយ កាលចុះអំពីភ្នំគិជ្ឈកូដ បានឃើញពពែឈ្មោលកំពុងរួមសង្វាសនឹងពពែញី លុះឃើញហើយ ទើបនិយាយគ្នាថា ម្នាលអាវុសោ ពួកយើងនឹងដាក់ឈ្មោះពពែឈ្មោលនេះឲ្យជាឈ្មោះទព្វមល្លបុត្ត (បុត្តមល្លក្សត្រ) ដាក់ពពែញីនេះឲ្យជាឈ្មោះនាងមេត្តិយាភិក្ខុនី យើងនឹងនាំគ្នាហៅយ៉ាងនេះ ម្នាលអាវុសោ កាលពីដើម យើងបាននិយាយពីទព្វមល្លបុត្តដោយពាក្យថា យើងបានឮ ប៉ុន្តែឥឡូវនេះ ទព្វមល្លបុត្ត សេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង ។

---

[*] អាចារ្យវេឡុវ័ន ប្រែតាមសព្ទថា វត្តព្រៃឫស្សី តែក្នុងនេះគឺដើមជាឧទ្យានព្រះរាជវាំងព្រះបាទពិម្ពិសារ ។ ទ្រង់បានថ្វាយដល់ព្រះពុទ្ធជាម្ចាស់កាលយាងចូលទៅកាន់ក្រុងរាជគ្រឹះជាដំបូង ។ ដើម្បីទ្រង់ស្តាប់ព្រះធម៌ទេសនា ព្រះបាទពិម្ពិសារបានដល់សោតាបត្តិផល មានព្រះហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយក៏បានថ្វាយឧទ្យានឈ្មោះវេឡុវ័ននោះថ្វាយជាព្រះអារាមសម្រាប់សង្ឃ មានព្រះពុទ្ធជាប្រធានជាអារាមដំបូងមុនអារាមទាំងអស់ ។ ដែលហៅថាកលន្ទកនិវាបស្ថាន ព្រោះក្នុងនោះឯងមនុស្សទាំងឡាយតែងឲ្យអាហារចំណីដល់ពួកសត្វកន្ធែន មានរឿងដំណាលក្នុងអដ្ឋកថាវិន័យថា គឺដើមមានព្រះរាជាមួយព្រះអង្គចេញទៅប្រពាតឧទ្យាននោះ ទ្រង់សោយសុរាស្រវឹងផ្ទំលក់ទៅ ។ ឯពស់វែកក៏តាមក្លិនស្រាចេញពីប្រហោងឈើ ផ្កាឈើ ក៏សត្វកន្ធែនឃើញ ។ មានពស់វែកមួយក៏ធុំក្លិនសុរាក៏លូនចេញមកពីគល់ឈើ ហើយបែរខ្លួនទៅរកព្រះរាជា ។ មានសត្វកន្ធែន

តេ ឥមំ ឆគលកំ ទព្វំ មល្លបុត្តំ នាម អកំសុ ឥមំ អជិកំ មេត្តិយំ នាម ភិក្ខុនឹ អកំសុ ។ តេ ភិក្ខូនំ អារោចេសុំ បុព្វេ មយំ អាវុសោ ទព្វំ មល្លបុត្តំ សុតេន អវោចុម្ហា ឥទានិ បន អម្ហេហិ សាមំ ទិដ្ឋោ មេត្តិយាយ ភិក្ខុនិយា សទ្ធិំ វិប្បដិបជ្ជន្តោតិ ។ ភិក្ខូ ឯវមាហំសុ មា អាវុសោ ឯវំ អវចុត្ថ នាយស្មា ទព្វោ មល្លបុត្តោ ឯវំ ករិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អាយស្មន្តំ ទព្វំ មល្លបុត្តំ បដិបុច្ឆិ សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថយិមេ ភិក្ខូ អាហំសូតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។



ភិក្ខុទាំងពីររូបនោះក៏បានតាំងសម្មតពពែឈ្មោលនោះថា ឈ្មោះទព្វមល្លបុត្ត សម្មតពពែញីនោះថា ឈ្មោះនាងមេត្តិយាភិក្ខុនី ។ ភិក្ខុទាំងនោះទៅនិយាយប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ កាលពីដើមយើងបាននោទទព្វមល្លបុត្តដោយបានឮ ប៉ុន្តែឥឡូវនេះ ទព្វមល្លបុត្តសេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង ។ ភិក្ខុទាំងឡាយបានឆ្លើយយ៉ាងនេះថា នែអាវុសោ លោកកុំនិយាយយ៉ាងហ្នឹង ឯទព្វមល្លបុត្តមិនមានកោយប៉ុនជាទីនឹងធ្វើដូច្នោះជាទេ ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះដើមហេតុនេះ រឿងនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ទព្វមល្លបុត្តដ៏មានអាយុថា នែទព្វ អ្នកនឹកឃើញឬទេ ពួកភិក្ខុទាំងនេះពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬទេ ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចំរើន (រឿងនុ៎ះ) ព្រះដ៏មានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គដោយពិតហើយ ។

---

១ ទីនិតនោះ ឃើញហេតុនោះ ចង់ឲ្យមនុស្សស្អប់ខ្ពើមអំពើអាក្រក់ ទើបនិមិត្តជាសត្វពពែទៅ ស្រែកទាក់ព្រះកាណ៌ស្មេច ។ ទើបស្តេចទ្រង់ឃើញសត្វទាំងពីរ ទ្រង់គ្រិះរិះថា សត្វពពែទាំងនោះ ព្រែអង្គ តាំងពីនោះមកបានទ្រង់ប្រកាសអភ័យ ឲ្យមានការឃ្លាំមើលសត្វពពែទៅ ទើប មនុស្សទាំងឡាយហៅកន្លែងនោះថា កលន្ទកនិវាបស្ថាន រៀងមក ។

តេរសកណ្ឌេ អដ្ឋមសង្ឃាទិសេសស្ស មេត្តិយភុម្មជកភិក្ខុវត្ថុ

ទុតិយម្បិ ខោ ភគវា ។ បេ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ ទព្វំ មល្លបុត្តំ ឯតទវោច សរសិ ត្វំ ទព្វ ឯវរូបំ កត្តា យថយិមេ ភិក្ខូ អាហំសូតិ ។ យថា មំ ភន្តេ ភគវា ជានាតីតិ ។ ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ សចេ តយា កតំ កតន្តិ វទេហិ សចេ តយា អកតំ អកតន្តិ វទេហីតិ ។ យតោហំ ភន្តេ ជាតោ នាភិជានាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតា បគេវ ជាគរោតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ឥមេ ភិក្ខូ អនុយុញ្ជថាតិ ។ ឥទំ វត្វា ភគវា ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេ ភិក្ខូ មេត្តិយភុម្មជកេ ភិក្ខូ អនុយុញ្ជឹសុ ។ តេ តេហិ ភិក្ខូហិ អនុយុញ្ជិយមានា ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ កឹ បន តុម្ហេ អាវុសោ អាយស្មន្តំ



តេរសកណ្ឌ សង្ឃាទិសេសទី ៨ រឿងមេត្តិយភុម្មជកភិក្ខុ

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សួរពាក្យនេះ នឹងទព្វមល្លបុត្តដ៏មានអាយុជាគំរប់ពីរដងផង ។ បេ ។ ជាគំរប់បីដងផងថា ម្នាលទព្វៈ អ្នករលឹកឃើញឬទេ ពួកភិក្ខុទាំងនេះពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬ ។ ទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយមិនដោះសារបណ្ដោះបណ្ដាលយ៉ាងនេះទេ បើ(អំពើ) ដែលអ្នកបានធ្វើហើយ អ្នកចូរឆ្លើយថាខ្ញុំបានធ្វើហើយ បើអ្នកមិនបានធ្វើទេ អ្នកចូរឆ្លើយថាខ្ញុំមិនបានធ្វើទេ ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងពីកើតមកវេលាណា មិនដែលសេពមេថុនធម្មទេ សូម្បីតែយល់សប្តិក៏មិនដែលឃើញទេ ចាំបាច់និយាយថ្វីដល់កាលភ្ញាក់រលឹក ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរដេញសួរភិក្ខុពួកនេះមើល ។ លុះព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ទ្រង់ក៏ក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ។ គ្រានោះ ភិក្ខុទាំងឡាយបានដេញសួរមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ភិក្ខុទាំងនោះ កាលបើភិក្ខុទាំងឡាយដេញសួរ ទើបប្រាប់សេចក្ដីនេះដល់ភិក្ខុទាំងឡាយ (តាមពិតត្រង់) ។ ភិក្ខុទាំងឡាយសួរថា

ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេថាតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ



នែអាវុសោ អ្នកទាំងពីរកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ដ៏ជាចំណែកដទៃមកជាគ្រឿងតាំង ហើយចោទទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិកឬ ។ ភិក្ខុទាំងពីរឆ្លើយថា យ៉ាងនេះហើយ អាវុសោ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល ខ្នាថា មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិនសមបើនឹងកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងតាំង ហើយចោទទព្វមល្លបុត្តដោយអាបត្តិបារាជិកសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនោះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ឮថាអ្នកទាំងពីរ កាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងតាំង ហើយចោទទព្វមល្លបុត្ត ដោយអាបត្តិបារាជិក ពិតមែនឬ ។ ភិក្ខុទាំងពីរក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកទាំងពីរមិនសមបើនឹងកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងតាំង ហើយចោទទព្វមល្លបុត្តដោយអាបត្តិបារាជិកសោះ នែមោឃបុរស អំពើដែលអ្នកទាំងពីរធ្វើនេះ មិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ ទោសោ អប្បតីតោ អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេយ្យ អប្បេវនាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា អញ្ញភាគិយញ្ចេវ តំ អធិករណំ ហោតិ កោចិ ទេសោ លេសមត្តោ ឧបាទិន្នោ ភិក្ខុ ច ទោសំ បតិដ្ឋាតិ សង្ឃាទិសេសោតិ ។

(៦៦៨) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ ទុដ្ឋោ ទោសោតិ កុបិតោ អនត្តមនោ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។ អប្បតីតោតិ តេន ច កោបេន តេន ច ទោសេន តាយ ច អនត្តមនតាយ តាយ ច អនភិរទ្ធិយា[១] អប្បតីតោ ហោតិ ។

---

១ កត្ថចិ បោត្ថកេ អនភិរតិយាតិបិ បាឋោ ទិស្សតិ ។



អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ មានទោសប្រទូស្តហើយ មានសេចក្តីក្រោធមានចិត្តមិនរីករាយបានកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុដោយអាបត្តិបារាជិក ដោយបំណងថា ធ្វើម្តេចហ្ន៎ អញគប្បីញ៉ាំងភិក្ខុនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌(សាសនា)នេះបាន លុះសម័យខាងក្រោយតពីនោះមក ភិក្ខុអ្នកចោទនោះមានគេសាកសួរក្តី មិនមានគេសាកសួរក្តី តែអធិករណ៍នោះជាចំណែកដទៃ ភិក្ខុកាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ហើយភិក្ខុប្តូរជាទោស ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

(៦៦៨) ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយដូចសិក្ខាបទទី ៨ ដែលពោលមកហើយ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ពាក្យថា មានទោសប្រទូស្តហើយ មានសេចក្តីក្រោធ គឺមានចិត្តក្រោធខឹង មានចិត្តមិនជារបស់ខ្លួន មិនត្រេកអរ មានចិត្តគុំគួន ជាឫសគល់ ។ ពាក្យថា មានចិត្តមិនរីករាយ គឺមានចិត្តកាន់អន់ ព្រោះក្រោធខឹងនោះផង ព្រោះទោសនោះផង ព្រោះសេចក្តីអន់ចិត្តនោះផង ព្រោះសេចក្តីមិនត្រេកអរនោះផង ។

(៦៦៦) អញ្ញភាគិយស្ស អធិករណស្សាតិ អា-បត្តញ្ញភាគិយំ ច ហោតិ អធិករណញ្ញភាគិយំ ច ។

(៦៦៧) កតមំ អធិករណំ អធិករណស្ស អញ្ញភា-គិយំ ។ វិវាទាធិករណំ អនុវាទាធិករណស្ស អាបត្តា-ធិករណស្ស កិច្ចាធិករណស្ស អញ្ញភាគិយំ អនុ-វាទាធិករណំ អាបត្តាធិករណស្ស កិច្ចាធិករណស្ស វិវាទាធិករណស្ស អញ្ញភាគិយំ អាបត្តាធិករណំ កិច្ចា-ធិករណស្ស វិវាទាធិករណស្ស អនុវាទាធិករណស្ស អញ្ញភាគិយំ កិច្ចាធិករណំ វិវាទាធិករណស្ស អនុ-វាទាធិករណស្ស អាបត្តាធិករណស្ស អញ្ញភាគិយំ ។ ឯវំ អធិករណំ អធិករណស្ស អញ្ញភាគិយំ ។

(៦៦៨) កតមំ អធិករណំ អធិករណស្ស តព្ភាគិយំ ។ វិវាទាធិករណំ វិវាទាធិករណស្ស តព្ភាគិយំ អនុវាទាធិ-ករណំ អនុវាទាធិករណស្ស តព្ភាគិយំ អាបត្តាធិករណំ



(៦៦៦) ពាក្យថា របស់អធិករណ៍ជាចំណែកដទៃ គឺចំណែកដទៃនៃអាបត្តិ ឬចំណែកដទៃនៃអធិករណ៍ ។

(៦៦៧) (សួរថា) អធិករណ៍[១]ដែលមានចំណែកផ្សេងពីអធិករណ៍ នោះដូចម្តេច ។ (ឆ្លើយថា) វិវាទាធិករណ៍[២] មានចំណែកផ្សេងអំពីអនុវា-ទាធិករណ៍[៣] អាបត្តាធិករណ៍[៤] និងកិច្ចាធិករណ៍[៥] អនុវាទាធិករណ៍ ដាច់ដោយឡែកផ្សេងអំពីអាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ អាបត្តាធិករណ៍ដាច់ដោយឡែកផ្សេងអំពីកិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ កិច្ចាធិករណ៍ដាច់ដោយឡែកផ្សេងអំពីវិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ ។ អធិករណ៍យ៉ាងនេះ ឈ្មោះថា មានចំណែកផ្សេងគ្នាអំពីអធិករណ៍ ។

(៦៦៨) (សួរថា) អធិករណ៍ដែលមានចំណែកដូចគ្នានឹងអធិករណ៍ នោះដូចម្តេច ។ (ឆ្លើយថា) វិវាទាធិករណ៍មានចំណែកដូចគ្នានឹងវិវាទាធិករណ៍ អនុវាទាធិករណ៍មានចំណែកដូចគ្នានឹងអនុវាទាធិករណ៍ អាបត្តាធិករណ៍

---

១ រឿងដែលកើតឡើងហើយ ត្រូវតែកាត់ ត្រូវតែធ្វើឲ្យស្ងប់ទៅ ហៅថា អធិករណ៍ ។ ២ ការវិវាទគ្នាព្រោះធម្មវិន័យ ហៅថាវិវាទាធិករណ៍ ។ ៣ ការចោទគ្នាដោយរឿងអាបត្តិ ឬវិបត្តិជាដើម ហៅថា អនុវាទាធិករណ៍ ។ ៤ គំនរដែលត្រូវអាបត្តិ ហៅថាអាបត្តាធិករណ៍ ។ ៥ កិច្ចធុរៈរបស់សង្ឃ មានអបលោកនកម្មជាដើម ហៅថាកិច្ចាធិករណ៍ ។

អាបត្តាធិករណស្ស សិយា តព្ភាគិយំ សិយា អញ្ញ-ភាគិយំ ។ កថំ អាបត្តាធិករណំ អាបត្តាធិ-ករណស្ស អញ្ញភាគិយំ ។ មេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិយា មនុស្សវិគ្គហបារាជិកា-បត្តិយា ឧត្តរិមនុស្សធម្មបារាជិកាបត្តិយា អញ្ញភាគិយា អទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ-យា ឧត្តរិមនុស្សធម្មបារាជិកាបត្តិយា មេថុនធម្មបារាជិ-កាបត្តិយា អញ្ញភាគិយា មនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិយា មេថុនធម្មបារាជិកា-បត្តិយា អទិន្នាទានបារាជិកាបត្តិយា អញ្ញភាគិយា ឧត្ត-រិមនុស្សធម្មបារាជិកាបត្តិ មេថុនធម្មបារាជិកាបត្តិយា អទិន្នាទានបារាជិកាបត្តិយា មនុស្សវិគ្គហបារាជិកា-បត្តិយា អញ្ញភាគិយា ។ ឯវំ អាបត្តាធិករណំ អា-បត្តាធិករណស្ស អញ្ញភាគិយំ ។ កថញ្ច អា-បត្តាធិករណំ អាបត្តាធិករណស្ស តព្ភាគិយំ ។



មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍ក៏មាន មានចំណែកផ្សេងអំពីគ្នាក៏មាន ។ (សួរថា) អាបត្តាធិករណ៍ មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍ តើដូចម្តេច ។ (ឆ្លើយថា) មេថុនធម្ម(១)បារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីអទិន្នាទាន(២)បារាជិកាបត្តិ មនុស្សវិគ្គហ(៣)បារាជិកាបត្តិ និងឧត្តរិមនុស្សធម្ម(៤)បារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ និងមេថុនធម្មបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីឧត្តរិមនុស្សធម្មបារាជិកាបត្តិ មេថុនធម្មបារាជិកាបត្តិ និងអទិន្នាទានបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ និងមនុស្សវិគ្គហបារាជិកាបត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ (ឈ្មោះថា) មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍ ។ (សួរថា) អាបត្តាធិករណ៍ មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍ តើដូចម្តេច ។

---

១ ត្រូវអាបត្តិបារាជិក ព្រោះសេពមេថុនធម្ម ។ ២ ត្រូវអាបត្តិបារាជិក ព្រោះលួចទ្រព្យគេមានតំលៃតាំងពី ៥ មាសកឡើងទៅ ។ ៣ ត្រូវអាបត្តិបារាជិក ព្រោះសម្លាប់មនុស្ស ។ ៤ ត្រូវអាបត្តិបារាជិក ព្រោះអួតគុណវិសេសដែលមិនមានក្នុងខ្លួន ។

មេថុនធម្មបារាជិកាបត្តិ មេថុនធម្មបារាជិកាបត្តិយា តព្ភាគិយា អទិន្នាទានបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិយា តព្ភាគិយា មនុស្សវិគ្គហបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិយា តព្ភាគិយា ឧត្តរិមនុស្សធម្មបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិយា តព្ភាគិយា ។ ឯវំ អាបត្តាធិករណំ អាបត្តាធិករណស្ស តព្ភាគិយំ ។ កិច្ចាធិករណំ កិច្ចាធិករណស្ស តព្ភាគិយំ ។ ឯវំ អធិករណំ អធិករណស្ស តព្ភាគិយំ ។

(៦៦៩) កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយាតិ លេសោ នាម ទស លេសា ជាតិលេសោ នាមលេសោ គោត្តលេសោ លិង្គលេសោ អាបត្តិលេសោ បត្តលេសោ ចីវរលេសោ ឧបជ្ឈាយលេសោ អាចរិយលេសោ សេនាសនលេសោ ។

(៦៧០) ជាតិលេសោ នាម ខត្តិយោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ ខត្តិយំ បស្សិត្វា ចោទេតិ ខត្តិយោ មយា ទិដ្ឋោ បារាជិកំ ធម្មំ



(ត្រូវថា) មេថុនធម្មបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងអទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងឧត្តរិមនុស្សធម្មបារាជិកាបត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ (ហៅថា) មានចំណែកជាមួយគ្នានឹងអាបត្តាធិករណ៍ ។ កិច្ចាធិករណ៍ក៏មានចំណែកជាមួយគ្នានឹងកិច្ចាធិករណ៍ដែរ ។ អធិករណ៍យ៉ាងនេះ (ហៅថា) មានចំណែកជាមួយគ្នានឹងអធិករណ៍ ។

[៦៦៩] ត្រង់ពាក្យថា កាន់យកហេតុបន្តិចបន្តួចបង្កជាគ្រឿងអាង ដែលហៅថាគ្រឿងអាងនោះបានដល់គ្រឿងអាង ១០ យ៉ាង គឺគ្រឿងអាង ជាតិ ១ នាម ១ គោត្រ ១ ភេទ ១ អាបត្តិ ១ បាត្រ ១ ចីវរ ១ ឧបជ្ឈាយ៍ ១ អាចារ្យ ១ សេនាសនៈ ១ ។

[៦៧០] ដែលហៅថា គ្រឿងអាងគឺជាតិនោះ បានដល់ភិក្ខុណាមួយឃើញភិក្ខុជាក្សត្រត្រូវអាបត្តិបារាជិក (តែមិនបានចោទភិក្ខុជាក្សត្រនោះក្នុងខណៈនោះ) លុះបានឃើញភិក្ខុដទៃជាជាតិក្សត្រដែរ ហើយ (ក៏ចោទ) ថា ខ្ញុំបានឃើញលោកជាក្សត្រត្រូវអាបត្តិបារាជិកហើយ

អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ព្រាហ្មណោ ទិដ្ឋោ ហោតិ ។បេ។ វេស្សោ ទិដ្ឋោ ហោតិ ។បេ។ សុទ្ទោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ សុទ្ទំ បស្សិត្វា ចោទេតិ សុទ្ទោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្ស-មណោសិ អសក្យបុត្តិយោសិ ។បេ។ សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(២៧១) នាមលេសោ នាម ពុទ្ធរក្ខិតោ ទិដ្ឋោ ហោតិ ។បេ។ ធម្មរក្ខិតោ ទិដ្ឋោ ហោតិ ។បេ។ សង្ឃរក្ខិតោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈា-បជ្ជន្តោ អញ្ញំ សង្ឃរក្ខិតំ បស្សិត្វា ចោទេតិ សង្ឃរក្ខិតោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។បេ។ សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



លោកមិនមែនជាសមណៈ លោកមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកទេ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗ ពាក្យ ។ ភិក្ខុអ្នកចោទ ឃើញភិក្ខុជាតិជាព្រាហ្មណ៍ ។បេ។ ឃើញភិក្ខុជាវេស្ស (អ្នកជំនួញ) ។បេ។ ឃើញភិក្ខុជាសុទ្ទ (អ្នកធ្វើការគុលី) ត្រូវអាបត្តិបារាជិក (តែអ្នកចោទមិនបានចោទ) លុះបានឃើញភិក្ខុដទៃជាជាតិសុទ្ទដែរ ទើប (ភិក្ខុ) ចោទថា ខ្ញុំបានឃើញអ្នកជាតិជាសុទ្ទ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗ ពាក្យ ។

(២៧១) ដែលហៅថា ត្រឡំនឹងនាមនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុឈ្មោះពុទ្ធរក្ខិត ។បេ។ ឃើញភិក្ខុឈ្មោះធម្មរក្ខិត ។បេ។ ឃើញភិក្ខុឈ្មោះសង្ឃរក្ខិតត្រូវអាបត្តិបារាជិក (តែភិក្ខុអ្នកចោទមិនបានចោទ) លុះបានឃើញភិក្ខុដទៃឈ្មោះសង្ឃរក្ខិតដែរ ហើយ (ភិក្ខុ) ចោទថា ខ្ញុំឃើញអ្នកឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗ ពាក្យ ។

[៦៧៦] គោត្តលេសោ នាម គោតមោ ទិដ្ឋោ ហោតិ ។បេ។ មោគ្គល្លានោ ទិដ្ឋោ ហោតិ ។បេ។ កច្ចាយនោ ទិដ្ឋោ ហោតិ ។បេ។ កស្សបោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ កស្សបំ បស្សិត្វា ចោទេតិ កស្សបោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។បេ។ សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

[៦៧៧] លិង្គលេសោ នាម ទីឃោ ទិដ្ឋោ ហោតិ ។បេ។ រស្សោ ទិដ្ឋោ ហោតិ ។បេ។ កណ្ហោ ទិដ្ឋោ ហោតិ ។បេ។ ឱទាតោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ ឱទាតំ បស្សិត្វា ចោទេតិ ឱទាតោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។បេ។ សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។





[៦៧៦] ដែលហៅថា លេសគឺគោត្រនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុដែលមានគោត្រជាគោតម ។បេ។ ឃើញភិក្ខុមានគោត្រជាមោគ្គល្លាន ។បេ។ ឃើញភិក្ខុមានគោត្រជាកច្ចាយន ។បេ។ ឃើញភិក្ខុមានគោត្រជាកស្សប ត្រូវអាបត្តិបារាជិក (តែមិនចោទ) លុះបានឃើញភិក្ខុដទៃមានគោត្រជាកស្សបដែរ ហើយ (ក៏ចោទ) ចោទថា ខ្ញុំបានឃើញអ្នកមានគោត្រជាកស្សប ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះសក្យបុត្រទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។

[៦៧៧] ដែលហៅថា លេសគឺភេទនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុមានកាយខ្ពស់ ។បេ។ ឃើញភិក្ខុមានកាយទាប ។បេ។ ឃើញភិក្ខុមានសម្បុរខ្មៅ ។បេ។ ឃើញភិក្ខុមានសម្បុរស ត្រូវអាបត្តិបារាជិក (តែមិនចោទ) លុះឃើញភិក្ខុដទៃមានសម្បុរសដែរ ហើយ (ក៏ចោទ) ចោទថា ខ្ញុំបានឃើញអ្នកមានសម្បុរស ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះសក្យបុត្រទេ ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។

(៤៧៦) អាបត្តិលេសោ នាម លហុកំ អាបត្តិំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ តញ្ចេ បារាជិកេន ធម្មេន ចោទេតិ ទិដ្ឋោ មយា បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។ បេ ។ សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៤៧៧) បត្តលេសោ នាម លោហបត្តធរោ ទិដ្ឋោ ហោតិ ។ បេ ។ មត្តិកាបត្តធរោ ទិដ្ឋោ ហោតិ ។ បេ ។ សាដកបត្តធរោ ទិដ្ឋោ ហោតិ ។ បេ ។ សុម្ភកបត្តធរោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ សុម្ភកបត្តធរំ បស្សិត្វា ចោទេតិ សុម្ភកបត្តធរោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។ បេ ។ សង្ឃកម្មំ វាតិ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



(៤៧៦) ដែលហៅថា លេសនៃអាបត្តិនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុត្រូវអាបត្តិស្រាល ហើយភិក្ខុអ្នកចោទ ចោទភិក្ខុនោះដោយអាបត្តិបារាជិកថា ខ្ញុំបានឃើញលោកត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ ពាក្យ ។

(៤៧៧) ដែលហៅថា លេសនៃបាត្រនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុប្រើបាត្រទង់ដែង ។ បេ ។ ឃើញភិក្ខុប្រើបាត្រដី ។ បេ ។ ឃើញភិក្ខុប្រើបាត្រសម្លក់សាដក(១) ។ បេ ។ ឃើញភិក្ខុប្រើបាត្រដី(២)ដែលមានសម្បុរលើម ត្រូវអាបត្តិបារាជិក (តែមិនចុះចោទ) លុះឃើញភិក្ខុដទៃប្រើបាត្រដីដែរ ហើយ(ក៏ចោទ)ថា ខ្ញុំឃើញអ្នកឯងប្រើបាត្រដីត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ១ ពាក្យ ។

---

១ តាមអដ្ឋកថាសមន្តបាសាទិកា ថា បាត្រដីនោះឯង តែហាលប្រទាំក្រយល្អ មានសម្បុរលោហៈ ... ។ ២ បាលីថា “សុម្ភកបត្ត” តាមអដ្ឋកថាថា ... ។

(៤៧៦) ចីវរលេសោ នាម បំសុកូលិកោ ទិដ្ឋោ ហោតិ ។ បេ ។ គហបតិចីវរធរោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ គហបតិចីវរធរំ បស្សិត្វា ចោទេតិ គហបតិចីវរធរោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។ បេ ។ សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៤៧៧) ឧបជ្ឈាយលេសោ នាម ឥត្ថន្នាមស្ស សទ្ធិវិហារិកោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ ឥត្ថន្នាមស្ស សទ្ធិវិហារិកំ បស្សិត្វា ចោទេតិ ឥត្ថន្នាមស្ស សទ្ធិវិហារិកោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។ បេ ។ សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៤៧៨) អាចរិយលេសោ នាម ឥត្ថន្នាមស្ស អន្តេវាសិកោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ ឥត្ថន្នាមស្ស អន្តេវាសិកំ បស្សិត្វា ចោទេតិ ឥត្ថន្នាមស្ស អន្តេវាសិកោ មយា ទិដ្ឋោ បារាជិកំ



(៤៧៦) ដែលហៅថា គ្រឿងអាងពីចីវរនោះ គឺភិក្ខុអ្នកចោទបានឃើញភិក្ខុប្រើចីវរបង្សុកូល ។ បេ ។ ឃើញភិក្ខុប្រើចីវររបស់គហបតី ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះបានឃើញភិក្ខុដទៃប្រើចីវររបស់គហបតីដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងប្រើចីវររបស់គហបតី ត្រូវអាបត្តិបារាជិក អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា ។

(៤៧៧) ដែលហៅថា គ្រឿងអាងពីព្រះឧបជ្ឈាយ៍នោះ គឺភិក្ខុអ្នកចោទបានឃើញសទ្ធិវិហារិករបស់ព្រះឧបជ្ឈាយ៍មានឈ្មោះយ៉ាងនេះ ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះបានឃើញភិក្ខុដទៃជាសទ្ធិវិហារិករបស់ព្រះឧបជ្ឈាយ៍មានឈ្មោះយ៉ាងហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងជាសទ្ធិវិហារិករបស់ឧបជ្ឈាយ៍ឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា ។

(៤៧៨) ដែលហៅថា គ្រឿងអាងពីអាចារ្យនោះ គឺភិក្ខុអ្នកចោទបានឃើញអន្តេវាសិករបស់អាចារ្យឈ្មោះនេះ ត្រូវអាបត្តិបារាជិក (តែមិនចោទ) លុះឃើញភិក្ខុដទៃជាអន្តេវាសិករបស់លោកអាចារ្យឈ្មោះហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងជាអន្តេវាសិករបស់លោកអាចារ្យ

ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ ។ បេ ។ សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

[៦៧៩] សេនាសនលេសោ នាម ឥត្ថន្នាមស្ស សេនាសនកសិកោ ទិដ្ឋោ ហោតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ អញ្ញំ ឥត្ថន្នាមស្ស សេនាសនកសិកំ បស្សិត្វា ចោទេតិ ឥត្ថន្នាមស្ស សេនាសនកសិកោ មយា ទិដ្ឋោ បារាជិកំ ធម្មំ អជ្ឈាបន្នោសិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វា អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

[៦៨០] បារាជិកេន ធម្មេនាតិ ចតុន្នំ អញ្ញតរេន ។ អនុទ្ធំសេយ្យាតិ ចោទេតិ វា ចោទាបេតិ វា ។ អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ ភិក្ខុភាវា ចាវេយ្យំ សមណធម្មា ចាវេយ្យំ សីលក្ខន្ធា ចាវេយ្យំ តបោគុណា ចាវេយ្យំ ។



ឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។

(៦៧៩) ដែលហៅថា លេសគឺសេនាសនៈនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុនៅក្នុងទីសេនាសនៈរបស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិក (តែមិនទាន់ចោទ) លុះឃើញភិក្ខុដទៃជាអ្នកនៅក្នុងទីសេនាសនៈរបស់ភិក្ខុឈ្មោះហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងនៅក្នុងទីសេនាសនៈ របស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកឯងទេ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។

(៦៨០) ពាក្យថា ដោយអាបត្តិបារាជិក គឺបានដល់អាបត្តិបារាជិក ៤ អាបត្តិបារាជិកណាមួយ ។ ពាក្យថា ចោទ គឺចោទឯងក្តី ប្រើគេឲ្យចោទក្តី ។ ពាក្យថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីញុំាងភិក្ខុនោះ ឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះ គឺថាអាត្មាអញគប្បីញុំាងភិក្ខុនេះឲ្យឃ្លាតចាកភាវៈជាភិក្ខុ ឲ្យឃ្លាតចាកសមណធម៌ ឲ្យឃ្លាតចាកសីលក្ខន្ធ ឲ្យឃ្លាតចាកតបោគុណ គឺធម៌ជាគ្រឿងដុតកិលេស ។

[៤៨១] កតោ អបរេន សមយេនាតិ យស្មិំ ខណេ អនុទ្ធំសិតោ ហោតិ តំ ខណំ តំ លយំ តំ មុហុត្តំ វីតិវត្តេ ។ សមនុគ្គាហិយមានោតិ យេន វត្ថុនា អនុទ្ធំសិតោ ហោតិ តស្មិំ វត្ថុស្មិំ សមនុគ្គាហិយមានោ ។ អសមនុគ្គាហិយមានោតិ ន កេនចិ វុច្ចមានោ ។

[៤៨២] អធិករណំ នាម ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ(១) អាបត្តាធិករណំ កិច្ចាធិករណំ ។

[៤៨៣] កោចិ ទេសោ លេសមត្តោ ឧបាទិន្នោតិ តេសំ ទសន្នំ លេសានំ អញ្ញតរោ លេសោ ឧបាទិន្នោ ហោតិ ។

[៤៨៤] ភិក្ខុ ច ទោសំ បតិដ្ឋាតីតិ តុច្ឆកំ មយា ភណិតំ មុសា មយា ភណិតំ អភូតំ មយា ភណិតំ អជានន្តេន មយា ភណិតំ ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

១ អយំ បាឋោ សព្វត្ថ ន ទិស្សតិ ។



[៤៨១] ពាក្យថា លុះសម័យកាលក្រោយអំពីនោះមក គឺភិក្ខុដែលគេមិនចោទក្នុងខណៈណា ខណៈនោះ ពេលនោះ ស្របក់នោះកន្លងទៅហើយ ។ ពាក្យថា មានគេសាកសួរ គឺថាភិក្ខុដែលគេចោទដោយវត្ថុណា គេសាកសួរចំពោះវត្ថុនោះ ។ ពាក្យថា មិនមានគេសាកសួរ គឺមិនមានអ្នកណាមួយនិយាយឡើយ ។

[៤៨២] ដែលហៅថា អធិករណ៍ បានដល់អធិករណៈ ៤ គឺ វិវាទាធិករណៈ ១ អនុវាទាធិករណៈ ១ អាបត្តាធិករណៈ ១ កិច្ចាធិករណៈ ១ ។

[៤៨៣] ពាក្យថា កាន់យកលេសគ្រាន់បន្តិចបន្តួចមកជាគ្រឿងអាង គឺបណ្តាគ្រឿងអាងទាំង ១០ យ៉ាងនោះ ភិក្ខុកាន់យកគ្រឿងអាងណាមួយ ។

[៤៨៤] ពាក្យថា ភិក្ខុប្តេជ្ញាទោស គឺ (ភិក្ខុប្តេជ្ញាថា) ខ្ញុំនិយាយពាក្យទទេសោះ ខ្ញុំនិយាយពាក្យកុហក ខ្ញុំនិយាយពាក្យមិនពិត ខ្ញុំនិយាយដោយមិនដឹង ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយដូចក្នុងសង្ឃាទិសេសសិក្ខាបទទី ១ ស្រេចហើយ ។

(២៨៨) ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ សង្ឃាទិសេសទិដ្ឋិ ហោតិ ឥតរញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធឹ ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ ថុល្លច្ចយទិដ្ឋិ ហោតិ ឥតរញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។បេ។ សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ បាចិត្តិយទិដ្ឋិ ហោតិ ឥតរញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។បេ។ សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ



(២៨៩) ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ ចំពោះសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិសង្ឃាទិសេស មែន តែបើភិក្ខុចោទភិក្ខុនោះ ដោយអាបត្តិបារាជិកវិញថា អ្នកឯងមិនមែន ជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ឧបោសថកម្ម បវារណាកម្ម សង្ឃកម្ម ជាមួយនឹងអ្នកឯងគ្មានទេ ឯអធិករណៈ យ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ចាំនឹងលេស[១] សោកភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ពាក្យ ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញចំពោះ សេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិថុល្លច្ច័យវិញ តែបើភិក្ខុ ចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ចាំនឹងលេសសោកភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗពាក្យ ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បាន ឃើញចំពោះសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាចិត្តិយ វិញ តែបើភិក្ខុចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែន ជាសមណៈ ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃ

១ លេសមាន ក្នុងអដ្ឋកថា ១០ យ៉ាង មានជាតិលេសជាដើម ។

លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ បាដិទេសនីយទិដ្ឋិ ហោតិ ។បេ។ សង្ឃាទិសេសេ ទុក្កដទិដ្ឋិ ហោតិ ។បេ។ សង្ឃាទិសេសេ ទុព្ភាសិតទិដ្ឋិ ហោតិ តញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។បេ។ សង្ឃកម្មំ វាតិ ឯវម្បិ អញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

(៤៨៦) ភិក្ខុ ថុល្លច្ចយំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ ថុល្លច្ចយេ ថុល្លច្ចយទិដ្ឋិ ហោតិ ។បេ។ ថុល្លច្ចយេ បាចិត្តិយទិដ្ឋិ ហោតិ ។បេ។ ថុល្លច្ចយេ បាដិទេសនីយទិដ្ឋិ ហោតិ ។បេ។ ថុល្លច្ចយេ ទុក្កដទិដ្ឋិ ហោតិ ។បេ។ ថុល្លច្ចយេ ទុព្ភាសិតទិដ្ឋិ ហោតិ ។បេ។ ថុល្លច្ចយេ សង្ឃាទិសេសទិដ្ឋិ តញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។បេ។ សង្ឃកម្មំ វាតិ



នៃអាបត្តាធិករណៈ តាំងលេសសាកក្តីនោះក៏នៅប្រកាន់ ជាប់ទោស ត្រូវសង្ឃាទិសេសគ្រប់ៗពាក្យ ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុឯកទេសក៏បានឃើញនឹងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាដិទេសនីយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុក្កដវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុព្ភាសិតវិញ តែបើភិក្ខុនោះចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ នៃអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ តាំងលេសសាកក្តីនោះក៏នៅប្រកាន់ជាប់ទោស ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។

(៤៨៦) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុឯកទេសក៏បានឃើញនឹងមានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុព្ភាសិតវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសវិញ បើភិក្ខុនោះចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។បេ។ សង្ឃ

អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ បាចិត្តិយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។បេ។ ភិក្ខុ បាដិទេសនីយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។បេ។ ភិក្ខុ ទុក្កដំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។បេ។ ភិក្ខុ ទុព្ភាសិតំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ទុព្ភាសិតេ ទុព្ភាសិតទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ សង្ឃាទិសេសទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ ថុល្លច្ចយទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ បាចិត្តិយទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ បាដិទេសនីយទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ ទុក្កដទិដ្ឋិ ហោតិ តញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។បេ។ [illegible] ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។

ឯកេកំ(១) មូលំ កាតូន ចក្កំ ពន្ធិតព្វំ ។

១ [illegible] ។



អធិករណៈយ៉ាងនេះ គឺឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោតភិក្ខុអ្នកចោទក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ ៗ ពាក្យ ។ ភិក្ខុក្រែងអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុក្រែងអាបត្តិបាដិទេសនីយ ។បេ។ ភិក្ខុក្រែងអាបត្តិទុក្កដ ។បេ។ ភិក្ខុក្រែងអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទ ក៏បានឃើញនឹងមានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជា អាបត្តិទុព្ភាសិត ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិ សង្ឃាទិសេស ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិ ថុល្លច្ច័យ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិ បាចិត្តិយ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាដិទេសនីយ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុក្កដ ទៅវិញ បើភិក្ខុនោះចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជា សមណៈទេ ។បេ។ សូម្បីអធិករណៈយ៉ាងនេះ គឺឈ្មោះថាចំណែក ដទៃនៃអាបត្តាធិករណៈ ទាំងលេសសោតភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ ៗ ពាក្យ ។

បណ្ឌិតគប្បីធ្វើអធិករណៈនោះ ៗ ឲ្យមានមូលមួយ ៗ ហើយចង ជាចក្ក (ដូច្នេះ) ។

[២៨៧] ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ សង្ឃាទិសេសទិដ្ឋិ ហោតិ តញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។ បេ ។ សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ សង្ឃាទិសេសំ អជ្ឈាបន្នោ ទិដ្ឋោ ហោតិ សង្ឃាទិសេសេ ថុល្លច្ចយទិដ្ឋិ ហោតិ ។ បេ ។ សង្ឃាទិសេសេ បាចិត្តិយទិដ្ឋិ ហោតិ ។ បេ ។ សង្ឃាទិសេសេ បាដិទេសនីយទិដ្ឋិ ហោតិ ។ បេ ។ សង្ឃាទិសេសេ ទុក្កដទិដ្ឋិ ហោតិ ។ បេ ។ សង្ឃាទិសេសេ ទុព្ភាសិតទិដ្ឋិ ហោតិ តញ្ចេ បារាជិកេន ចោទេតិ អស្សមណោសិ ។ បេ ។ សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។



[២៨៧] ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ ទាំងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិសង្ឃាទិសេសដែរ បើភិក្ខុអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។ បេ ។ សូម្បីអធិករណៈយ៉ាងនេះ គឺឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ចំណែកលេសនោះភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ ១ ពាក្យ ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ ទាំងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិថុល្លច្ច័យទៅវិញ ។ បេ ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាចិត្តិយទៅវិញ ។ បេ ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាដិទេសនីយទៅវិញ ។ បេ ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុក្កដទៅវិញ ។ បេ ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុព្ភាសិតទៅវិញ បើភិក្ខុអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។ បេ ។ សូម្បីអធិករណៈយ៉ាងនេះ គឺឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ចំណែកលេសនោះភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ ១ ពាក្យ ។

(៤៨៨) ភិក្ខុ ថុល្លច្ចយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ថុល្លច្ចយេ ថុល្លច្ចយទិដ្ឋិ ហោតិ ។ បេ ។ ថុល្លច្ចយេ បាចិត្តិយទិដ្ឋិ ហោតិ ។ បេ ។ ថុល្លច្ចយេ បាដិទេសនីយទិដ្ឋិ ហោតិ ។ បេ ។ ថុល្លច្ចយេ ទុក្កដទិដ្ឋិ ហោតិ ។ បេ ។ ថុល្លច្ចយេ ទុព្ភាសិតទិដ្ឋិ ហោតិ ។ បេ ។ ថុល្លច្ចយេ សង្ឃាទិសេសទិដ្ឋិ ហោតិ តញ្ចេ បារាជិកេន ចោទាបេតិ អស្សមណោសិ ។ បេ ។ សង្ឃកម្មំ វាតិ ឯវម្បិ អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ វាចាយ វាចាយ សង្ឃាទិសេសស្ស ។ ភិក្ខុ បាចិត្តិយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។ បេ ។ ភិក្ខុ បាដិទេសនីយំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។ បេ ។ ភិក្ខុ ទុក្កដំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ។ បេ ។ ទុព្ភាសិតំ អជ្ឈាបជ្ជន្តោ ទិដ្ឋោ ហោតិ ទុព្ភាសិតេ ទុព្ភាសិតទិដ្ឋិ ហោតិ ។ បេ ។ ទុព្ភាសិតេ សង្ឃាទិសេសទិដ្ឋិ ហោតិ ។ បេ ។ ទុព្ភាសិតេ ថុល្លច្ចយទិដ្ឋិ ហោតិ ។ បេ ។ ទុព្ភាសិតេ បាចិត្តិយទិដ្ឋិ ហោតិ ។ បេ ។ ទុព្ភាសិតេ



(៤៨៨) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុអ្នកចោទក៏បានឃើញនឹងមានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុព្ភាសិតវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសវិញ បើអ្នកនោះចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។ បេ ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ តាំងលេសលោកភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពាក្យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ អ្នកចោទក៏បានឃើញ ។ បេ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយ ។ បេ ។ ភិក្ខុត្រូវអាបត្តិទុក្កដ ។ បេ ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទក៏បានឃើញនឹងមានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុព្ភាសិតមែន ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិសង្ឃាទិសេសវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិថុល្លច្ច័យវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាចិត្តិយវិញ ។ បេ ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិត

រាជិកេ ថុល្លច្ចយទិដ្ឋិ ហោតិ ។បេ។ ទុព្ភាសិតេ ទុក្ក-
ដទិដ្ឋិ ហោតិ តញ្ចេ ចោទេតិ ចោទាបេតិ អស្ស-
មណោសិ អសក្យបុត្តិយោសិ នត្ថិ តយា សទ្ធិំ
ឧបោសថោ វា បវារណា វា សង្ឃកម្មំ វាតិ [illegible]
អាបត្តញ្ញភាគិយំ ហោតិ លេសោ ច ឧបាទិន្នោ អាបត្តិ
វាចាយ វាចាយ សង្ឃាទិសេសស្ស[១] ។

(៦៨៩) អនាបត្តិ តថាសញ្ញី ចោទេតិ វា ចោទាបេតិ
វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសង្ឃាទិសេសំ និដ្ឋិតំ ។

---

១ [illegible] ។



ថាជាអាបត្តិថុល្លច្ចយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិ
ទុព្ភាសិតថាជាអាបត្តិទុក្កដវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិ
បារាជិកថា អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធ
ជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នក
ឯងគ្មានទេ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃ
អាបត្តាធិករណៈ តាំងលេសរបស់ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិ
សង្ឃាទិសេសគ្រប់ៗពាក្យ ។

(៦៨៩) អាបត្តិមិនមានដល់ភិក្ខុអ្នកចោទមានសេចក្តីសំគាល់ពិត
ហើយចោទឯង ឬឲ្យអ្នកដទៃចោទ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអាទិកម្មិក ។

សង្ឃាទិសេស ទី ៩ ចប់ ។

# ទសមសង្ឃាទិសេសំ

[៤៩០] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ ទេវទត្តោ យេន កោកាលិកោ កដមោរកតិស្សកោ ខណ្ឌទេវិយា បុត្តោ សមុទ្ទទត្តោ តេនុបសង្កមិ ឧបសង្កមិត្វា កោកាលិកំ កដមោរកតិស្សកំ ខណ្ឌទេវិយា បុត្តំ សមុទ្ទទត្តំ ឯតទវោច ឯថ មយំ អាវុសោ សមណស្ស គោតមស្ស សង្ឃភេទំ ករិស្សាម ចក្កភេទន្តិ ។ ឯវំ វុត្តេ កោកាលិកោ ទេវទត្តំ ឯតទវោច សមណោ ខោ អាវុសោ គោតមោ មហិទ្ធិកោ មហានុភាវោ កថំ មយំ សមណស្ស គោតមស្ស សង្ឃភេទំ ករិស្សាម ចក្កភេទន្តិ ។ ឯថ មយំ អាវុសោ សមណំ គោតមំ ឧបសង្កមិត្វា បញ្ច វត្ថូនិ យាចិស្សាម ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស

# សង្ឃាទិសេសទី ១០

(៤៩០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ប្រថាប់នៅក្នុងវត្តវេឡុវន ជាទីដែលស្តេចប្រទានចំណីដល់សត្វកន្ធ្លែន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះ ភិក្ខុឈ្មោះទេវទត្តបានចូលទៅរកភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្ត ហើយបាននិយាយពាក្យនេះនឹងភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្តថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនឹងធ្វើការបំបែកសង្ឃ និងចំណាយចក្រ(*) របស់ព្រះសមណគោតម ។ កាលទេវទត្តពោលយ៉ាងនេះហើយ ទើបភិក្ខុឈ្មោះកោកាលិកនិយាយពាក្យនេះនឹងទេវទត្តថា អាវុសោ ព្រះសមណគោតមមានឫទ្ធិច្រើន មានអានុភាពធំ ពួកយើងនឹងធ្វើការបំបែកសង្ឃនិងចំណាយចក្ររបស់ព្រះសមណគោតមដូចម្តេចបាន ។ ទេវទត្តឆ្លើយថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនឹងនាំគ្នាចូលទៅគាល់ព្រះសមណគោតម ទូលសូមវត្ថុ ៥ ប្រការថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគទ្រង់សរសើរគុណនៃបុគ្គលអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ដុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត ប្រកបដោយសេចក្តីជ្រះថ្លា មិនចំរើនកិលេសវដ្ត

---

* មិនឲ្យគេប្រព្រឹត្តបង្គាប់តាមអាណាចក្ររបស់ព្រះសម្មាសម្ពុទ្ធ ។

វិរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេក-
បរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ[១] សល្លេខាយ
ធុតាយ[២] បាសាទិកាយ[៣] អបចយាយ វិរិយារម្ភាយ
សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ
គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បិណ្ឌបាតិកា
អស្សុ យោ និមន្តនំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ
យាវជីវំ បំសុកូលិកា អស្សុ យោ គហបតិចីវរំ សាទិ-
យេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ រុក្ខមូលិកា អស្សុ យោ
ឆន្នំ ឧបគច្ឆេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ មច្ឆមំសំ
ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ វជ្ជំ នំ ផុសេយ្យាតិ
ឥមានិ សមណោ គោតមោ នានុជានិស្សតិ តេ មយំ
ឥមេហិ បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេស្សាមាតិ ។
សក្កា ខោ អាវុសោ ឥមេហិ បញ្ចហិ វត្ថូហិ សមណ-
ស្ស គោតមស្ស សង្ឃភេទំ[៤] កាតុំ ចក្កភេទំ[៥]
លូខប្បសន្នា ហិ អាវុសោ មនុស្សាតិ ។

---

១ ឱ. ម. សន្តុដ្ឋិយា ។ ២ ឱ. ម. ធុតតាយ ។ ៣ ឱ. ម. បាសាទិកតាយ ។ ៤ ឱ. ម. សង្ឃភេទោ ។ ៥ ឱ. ម. ចក្កភេទោ ។



ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយដ៏ច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីដុសខាត់ចិត្ត ដើម្បីធុតគុណ ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនចំរើនកិលេសវដ្ត ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយដ៏ច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាទៅកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតិចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាទៅនៅក្នុងទីប្រក់បាំង ភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស យើងនឹងសូមវត្ថុនេះ ព្រះសមណគោតមមុខជានឹងមិនអនុញ្ញាតឡើយ ហើយពួកយើងនឹងនាំឲ្យយល់ជន (ឲ្យត្រេកអរនឹងយើង) ដោយវត្ថុ ៥ ប្រការនេះ ។ ទើបកោកាលិកភិក្ខុពោលថា ម្នាលអាវុសោ ពួកយើងអាចនឹងធ្វើការបែកសង្ឃនិងចំលាយចក្ររបស់ព្រះសមណគោតម ដោយវត្ថុ ៥ ប្រការនេះបាន ព្រោះមនុស្សទាំងឡាយដែលជ្រះថ្លាក្នុងវត្ថុសៅហ្មង (មានច្រើន) អាវុសោ ។

[២៩០] អថខោ ទេវទត្តោ សបរិសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទេវទត្តោ ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខតាយ ធុតតាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញិកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បិណ្ឌបាតិកា អស្សុ យោ និមន្តនំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បំសុកូលិកា អស្សុ យោ គហបតិចីវរំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ រុក្ខមូលិកា អស្សុ យោ ឆន្នំ ឧបគច្ឆេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ





[២៩០] គ្រានោះ ទេវទត្តភិក្ខុព្រមទាំងបរិស័ទចូលទៅគាល់ព្រះដ៏មានព្រះភាគម្ចាស់ ហើយក្រាបថ្វាយបង្គំ អង្គុយក្នុងទីដ៏សមគួរ ។ លុះទេវទត្តភិក្ខុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគម្ចាស់ថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គដ៏ចំរើនតែងទ្រង់សរសើរគុណរបស់បុគ្គលប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកខាត់ចិត្ត ទ្រទ្រង់ធុតង្គ មានសេចក្តីជ្រះថ្លា មិនចំរើនកិលេសវត្ថុ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការទាំងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច សន្តោស ជួសខាត់ចិត្ត កំចាត់បង់គ្រឿងសៅហ្មង ដើម្បីសេចក្តីជ្រះថ្លា មិនចំរើនកិលេសវត្ថុ ប្រារព្ធសេចក្តីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមព្រះអង្គទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតិចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅទៀបគល់ឈើអស់មួយជីវិត ភិក្ខុណាចូលជ្រកទីប្រក់ទំបាំង ភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់មួយជីវិត

ជ្ជំ នំ ផុសេយ្យាតិ ។ អលំ ទេវទត្ត យោ ឥច្ឆតិ អារញ្ញកោ ហោតុ យោ ឥច្ឆតិ គាមន្តេ វិហរតុ យោ ឥច្ឆតិ បិណ្ឌបាតិកោ ហោតុ យោ ឥច្ឆតិ និមន្តនំ សាទិយតុ យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិចីវរំ សាទិយតុ អដ្ឋមាសេ ខោ មយា ទេវទត្ត រុក្ខមូលសេនាសនំ អនុញ្ញាតំ តិកោដិបរិសុទ្ធំ មច្ឆមំសំ អទិដ្ឋំ អស្សុតំ អបរិសង្កិតន្តិ ។

[៦៨៦] អថខោ ទេវទត្តោ ន ភគវា ឥមានិ បញ្ច វត្ថូនិ អនុជានាតីតិ ហដ្ឋោ ឧទគ្គោ សបរិសោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ទេវទត្តោ សបរិសោ(១) រាជគហំ បវិសិត្វា បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេសិ មយំ អាវុសោ សមណំ គោតមំ ឧបសង្កមិត្វា បញ្ច វត្ថូនិ យាចិម្ហា ភគវា ភន្តេ អនេកបរិយាយេន

១ ម. ឆ. [illegible] ។



ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលទេវទត្ត ភិក្ខុណាចង់នៅព្រៃ ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់នៅស្រុក ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់ប្រព្រឹត្តបិណ្ឌបាតវត្ត ភិក្ខុនោះចូរប្រព្រឹត្តចុះ ភិក្ខុណាត្រេកអរដោយកិច្ចនិមន្ត ភិក្ខុនោះចូរត្រេកអរចុះ ភិក្ខុណាចង់ប្រើប្រាស់សំពត់បង្សុកូល ភិក្ខុនោះចូរប្រើប្រាស់ចុះ ភិក្ខុណាចង់បានគហបតិចីវរ ភិក្ខុនោះចូរត្រេកអរនឹងចីវរនោះចុះ ម្នាលទេវទត្ត តថាគតអនុញ្ញាតសេនាសនៈទៀបគល់ឈើអស់កាល ៨ ខែ អនុញ្ញាតត្រីសាច់ ដែលបរិសុទ្ធដោយចំណុច ៣ ប្រការ គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស (ឲ្យភិក្ខុទាំងឡាយជាមុន) ។

(៦៨៦) លំដាប់នោះ ទេវទត្តភិក្ខុត្រេកអរ រីករាយ សប្បាយ ត្រេកអររីករាយ ថា ព្រះដ៏មានព្រះភាគមិនទ្រង់អនុញ្ញាតវត្ថុ ៥ ប្រការនេះទេ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ ទើបទេវទត្តភិក្ខុព្រមទាំងបរិស័ទចូលទៅក្រុងរាជគ្រឹះ ញុំាងជនឲ្យយល់ដោយវត្ថុ ៥ ប្រការហើយពោលថា អាវុសោទាំង-ឡាយ ពួកយើងបានចូលទៅគាល់ព្រះសមណគោតមហើយទូលសូមវត្ថុ ៥ ប្រការថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគមានប្រក្រតី

អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណកថី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខាយ ធុតតាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បិណ្ឌបាតិកា អស្សុ យោ និមន្តនំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បំសុកូលិកា អស្សុ យោ គហបតិចីវរំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ រុក្ខមូលិកា អស្សុ យោ ឆន្នំ ឧបគច្ឆេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ វជ្ជំ នំ ផុសេយ្យាតិ ឥមានិ សមណោ គោតមោ នានុជានាតិ តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ សមាទាយ វត្តាមាតិ ។





សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច សន្តោស ផុសកាត់ចិត្ត កំចាត់គតិគ្រឿងសៅហ្មង មានសេចក្ដីជ្រះថ្លា មិនចំរើនកិលេសវដ្ដ ប្រារព្ធសេចក្ដីព្យាយាមដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការនេះប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ដើម្បីសេចក្ដីសន្តោស ដើម្បីសេចក្ដីប្រតិបត្តិដ៏ផូរផង់ ដើម្បីកំចាត់កិលេសធម៌ ដើម្បីសេចក្ដីជ្រះថ្លា ដើម្បីមិនចំរើនកិលេសវដ្ដ ដើម្បីប្រារព្ធសេចក្ដីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តា សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយត្រាច់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតិចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅក្បែរគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាចូលជ្រកទីប្រក់បាំង ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកុំឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស ព្រះសមណគោតមមិនទ្រង់អនុញ្ញាតវត្ថុ ៥ ប្រការនេះទេ តែពួកយើងនឹងនាំគ្នាសមាទានវត្ថុ ៥ នេះវិញ ។

(៤៩៣) តត្ថ យេ តេ មនុស្សា អស្សទ្ធា អប្បសន្នា ទុព្ពុទ្ធិនោ តេ ឯវមាហំសុ កថំ ហិ នាម សមណា សក្យ-បុត្តិយា ធុតា សល្លេខវុត្តិនោ សមណោ បន គោតមោ ពាហុល្លិកោ ពាហុល្លាយ ចេតេតីតិ ។ យេ បន តេ មនុស្សា សទ្ធា បសន្នា បណ្ឌិតា ពុទ្ធិមន្តោ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ ភគវតោ សង្ឃភេទាយ បរក្កមិស្សតិ ចក្កភេទាយាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ សង្ឃភេទាយ បរក្កមិស្សតិ ចក្កភេ-ទាយាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ទេវទត្តំ បដិបុច្ឆិ ។បេ។ សច្ចំ កិរ ត្វំ ទេវទត្ត សង្ឃភេទាយ បរក្កមសិ ចក្កភេទាយាតិ ។ សច្ចំ ភគវាតិ ។



[៤៩៣] បណ្តាមនុស្សទាំងនោះ មនុស្សទាំងឡាយណាជាអ្នកអសទ្ធា មិនជ្រះថ្លា មានប្រាជ្ញាថោកថយ ទើបមនុស្សទាំងនោះពោលយ៉ាងនេះថា ពួកសមណៈទាំងនេះឯងជាកូនចៅព្រះសក្យបុត្ត ជាអ្នកកំចាត់កិលេសធម៌ ជាអ្នកប្រព្រឹត្តគុណធម៌ដ៏ផូរផង់ ចំណែកព្រះសមណ-គោតមជាអ្នកប្រព្រឹត្តល្មោភដោយបច្ច័យមានចីវរបច្ច័យជាដើម តែងត្រិះរិះដោយបច្ច័យមានចីវរបច្ច័យជាដើមដ៏ច្រើន ។ ពួកមនុស្សណា ជាអ្នកមានសទ្ធាជ្រះថ្លា ជាបណ្ឌិតមានប្រាជ្ញា ពួកមនុស្សទាំងនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ទេវទត្តភិក្ខុមិនគួរសោះនឹងបំបែកទំលាយសង្ឃ ទំលាយចក្ររបស់ព្រះដ៏មានព្រះភាគម្ចាស់ ។ ពួកភិក្ខុបានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ភិក្ខុទាំង-ឡាយឯណាជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ទេវទត្តភិក្ខុមិនសមបើខ្នះខ្នែងដើម្បីទំលាយសង្ឃ ដើម្បីទំលាយចក្រសោះ ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះអង្គទ្រង់ឲ្យប្រជុំភិក្ខុសង្ឃហើយត្រាស់សួរភិក្ខុទេវទត្តក្នុងពេលនោះ ។បេ។ ម្នាលទេវទត្ត គេថាអ្នកខំព្យាយាមទំលាយសង្ឃ ទំលាយចក្រ ពិតមែនឬ ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។

វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស ។បេ។ កថំ ហិ នាម ត្វំ មោឃបុរិស សង្ឃភេទាយ បរក្កមិស្សសិ ចក្កភេទាយ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ សមេតាយស្មា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ



ព្រះសម្ពុទ្ធមានព្រះភាគតិះដៀលថា ម្នាលមោឃបុរស មិនសមគួរសោះ ។បេ។ មោឃបុរស ហេតុម្តេចហ្ន៎បានជាអ្នកឯងនឹងព្យាយាមទំលាយសង្ឃទំលាយចក្រ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនតាំងឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយព្យាយាមដើម្បីទំលាយសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នា ហើយតាំងនៅ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ភិក្ខុនោះយ៉ាងនេះថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នាហើយតាំងនៅ សូមលោកម្ចាស់ព្រមព្រៀងនឹងជាមួយនឹងសង្ឃទៅ ព្រោះថា ព្រះសង្ឃព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុនោះកាលភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះហើយ នៅប្រកាន់សង្កត់យ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ពោលប្រដៅហាមប្រាម) ជាគំរប់បីដង ដើម្បីឲ្យលះបង់សង្ឃភេទកម្មនោះ ។ កាលបើភិក្ខុទាំងឡាយ

សមនុគ្គាហិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោតិ ។

[៨៤៨] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សមគ្គោ នាម សង្ឃោ សមានសំវាសកោ សមានសីមាយ ឋិតោ ។ ភេទាយ បរក្កមេយ្យាតិ កថំ ឥមេ នានា អស្សុ វិនា អស្សុ វគ្គា អស្សូតិ បក្ខំ បរិយេសតិ គណំ ពន្ធតិ ។ ភេទនសំវត្តនិកំ វា អធិករណន្តិ អដ្ឋារសភេទករវត្ថូនិ ។ សមាទាយាតិ អាទាយ ។ បគ្គណ្ហេយ្យាតិ ទីបេយ្យ ។ តិដ្ឋេយ្យាតិ ន បដិនិស្សជ្ជេយ្យ ។



សូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់បីដងហើយ ភិក្ខុនោះបានលះបង់វត្ថុនោះចេញ ការលះបង់ដូច្នេះជាការប្រពៃ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨៤៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយពិស្ដារក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ រួចហើយ ។ សង្ឃដែលមានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាជាមួយគ្នា ហៅថាព្រមព្រៀងគ្នា ។ ពាក្យថា ព្យាយាមដើម្បីបំបែក គឺភិក្ខុស្វែងរកបក្សពួកចងជាគណៈដោយចិត្តបំណងថា ធ្វើម្ដេចឲ្យភិក្ខុពួកនេះនៅផ្សេងៗគ្នា បែកគ្នាជាពួកជាកង ។ ពាក្យថា អធិករណៈដែលនឹងនាំឲ្យសង្ឃបែកគ្នា គឺផ្លូវខុសរឿងដែលជាហេតុធ្វើឲ្យបែកគ្នាមាន ១៨ (១) ប្រការ ។ ពាក្យថា ប្រកាន់ គឺកាន់យក ។ ពាក្យថា ផ្គងឡើង គឺសំដែង ។ ពាក្យថា តាំងនៅ គឺមិនលះបង់ ។

---

១ សំដែងអធម្មថាជាធម្ម ។ ២ សំដែងធម្មថាជាអធម្ម ។ ៣ សំដែងអវិន័យថាជាវិន័យ ។ ៤ សំដែងវិន័យថាជាអវិន័យ ។ ៥ ពាក្យដែលព្រះតថាគតមិនបានសំដែងថាព្រះតថាគតបានសំដែង ។ ៦ ពាក្យដែលព្រះតថាគតបានសំដែងថាព្រះតថាគតមិនបានសំដែង ។ ៧ អាចារៈដែលព្រះតថាគតមិនបានសន្សំទុកមកថាព្រះតថាគតបានសន្សំទុកមក ។ ៨ ដែលព្រះតថាគតបានសន្សំទុកមកថាព្រះតថាគតមិនបានសន្សំទុកមក ។ ៩ សេចក្ដីដែលព្រះតថាគតមិនបានបញ្ញត្តថាព្រះតថាគតបានបញ្ញត្ត ។ ១០ ដែលព្រះតថាគតបានបញ្ញត្តថាមិនបានបញ្ញត្ត ។ ១១ សំដែងអនាបត្តិថាជាអាបត្តិ ។ ១២ សំដែងអាបត្តិថាជាអនាបត្តិ ។ ១៣ សំដែងលហុកាបត្តិថាជា

(៦៩៥) សោ ភិក្ខូតិ យោ សោ សង្ឃភេទកោ ភិក្ខុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ សមេតាយស្មា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ទុតិយម្បិ វត្តព្វោ ។ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សោ ភិក្ខុ



[៦៩៥] ពាក្យថា ភិក្ខុនោះ គឺភិក្ខុអ្នកបំបែកសង្ឃនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយឯទៀត (ក្រៅពីភិក្ខុដែលបំបែកសង្ឃនោះ) ។ ភិក្ខុណាបានឃើញ ឬបានឮ ពួកភិក្ខុទាំងនោះ ត្រូវនិយាយនឹងភិក្ខុដែលបំបែកសង្ឃនោះថា លោកម្ចាស់ កុំព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈ ដែលជាគ្រឿងឲ្យសង្ឃបែកគ្នា សូមឲ្យលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយបានឮហើយ មិនពោល (ហាម) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវនាំភិក្ខុ

---

ពុទ្ធបញ្ញត្តិ ។ ១៤. សំដៅយកព្រះបញ្ញត្តិជាដើមមុនបញ្ញត្តិ ។ ១៥. សំដៅយកសេសសេសាបត្តិ (អាបត្តិ ៥ គង លើកសាបត្តិបារាជិកនិងសង្ឃាទិសេសចេញ) ជាបាតសេសសាបត្តិ (ដំណាក់នឹងសង្ឃាទិសេស) ។ ១៦. សំដៅយកអសេសសាបត្តិជាសាវសេសសាបត្តិ ។ ១៧. សំដៅយកទុដ្ឋុល្លាបត្តិជាអទុដ្ឋុល្លាបត្តិ ។ ១៨. សំដៅយកអទុដ្ឋុល្លាបត្តិជាទុដ្ឋុល្លាបត្តិ ។

(មានក្នុងគម្ពីរចុល្លវគ្គ ក្រុងសង្ឃភេទក្ខន្ធក)

សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វោ មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ សមេតាយស្មា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

(៤៨៦) សោ ភិក្ខុ សមនុភាសិតព្វោ ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមតិ ។ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ



ទាំងឡាយ ចាប់ទាញមកកាន់កណ្តាលជំនុំសង្ឃ ហើយពោល (ហាម)ថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា មួយប្រកាន់ផ្គងឡើងនូវអធិករណៈដែលនឹងនាំឲ្យសង្ឃបែកគ្នាឡើយ សូមឲ្យលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ភិក្ខុជាអ្នកបំបែកសង្ឃនោះ ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការប្រពៃ បើមិនលះបង់ទេ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

(៤៨៦) ភិក្ខុទាំងឡាយគប្បីសូត្រសមនុភាសនកម្មដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឆ្លៀវឆ្លាសអង់អាចគប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្ម

សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមតិ ។ សោ តំ វត្ថុំ ន បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមតិ ។ សោ តំ វត្ថុំ ន បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស



(ហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ ។ នេះជាញត្តិ (ការប្រកាសដល់សង្ឃ) ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះដើម្បីឲ្យលះបង់រឿងនោះ ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះនេះដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា សូមឲ្យលោកម្ចាស់អង្គនោះពោលឡើង ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះចេញ ។ ការសូត្រប្រាប់ភិក្ខុមានឈ្មោះនេះដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា

នក្ខមតិ សោ ភាសេយ្យ ។ សមនុភដ្ឋោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(២៤៧) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ច-យា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។ សង្ឃាទិសេ-សោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(២៤៨) ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកោ



លោកអង្គនោះត្រូវតែពោលឡើង ។ ភិក្ខុឈ្មោះនេះ ត្រូវសង្ឃធ្វើសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់រឿងនោះ ។ សមនុភាសន-កម្មនេះ សមគួរដល់សង្ឃ ហេតុនោះត្រូវសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវពាក្យនេះដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

(២៤៧) (កាលសង្ឃ)សូត្រញត្តិចប់ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាតែពីរ (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុនោះ) ត្រូវអាបត្តិសង្ឃាទិ-សេស ។ កាលបើភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដ ដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី នឹងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាទាំងពីរក្តី ក៏រម្ងាប់ទៅឯង ។ ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទទី ១ សង្ឃាទិសេសខាងដើមរួចហើយ ។

(២៤៨) ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ ថាកម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ (សង្ឃទេកម្មនោះ) ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្ម

នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៦៨៨] អនាបត្តិ អសមនុភាសន្តស្ស បដិនិស្សជ្ជន្តស្ស ឧម្មត្តកស្ស(១) អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

---

១ [illegible] [illegible] ខិត្តចិត្តស្ស វេទនដ្ដស្សាតិ ទិស្សតិ ។



ដែលសង្ឃធ្វើត្រូវតាមធម៌ តែមិនលះបង់ (គំនិតប្រកាន់) ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្ដីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ថាកម្មមិនត្រូវតាមធម៌ មិនលះបង់ ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្ដីសំគាល់ក្នុងកម្មដែលសង្ឃធ្វើមិនត្រូវតាមធម៌ថាកម្មធ្វើត្រូវតាមធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងកម្មមិនមែនជាធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដដែរ ។ ភិក្ខុមានសេចក្ដីសំគាល់ក្នុងកម្មមិនមែនជាធម៌ ថាកម្មមិនមែនជាធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[៦៨៨] អាបត្តិមិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រប្រកាសហាម ដល់ភិក្ខុដែលបានលះបង់ (សង្ឃភេទកម្ម) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សិក្ខាបទទី ១០ ចប់ ។

## ឯកាទសមសង្ឃាទិសេសំ

[៣០០] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ទេវទត្តោ សង្ឃភេទាយ បរក្កមតិ ចក្កភេទាយ ។ ភិក្ខូ ឯវមាហំសុ អធម្មវាទី ទេវទត្តោ អវិនយវាទី ទេវទត្តោ កថំ ហិ នាម ទេវទត្តោ សង្ឃភេទាយ បរក្កមិស្សតិ ចក្កភេទាយាតិ ។ ឯវំ វុត្តេ កោកាលិកោ កដមោរកតិស្សកោ ខណ្ឌទេវិយា បុត្តោ សមុទ្ទទត្តោ តេ ភិក្ខូ ឯតទវោចុំ មា អាយស្មន្តោ ឯវំ អវចុត្ថ ធម្មវាទី ទេវទត្តោ វិនយវាទី ទេវទត្តោ អម្ហាកញ្ច ទេវទត្តោ ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ ជានាតិ នោ ភាសតិ អម្ហាកម្បេតំ ខមតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា ភវិស្សន្តិ វគ្គវាទកាតិ ។

## សង្ឃាទិសេសទី ១១

(៣០០) សម័យនោះ ព្រះពុទ្ធដ៏មានឥស្សរិយយស ទ្រង់ប្រថាប់គង់នៅក្នុងវត្តវេឡុវ័ន ជាទីដែលស្តេចប្រទានចំណីដល់សត្វកន្ធែនទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ ។ ភិក្ខុទាំងឡាយពោលយ៉ាងនេះថា ទេវទត្តជាអ្នកពោលខុសធម៌ ទេវទត្តជាអ្នកពោលខុសវិន័យ ទេវទត្តមិនគួរប្រឹងព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ ។ កាលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ទើបកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវីបុត្តភិក្ខុនឹងសមុទ្ទទត្តភិក្ខុ ក៏ពោលពាក្យនេះនឹងពួកភិក្ខុទាំងនោះថា សូមលោកម្ចាស់ទាំងឡាយកុំពោលយ៉ាងហ្នឹង ទេវទត្តពោលត្រូវតាមធម៌ ទេវទត្តពោលត្រូវតាមវិន័យ មួយវិញទៀត ទេវទត្តកាន់យកសេចក្តីពេញចិត្តនិងសេចក្តីគាប់ចិត្តរបស់ពួកយើង ហើយទើបពោល លោកដឹង (សេចក្តីពេញចិត្តជាដើមរបស់ពួកយើង) ទើបពោល អំពើដែលលោកបានធ្វើមកនោះក៏សមគួរដល់យើងទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច បានជាភិក្ខុទាំងឡាយប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។

អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា វគ្គវាទកាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិសានំ ។បេ។ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា ភវិស្សន្តិ វគ្គវាទកា នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ តស្សេវ ខោ បន ភិក្ខុស្ស ភិក្ខូ ហោន្តិ អនុវត្តកា វគ្គវាទកា ឯកោ វា ទ្វេ វា តយោ វា តេ ឯវំ វទេយ្យុំ មា អាយស្មន្តោ ឯតំ ភិក្ខុំ កិញ្ចិ អវចុត្ថ ធម្មវាទី ចេសោ ភិក្ខុ



វេលានោះ ពួកភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគអម្ចាស់ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគអម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុទាំងឡាយក្នុងខណៈនោះថា នែភិក្ខុទាំងឡាយ ឮថា មានពួកភិក្ខុប្រព្រឹត្តតាមទេវទត្តភិក្ខុជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់មានឥស្សរិយយសទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើដែលមោឃបុរសទាំងនោះបានធ្វើ មិនសមគួរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុម្តេច ពួកមោឃបុរសទាំងនោះ ប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក នែភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុទាំងឡាយមួយរូបក្តី ពីររូបក្តី បីរូបក្តី ជាអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះឯង ទាំងជាអ្នកពោលប្រកាន់ពួក ហើយពួកភិក្ខុទាំងនោះពោលហាម ភិក្ខុទាំងឡាយ (ដែលជាភិក្ខុបរិសុទ្ធ) យ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ព្រោះភិក្ខុនេះជាអ្នកពោលត្រូវតាមធម៌ផង

វិនយវាទី ចេសោ ភិក្ខុ អម្ហាកញ្ចេសោ ភិក្ខុ ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ ជានាតិ នោ ភាសតិ អម្ហាកម្បេតំ ខមតីតិ ។ តេ ភិក្ខូ ភិក្ខូហិ ឯវមស្សុ វចនីយា មាយស្មន្តោ ឯវំ អវចុត្ថ ន ចេសោ ភិក្ខុ ធម្មវាទី ន ចេសោ ភិក្ខុ វិនយវាទី មា អាយស្មន្តានម្បិ សង្ឃភេទោ រុច្ចិត្ថ សមេតាយស្មន្តានំ សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច តេ ភិក្ខូ ភិក្ខូហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យុំ តេ ភិក្ខូ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យុំ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យុំ សង្ឃាទិសេសោតិ ។



ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផង មួយទៀត ភិក្ខុនេះកាន់យកសេចក្តីពេញចិត្តនិងសេចក្តីគាប់ចិត្តរបស់ពួកយើង ទើបពោល លោកដឹងសេចក្តីពេញចិត្តជាដើមរបស់ពួកយើង ទើបពោល ដំណើរនេះគឺគាប់ចិត្តដល់យើងទាំងឡាយ ។ ពួកភិក្ខុទាំងនោះត្រូវពួកភិក្ខុទាំងឡាយ (ដែលបរិសុទ្ធ) ពោលយ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ព្រោះភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំងឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះព្រះសង្ឃព្រមព្រៀងនឹងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា មានឧទ្ទេសតែមួយគ្នា តែងនៅសប្បាយ ។ ពួកភិក្ខុទាំងនោះ កាលដែលភិក្ខុទាំងឡាយពោលតាមយ៉ាងនេះ ក៏នៅប្រកាន់ស្វិតយ៉ាងនោះដដែល ពួកភិក្ខុទាំងនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈគំរប់បីដង ដើម្បីឲ្យលះបង់នូវកម្មនោះ ។ កាលបើភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្មដល់គំរប់បីដងហើយ ពួកភិក្ខុទាំងនោះលះបង់នូវរឿងនោះចេញ ការលះបង់បានយ៉ាងនេះជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

(៣០១) តស្សេវ ខោ បនាតិ តស្ស សង្ឃភេទកស្ស ភិក្ខុនោ ។ ភិក្ខូ ហោន្តីតិ អញ្ញេ ភិក្ខូ ហោន្តិ ។ អនុវត្តកាតិ យំទិដ្ឋិកោ ហោតិ យំខន្តិកោ យំរុចិកោ តេបិ តំទិដ្ឋិកា ហោន្តិ តំខន្តិកា តំរុចិកា ។ វគ្គវាទកាតិ តស្ស វណ្ណាយ បក្ខាយ ឋិតា ហោន្តិ ។ ឯកោ វា ទ្វេ វា តយោ វាតិ ឯកោ វា ហោតិ ទ្វេ វា តយោ វា តេ ឯវំ វទេយ្យុំ មា អាយស្មន្តោ ឯតំ ភិក្ខុំ កិញ្ចិ អវចុត្ថ ធម្មវាទី ចេសោ ភិក្ខុ វិនយវាទី ចេសោ ភិក្ខុ អម្ហាកញ្ចេសោ ភិក្ខុ ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ ជានាតិ នោ ភាសតិ អម្ហាកម្បេតំ ខមតីតិ ។

(៣០២) តេ ភិក្ខូតិ យេ តេ អនុវត្តកា ភិក្ខូ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វា មា អាយស្មន្តោ ឯវំ អវចុត្ថ



(៣០១) ត្រង់ពាក្យថា ភិក្ខុនោះឯង គឺភិក្ខុជាអ្នកបំបែកសង្ឃនោះ ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ ។ ពាក្យថា ជាអ្នកប្រព្រឹត្តតាម គឺភិក្ខុអ្នកបំបែកសង្ឃយល់ឃើញ ត្រេកចិត្ត គាប់ចិត្តដូចម្ដេច ភិក្ខុទាំងនោះក៏យល់តាម ត្រេកចិត្តតាម គាប់ចិត្តតាមដូច្នោះដែរ ។ ពាក្យថា ជាអ្នកពោលប្រកាន់ពួក គឺតាំងនៅក្នុងសេចក្ដីសរសើរនូវភិក្ខុជាអ្នកបំបែកសង្ឃនោះផង ក្នុងពួកនៃភិក្ខុនោះផង ។ ពាក្យថា មួយរូបក្ដី ពីររូបក្ដី បីរូបក្ដី គឺភិក្ខុមួយរូបក្ដី ពីររូបក្ដី បីរូបក្ដី ភិក្ខុទាំងនោះពោលនឹងភិក្ខុទាំងឡាយយ៉ាងនេះថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ភិក្ខុនេះជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះជាអ្នកពោលត្រូវតាមវិន័យផង មួយទៀត ភិក្ខុនេះកាន់យកសេចក្ដីពេញចិត្ត និងសេចក្ដីគាប់ចិត្តរបស់ពួកយើងហើយ ទើបពោល លោកដឹង (សេចក្ដីពេញចិត្តជាដើម) របស់ពួកយើងហើយ ទើបពោល អំពើដែលលោកធ្វើនេះក៏សមគួរដល់ពួកយើង ។

(៣០២) ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុអ្នកប្រព្រឹត្តតាមអម្បូលនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ភិក្ខុដទៃទៀត (ក្រៅពីសង្ឃភេទកភិក្ខុនោះ) ។ ពួកភិក្ខុដែលបានឃើញបានឮតម្រូវពោលថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងនេះ

ន ចេសោ ភិក្ខុ ធម្មវាទី ន ចេសោ ភិក្ខុ វិនយវាទី មា អាយស្មន្តានម្បិ សង្ឃភេទោ រុច្ចិត្ថ សមេតាយស្មន្តានំ សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ តេ ភិក្ខូ សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វា មា អាយស្មន្តោ ឯវំ អវចុត្ថ ន ចេសោ ភិក្ខុ ធម្មវាទី ន ចេសោ ភិក្ខុ វិនយវាទី មា អាយស្មន្តានម្បិ សង្ឃភេទោ រុច្ចិត្ថ សមេតាយស្មន្តានំ សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជន្តិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជន្តិ អាបត្តិ ទុក្កដស្ស ។



ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ទេ ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យទេ សូមលោកម្ចាស់ទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោលជាគំរប់ពីរដងផង ត្រូវពោលជាគំរប់បីដងផង ។ បើពួកភិក្ខុទាំងនោះលះបង់រឿងនោះបាន ការលះបង់បានយ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ពួកភិក្ខុឯទៀតឮហើយមិនពោលហាមប្រាម ត្រូវអាបត្តិទុក្កដដែរ ។ ភិក្ខុទាំងឡាយត្រូវនាំភិក្ខុទាំងនោះមកកាន់កណ្តាលជំនុំសង្ឃ ហើយពោលហាមថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ទេ ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យទេ សូមលោកម្ចាស់ទាំងឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយគប្បីពោលហាមជាគំរប់ពីរដងផង ជាគំរប់បីដងផង ។ បើលោកទាំងនោះលះបង់រឿងនោះបាន ការលះបង់បាននេះ ជាការឥតទោស បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

[៣០៣] តេ ភិក្ខូ ភិក្ខូហិ សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខូ ឥត្ថន្នាមស្ស ភិក្ខុនោ សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា វគ្គវាទកា ។ តេ តំ វត្ថុំ នប្បដិនិស្សជ្ជន្តិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខូ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខូ ឥត្ថន្នាមស្ស ភិក្ខុនោ សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា វគ្គវាទកា ។ តេ តំ វត្ថុំ នប្បដិនិស្សជ្ជន្តិ ។ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខូ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច ភិក្ខូនំ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ



[៣០៣] ភិក្ខុទាំងឡាយគប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុទាំងនោះ គឺភិក្ខុសង្ឃគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឈ្លាសប្រតិពលគប្បីផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះឯនេះផង ឈ្មោះឯនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះឯនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ហើយជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះមិនលះបង់វត្ថុនោះទេ ។ បើសមនុភាសនកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុមានឈ្មោះឯនេះផង ឈ្មោះឯនេះផង ដើម្បីឲ្យលះបង់នូវវត្ថុនោះចេញ ។ ពាក្យនេះសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះឯនេះផង ឈ្មោះឯនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះឯនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះមិនលះបង់នូវវត្ថុនោះទេ ។ សង្ឃសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះឯនេះផង មានឈ្មោះឯនេះផង ដើម្បីឲ្យលះបង់នូវវត្ថុនោះ ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះឯនេះផង ឈ្មោះឯនេះផង ដើម្បីឲ្យលះបង់នូវវត្ថុនោះ សមគួរដល់លោកម្ចាស់អង្គណា

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខូ ឥត្ថន្នាមស្ស ភិក្ខុនោ សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា វគ្គវាទកា ។ តេ តំ វត្ថុំ នប្បដិនិស្សជ្ជន្តិ ។ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខូ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច ភិក្ខូនំ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សមនុភដ្ឋា សង្ឃេន ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច ភិក្ខូ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។



សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្មតាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ការសូត្រសមនុភាសនកម្មតាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ សមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង គឺព្រះសង្ឃបានសូត្រសមនុភាសនកម្មរួចហើយ ដើម្បីឲ្យលះបង់នូវរឿងនោះ ។ (សមនុភាសនកម្មនោះ) សមគួរដល់សង្ឃ ហេតុនោះ ព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

(៣០៤) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តានំ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។ ទ្វេ តយោ ឯកតោ សមនុភាសិតព្វា តទុត្តរិ ន សមនុភាសិតព្វា ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(៣០៥) ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជន្តិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា នប្បដិនិស្សជ្ជន្តិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ



(៣០៤) (កាលសង្ឃ)សូត្រញត្តិចប់(ភិក្ខុទាំងនោះ)ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាពីរចប់ ភិក្ខុទាំងនោះ ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ)សូត្រកម្មវាចាចប់ (ភិក្ខុទាំងនោះ) ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុទាំងនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុទាំងនោះត្រូវក្នុងខណៈចប់ញត្តិក្តី នឹងអាបត្តិថុល្លច្ច័យទាំងពីរដែលភិក្ខុទាំងនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏រម្ងាប់ទៅឯង ។ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមប្រាមភិក្ខុពីរ (រូប) ឬ ៣ រូបក៏បានជាមួយគ្នាបាន បើភិក្ខុច្រើនជាងចំនួននោះឡើងទៅ សង្ឃមិនគប្បីសូត្រទេ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយដូចក្នុងសិក្ខាបទទី ១ ខាងដើមរួចហើយ ។

(៣០៥) ភិក្ខុទាំងឡាយ(ជាអ្នកប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ) មានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ថា កម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ចោល (គំនិតប្រព្រឹត្តដែល) ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យក្នុងកម្មដែលត្រូវតាមធម៌ តែមិនលះបង់ចោល ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់

អធម្មកម្មសញ្ញី នប្បដិនិស្សជ្ជន្តិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣០៦] អនាបត្តិ អសមនុភាសន្តស្ស បដិនិស្សជ្ជន្តស្ស ឧម្មត្តកស្ស ខិត្តចិត្តស្ស វេទនដ្ដស្ស អាទិកម្មិកស្សាតិ ។

ឯកាទសមសង្ឃាទិសេសំ និដ្ឋិតំ ។



ក្នុងកម្មដែលត្រូវតាមធម៌ថា កម្មមិនត្រូវតាមធម៌វិញ តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុទាំងនោះមានសេចក្ដីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ថាកម្មត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះមានសេចក្ដីសង្ស័យក្នុងកម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះមានសេចក្ដីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ថា កម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដដែរ ។

[៣០៧] អាបត្តិមិនមានដល់ពួកភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ពួកភិក្ខុដែលបានលះបង់ ដល់ពួកភិក្ខុឆ្កួត ដល់ពួកភិក្ខុមានចិត្តរវើរវាយ ដល់ពួកភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ពួកភិក្ខុជាអាទិកម្មិក ។

សង្ឃាទិសេសទី ១១ ចប់ ។

# ទ្វាទសមសង្ឃាទិសេសំ

(៣១៧) តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អនាចារំ អាចរតិ ។ ភិក្ខូ ឯវមាហំសុ មា អាវុសោ ឆន្ន ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ សោ ឯវំ វទេតិ កឹ នុ ខោ នាម តុម្ហេ អាវុសោ មំ វត្តព្វំ មញ្ញថ អហំ ខោ នាម តុម្ហេ វទេយ្យំ អម្ហាកំ ពុទ្ធោ អម្ហាកំ ធម្មោ អម្ហាកំ អយ្យបុត្តេន ធម្មោ អភិសមិតោ សេយ្យថាបិ នាម មហាវាតោ វាយន្តោ តិណកដ្ឋបណ្ណសដំ(១) ឯកតោ ឧស្សារេយ្យ(២) សេយ្យថាបិ វា បន នទី បព្វតេយ្យា សង្ខសេវាលបណកំ ឯកតោ ឧស្សារេយ្យ ឯវមេវ តុម្ហេ នានានាមា នានាគោត្តា នានាជច្ចា នានាកុលា បព្វជិតា ឯកតោ ឧស្សារិតា(៣) កឹ នុ ខោ នាម តុម្ហេ អាវុសោ មំ វត្តព្វំ មញ្ញថ អហំ ខោ នាម

១ ឱ. ម. តិណកដ្ឋបណ្ណសដំ ។ ២ ឧស្សារេយ្យ ។ ៣ ម. ឱ. ឧស្សារិតា ។

# សង្ឃាទិសេសទី ១២

(៣១៧) សម័យនោះ ព្រះសម្ពុទ្ធមានព្រះភាគ ទ្រង់ប្រថាប់នៅឃោសិតារាម ក្បែរក្រុងកោសម្ពី ។ សម័យនោះឯង ឆន្នភិក្ខុធ្វើមារយាទប្រព្រឹត្តអនាចារ (មារយាទមិនសមគួរផ្សេងៗ) ។ ភិក្ខុទាំងឡាយពោលប្រដៅយ៉ាងនេះថា ម្នាលអាវុសោឆន្ន លោកកុំធ្វើអំពើមានសភាពយ៉ាងនេះ អំពើនេះមិនសមគួរទេ ។ ឆន្នភិក្ខុនោះឆ្លើយតបវិញថា អាវុសោ លោកទាំងឡាយសំគាល់ថា លោកគួរតែពោលប្រដៅខ្ញុំ ខ្ញុំឯងទេតើ ខ្ញុំគួរប្រដៅលោកទាំងឡាយ (ព្រោះថា) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្តរបស់យើង បានត្រាស់ដឹងនូវព្រះធម៌ ដូចខ្យល់ព្យុះធំបក់បោកប្រមូលយកស្មៅ កំណាត់ឈើ ស្លឹកឈើទំនង សំណាត់មកគរមូលជាមួយគ្នា ម្យ៉ាងដូចជា ទឹកស្ទឹងដែលហូរចុះពាក់ភ្នំតែង ប្រមូលស្តូបយកខ្យងចកសារាយទឹមចកធ្លាយ មកគរជាមួយគ្នាបាន មានឧបមាយ៉ាងណាមិញ លោកទាំងឡាយមានឈ្មោះផ្សេងៗ មានគោត្រផ្សេងៗ មានជាតិផ្សេងៗ ចេញចាកត្រកូលផ្សេងៗ ហើយបួស តែងប្រមូលមកឡើមូលត្រកូលគ្នា ក៏មានឧបមេយ្យដូច្នោះឯង រីឯអាវុសោទាំងឡាយ លោកទាំងឡាយនៅសំគាល់ថា លោកគួរតែពោលប្រដៅខ្ញុំ ខ្ញុំឯងទេតើ

តុម្ហេ វទេយ្យំ អម្ហាកំ ពុទ្ធោ អម្ហាកំ ធម្មោ អម្ហាកំ អយ្យបុត្តេន ធម្មោ អភិសមិតោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុច្ចកា សិក្ខាកាមា តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតា-បេត្វា អាយស្មន្តំ ឆន្នំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឆន្ន ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស ។ បេ ។ អករណីយំ កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ



ទើបត្រូវប្រដៅលោកទាំងឡាយ (ព្រោះថា) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្ររបស់យើងបានត្រាស់ដឹងនូវព្រះធម៌ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីខ្មាសបាប មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សា ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុទាំងឡាយពោលប្រដៅដោយធម៌ ឬដោយសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្ត មិនសម្បីបើនឹងធ្វើខ្លួនឲ្យគេពោលប្រដៅមិនបាន ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឆន្ន-ភិក្ខុដ៏មានអាយុក្នុងវេលានោះថា ឆន្ន ឮថា អ្នកឯង កាលពួកភិក្ខុពោលប្រដៅដោយធម៌ ត្រឡប់ធ្វើខ្លួនឲ្យគេប្រដៅមិនបានវិញ មែនឬ ។ ឆន្ន-ភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធអ្នកមានឥស្សរិយយសទ្រង់តិះដៀលថា ម្នាលមោឃបុរស មិនចំនឹងសោះ ។ បេ ។ មិនគួរធ្វើសោះ ម្នាលមោឃបុរស ហេតុម្តេចបានជាអ្នកឯង កាលពួកភិក្ខុពោលប្រដៅដោយធម៌ (ត្រឡប់) ជាធ្វើខ្លួនឲ្យគេពោលប្រដៅមិនបានទៅវិញ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុ បនេវ ទុព្វចជាតិកោ ហោតិ ឧទ្ទេសបរិយាបន្នេសុ សិក្ខាបទេសុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោតិ មា មំ អាយស្មន្តោ កិញ្ចិ អវចុត្ថ កល្យាណំ វា បាបកំ វា អហម្បាយស្មន្តេ ន កិញ្ចិ វក្ខាមិ កល្យាណំ វា បាបកំ វា វិរមថាយស្មន្តោ មម វចនាយាតិ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាយស្មា អត្តានំ អវចនីយំ អកាសិ វចនីយមេវ អាយស្មា អត្តានំ ករោតុ អាយស្មាបិ ភិក្ខូ វទេតុ សហធម្មេន ភិក្ខូបិ អាយស្មន្តំ វក្ខន្តិ សហធម្មេន ឯវំ សំវទ្ធា ហិ តស្ស ភគវតោ បរិសា យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋាបនេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ យាវតតិយញ្ចេ



អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុមានជាតិដែលគេប្រដៅក្រ កាលភិក្ខុទាំងឡាយពោលប្រដៅ (ខ្លួន) ដោយធម៌ក្នុងសិក្ខាបទទាំងឡាយដែលរាប់បញ្ចូលក្នុងឧទ្ទេស (បាដិមោក្ខ) ធ្វើខ្លួនឲ្យគេប្រដៅមិនបាន ដោយពាក្យថា លោកម្ចាស់ទាំងឡាយ លោកកុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ចំណែកខ្ញុំក៏នឹងមិនពោលពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងលោកម្ចាស់ទាំងឡាយដែរ បពិត្រលោកម្ចាស់ទាំងឡាយ ចូរលោកឈប់និយាយប្រដៅខ្ញុំចុះ ។ ភិក្ខុនោះត្រូវភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេប្រដៅមិនបានឡើយ លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេពោលប្រដៅបានវិញ ចំណែកលោកម្ចាស់ ចូរប្រដៅភិក្ខុទាំងឡាយដោយសហធម៌ (ក្នុងបញ្ញត្តិ) សូម្បីពួកភិក្ខុក៏ពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិស័ទរបស់ព្រះដ៏មានព្រះភាគអម្ចាស់នោះ រីកចំរើនឡើងដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា នឹងដោយញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិយ៉ាងនេះ ។ កាលភិក្ខុទាំងឡាយពោលប្រដៅភិក្ខុនោះយ៉ាងនេះ (ភិក្ខុនោះ)គឺនៅប្រកាន់យ៉ាងហ្នឹងដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ហាម) ដរាបដល់បីដង ដើម្បីឲ្យលះបង់នូវកម្មនោះ

សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោតិ ។

(៣០៨) ភិក្ខុ បនេវ ទុព្វចជាតិកោ ហោតីតិ ទុព្វចោ ហោតិ ទោវចស្សករណេហិ ធម្មេហិ សមន្នាគតោ អក្ខមោ អប្បទក្ខិណគ្គាហី អនុសាសនឹ ។ ឧទ្ទេសបរិយាបន្នេសុ សិក្ខាបទេសូតិ បាតិមោក្ខបរិយាបន្នេសុ សិក្ខាបទេសុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ សហធម្មិកំ នាម យំ ភគវតា បញ្ញត្តំ សិក្ខាបទំ ឯតំ សហធម្មិកំ នាម ។ តេន វុច្ចមានោ អត្តានំ អវចនីយំ ករោតិ មា មំ អាយស្មន្តោ កិញ្ចិ អវចុត្ថ កល្យាណំ វា បាបកំ វា អហម្បាយស្មន្តេ ន កិញ្ចិ វក្ខាមិ កល្យាណំ វា បាបកំ វា វិរមថាយស្មន្តោ មម វចនាយាតិ ។



បើភិក្ខុនោះ កាលពួកភិក្ខុសូត្រសមនុភាសនកម្មដល់គំរប់បីដង ហើយលះបង់រឿងនោះបាន ការលះបង់បាននុ៎ះ ជាការប្រពៃ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

(៣០៨) ត្រង់ពាក្យថា ភិក្ខុមានជាតិដែលគេប្រដៅក្រ គឺជាអ្នកដែលគេស្តីប្រដៅបានដោយក្រ ប្រកបដោយធម៌ជាហេតុធ្វើឲ្យប្រដៅក្រ មិនអត់ធន់ មិនកាន់យកពាក្យប្រៀនប្រដៅដោយខាងស្តាំ (មិនកាន់យកពាក្យប្រៀនប្រដៅដោយគោរព) ។ ពាក្យថា ក្នុងសិក្ខាបទទាំងឡាយដែលរាប់បញ្ចូលក្នុងឧទ្ទេស គឺក្នុងសិក្ខាបទទាំងឡាយ ដែលរាប់បញ្ចូលក្នុងបាតិមោក្ខ ។ ពាក្យថា ពួកភិក្ខុ គឺភិក្ខុទាំងឡាយដទៃ ។ បទដែលឈ្មោះថា សហធម្ម៌ គឺសិក្ខាបទណាដែលព្រះដ៏មានព្រះភាគបញ្ញត្តហើយ សិក្ខាបទនេះឈ្មោះថា សហធម្ម៌ ។ ភិក្ខុនោះកាលគេស្តីប្រដៅដោយសហធម៌នោះ ក៏ធ្វើខ្លួនជាអ្នកមិនឲ្យគេស្តីប្រដៅបាន ដោយពាក្យថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តីនឹងខ្ញុំ ចំណែកខ្ញុំក៏មិននិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តីនឹងពួកលោកម្ចាស់ សូមពួកលោកម្ចាស់វៀរចាកការពោលប្រដៅខ្ញុំ ។

តេរសកណ្ឌំ ទ្វាទសមសង្ឃាទិសេសស្ស សិក្ខាបទវិភង្គោ

(៣០៩) សោ ភិក្ខូតិ យោ សោ ទុព្វចជាតិកោ ភិក្ខុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ មា អាយស្មា អត្តានំ អវចនីយំ អកាសិ វចនីយមេវ អាយស្មា អត្តានំ ករោតុ អាយស្មាបិ ភិក្ខូ វទេតុ សហធម្មេន ភិក្ខូបិ អាយស្មន្តំ វក្ខន្តិ សហធម្មេន ឯវំ សំវឌ្ឍា ហិ តស្ស ភគវតោ បរិសា យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋាបនេនាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សោ ភិក្ខុ សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វោ មា អាយស្មា អត្តានំ អវចនីយំ អកាសិ



តេរសកណ្ឌ សង្ឃាទិសេសទី ១២ ការពន្យល់សិក្ខាបទ

(៣០៩) ពាក្យថា ភិក្ខុនោះ គឺភិក្ខុមានជាតិដែលគេប្រដៅបានដោយក្រនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ ។ មានអធិប្បាយថា ពួកភិក្ខុណាឃើញ ពួកភិក្ខុណាបានស្តាប់ (ដំណឹង) ពួកភិក្ខុទាំងនោះត្រូវពោលថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេស្តីប្រដៅបាន សូម្បីលោកម្ចាស់សោតចូរពោលប្រដៅភិក្ខុទាំងឡាយដោយសហធម៌ សូម្បីភិក្ខុទាំងឡាយក៏នឹងពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះរីកចំរើនឡើងដោយហេតុយ៉ាងនេះ គឺដោយកិរិយាពោលប្រដៅគ្នានិងគ្នា ដោយញ៉ាំងគ្នានិងគ្នាឲ្យចេញចាកអាបត្តិ ។ ភិក្ខុនោះត្រូវភិក្ខុទាំងឡាយពោល (ហាម) ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននុ៎ះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយបានឮហើយមិនពោល (ហាម) ត្រូវអាបត្តិទុក្កដដែរ ។ ភិក្ខុទាំងឡាយគប្បីទាញភិក្ខុនោះមកកាន់កណ្តាលប្រជុំសង្ឃ ហើយពោល (ហាម) ថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន

វចនីយមេវ អាយស្មា អត្តានំ ករោតុ អាយស្មាបិ ភិក្ខូ វទេតុ សហធម្មេន ភិក្ខូបិ អាយស្មន្តំ វក្ខន្តិ សហធម្មេន ឯវំ សំវឌ្ឍា ហិ តស្ស ភគវតោ បរិសា យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋាបនេនាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣១១] សោ ភិក្ខុ សមនុភាសិតព្វោ ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោតិ ។ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសេយ្យ



លោកម្ចាស់ចូរធ្វើខ្លួនឲ្យគេស្តីប្រដៅបានផង សូម្បីលោកម្ចាស់សោតក៏ចូរគោរពប្រដៅពួកភិក្ខុដោយសហធម៌ ចំណែកពួកភិក្ខុទាំងឡាយក៏នឹងគោរពប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិស័ទរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះ តែងចំរើនដោយអាការយ៉ាងនេះ គឺដោយការនិយាយពោលពាក្យ ដាស់ប្រដៅគ្នានឹងគ្នា ដោយការញ៉ាំងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោលហាមជាគំរប់ពីរដងផង ត្រូវពោលហាមជាគំរប់បីដងផង ។ បើភិក្ខុលះបង់បាន ការលះបង់យ៉ាងនេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

[៣១០] ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុត្រូវសូត្រសមនុភាសនកម្មយ៉ាងនេះ ។ ភិក្ខុដែលឆ្លាសអង់អាច គប្បីប្រកាសឲ្យសង្ឃដឹងដោយវាចាថា បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ កាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ ត្រឡប់ធ្វើខ្លួនមិនឲ្យគេស្តីប្រដៅបានវិញ ។ ភិក្ខុនោះមិនលះបង់វត្ថុនោះទេ ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ ព្រះសង្ឃគប្បីសូត្រសមនុភាសនកម្ម(ហាម)

តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោតិ ។ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ ករោតិ ។ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា



ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ ។ នេះជាញត្តិ (គឺការប្រកាសឲ្យសង្ឃដឹង) ។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ត្រឡប់ជាធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ ។ ការសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីផង ។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ កាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ នៅធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ការសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ

តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សមនុភដ្ឋោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤១១) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។ សង្ឃាទិសេសោតិ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(៤១២) ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកោ



គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ភិក្ខុមានឈ្មោះនេះ នឹងត្រូវសង្ឃបានសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់រឿងនោះ ។ សមនុភាសនកម្មនោះ គាប់ចិត្តដល់ព្រះសង្ឃ ហេតុនោះ ព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

[៣១១] (កាលសង្ឃ) សូត្រញត្តិចប់ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាពីរដង (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុនោះ) ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី នឹងអាបត្តិថុល្លច្ច័យពីរទៀតដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏រងាប់ទៅឯង ។ ពាក្យថា អាបត្តិសង្ឃាទិសេស មានសេចក្តីប្រាយដូចក្នុងសិក្ខាបទខាងដើមនោះហើយ ។

(៣១២) ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលប្រកបដោយធម៌ថា កម្មប្រកបដោយធម៌ រួចមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មដែលប្រកបដោយធម៌

នបដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី នបដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

(៣១៣) អនាបត្តិ អសមនុភាសន្តស្ស បដិនិស្សជ្ជន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទ្វាទសមសង្ឃាទិសេសំ និដ្ឋិតំ ។



មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដដែរ ។

(៣១៣) អាបត្តិមិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុលះបង់ស្រឡះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សង្ឃាទិសេស ទី១២ ចប់ ។

# តេរសមសង្ឃាទិសេសំ

[៣១៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អស្សជិបុនព្វសុកា នាម កីដា-គិរិស្មឹ អាវាសិកា ហោន្តិ អលជ្ជិនោ បាបភិក្ខូ ។ តេ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិនាបេន្តិបិ គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធុតិកំ ករោន្តិបិ ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការាបេន្តិបិ ។

# សង្ឃាទិសេសទី ១៣

(៣១៤) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានបុណ្យសិរី គង់នៅក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុពីររូបឈ្មោះអស្សជិនិងបុនព្វសុកៈជាអ្នកនៅក្នុងអាវាសទៀបកិដាគិរីជនបទ ជាភិក្ខុលាមកឥតខ្មាស ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចទឹកឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើជាកម្រងចង្កោម(១)ឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើដែលដោតជាបន្ទោង(២)ឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។

---

១ តាមអដ្ឋកថា ថាធ្វើជា ក្បាច់ផ្កាផ្សេងៗដែលគេធ្វើឡើងជាចង្កោមដែលមានទងតែ ១ ។ ២ ក្នុងអដ្ឋកថា ថាផ្កាកម្រងដែលគេដោតដោយម្ជុល ឬក៏ទ្រនុង ។

តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុលសុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរន្តិបិ ហារាបេន្តិបិ ឧភតោវណ្ដិកមាលំ ហរន្តិបិ ហារាបេន្តិបិ មញ្ជរិកំ ហរន្តិបិ ហារាបេន្តិបិ វិធុតិកំ ហរន្តិបិ ហារាបេន្តិបិ វដំសកំ ហរន្តិបិ ហារាបេន្តិបិ អាវេឡំ ហរន្តិបិ ហារាបេន្តិបិ ឧរច្ឆទំ ហរន្តិបិ ហារាបេន្តិបិ ។ តេ កុលិត្ថីហិ កុលធីតាហិ កុលកុមារីហិ កុលសុណ្ហាហិ កុលទាសីហិ សទ្ធឹ ឯកភាជនេបិ ភុញ្ជន្តិ ឯកថាលកេបិ បិវន្តិ ឯកាសនេបិ និសីទន្តិ ឯកមញ្ចេបិ តុវដ្ដេន្តិ ឯកត្ថរណាបិ តុវដ្ដេន្តិ ឯកបាវុរណាបិ[១] តុវដ្ដេន្តិ ឯកត្ថរណបាវុរណាបិ តុវដ្ដេន្តិ វិកាលេបិ ភុញ្ជន្តិ មជ្ជំបិ បិវន្តិ មាលាគន្ធវិលេបនំបិ ធារេន្តិ នច្ចន្តិបិ គាយន្តិបិ

១ ឧត្តរំ បោត្ថកេ ឯកប្បាវុរណ ទិស្សតិ ។



អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើជាកម្រងចងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើដែលគេធ្វើជាបង្កើមទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះឆាន់ (ភោជន) ក្នុងភាជន៍មួយ ជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយខ្លះ ផឹក (ទឹក) ក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្ដប់ជាមួយគ្នាខ្លះ ដេកលើកម្រាលនិងដណ្ដប់ជាមួយគ្នាខ្លះ ស៊ីខុសវេលាខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់នូវផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ

វាទេន្តិបិ លាសេន្តិបិ នច្ចន្តិយាបិ នច្ចន្តិ នច្ចន្តិយាបិ គា-យន្តិ នច្ចន្តិយាបិ វាទេន្តិ នច្ចន្តិយាបិ លាសេន្តិ គាយន្តិ-យាបិ នច្ចន្តិ គាយន្តិយាបិ គាយន្តិ គាយន្តិយាបិ វាទេន្តិ គាយន្តិយាបិ លាសេន្តិ វាទេន្តិយាបិ នច្ចន្តិ វាទេន្តិយាបិ គាយន្តិ វាទេន្តិយាបិ វាទេន្តិ វាទេន្តិយាបិ លាសេន្តិ លាសេន្តិយាបិ នច្ចន្តិ លាសេន្តិយាបិ គាយន្តិ លា-សេន្តិយាបិ វាទេន្តិ លាសេន្តិយាបិ លាសេន្តិ អដ្ឋបទេបិ កីឡន្តិ ទសបទេបិ កីឡន្តិ អាកាសេបិ កីឡន្តិ បរិហារបថេបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិ-កាយបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាក-ហត្ថេនបិ កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ[1] កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កី-ឡន្តិ ចិង្គុលកេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ

១ ម. យ. បង្កចីរេនបិ ។



ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡាប្រាំបី[1]ខ្លះ លេងបាស្កាមានក្រ-ឡាដប់[2]ខ្លះ លេងបាស្កាក្នុងអាកាស[3]ខ្លះ លេងផ្លូវកន្លែងដែលខ្លួនគូរ[4]ខ្លះ លេងដាក់គ្រាប់មានក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងចំហ៊ីងខ្លះ លេងទះដៃយកពណ៌សំគាល់ឲ្យទាយរូបខ្លះ លេងសន្ទាញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងតាំផ្ទួនខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ ([illegible]) ខ្លះ

១ បន្ទះមានក្រឡា ៨ ។ ២ បន្ទះមានក្រឡា ១០ ន័យខ្លះប្រែថា [illegible] ។ ៣ បន្ទះគ្មានក្ដារ លេងតែមាត់ទទេ ។ ៤ ប្រហែលជាលេង [illegible] ។

រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ ហត្ថិស្មឹម្បិ សិក្ខន្តិ អស្សស្មឹម្បិ សិក្ខន្តិ រថស្មឹម្បិ សិក្ខន្តិ ធនុស្មឹម្បិ សិក្ខន្តិ ថរុស្មឹម្បិ សិក្ខន្តិ ហត្ថិស្សបិ បុរតោ ធាវន្តិ អស្សស្សបិ បុរតោ ធាវន្តិ រថស្សបិ បុរតោ ធាវន្តិ ធាវន្តិបិ អាធាវន្តិបិ ឧស្សេឡេន្តិបិ អប្ផោដេន្តិបិ និព្ពុជ្ឈន្តិបិ មុដ្ឋីហិបិ យុជ្ឈន្តិ រង្គមជ្ឈេបិ សង្ឃាដឹ បត្ថរិត្វា នច្ចន្តឹ(១) ឯវំ វទន្តិ(២) ឥធ ភគិនិ នច្ចស្សូតិ នលាដិកម្បិ ទេន្តិ វិវិធម្បិ អនាចារំ អាចរន្តិ ។

(៣០៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កាសីសុ វស្សំវុត្ថោ សាវត្ថឹ គច្ឆន្តោ ភគវន្តំ ទស្សនាយ យេន កីដាគិរិ តទវសរិ ។ អថខោ សោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កីដាគិរឹ បិណ្ឌាយ បាវិសិ បាសាទិកេន អភិក្កន្តេន បដិក្កន្តេន អាលោកិតេន វិលោកិតេន សម្មិញ្ជិតេន បសារិតេន ឱក្ខិត្តចក្ខុ ឥរិយាបថសម្បន្នោ ។ មនុស្សា

១. ឱ. ម. នច្ចកឹ ។ ២. ឱ. ម. វទន្តិ ។



លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរលើខ្យល់ទាយខ្លះ លេងទាយចិត្ត (ស្មុគចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់ដំរីខ្លះ ហាត់សេះខ្លះ ហាត់រថខ្លះ ហាត់ធ្នូខ្លះ ហាត់ជន់មាឌដង់ដាវដើមខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលវេទិកា ហើយនិយាយនឹងស្រីដែលរាំ យ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះខ្លះ ដាក់ម្រាមដៃលើថ្ងាសអ្នកនិងលើថ្ងាសស្រីរាំខ្លះ ប្រព្រឹត្តអនាចារផ្សេង ៗ ខ្លះ ។

(៣០៨) សម័យនោះឯង ភិក្ខុមួយរូបចាំវស្សាក្នុងដែនឈ្មោះកាសី រួចហើយទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរទៅត្រង់កិដាគិរីជនបទ ។ ភិក្ខុនោះឯង ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាព្រឹកព្រហាម មានដំណើរឈានទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលចំហៀង បត់ចូលនិងលាចេញ គួរជាទីជ្រះថ្លា ព្រោះភិក្ខុអង្គនោះមានភ្នែកសម្លឹងចុះនិងមានឥរិយាបថបរិបូណ៌ ចូលទៅកាន់កិដាគិរីជនបទ ដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយ

តំ ភិក្ខុំ បស្សិត្វា ឯវមាហំសុ ក្វាយំ អពលពលោ[១] វិយ មន្ទមន្ទោ វិយ ភាកុដិកភាកុដិកោ វិយ កោ ឥមស្ស ឧបគតស្ស បិណ្ឌម្បិ ទស្សតិ អម្ហាកំ បន អយ្យា អស្សជិបុនព្វសុកា សណ្ហា សខិលា សុខសម្ភាសា មិហិតបុព្វង្គមា ឯហិស្វាគតវាទិនោ អព្ភាកុដិកា ឧត្តានមុខា បុព្វភាសិនោ តេសំ ខោ នាម បិណ្ឌោ ទាតព្វោតិ ។ អទ្ទសា ខោ អញ្ញតរោ ឧបាសកោ តំ ភិក្ខុំ កីដាគិរិស្មឹ បិណ្ឌាយ ចរន្តំ ទិស្វាន យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯតទវោច អបិ ភន្តេ បិណ្ឌោ លព្ភតីតិ ។ ន ខោ អាវុសោ បិណ្ឌោ លព្ភតីតិ ។ ឯហិ ភន្តេ ឃរំ គមិស្សាមាតិ ។ អថ ខោ សោ ឧបាសកោ តំ ភិក្ខុំ ឃរំ នេត្វា ភោជេត្វា ឯតទវោច កហំ ភន្តេ អយ្យោ គមិស្សតីតិ ។ សាវត្ថឹ ខោ អហំ អាវុសោ គមិស្សាមិ ភគវន្តំ ទស្សនាយាតិ ។ តេនហិ ភន្តេ មម វចនេន ភគវតោ បាទេ សិរសា វន្ទ ឯវញ្ច វទេហិ

១ កក្ខុចំ យោត្តកេ គពក្ខុរក្ខោតិ បាឋោ ទិស្សតិ ។



ឃើញភិក្ខុនោះហើយនិយាយយ៉ាងនេះថា លោកម្ចាស់នេះ ដូចជាស្រឹមហួស ដូចជាទន់ល្មន់ពេក ដូចជាមុខស្រពោនពេក អ្នកណាគេនឹងឲ្យដុំបាយដល់លោកនេះដែលចូលទៅរក (គេនោះ) ចំណែកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុជាម្ចាស់យើង ពោលពាក្យផ្អែម ពោលពាក្យពីរោះ ពោលពាក្យរាបសា មានញញឹមញញែមជាមុន តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ មានមុខមិនស្រពោន មានមុខរើប តែងនិយាយមុន យើងគួរប្រគេនដុំបាយដល់លោកម្ចាស់អស់នោះ ។ ឧបាសកម្នាក់បានឃើញភិក្ខុនោះត្រាច់ទៅក្នុងកិដាគិរីជនបទ ដើម្បីបិណ្ឌបាត លុះឃើញហើយក៏ចូលទៅរកភិក្ខុនោះ ថ្វាយបង្គំហើយនិយាយពាក្យនេះថា មេត្តាប្រោស លោកម្ចាស់បានបាយបិណ្ឌបាតខ្លះដែរឬ ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាត្មាបិណ្ឌបាតមិនបានទេ ។ ឧបាសកនោះនិយាយថា លោកម្ចាស់សូមនិមន្តមក យើងនឹងទៅផ្ទះ ។ ទើបឧបាសកនោះ នាំភិក្ខុនោះទៅផ្ទះ ឲ្យឆាន់ហើយនិយាយពាក្យនេះថា លោកម្ចាស់នឹងនិមន្តទៅក្នុងទីណា ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ ឧបាសកនោះពោលថា បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទនៃព្រះដ៏មានព្រះភាគដោយត្បូង តាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបទូលយ៉ាងនេះថា

ទុដ្ឋោ ភន្តេ កីដាគិរិស្មឹ អាវាសោ អស្សជិបុ-នព្វសុកា នាម កីដាគិរិស្មឹ អាវាសិកា អលជ្ជិនោ បាបភិក្ខូ តេ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិនាបេន្តិបិ គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិក(១)មា-លំ ករោន្តិបិ ការាបេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ ។បេ។ វិវិធម្បិ អនាចារំ អាចរន្តិ យេបិ តេ ភន្តេ មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទានបថានិ តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូ សាធុ ភន្តេ ភគវា កីដាគិរឹ ភិក្ខូ បហិណេយ្យ យថាយំ កីដាគិរិស្មឹ អាវាសោ សណ្ឋហេយ្យាតិ ។ ឯវមាវុសោតិ ខោ សោ ភិក្ខុ តស្ស ឧបាសកស្ស បដិស្សុត្វា(២) យេន សាវត្ថី តេន បក្កាមិ អនុបុព្វេន យេន សាវត្ថី ជេតវនំ

១ កត្ថចិ ឯកតោវណ្ណិកន្តិ បាឋោ ទិស្សតិ ។ ២ ឥតោ បរំ [illegible] ទិស្សតិ ។



សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកីដាគិរីជនបទខូចហើយ ព្រោះភិក្ខុឈ្មោះអស្សជិនិងភិក្ខុឈ្មោះបុនព្វសុក ជាអ្នកនៅអាវាស ក្នុងកីដាគិរីជនបទជាភិក្ខុលាមកឥតខ្មាស ភិក្ខុទាំងឡាយនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងៗ ទៀត សូមទ្រង់ព្រះមេត្តាប្រោស ពួកមនុស្សណា មានសទ្ធាជ្រះថ្លាក្នុងកាលមុន ឥឡូវនេះមនុស្សអស់នោះគ្មានសទ្ធាមិនជ្រះថ្លាហើយ ទានបថណាមួយ (ដែលគេធ្លាប់ឲ្យ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះទានបថនោះ គេលែងឲ្យហើយ ភិក្ខុមានសីលជាទីស្រឡាញ់ក៏នាំគ្នាថយ នៅតែពួកភិក្ខុលាមក សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ បញ្ជូនពួកភិក្ខុទៅកីដាគិរីជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកីដាគិរីជនបទនេះរៀបរយល្អឡើងវិញ ។ ភិក្ខុនោះទទួលស្តាប់ពាក្យឧបាសកនោះហើយថា អើអាវុសោ រួចចៀសចេញទៅកាន់ក្រុងសាវត្ថី

អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

(៣១៦) អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធិំ បដិសម្មោទិតុំ ។ អថខោ ភគវា តំ ភិក្ខុំ ឯតទវោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ អប្បកិលមថេន អទ្ធានំ អាគតោ កុតោ ច ត្វំ ភិក្ខុ អាគច្ឆសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា អប្បកិលមថេន ចាហំ ភន្តេ អទ្ធានំ អាគតោ ឥធាហំ ភន្តេ កាសីសុ វស្សំ វុដ្ឋោ សាវត្ថិំ អាគច្ឆន្តោ ភគវន្តំ ទស្សនាយ យេន កីដាគិរិ តទវសរឹ អទ្ធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមា-ទាយ កីដាគិរិំ បិណ្ឌាយ បាវិសឹ អទ្ទសា ខោ មំ



អោយសំដៅ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងវត្តព្រះជេតពនជារបស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី លុះចូលទៅហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

(៣១៦) ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ព្រះអង្គតែងធ្វើសេចក្តីរីករាយជាមួយនឹងភិក្ខុជាអាគន្តុកទាំងឡាយយ៉ាងនេះ ។ ហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ សរីរយន្តអ្នកល្មមអត់ធន់បានឬទេ អ្នកល្មមប្រព្រឹត្តទៅបានស្រួលទេ [1] អ្នកមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេឬ ម្យ៉ាងទៀត អ្នកដើរចេញមកពីទីណា ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សរីរយន្តខ្ញុំព្រះអង្គល្មមអត់ធន់បាន ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបានស្រួលទេ បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀតខ្ញុំព្រះអង្គមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនៅចាំវស្សាក្នុងដែនកាសីនេះ ហើយមកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ បានដើរទៅត្រង់កិដាគិរីជនបទ បពិត្រព្រះអង្គដ៏ចំរើន ក្នុងគ្រានោះ ខ្ញុំព្រះអង្គ ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនឹងចីវរចូលទៅកាន់កិដាគិរីជន-បទ ដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាម សូមទ្រង់ព្រះមេត្តាប្រោស

---

១ សួរសុខទុក្ខ ។

ភន្តេ អញ្ញតរោ ឧបាសកោ កីដាគិរិស្មឹ បិណ្ឌាយ ចរន្តំ ទិស្វាន យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯតទវោច អបិ ភន្តេ បិណ្ឌបាតោ លទ្ធោតិ ន ខោ អាវុសោ បិណ្ឌបាតោ លទ្ធោតិ ឯហិ ភន្តេ ឃរំ គមិស្សាមាតិ អថខោ ភន្តេ សោ ឧបាសកោ មំ ឃរំ នេត្វា ភោជេត្វា ឯតទវោច កហំ ភន្តេ អយ្យោ គមិស្សតីតិ សាវត្ថឹ ខោ អហំ អាវុសោ គមិស្សាមិ ភគវន្តំ ទស្សនាយាតិ តេនហិ ភន្តេ មម វចនេន ភគវតោ បាទេ សិរសា វន្ទ ឯវញ្ច វទេហិ ទុដ្ឋោ ភន្តេ កីដាគិរិស្មឹ អាវាសោ អស្សជិបុនព្វសុកា នាម កីដាគិរិស្មឹ អាវាសិកា អលជ្ជិនោ បាបភិក្ខូ តេ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ។បេ។ វិវិធម្បិ អនាចារំ អាចរន្តិ



ឧបាសកម្នាក់ បានឃើញខ្ញុំព្រះអង្គកំពុងត្រាច់ទៅបិណ្ឌបាតក្នុងកីដាគិរីជនបទ លុះឃើញហើយក៏ចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយ ថ្វាយបង្គំខ្ញុំព្រះអង្គ រួចនិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់បានអាហារបិណ្ឌបាតខ្លះឬទេ ខ្ញុំព្រះអង្គនិយាយថា ម្នាលអាវុសោ អាត្មាមិនទាន់បានអាហារបិណ្ឌបាតទេ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ចូរនិមន្តមក យើងនឹងទៅផ្ទះ សូមទ្រង់ព្រះមេត្តាប្រោស ទើបឧបាសកនោះនាំខ្ញុំព្រះអង្គទៅផ្ទះ ហើយឲ្យឆាន់ រួចហើយប្រាប់ពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់នឹងទៅកន្លែងណា ខ្ញុំព្រះអង្គប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ឧបាសកនោះពោលថា បពិត្រលោកដ៏ចំរើន បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទានៃព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ទូលព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកីដាគិរីជនបទ វិនាសខូចអស់ហើយ ព្រោះភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកជាអ្នកនៅអាវាសក្នុងកីដាគិរីជនបទជាភិក្ខុលាមកឥតខ្មាស ភិក្ខុពីររូបនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេស្រោចខ្លះ ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងទៀត

យម្បិ តេ ភន្តេ មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទានបថានិ តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូ សាធុ ភន្តេ ភគវា កីដាគិរឹ ភិក្ខូ បហិណេយ្យ យថាយំ កីដាគិរិស្មឹ អាវាសោ សណ្ឋហេយ្យាតិ តតោ អហំ ភគវ អាគច្ឆាមីតិ ។

(៣១៧) អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ អស្សជិបុនព្វសុកា នាម កីដាគិរិស្មឹ អាវាសិកា អលជ្ជិនោ បាបភិក្ខូ ឯវរូបំ អនាចារំ អាចរន្តិ មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ឱចិនន្តិបិ ឱចិនាបេន្តិបិ គន្ថេន្តិបិ គន្ថាបេន្តិបិ ឯកតោវណ្ដិកមាលំ ករោន្តិបិ ការា-បេន្តិបិ ឧភតោវណ្ដិកមាលំ ករោន្តិបិ ការាបេន្តិបិ



សូមទ្រង់ព្រះមេត្តាប្រោស កាលមុន មនុស្សទាំងឡាយណា ធ្លាប់មានសទ្ធាជ្រះថ្លាហើយ សព្វថ្ងៃនេះមនុស្សអម្បាលនោះ មិនមានសទ្ធា មិនជ្រះថ្លាទេ ទានទាំងឡាយណា ដែលគេយកធ្លាប់ឲ្យ ដល់សង្ឃក្នុងកាលមុន សព្វថ្ងៃនេះទានទាំងនោះ គេឈប់ឲ្យហើយ ភិក្ខុទាំងឡាយមានសីលបរិសុទ្ធស្អាតចៀសចេញទៅ ចំណែកពួកភិក្ខុលាមកក៏នៅ (ក្នុងវត្តនោះ) សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគបញ្ជូនភិក្ខុ (គឺសំណាក់ព្រះអង្គ) ទៅកីដាគិរីជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកីដាគិរីជនបទបានរៀបរយល្អ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងមកពីកីដាគិរីជនបទនោះ ។

(៣១៧) ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុពួកឈ្មោះអស្សជិនិងបុនព្វសុកជាចៅអាវាសក្នុងកីដាគិរីជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុពួកនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ

មញ្ជរិកំ ករោន្តិបិ ការាបេន្តិបិ វិធូតិកំ ករោន្តិបិ ការាបេន្តិបិ វដំសកំ ករោន្តិបិ ការាបេន្តិបិ អាវេឡំ ករោន្តិបិ ការាបេន្តិបិ ឧរច្ឆទំ ករោន្តិបិ ការាបេន្តិបិ ។ បេ ។ វិវិធម្បិ អនាចារំ អាចរន្តិ យេបិ តេ(១) មនុស្សា បុព្វេ សទ្ធា អហេសុំ បសន្នា តេបិ ឯតរហិ អស្សទ្ធា អប្បសន្នា យានិបិ តានិ សង្ឃស្ស បុព្វេ ទានបថានិ តានិបិ ឯតរហិ ឧបច្ឆិន្នានិ រិញ្ចន្តិ បេសលា ភិក្ខូ និវសន្តិ បាបភិក្ខូតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិសានំ ។ បេ ។ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ឯវរូបំ អនាចារំ អាចរិស្សន្តិ មាលាវច្ឆំ រោបេស្សន្តិបិ រោបាបេស្សន្តិបិ សិញ្ចិស្សន្តិបិ សិញ្ចាបេស្សន្តិបិ ឱចិនិស្សន្តិបិ ឱចិនាបេស្សន្តិបិ

---

១ ឱ. យុ. ម. ក. បោត្ថកេសុ ភិក្ខូតិ បាឋោ បញ្ញាយតិ ។



ធ្វើផ្កាឈើជាកម្រងមានទង(១)ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់សិតក្នុងសក់(២)ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ប្រព្រឹត្តអនាចារផ្សេងទៀត មនុស្សទាំងឡាយណា ធ្លាប់មានសទ្ធាជ្រះថ្លាហើយក្នុងកាលមុន ឥឡូវនេះមនុស្សទាំងឡាយនោះ មិនមានសទ្ធាមិនជ្រះថ្លាទេ ទានទាំងឡាយណាដែលពួកគេធ្លាប់ឲ្យដល់សង្ឃក្នុងកាលមុន ឥឡូវនេះទានទាំងនោះ គេឈប់ឲ្យអស់ហើយ ភិក្ខុទាំងឡាយមានសីលស្អាតបរិសុទ្ធចៀសចេញទៅ ចំណែកខាងពួកភិក្ខុលាមកតែងនៅក្នុងទីនោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ រឿងនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះមិនសមគួរទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ម្តេចក៏ពួកមោឃបុរសនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ

---

១ តាមអដ្ឋកថាថាប្រែថា ផ្កាក្បាច់ក្បាលផ្កាដែលគេធ្វើឲ្យខ្ជាប់ជាមួយនឹងទងដែលមានផ្កា ។ ២ ក្នុងអដ្ឋកថាថា ផ្កាកម្រងដែលគេតាក់តែងដោយម្ជុល ឬកន្ទះ ។

គន្ថិស្សន្តិបិ គន្ថាបេស្សន្តិបិ ឯកតោវណ្ដិកមាលំ ករិស្សន្តិបិ ការាបេស្សន្តិបិ ឧភតោវណ្ដិកមាលំ ករិស្សន្តិបិ ការាបេស្សន្តិបិ មញ្ជរិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វិធុតិកំ ករិស្សន្តិបិ ការាបេស្សន្តិបិ វដំសកំ ករិស្សន្តិបិ ការាបេស្សន្តិបិ អាវេឡំ ករិស្សន្តិបិ ការាបេស្សន្តិបិ ឧរច្ឆទំ ករិស្សន្តិបិ ការាបេស្សន្តិបិ តេ កុលិត្ថីនំ កុលធីតានំ កុលកុមារីនំ កុលសុណ្ហានំ កុលទាសីនំ ឯកតោវណ្ដិកមាលំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ ឧភតោវណ្ដិកមាលំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ មញ្ជរិកំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ វិធុតិកំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ វដំសកំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ អាវេឡំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ ឧរច្ឆទំ ហរិស្សន្តិបិ ហរាបេស្សន្តិបិ តេ កុលិត្ថីហិ កុលធីតាហិ កុលកុមារីហិ កុលសុណ្ហាហិ កុលទាសីហិ សទ្ធឹ ឯកភាជនេបិ ភុញ្ជិស្សន្តិ ឯកថាលកេបិ បិវិស្សន្តិ



ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងនៅតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាចាក់ក្រលាទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់សិតក្បិតកន់ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ភិក្ខុទាំងឡាយនោះ នាំផ្កាកម្រងមានទងនៅតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាចាក់ក្រលាទងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាឈើសម្រាប់សិតក្បិតកន់ខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ភិក្ខុទាំងឡាយនោះ ឆាន់ក្នុងភាជន៍មួយជាមួយនឹងពួកស្រីនៃត្រកូល ពួកធីតានៃត្រកូល ពួកកុមារីនៃត្រកូល ពួកស្រីជាកូនប្រសានៃត្រកូល ពួកទាសីនៃត្រកូលខ្លះ ផឹកក្នុងផ្តិលជាមួយគ្នាខ្លះ

ឯកាសនេបិ និសីទន្តស្ស ឯកមញ្ចេបិ តុវដ្ដន្តស្ស ឯកត្ថរណាបិ តុវដ្ដន្តស្ស ឯកបាវុរណាបិ តុវដ្ដន្តស្ស ឯកត្ថរណបាវុរណាបិ តុវដ្ដន្តស្ស វិកាលេបិ ភុញ្ជន្តស្ស មជ្ជំបិ បិវន្តស្ស មាលាគន្ធវិលេបនំបិ ធារេន្តស្ស នច្ចន្តស្សបិ គាយន្តស្សបិ វាទេន្តស្សបិ លាសេន្តស្សបិ នច្ចន្តិយាបិ នច្ចន្តស្ស នច្ចន្តិយាបិ គាយន្តស្ស នច្ចន្តិយាបិ វាទេន្តស្ស នច្ចន្តិយាបិ លាសេន្តស្ស គាយន្តិយាបិ នច្ចន្តស្ស គាយន្តិយាបិ គាយន្តស្ស គាយន្តិយាបិ វាទេន្តស្ស គាយន្តិយាបិ លាសេន្តស្ស វាទេន្តិយាបិ នច្ចន្តស្ស វាទេន្តិយាបិ គាយន្តស្ស វាទេន្តិយាបិ វាទេន្តស្ស វាទេន្តិយាបិ លាសេន្តស្ស លាសេន្តិយាបិ នច្ចន្តស្ស លាសេន្តិយាបិ គាយន្តស្ស លាសេន្តិយាបិ វាទេន្តស្ស លាសេន្តិយាបិ លាសេន្តស្ស អដ្ឋបទេបិ កីឡន្តស្ស ទសបទេបិ កីឡន្តស្ស អាកាសេបិ កីឡន្តស្ស បរិហារបថេបិ កីឡន្តស្ស សន្តិកាយបិ កីឡន្តស្ស ខលិកាយបិ កីឡន្តស្ស ឃដិកាយបិ កីឡន្តស្ស សលាកហត្ថេនបិ កីឡន្តស្ស



អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ មានគ្រឿងកម្រាលនិងដេកដណ្តប់ជាមួយគ្នាខ្លះ ស៊ីក្នុងវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ រៃករាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ រៃករាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ រៃករាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ រៃករាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងរៃករាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរៃករាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងរៃករាយខ្លះ រៃករាយជាមួយនឹងស្រីកំពុងរៃករាយខ្លះ លេងបាយ៉ស្កាមានក្រឡា ៨ ខ្លះ លេងបាយ៉ស្កាមានក្រឡា ១០ ខ្លះ លេងបាយ៉ស្កាក្នុងអាកាសខ្លះ លេងផ្លូវកន្លែងដែលខ្នុនខ្នួរកន្ទ(១)ខ្លះ លេងដាក់ស្រាប់មានស្រេសជាដើមខ្លះ លេងបាយ៉ស្កាក្នុងលានសម្រាប់លេងខ្លះ លេងឃ្លីខ្លះ លេងរលាស់ទឹកលាក់ឲ្យតាយរូបខ្លះ

---

១ ប្រហែលជាលេងចិត្រមុខ.ចិត្រកូន ។

អក្ខេនបិ កីឡិស្សន្តិ បង្គចីរេនបិ កីឡិស្សន្តិ វង្កកេនបិ កីឡិស្សន្តិ មោក្ខចិកាយបិ កីឡិស្សន្តិ ចិង្គុលកេនបិ កីឡិស្សន្តិ បត្តាឡ្ហកេនបិ កីឡិស្សន្តិ រថកេនបិ កីឡិស្សន្តិ ធនុកេនបិ កីឡិស្សន្តិ អក្ខរិកាយបិ កីឡិស្សន្តិ មនេសិកាយបិ កីឡិស្សន្តិ យថាវជ្ជេនបិ កីឡិស្សន្តិ ហត្ថិស្មឹម្បិ សិក្ខិស្សន្តិ អស្សស្មឹម្បិ សិក្ខិស្សន្តិ រថស្មឹម្បិ សិក្ខិស្សន្តិ ធនុស្មឹម្បិ សិក្ខិស្សន្តិ ថរុស្មឹម្បិ សិក្ខិស្សន្តិ ហត្ថិស្សបិ បុរតោ ធាវិស្សន្តិ អស្សស្សបិ បុរតោ ធាវិស្សន្តិ រថស្សបិ បុរតោ ធាវិស្សន្តិ ធាវិស្សន្តិបិ អាធាវិស្សន្តិបិ ឧស្សេឡេស្សន្តិបិ អប្ផោដេស្សន្តិបិ(១) និព្វុជ្ឈិស្សន្តិបិ មុដ្ឋីហិបិ យុជ្ឈិស្សន្តិ រង្គមជ្ឈេបិ សង្ឃាដឹ បត្ថរិត្វា នច្ចកឹ ឯវំ វក្ខន្តិ ឥធ ភគិនិ នច្ចស្សូតិ នលាដិកំបិ ទស្សន្តិ វិវិធម្បិ អនាចារំ អាចរិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ អញ្ញថត្តាយាតិ ។

(៣១៨) អថខោ ភគវា អស្សជិបុនព្វសុកេ ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ធម្មឹ កថំ កត្វា

---

១. ម. អប្ផោដិស្សន្តិ ។



លេងអង្គុញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងកូនខ្ទះល្អខ្លះ លេងជាំងួនខ្លះ លេងកង្ហារខ្លះ លេងក្រល់ដីរង្វាស់ (ថ្វាយម្ដុកថ្វាយម្ដង)ខ្លះ លេងដោយរថតូចខ្លះ លេងដោយធ្នូតូចខ្លះ លេងសរសេរអក្សរលើខ្នងគ្នាខ្លះ លេងទាយចិត្ត (ស្មានចិត្ត)ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់មនដាវដងជាដើមខ្លះ រត់ពីមុខដំរីខ្លះ រត់ទៅពីមុខសេះខ្លះ រត់ទៅពីមុខរថខ្លះ រត់ទៅខ្លះ រត់ត្រឡប់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់ខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដីក្នុងកណ្ដាលរោងរាំហើយនិយាយនឹងស្រីដែលរាំយ៉ាងនេះថា នែប្អូនស្រី នាងចូររាំក្នុងទីនេះចុះខ្លះ ដាក់ស្នាមដៃលើថ្ងាស (ខ្លួននឹងថ្ងាសស្រីរាំ)ខ្លះ ប្រព្រឹត្តអនាចារផ្សេងៗទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់មនុស្សដែលមិនទាន់ជ្រះថ្លាហើយផង ។ បេ ។

(៣១៨) លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលភិក្ខុពួកអស្សជិនិងបុនព្វសុកៈ ដោយបរិយាយច្រើន ហើយព្រះអង្គសំដែងធម្មីកថា

សារីបុត្តមោគ្គល្លានេ អាមន្តេសិ គច្ឆថ តុម្ហេ សារីបុត្តា កីដាគិរឹ គន្ត្វា អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដា-គិរិស្មា បព្វាជនីយកម្មំ ករោថ តុម្ហាកំ ឯតេ សទ្ធិវិហារិកាតិ ។ កថំ មយំ ភន្តេ អស្សជិបុនព្វ-សុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករោម ចណ្ឌា តេ ភិក្ខូ ផរុសាតិ ។ តេនហិ តុម្ហេ សារីបុត្តា ពហុកេហិ ភិក្ខូហិ សទ្ធឹ គច្ឆថាតិ ។ ឯវំ ភន្តេតិ ខោ សារីបុត្តមោគ្គល្លានា ភគវតោ បច្ចស្សោសុំ ។

(៣១៩) ឯវញ្ច បន ភិក្ខវេ កាតព្វំ ។ បឋមំ អស្សជិបុនព្វសុកា ភិក្ខូ ចោទេតព្វា ចោទេត្វា សារេ-តព្វា សារេត្វា អាបត្តឹ រោបេតព្វា អាបត្តឹ រោបេត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ អស្សជិបុនព្វសុកា



ត្រូវទ្រង់ហៅព្រះសារីបុត្តត្ថេរនិងព្រះមោគ្គល្លានត្ថេរមក ហើយត្រាស់ថា ម្នាលសារីបុត្តនិងមោគ្គល្លាន អ្នកទាំងពីរចូរទៅកាន់កិដាគីរីជនបទ លុះទៅហើយ ចូរធ្វើបព្វាជនីយកម្ម(*) ភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកៈ ចេញពីកិ-ដាគីរីជនបទ (ព្រោះ) ភិក្ខុអម្បាលនោះជាសទ្ធិវិហារិករបស់អ្នកទាំងពីរ ។ ព្រះសារីបុត្តត្ថេរនិងព្រះមោគ្គល្លានត្ថេរក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គទាំងពីរ នឹងធ្វើបព្វាជនីយកម្មភិក្ខុឈ្មោះអស្ស-ជិនិងបុនព្វសុកៈ ចេញពីកិដាគីរីជនបទដូចម្តេចបាន (ព្រោះ) ភិក្ខុទាំងនោះជាមនុស្សកាចអាក្រក់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្តនិងមោគ្គល្លាន បើដូច្នោះអ្នកទាំងពីរ ចូរទៅជាមួយនឹងភិក្ខុជាច្រើនរូប ។ ព្រះសារីបុត្តត្ថេរនិងព្រះមោគ្គល្លានត្ថេរ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគហើយទូលថា យ៉ាងហ្នឹងហើយព្រះអង្គ ។

(៣១៩) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើយ៉ាងនេះ ដំបូងគប្បីភិក្ខុត្រូវដាស់តឿនភិក្ខុឈ្មោះអស្សជិនិងបុន-ព្វសុកៈសិន លុះដាស់តឿនហើយ គួររំលឹក លុះរំលឹករួចហើយ គួរលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាសគាត់អាចប្រាប់សង្ឃឲ្យដឹងដោយញត្តិថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ខ្ញុំ

* ការបណ្តេញភិក្ខុលាមក ដែលប្រព្រឹត្តអនាចារ ឲ្យចេញពីទីកន្លែង ។

ភិក្ខូ កុលទូសកា បាបសមាចារា ។ ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករេយ្យ នាស្សជិបុនព្វសុកេហិ[1] ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ អស្សជិបុនព្វសុកា ភិក្ខូ កុលទូសកា បាបសមាចារា ។ ឥមេសំ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច ឥមេហិ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សង្ឃោ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មំ ករោតិ នាស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ ។ យស្សាយស្មតោ ខមតិ អស្សជិបុនព្វសុកានំ ភិក្ខូនំ កីដាគិរិស្មា បព្វាជនីយកម្មស្ស ករណំ នាស្សជិបុនព្វសុកេហិ ភិក្ខូហិ កីដាគិរិស្មឹ វត្ថព្វន្តិ

---

១ យោត្តយ្យេ បទម្ហោតេ ឥតោ ។



ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកនេះ ជាអ្នកប្រទូស្តត្រកូល តែងញ៉ាំងសេចក្តីជ្រះថ្លារបស់ត្រកូលឲ្យវិនាស ព្រោះសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកនេះ ប្រាកដជាគេឃើញផង គេឮផង មួយទៀត ត្រកូលទាំងឡាយដែលពួកភិក្ខុនេះប្រទូស្តហើយ ប្រាកដជាគេឃើញផង គេឮផង ។ បើបព្វាជនីយកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ឲ្យចេញពីកិដាគិរីជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ពាក្យខ្ញុំ ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកជាអ្នកប្រទូស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ ។ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកអម្បាលនេះប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលភិក្ខុអម្បាលនេះប្រទូស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង ។ សង្ឃធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ឲ្យចេញពីកិដាគិរីជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ ការធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ឲ្យចេញពីកិដាគិរីជនបទថា ភិក្ខុទាំងឡាយ ជាពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ សមគួរដល់លោកដ៏មានអាយុអង្គណា

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ បេ ។ សោ ភាសេយ្យ ។ កតំ សង្ឃេន អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មំ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មឹ វត្ថព្វន្តិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៣៦០] អថខោ សារីបុត្តមោគ្គល្លានប្បមុខោ ភិក្ខុសង្ឃោ កិដាគិរឹ គន្ត្វា អស្សជិបុនព្វសុកានំ ភិក្ខូនំ កិដាគិរិស្មា បព្វាជនីយកម្មំ អកាសិ ន អស្សជិបុនព្វសុកេហិ ភិក្ខូហិ កិដាគិរិស្មឹ វត្ថព្វន្តិ ។ តេ សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តន្តិ ន លោមំ-បាតេន្តិ ន នេត្ថារំ វត្តន្តិ ន ភិក្ខូ ខមាបេន្តិ អក្កោសន្តិ បរិភាសន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេន្តិ បក្កមន្តិបិ វិព្ភមន្តិបិ ។



លោកអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកអង្គណា លោកអង្គនោះត្រូវពោលឡើង ។ ខ្ញុំសូមប្រកាសសេចក្តីនេះអស់វារៈពីរដងផង ។ បេ ។ ខ្ញុំសូមប្រកាសសេចក្តីនេះអស់វារៈបីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ពាក្យខ្ញុំ ។ បេ ។ លោកអង្គនោះត្រូវពោលឡើង ។ សង្ឃបានធ្វើបព្វាជនីយកម្ម ដល់ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ឲ្យចេញពីកិដាគិរី-ជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ ការធ្វើបព្វាជនីយកម្មនោះគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ ។ ខ្ញុំចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៣៦០) លំដាប់នោះ ភិក្ខុសង្ឃមានព្រះសារីបុត្តនិងព្រះមោគ្គល្លានជាប្រធាន ទៅកាន់កិដាគិរីជនបទ ហើយបានធ្វើបព្វា-ជនីយកម្ម ដល់ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកចេញពីកិដាគិរីជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរីជនបទទេ ។ ភិក្ខុអម្បាលនោះដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយប្រពៃ មិនសង្រួមរោមក៏មិនព្រមតាម មិនព្រមប្រតិបត្តិតាមទំនងដើម្បីរើខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ត្រឡប់ជាជេរប្រទេចផ្តាសាពួកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ ។

យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តន្តិ ន លោមំ បាតេន្តិ ន នេត្ថារំ វត្តន្តិ ន ភិក្ខូ ខមាបេន្តិ អក្កោសន្តិ បរិភាសន្តិ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេន្តិ បក្កមន្តិបិ វិព្ភមន្តិបីតិ ។

(៣៦០) អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន បព្វាជនីយកម្មកតា ន សម្មា វត្តន្តិ ។បេ។ វិព្ភមន្តិបីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ ភិក្ខវេ តេសំ មោឃបុរិសានំ ។បេ។ កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សង្ឃេន បព្វាជនីយកម្មកតា



ពួកភិក្ខុណា ប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល មិនសម្ងួបរោម មិនត្រមប្រតិបត្តិតាមចំនងជាទីរលាស់ខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ក្រឡប់ជាជេរប្រទេច បន្ទូស ការកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ ។

(៣៦១) លំដាប់នោះ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល ។បេ។ ហើយភិក្ខុទាំងនោះសឹកទៅខ្លះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុណ្យទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះមិនសមគួរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច ក៏មោឃបុរសទាំងនោះ ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល

ច សន្តា ទិស្សន្តិ ។ បេ ។ វិគរហិស្សន្តិបិ ។ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុ បនេវ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ កុលទូសកោ បាបសមាចារោ ។ តស្ស ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច តេន ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតាយស្មា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តេ ភិក្ខូ ឯវំ វទេយ្យ ឆន្ទគាមិនោ ច ភិក្ខូ ទោសគាមិនោ ច ភិក្ខូ មោហគាមិនោ ច ភិក្ខូ ភយគាមិនោ ច ភិក្ខូ



។ បេ ។ ភិក្ខុទាំងនោះសើកតាទុះ ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងឡាយនេះ មិនទាន់ឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាហើយផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុចូលទៅជិតអាស្រ័យស្រុក ឬនិគម ណាមួយហើយនៅ ជាអ្នកប្រទូស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ ។ សេចក្តីប្រព្រឹត្តអាក្រក់របស់ភិក្ខុនោះឯង ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយ ដែលភិក្ខុនោះប្រទូស្តហើយ ប្រាកដជាគេឃើញផង គេឮផង ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយស្តីឲ្យយ៉ាងនេះថា លោកដ៏មានអាយុជាអ្នកប្រទូស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលលោកដ៏មានអាយុប្រទូស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងទីនេះទេ ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ ត្រឡប់ជាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខឹងផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីវង្វេងផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង

ភាជិសិកាយ អាបត្តិយា ឯកច្ចំ បញ្ញាបេន្តិ ឯកច្ចំ ន បញ្ញាបេន្តីតិ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាយស្មា ឯវំ អវច ន ច ភិក្ខូ ឆន្ទាគាមិនោ ន ច ភិក្ខូ ទោសាគាមិនោ ន ច ភិក្ខូ មោហាគាមិនោ ន ច ភិក្ខូ ភយាគាមិនោ អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតាយស្មា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោតិ ។



(ព្រោះ) ភិក្ខុទាំងឡាយនោះ បណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ដោយអាបត្តិដូចគ្នា ។ ភិក្ខុនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីស្រឡាញ់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីស្អប់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីល្ងង់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីខ្លាច លោកដ៏មានអាយុឯង ជាអ្នកប្រទូស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ព្រោះជាគេឃើញផង គេឮផង ត្រកូលទាំងឡាយណា ដែលលោកដ៏មានអាយុប្រទូស្តហើយ ព្រោះជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញចាកអាវាសនេះទៅ លោកកុំនៅក្នុងអាវាសនេះ ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាម ដើម្បីឱ្យលះបង់អំពើអាក្រក់នោះតែ៣ដងផង ។ ភិក្ខុនោះ បើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មតែ៣ដងផង លះអំពើអាក្រក់នោះចេញ សេចក្តីលះបង់បាននោះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

(៣៦៦) ភិក្ខុ បនេវ អញ្ញតរំ គាមំ វា និគមំ វាតិ គាមោបិ និគមោបិ នគរំបិ គាមោ ចេវ និគមោ ច ។ ឧបនិស្សាយ វិហរតីតិ តត្ថ បដិពទ្ធា ហោន្តិ ចីវរ-បិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារា ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណ-កុលំ វេស្សកុលំ សុទ្ទកុលំ ។ កុលទូសកោតិ កុលានិ ទូសេតិ បុប្ផេន វា ផលេន វា ចុណ្ណេន វា មត្តិកាយ វា ទន្តកដ្ឋេន វា វេឡុនា[១] វា វេជ្ជិកាយ វា ជង្ឃបេសនិកេន វា ។ បាបសមាចារោតិ មាលាវច្ចំ រោបេតិបិ រោបាបេតិបិ សិញ្ចតិបិ សិញ្ចា-បេតិបិ ឱចិនាតិបិ ឱចិនាបេតិបិ គន្ថេតិបិ គន្ថាបេតិបិ ។

(៣៦៧) ទិស្សន្តិ ចេវ សុយ្យន្តិ ចាតិ យេ សម្មុខា តេ បស្សន្តិ យេ តិរោក្ខា តេ សុណន្តិ ។ កុលានិ ច តេន ទុដ្ឋានីតិ បុព្វេ សទ្ធា ហុត្វា តំ អាគម្ម អស្សទ្ធា

១ ឱ. ម. វេឡុយា ។



(៣៦៦) ត្រង់ពាក្យថា ភិក្ខុ(ចូលទៅជិតអាស្រ័យនៅ)ស្រុកឬនិគម កន្លែងណាមួយ សេចក្តីថា ស្រុកក្តី និគមក្តី នគរក្តី ក៏គឺស្រុក គឺនិគមហ្នឹងឯង ។ ពាក្យថា ចូលទៅជិតអាស្រ័យនៅ (គឺភិក្ខុចូលទៅជិតអាស្រ័យនៅក្នុងស្រុកនិគមណា) ដើម្បី បិណ្ឌបាត សេនាសនៈ និងគិលានបច្ចយភេសជ្ជបរិក្ខារជាប់ចំពោះមានទៅហើយ ក្នុងស្រុក និងនិគមនោះ ។ ត្រកូល ៤ ពួកគឺ ត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលអ្នកឈ្មួញ (ត្រកូលអ្នករកស៊ីធម្មតា) ត្រកូលអ្នកស្រែ (អ្នកស៊ីឈ្នួល) ហៅថាត្រកូល ។ ពាក្យថា ជាអ្នកប្រទូស្តត្រកូល គឺភិក្ខុប្រទូស្តត្រកូលទាំងឡាយដោយ(ឲ្យ)ផ្កាខ្លះ (ឲ្យ)ផ្លែខ្លះ (ឲ្យ)គ្រឿងលំអិតសម្រាប់ងូតខ្លះ (ឲ្យ)ដីស្អិតខ្លះ (ឲ្យ)ឈើស្ទន់ខ្លះ (ឲ្យ)ឫស្សីខ្លះ ដោយកិរិយាធ្វើពេទ្យខ្លះ ដោយការបម្រើដោយស្មងខ្លះ ។ ពាក្យថា មានសេចក្តីប្រព្រឹត្តអាក្រក់ គឺភិក្ខុដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ។

(៣៦៧) ពាក្យថា ប្រាកដផងគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ ។ ពាក្យថា ត្រកូលទាំងឡាយសោតដែលភិក្ខុនោះប្រទូស្តហើយ គឺពីមុនមនុស្សទាំងឡាយមានសទ្ធា អាស្រ័យនេះជាមនុស្សមិនមានសទ្ធាវិញ

ហោន្តិ បសន្នា ហុត្វា អប្បសន្នា ហោន្តិ ។ ទិស្សន្តិ ចេវ សុយ្យន្តិ ចាតិ យេ សម្មុខា តេ បស្សន្តិ យេ តិរោក្ខា តេ សុណន្តិ ។

(៣៦៦) សោ ភិក្ខូតិ យោ សោ កុលទូសកោ ភិក្ខុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតាយស្មា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តេ ភិក្ខូ ឯវំ វទេយ្យ ឆន្ទគាមិនោ ច ភិក្ខូ ទោសគាមិនោ ច ភិក្ខូ មោហគាមិនោ ច ភិក្ខូ ភយគាមិនោ ច ភិក្ខូ តាទិសិកាយ អាបត្តិយា ឯកច្ចំ បព្វាជេន្តិ ឯកច្ចំ ន បព្វាជេន្តីតិ ។



ធ្លាប់ជ្រះថ្លា ក៏លែងជ្រះថ្លាទៅវិញ ព្រោះតែប្រយោជន៍ភិក្ខុនោះ ។ ពាក្យថា ប្រាកដជាគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ ។

(៣៦៦) ពាក្យថា ភិក្ខុនោះ គឺភិក្ខុណាមួយ ជាអ្នកប្រទូស្តត្រកូល ។ ពាក្យថា គឺភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយដទៃ ។ ភិក្ខុទាំងឡាយណាឃើញ ណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រាប់ថា លោកដ៏មានអាយុ ជាអ្នកប្រទូស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុប្រទូស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ម្យ៉ាងទៀត ភិក្ខុនោះដែលភិក្ខុទាំងឡាយនិយាយប្រាប់យ៉ាងនេះហើយ ក្រឡប់ជាថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះថា ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្អប់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង ទើបបណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ព្រោះអាបត្តិដូចគ្នានេះ ។

[៣៤៩] សោ ភិក្ខូតិ យោ សោ កម្មកតោ ភិក្ខុ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ មា អាយស្មា ឯវំ អវច ន ច ភិក្ខូ ឆន្ទគាមិនោ ន ច ភិក្ខូ ទោសគាមិនោ ន ច ភិក្ខូ មោហគាមិនោ ន ច ភិក្ខូ ភយគាមិនោ អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតាយស្មា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សោ ភិក្ខុ សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វោ មា អាយស្មា ឯវំ អវច ន ច ភិក្ខូ ឆន្ទគាមិនោ



[៣៤៩] ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលបានធ្វើកម្មនោះ ។ ពាក្យថា ពីភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយដទៃទៀត ។ ភិក្ខុណាឃើញ ភិក្ខុណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រាប់ថា លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងឆន្ទាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងទោសាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងមោហាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងភយាគតិ លោកដ៏មានអាយុ ជាអ្នកប្រទូស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ត្រូវគេជាគេឃើញផង គេឮផង ត្រកូលទាំងឡាយណា ដែលលោកដ៏មានអាយុប្រទូស្តហើយ ត្រូវគេជាគេឃើញផង គេឮផង លោកដ៏មានអាយុ ចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ភិក្ខុប្រទូស្តត្រកូលនោះ ពីភិក្ខុទាំងឡាយ ត្រូវនិយាយប្រាប់អស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយប្រាប់ អស់វារៈជាគំរប់បីដងផង ។ បើភិក្ខុនោះលះបង់ (កម្មនោះ) បាន ការលះបង់នោះ ជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ពួកភិក្ខុឮហើយមិននិយាយប្រាប់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុ(ប្រទូស្តត្រកូល)នោះ គឺភិក្ខុទាំងឡាយត្រូវទាញមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយប្រាប់ថា លោកដ៏មានអាយុ កុំពោលពាក្យយ៉ាងនេះ ភិក្ខុទាំងឡាយមិនមែនលុះក្នុងឆន្ទាគតិទេ

ន ច ភិក្ខូ ទោសាគាមិនោ ន ច ភិក្ខូ មោហាគាមិនោ ន ច ភិក្ខូ ភយាគាមិនោ អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតាយស្មា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

(៣៤៦) សោ ភិក្ខុ សមនុភាសិតព្វោ ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បព្វាជនិយកម្មកតោ ភិក្ខូ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេតិ ។ សោ



ភិក្ខុទាំងឡាយមិនមែនលុះក្នុងទោសាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងមោហាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងភយាគតិទេ លោកដ៏មានអាយុ ជាអ្នកប្រទូស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ត្រូវគេឃើញផង គេឮផង ត្រកូលទាំងឡាយរបស់លោក ដែលលោកដ៏មានអាយុប្រទូស្តហើយនោះ ត្រូវគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញអំពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយប្រដៅ អស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយប្រដៅអស់វារៈជាគំរប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើភិក្ខុនោះលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

(៣៤៦) ភិក្ខុនោះ សង្ឃត្រូវសូត្រប្រកាសហាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ សង្ឃត្រូវសូត្រប្រកាសហាមយ៉ាងនេះ ។ ភិក្ខុដ៏ឈ្លាសអង់អាចត្រូវប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃលុះក្នុងឆន្ទាគតិ លុះក្នុងទោសាគតិ លុះក្នុងមោហាគតិ លុះក្នុងភយាគតិ ។ ភិក្ខុ (អ្នកប្រទូស្តត្រកូល) នោះ

តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ សង្ឃេន បព្វាជនីយកម្មកតោ ភិក្ខូ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា បាបេតិ ។ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ បេ ។ សោ ភាសេយ្យ ។ សមនុភដ្ឋោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ



មិនលះបង់នូវវត្ថុនោះ ។ បើកម្មរបស់សង្ឃមានកាលគួរដល់ហើយ សង្ឃគប្បីសូត្រប្រកាសហាមភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់នូវវត្ថុនោះ ។ នេះញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃលុះក្នុងសេចក្តីស្រឡាញ់ លុះក្នុងសេចក្តីស្អប់ លុះក្នុងសេចក្តីល្ងង់ លុះក្នុងសេចក្តីខ្លាច ។ ភិក្ខុ (អ្នកប្រទូស្តត្រកូល) នោះមិនលះបង់នូវវត្ថុនោះ ។ សង្ឃសូត្រសមនុភាសនកម្ម (ប្រកាសហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់នូវវត្ថុនោះ ។ ការសូត្រសមនុភាសនកម្ម (ប្រកាសហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់នូវវត្ថុនោះ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំពោលសេចក្តីនេះអស់វារៈពីរដងផង ។ បេ ។ ខ្ញុំពោលសេចក្តីនេះអស់វារៈបីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ។ បេ ។ លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃសូត្រសមនុភាសនកម្ម (ប្រកាសហាម)

តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៣២៧] ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។ សង្ឃាទិសេសោតិ សង្ឃោវ តស្សា អាបត្តិយា បរិវាសំ ទេតិ មូលាយ បដិកស្សតិ មានត្តំ ទេតិ អព្ភេតិ ន សម្ពហុលា ន ឯកបុគ្គលោ តេន វុច្ចតិ សង្ឃាទិសេសោតិ ។ តស្សេវ អាបត្តិនិកាយស្ស នាមកម្មំ អធិវចនំ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។



ដើម្បីឲ្យលះបង់វត្ថុនោះហើយ ។ សមនុភាសនកម្មនោះ សមគួរដល់សង្ឃហើយ ហេតុនោះ សង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៣២៧) (កាលសង្ឃ)សូត្រញត្តិចប់ (ភិក្ខុអ្នកខំស្តូកំពូលនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាចប់ជាគំរប់ពីរដង (ភិក្ខុអ្នកខំស្តូកំពូលនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុអ្នកខំស្តូកំពូលនោះ) ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុនោះត្រូវព្រោះចប់ញត្តិ ទាំងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះ ត្រូវព្រោះចប់កម្មវាចាជាគំរប់ពីរដងក្តី គឺតែងរម្ងាប់ទៅវិញ ។ ត្រង់ពាក្យថា សង្ឃាទិសេស គឺសង្ឃ[១]តែងឲ្យបរិវាសដើម្បីអាបត្តិនោះផង ទាញមកកាន់អាបត្តិខាងដើម ឲ្យនូវមានត្ត សូត្រអព្ភាន (រាប់ភិក្ខុនោះចូលពួកគណ៍) គណៈ[២]ឲ្យមិនបាន បុគ្គល[៣]ម្នាក់ឲ្យមិនបាន ហេតុនោះ ព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស ។ នាមកម្ម[៤]ជាឈ្មោះពួកអាបត្តិនោះឯង ហេតុនោះ បានជាព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស ។

---

១ ភិក្ខុ ៤ រូបឡើងទៅ ហៅថាសង្ឃ ។ ២ ភិក្ខុពីររូប ឬបីរូប ហៅថា គណៈ ។ ៣ សំដៅយកភិក្ខុតែមួយរូប ។ ៤ ពួកអាបត្តិទាំង ១៣ សិក្ខាបទចាប់តាំងអំពីសញ្ចេតនិកសិក្ខាបទរហូតដល់ កុលទូសកសិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់ឈ្មោះថា សង្ឃាទិសេស ។

តេរសកណ្ឌោ តេរសមសង្ឃាទិសេសស្ស អនាបត្តិកា

[៣៦៨] ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកោ នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣៦៩] អនាបត្តិ អសមនុភាសន្តស្ស បដិនិស្សជ្ជន្តស្ស ឧម្មត្តកស្ស ខិត្តចិត្តស្ស(១) វេទនដ្ដស្ស(២) អាទិកម្មិកស្សាតិ ។

តេរសមសង្ឃាទិសេសំ និដ្ឋិតំ ។

[៣៧០] ឧទ្ទិដ្ឋា ខោ អាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា នវ បឋមាបត្តិកា ចត្តារោ យាវតតិយកា

---

១-២ ឥទំ បាឋទ្វយំ ម. យ. ពោត្ថកេសុ ន ទិស្សតិ ។



តេរសកណ្ឌ សង្ឃាទិសេសទី ១៣ និយាយអំពីការមិនត្រូវអាបត្តិ

(៣៦៨) ភិក្ខុសំគាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ តែមិនលះបង់ (សេចក្ដីប្រតិព្ធាន គ្រឿងនោះ) ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងកម្មប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៣៦៩) អាបត្តិមិនមាន ដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុដែលបានលះបង់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តរវើរវាយ ដល់ភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សង្ឃាទិសេសទី ១៣ ចប់ ។

(៣៧០) បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិទាំងឡាយ ឈ្មោះសង្ឃាទិសេសទាំង ១៣ ខ្ញុំសំដែងឡើងហើយ អាបត្តិទាំងឡាយ ៩ ហៅថាបឋមាបត្តិកា គឺត្រូវអាបត្តិក្នុងវេលាល្មើសព្រមនឹងបញ្ញត្តិជាដំបូង អាបត្តិទាំងឡាយ ៤ ហៅថាយាវតតិយកា គឺត្រូវអាបត្តិក្នុងវេលាដែល សង្ឃសូត្រប្រកាសហាមឃាត់ដល់បីដង ហើយមិនលះបង់ការប្រកាន់នោះ

យេសំ ភិក្ខុ អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជិត្វា យាវតិហំ ជានំ បដិច្ឆាទេតិ តាវតិហំ តេន ភិក្ខុនា អកាមា បរិវត្ថព្វំ ។ បរិវុត្ថបរិវាសេន ភិក្ខុនា ឧត្តរិ ឆារត្តំ ភិក្ខុមានត្តាយ បដិបជ្ជិតព្វំ ។ ចិណ្ណមានត្តោ ភិក្ខុ យត្ថ សិយា វីសតិគណោ ភិក្ខុសង្ឃោ តត្ថ សោ ភិក្ខុ អព្ភេតព្វោ ។ ឯកេនបិ ចេ ឩនោ វីសតិគណោ ភិក្ខុសង្ឃោ តំ ភិក្ខុំ អព្ភេយ្យ ។ សោ ច ភិក្ខុ អនព្ភិតោ តេ ច ភិក្ខូ គារយ្ហា ។ អយំ តត្ថ សាមីចិ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

តេរសកំ និដ្ឋិតំ ។



បណ្ដាអាបត្តិទាំង ១៣ បើភិក្ខុណា ត្រូវអាបត្តិណាមួយ ហើយដឹងច្បាស់ បិទបាំងទុកអស់ប៉ុន្មានថ្ងៃ ភិក្ខុនោះត្រូវនៅបរិវាសអស់ប៉ុណ្ណោះថ្ងៃ ព្រោះខ្លួនមិនមានសេចក្ដីប្រាថ្នានឹងនៅបរិវាស ។ ភិក្ខុដែលនៅបរិវាសហើយ ត្រូវប្រព្រឹត្តភិក្ខុមានត្ត[1]អស់ ៦ រាត្រីតទៅទៀត ។ ភិក្ខុប្រព្រឹត្តមានត្តហើយ ភិក្ខុសង្ឃពួក ២០ រូបមានក្នុងទីណា ភិក្ខុនោះ គឺភិក្ខុសង្ឃពួក ២០ រូប គប្បីឲ្យអព្ភាន[2]ក្នុងទីនោះ ។ បើភិក្ខុសង្ឃមិនគ្រប់ ២០ រូបទេ សូម្បីខ្វះតែមួយរូប ហើយនាំគ្នាឲ្យអព្ភានកម្មដល់ភិក្ខុនោះ ។ ឯភិក្ខុនោះមិនបានឈ្មោះថាសង្ឃឲ្យអព្ភានកម្មផង ពួកភិក្ខុ (ជាការកសង្ឃ) នោះ ឈ្មោះថាត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលបានផង ។ សេចក្ដីប្រតិបត្តិនេះ ជាការដ៏សមគួរក្នុងកម្មនោះ ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងរឿងនោះ លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈពីរផង លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈបីផង លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ ជាភិក្ខុបរិសុទ្ធក្នុងរឿងនេះហើយ ហេតុនោះ បានជាស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

សង្ឃាទិសេសទាំង ១៣ ចប់ ។

---

១ កម្មជាគ្រឿងប្រព្រឹត្ត ដើម្បីឲ្យជាទីរាប់អានរបស់ភិក្ខុ ។ ២ កម្មដែលសង្ឃសូត្រប្រកាសហៅភិក្ខុដែលបានបរិវាសហើយនោះមកបញ្ចូលក្នុងពួកវិញ ។

## គាថាសង្គហ

វិស្សដ្ឋិ កាយសំសគ្គំ[1] ទុដ្ឋុល្លំ[2] អត្តកាមញ្ច

សញ្ចរិត្តំ កុដី ចេវ វិហារោ ច អមូលកំ

កិញ្ចិ លេសញ្ច[3] ភេទោ ច តស្សេវ អនុវត្តកា

ទុព្វចំ កុលទូសញ្ច សង្ឃាទិសេសា តេរសាតិ[4] ។

---

១ ឬ កាយសំសគ្គោ ។ ២ ឬ ទុដ្ឋុល្លោ ។ ៣ ឬ លេសញ្ច ។ ៤ មន្ដ្របញ្ញាបេញ្ចលេស សង្ខេប ៦ ហោត ។



## បញ្ជីប្រែនៃសង្ឃាទិសេសទោស

សង្ឃាទិសេស ទាំង ១៣ គឺ

| | |
|---|---|
| វិស្សដ្ឋិ | ការបញ្ចេញទឹកសុក្ក ១ |
| កាយសំសគ្គ | ស្ទាបអង្អែលកាយស្រី ១ |
| ទុដ្ឋុល្ល | ពោលពាក្យអាក្រក់ ១ |
| អត្តកាម | ឲ្យស្រីបម្រើខ្លួនដោយកាម ១ |
| សញ្ចរិត្ត | ដឹកនាំប្រុសស្រីឲ្យបានគ្នាជាប្ដីប្រពន្ធ ១ |
| កុដិ | ធ្វើកុដិ ១ |
| វិហារ | ធ្វើវិហារធំ ១ |
| អមូលក | ចោទអាបត្តិគេដោយហេតុគ្មាន ១ |
| កិញ្ចិលេស | ចោទតាមលេសតិចមួយ ១ |
| ភេទ | បំបែកសង្ឃ ១ |
| តស្សេវអនុវត្តកា | ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ នោះឯង ១ |
| ទុព្វច | ប្រដៅក្រ ១ |
| កុលទូស | ប្រទូស្តត្រកូល ១ |

# អនិយតកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ ទ្វេ អនិយតា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## បឋមានិយតោ

(៣៣១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយី សាវត្ថិយំ កុលូបកោ ហោតិ ពហុកានិ កុលានិ ឧបសង្កមតិ ។ តេន ខោ បន សមយេន អាយស្មតោ ឧទាយិស្ស ឧបដ្ឋាកកុលស្ស កុមារិកា អញ្ញតរស្ស កុលស្ស កុមារកស្ស ទិន្នា ហោតិ ។ អថខោ អាយស្មា ឧទាយិ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា មនុស្សេ បុច្ឆិ កហំ ឥត្ថន្នាមាតិ ។ តេ ឯវមាហំសុ ទិន្នា ភន្តេ អមុកស្ស កុលស្ស កុមារកស្សាតិ ។ តម្បិ ខោ កុលំ អាយស្មតោ ឧទាយិស្ស ឧបដ្ឋាកំ ហោតិ ។ អថខោ

# អនិយតកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ ធម៌ទាំងឡាយគឺ ឈ្មោះ អនិយត ២ នេះ មកកាន់ឧទ្ទេស ។

## អនិយតទី ១

(៣៣១) សម័យនោះ ព្រះពុទ្ធដ៏មានបុណ្យស័ក្តិ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ឧទាយីដ៏មានអាយុ ជាកុលូបកចូលទៅកាន់ត្រកូល តែងចូលទៅកាន់ត្រកូលទាំងឡាយ ជាច្រើនក្នុងក្រុងសាវត្ថី ។ សម័យនោះ កុមារិកានៃត្រកូលជាឧបដ្ឋាក លោកឧទាយីដ៏មានអាយុ មាតាបិតាបានឲ្យទៅជាប្រពន្ធកុមារម្នាក់នៃត្រកូល ។ គ្រាក្រោយ ឧទាយីដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាព្រឹកព្រហាម ហើយចូលទៅកាន់ត្រកូលនោះ លុះចូលទៅហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះទៅណាហើយ ។ មនុស្សទាំងនោះ បានតបពាក្យយ៉ាងនេះថា បពិត្រលោកដ៏ចំរើន កុមារិកានោះ យើងឲ្យទៅកុមារនៃត្រកូលឯណោះហើយ ។ ឯត្រកូលនោះឯង ក៏ជាឧបដ្ឋាកឧទាយីដ៏មានអាយុដែរ ។ គ្រានោះឯង ឧទាយីដ៏មានអាយុ

អាយស្មា ឧទាយី យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា មនុស្សេ បុច្ឆិ កហំ ឥត្ថន្នាមាតិ ។ ឯសយ្យ ទិវាគោ និសិន្នាតិ ។ អថខោ អាយស្មា ឧទាយី យេន សា កុមារិកា តេនុបសង្កមិ ឧបសង្កមិត្វា តស្សា កុមារិកាយ សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេសិ កាលយុត្តំ សមុល្លបន្តោ កាលយុត្តំ ធម្មំ ភណន្តោ ។

[៣៣៦] តេន ខោ បន សមយេន វិសាខា មិគារមាតា ពហុបុត្តា ហោតិ ពហុនត្តា អរោគបុត្តា អរោគនត្តា អភិមង្គលសម្មតា ។ មនុស្សា យញ្ញេសុ ឆណេសុ ឧស្សវេសុ វិសាខំ មិគារមាតរំ បឋមំ



ចូលទៅកាន់ត្រកូលនោះ លុះចូលទៅហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះ នៅឯណា ។ មនុស្សទាំងឡាយឆ្លើយថា លោកម្ចាស់ចូរក្រមើលចុះ កុមារិកានោះ នៅក្នុងបន្ទប់តូច ។ ទើបព្រះឧទាយីដ៏មានអាយុ តែម្នាក់ឯង ចូលទៅរកកុមារិកានោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ(មេថុនកម្ម)បាន ជាមួយនឹងកុមារិកាតែម្នាក់ឯងនោះ ហើយនិយាយតាមសមគួរដល់កាល(១) នឹងនិយាយធម៌សមគួរដល់កាល(២) ។

(៣៣៦) សម័យនោះឯង នាងវិសាខា ជាម្តាយនៃមិគារសេដ្ឋី ជាអ្នកមានកូនច្រើនមានចៅច្រើន ទាំងកូនក៏មិនសូវមានរោគ ចៅក៏មិនសូវមានរោគ ជាស្រីមានមង្គលដ៏ប្រសើរ ។ មនុស្សទាំងឡាយ កាលបើមានធ្វើពិធី កាលបើមានការវិវាហៈនិងអាវាហមង្គលជាដើម កាលបើមានមហោស្រព មានថ្ងៃចូលវស្សានឹងចេញវស្សាជាដើម តែងឲ្យនាងវិសាខា

---

១ គឺចូលអង្គុយជាមួយនឹងស្រីអស់ពេលដែលល្មមអ្នកណាទៅមក ហើយនិយាយពាក្យស្និទ្ធស្នាលនឹងគ្នាថា សព្វថ្ងៃនាងឯងមិនអផ្សុកទេឬ នាងឯងមិនលំបាកចិត្តទេឬ នាងឯងមិនឃ្លានទេឬ ដូច្នេះជាដើម ។ ២ គឺចូលអង្គុយជាមួយនឹងស្រីអស់ពេលដែលល្មមអ្នកណាទៅមក ហើយនិយាយធម៌ប្រាប់ស្រីនោះថា នាងឯងត្រូវរក្សាឧបោសថសីល នាងឯងត្រូវឲ្យសលាកភត្ត ដូច្នេះជាដើម ។

ករោន្តិ ។ អថខោ វិសាខា មិគារមាតា និមន្តិតា តំ កុលំ អគមាសិ ។ អទ្ទសា ខោ វិសាខា មិគារមាតា អាយស្មន្តំ ឧទាយឹ តស្សា កុមារិកាយ សទ្ធឹ ឯកំ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសិន្នំ ទិស្វាន អាយស្មន្តំ ឧទាយឹ ឯតទវោច ឥទំ ភន្តេ នច្ឆន្នំ នប្បដិរូបំ យំ អយ្យោ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសីទតិ កិញ្ចាបិ ភន្តេ អយ្យោ អនត្ថិកោ តេន ធម្មេន អបិច ទុស្សទ្ធាបយា អប្បសន្នា មនុស្សាតិ ។ ឯវម្បិ ខោ អាយស្មា ឧទាយី វិសាខាយ មិគារមាតុយា វុច្ចមានោ នាទិយិ ។ អថខោ វិសាខា មិគារមាតា និក្ខមិត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយី មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេស្សតីតិ ។ អថខោ តេ ភិក្ខូ អនេកបរិយាយេន អាយស្មន្តំ





ជាម្ចាយនៃមិគារសេដ្ឋី បរិភោគមុខនោះជាដើម ។ គ្រានោះឯង នាងវិសាខាជាមិគារមាតា ដែលគេបានអញ្ជើញឲ្យទៅកាន់ត្រកូល ក៏ចូលទៅកាន់ត្រកូលនោះ ។ នាងវិសាខាជាមិគារមាតាបានឃើញព្រះឧទាយិដ៏មានអាយុតែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំងល្មមធ្វើ (មេថុនកិច្ច) បាន ជាមួយនឹងកុមារីតែម្នាក់ឯងនោះ លុះឃើញហើយបាននិយាយពាក្យនេះ នឹងព្រះឧទាយិដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ការនេះ មិនមែនជាការស្អាតកំបាំងទេ មិនសមគួរទេ លោកម្ចាស់តែមួយអង្គ មកអង្គុយលើអាសនៈដ៏ស្ងាត់កំបាំងល្មមធ្វើ (មេថុនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកដ៏ចំរើន លោកម្ចាស់មិនត្រូវការដោយធម៌នោះក៏ពិតមែនហើយ តែថា មនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ទំនងជឿបានដោយក្រ ។ បើលោកព្រះឧទាយិដ៏មានអាយុ ទុកជានាងវិសាខាជាមិគារមាតាជាអ្នកនិយាយនេះ ក៏នៅមិនអើពើសោះ ។ ទើបនាងវិសាខាជាមិគារ-មាតាចេញទៅ ហើយប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេចក៏ព្រះឧទាយិដ៏មានអាយុម្នាក់ឯងអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (មេថុនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ។ លំដាប់នោះឯង ភិក្ខុទាំងនោះ ក្រាបទូល

។ បេ ។ សច្ចំ កិរ ត្វំ ឧទាយិ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិស អននុលោមិកំ ។ បេ ។ កថញ្ហិ នាម ត្វំ មោឃបុរិស មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេយ្យ តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា និសជ្ជំ ភិក្ខុ បដិជានមានោ តិណ្ណំ ធម្មានំ អញ្ញតរេន ការេតព្វោ បារាជិកេន វា



ឡើងនូវចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ឮថាអ្នកឯងនៃម្នាក់ឯង នៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (មេថុនកម្ម) បាន ជាមួយនឹងមាតុគ្រាមនៃម្នាក់ឯង ពិតមែនឬ ។ ឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុណ្យទ្រង់តិះដៀលថា ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិនស្រួល មិនសមគួរ ។ បេ ។ ម្នាលមោឃបុរស ហេតុដូចម្តេចក៏អ្នកឯងនៃម្នាក់ឯង នៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (មេថុនកម្ម) បាន ជាមួយនឹងមាតុគ្រាមនៃម្នាក់ឯង ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ នៃម្នាក់នឹងម្នាក់ អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (មេថុនកម្ម) បាន ជាមួយនឹងមាតុគ្រាម ឧបាសិកាដែលមានពាក្យគួរជឿបាន ឃើញភិក្ខុនោះ ហើយនិយាយដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះមែន) វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី

សង្ឃាទិសេសេន វា បាចិត្តិយេន វា យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ តេន សោ ភិក្ខុ ការេតព្វោ ។ អយម្បិ ធម្មោ អនិយតោតិ ។

(៣៣៣) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគ្គាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា អន្តមសោ តទហុជាតាបិ ទារិកា បគេវ មហត្តរី[១] ។ សទ្ធិន្តិ ឯកតោ ។ ឯកោ ឯកាយាតិ ភិក្ខុ ចេវ ហោតិ មាតុគ្គាមោ ច ។ រហោ នាម ចក្ខុស្ស រហោ សោតស្ស រហោ ។ ចក្ខុស្ស រហោ នាម ន សក្កា ហោតិ អក្ខឹ វា និខណីយមានេ ភមុកំ វា ឧក្ខិបីយមានេ សីសំ វា ឧក្ខិបីយមានេ បស្សិតុំ ។ សោតស្ស រហោ នាម ន សក្កា ហោតិ បកតិកថា សោតុំ ។ បដិច្ឆន្នំ នាម អាសនំ កុឌ្ឌេន វា កវាដេន វា កិលញ្ជេន វា សាណិបាការេន វា រុក្ខេន វា

---

១ ម. ឆ. ក. មហត្ថី ។



សង្ឃាទិសេសក្តី បាចិត្តិយក្តី ឬក៏ទៀត ឧបាសិកានោះមានពាក្យគួរជឿបាន និយាយដោយអាបត្តិណា ឲ្យសង្ឃត្រូវធ្វើដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ អាបត្តិនេះ ឈ្មោះថាអនិយត (មិនទៀង) ។

(៣៣៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយដូច ពោលក្នុងសិក្ខាបទទី ១ រួចហើយ ។ មនុស្សស្រី ហៅថា មាតុគ្រាម យក្សស្រី ប្រេតស្រី តិរច្ឆានញី មិនឈ្មោះថាមាតុគ្រាមទេ ដោយហោចទៅ សូម្បីតែទារិកាកើតក្នុងថ្ងៃនោះ ក៏ហៅថាមាតុគ្រាមដែរ មិនបាច់ពោលដល់ស្រីចាស់ទេ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា ។ ពាក្យថា តែម្នាក់ឯងនឹងម្នាក់ គឺភិក្ខុម្នាក់ មាតុគ្រាមម្នាក់ ។ កំបាំងភ្នែក ស្ងាត់ត្រចៀក ហៅថាស្ងាត់ ។ ដែលហៅថា ទីកំបាំងភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលមិនអាចនឹងមើលឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ដែលហៅថា អាសនៈកំបាំង គឺអាសនៈដែលបិទបាំង ដោយជញ្ជាំងក្តី ដោយសន្លឹកទ្វារក្តី ដោយកន្ទេលក្តី ដោយការពាំងដោយសំពត់ក្តី ដោយឈើក្តី

ថម្ភេន វា កោដ្ឋលិយា វា យេន កេនចិ បដិច្ឆន្នំ ហោតិ ។ អលំកម្មនិយេតិ សក្កា ហោតិ មេថុនំ ធម្មំ បដិសេវិតុំ ។ និសជ្ជំ កប្បេយ្យាតិ មាតុគាមេ និសិន្នេ ភិក្ខុ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា ភិក្ខុ និសិន្នេ មាតុគាមោ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា ឧភោ វា និសិន្នា ហោន្តិ ឧភោ វា និបន្នា ។

(៣៣៦) សទ្ធេយ្យវចសា នាម អាគតផលា អភិសមេតាវិនី វិញ្ញាតសាសនា ។ ឧបាសិកា នាម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា ។ ទិស្វាតិ បស្សិត្វា ។

(៣៣៧) តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា និសជ្ជំ ភិក្ខុ បដិជានមានោ តិណ្ណំ ធម្មានំ អញ្ញតរេន ការេតព្វោ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ តេន សោ ភិក្ខុ ការេតព្វោ ។



ដោយសសរក្ដី ដោយស៊ុមក្ដី ដោយវត្ថុណាមួយក្ដី ។ ពាក្យថា ល្មមនឹង (សេវកិច្ច) បាន គឺភិក្ខុអាចសេពមេថុនធម្មបាន ។ ពាក្យថា អង្គុយ គឺកាលបើមាតុគ្រាមអង្គុយហើយ ភិក្ខុទៅអង្គុយជិតក្ដី ដេកជិតក្ដី កាលបើភិក្ខុអង្គុយហើយ មាតុគ្រាមទៅអង្គុយជិតក្ដី ដេកជិតក្ដី អ្នកទាំងពីរអង្គុយក្ដី អ្នកទាំងពីរដេកក្ដី ។

(៣៣៦) ស្រីដែលមានផលមកហើយ (សម្រេចសោតាបត្តិផល) ត្រាស់ដឹងសច្ចៈបួន ស្គាល់សាសនាច្បាស់ ហៅថា មានពាក្យគួរជឿបាន ។ ស្រីដែលដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង ហៅថា ឧបាសិកា ។ ពាក្យថា ឃើញ គឺ មើលឃើញ ។

(៣៣៧) ឧបាសិកានោះ ចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺ អាបត្តិបារាជិកក្ដី សង្ឃាទិសេសក្ដី បាចិត្តិយក្ដី កាលភិក្ខុទទួលប្ដេជ្ញាការអង្គុយ (នោះមែន) ត្រូវប្រាប់ទោសដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺ អាបត្តិបារាជិកក្ដី សង្ឃាទិសេសក្ដី បាចិត្តិយក្ដី ម្យ៉ាងទៀត ឧបាសិកាមានពាក្យគួរជឿបាននោះ និយាយចោទដោយអាបត្តិណា ភិក្ខុនោះ ត្រូវប្រាប់ទោសដោយអាបត្តិនោះ ។

(៣៣៦) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ច[1] តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ច ឯវំ វទេយ្យ សច្ចាហំ និសិន្នោ នោ ច ខោ មេថុនំ ធម្មំ បដិសេវិន្តិ និសជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ច ឯវំ វទេយ្យ នាហំ និសិន្នោ អបិច ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ច ឯវំ វទេយ្យ នាហំ និសិន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៣៧) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ច តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។

---

[illegible]



(៣៣៦) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ហើយ លោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ។ ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ (ដែលភិក្ខុនោះ) ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាមហើយ ឯភិក្ខុនោះ ពោលយ៉ាងនេះថា អាត្មាអង្គុយមែន តែមិនសេពមេថុនធម្មទេ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ដោយការអង្គុយ ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះ ពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ តែជាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ដោយការដេក ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះ ពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ អាត្មាគ្រាន់តែឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

(៣៣៧) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ បើឧបាសិកានោះពោលយ៉ាងនេះថា

សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគ្គាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ចេ ឯវំ វទេយ្យ សច្ចាហំ និបន្នោ នោ ច ខោ មេថុនំ ធម្មំ បដិសេវិន្តិ និបជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគ្គាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ចេ ឯវំ វទេយ្យ នាហំ និបន្នោ អបិច ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគ្គាមស្ស មេថុនំ ធម្មំ បដិសេវន្តោតិ សោ ចេ ឯវំ វទេយ្យ នាហំ និបន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៣៨) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ច តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ



ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាដេកមែន តែអាត្មាមិនសេពមេថុនធម្មទេ វិន័យធរត្រូវធ្វើទោសដោយការដេក ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែអង្គុយ វិន័យធរត្រូវធ្វើទោសដោយការអង្គុយ ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែឈរ វិន័យធរមិនត្រូវធ្វើទោសឡើយ ។

(៣៣៨) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់កាយមាតុគ្រាម ឯភិក្ខុនោះទទួលប្ដេជ្ញាតាមនោះ វិន័យធរត្រូវធ្វើទោសតាមអាបត្តិ ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់កាយមាតុគ្រាម

សមាបជ្ជន្តោតិ សោ ចេ ឯវំ វទេយ្យ សច្ចាហំ និសិន្នោ នោ ច ខោ កាយសំសគ្គំ សមាបជ្ជិន្តិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៥៩) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគាមេន សទ្ធិំ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគាមេន សទ្ធិំ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ ឯវំ វទេយ្យ សច្ចាហំ និបន្នោ នោ ច ខោ កាយសំសគ្គំ សមាបជ្ជិន្តិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៦០) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ មាតុគាមេន សទ្ធិំ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសិន្នោតិ សោ ចេ តំ បដិជានាតិ



ឯភិក្ខុនោះពោលយ៉ាងនេះថា ករុណាអង្គុយមែន តែករុណាមិនបានចាប់ពាល់កាយមាតុគ្រាមទេ វិន័យធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។ បេ ។ ករុណាមិនមែនអង្គុយទេ តែជាករុណាដេក វិន័យធរត្រូវវិនិច្ឆ័យទោសដោយការដេក ។ បេ ។ ករុណាមិនមែនអង្គុយទេ តែជាករុណាឈរ វិន័យធរមិនត្រូវវិនិច្ឆ័យទោសឡើយ ។

(៣៥៩) បើស្ត្រីនោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់កាយមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាតាមពាក្យនោះ វិន័យធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ បើស្ត្រីពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់កាយមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា ករុណាដេកមែន តែករុណាមិនចាប់ពាល់កាយមាតុគ្រាមទេ វិន័យធរត្រូវវិនិច្ឆ័យទោសដោយការដេក ។ បេ ។ ភិក្ខុពោលថា ករុណាមិនមែនដេកទេ តែជាករុណាអង្គុយ វិន័យធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។ បេ ។ ករុណាមិនមែនដេកទេ តែជាករុណាឈរ វិន័យធរមិនត្រូវវិនិច្ឆ័យទោសឡើយ ។

(៣៦០) បើស្ត្រីនោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ(មេថុនកិច្ច)បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ

និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អហំ ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អហំ ខោ ឋិតោតិ ន ការេតព្វោ ។

[៣៦១] សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ មាតុគាមេន សទ្ធិំ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និបន្នោ សោ ចេ តំ បដិជានាតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អហំ ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អហំ ខោ ឋិតោតិ ន ការេតព្វោ ។

[៣៦២] អនិយតោតិ ន និយតោ បារាជិកំ វា សង្ឃាទិសេសោ វា បាចិត្តិយំ វា ។

[៣៦៣] គមនំ បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ នប្បដិជានាតិ និសជ្ជាយ ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ



វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។ បេ ។ អាត្មាមិនមែនអង្គុយទេ តែជាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។ បេ ។ ថា អាត្មាមិនមែនអង្គុយទេ តែជាអាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[៣៦១] បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង ដេកលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ(មេថុនកិច្ច)បាន ជាមួយនឹងមាតុគ្រាម តែម្នាក់ឯង បើភិក្ខុនោះទទួលប្រតិជ្ញាការដេកនោះ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក ។ បេ ។ អាត្មាមិនមែនដេកទេ តែជាអាត្មាអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ ។ បេ ។ អាត្មាមិនមែនដេកទេ តែជាអាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។

[៣៦២] ពាក្យថា អនិយត គឺមិនទៀងថាជាអាបត្តិបារាជិក ឬសង្ឃាទិសេស ឬបាចិត្តិយ ។

[៣៦៣] ភិក្ខុទទួលប្រតិជ្ញានូវកិរិយាដើរ ប្រតិជ្ញានូវកិរិយាអង្គុយ ប្រតិជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ ។ ភិក្ខុទទួលប្រតិជ្ញានូវកិរិយាដើរ មិនប្រតិជ្ញានូវកិរិយាអង្គុយ ប្រតិជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។ ភិក្ខុទទួលប្រតិជ្ញានូវកិរិយាដើរ ប្រតិជ្ញានូវកិរិយាអង្គុយ មិនប្រតិជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសដោយកិរិយាអង្គុយ ។ ភិក្ខុទទួលប្រតិជ្ញានូវកិរិយាដើរ មិនប្រតិជ្ញានូវកិរិយាអង្គុយ មិនប្រតិជ្ញានូវអាបត្តិ

នប្បដិជានាតិ ន ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ នប្បដិជានាតិ និសជ្ជាយ ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ នប្បដិជានាតិ ន ការេតព្វោ ។

បឋមោ អនិយតោ និដ្ឋិតោ ។



វិន័យធរមិនត្រូវធ្វើទោសឡើយ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិន័យធរត្រូវធ្វើទោសតាមអាបត្តិ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ តែប្តេជ្ញានូវអាបត្តិ វិន័យធរត្រូវធ្វើទោសតាមអាបត្តិ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិន័យធរត្រូវធ្វើទោសតាមការអង្គុយ ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិន័យធរមិនត្រូវធ្វើទោសឡើយ ។

អនិយតទី ១ ចប់ ។

## ទុតិយានិយតោ

(៣៦៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ ភគវតា បដិក្ខិត្តំ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេតុន្តិ តស្សាយេវ កុមារិកាយ សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ កាលយុត្តំ សមុល្លបន្តោ កាលយុត្តំ ធម្មំ ភណន្តោ ។ ទុតិយម្បិ ខោ វិសាខា មិគារមាតា និមន្តិតា តំ កុលំ អគមាសិ ។ អទ្ទសា ខោ វិសាខា មិគារមាតា អាយស្មន្តំ ឧទាយឹ តស្សាយេវ កុមារិកាយ សទ្ធឹ ឯកំ ឯកាយ រហោ និសិន្នំ ទិស្វាន អាយស្មន្តំ ឧទាយឹ ឯតទវោច ឥទំ ភន្តេ នច្ឆន្នំ នប្បតិរូបំ យំ អយ្យោ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ

## អនិយតទី២

(៣៦៦) សម័យនោះ ព្រះពុទ្ធដ៏មានបុណ្យសិរី គង់នៅក្នុងជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិដ៏មានអាយុគិតថា ការដែលភិក្ខុម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ(មេថុនកិច្ច)បាន ជាមួយនឹងមាតុគ្រាម តែម្នាក់ឯង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (គិតដូច្នេះ ឧទាយិនោះ) តែម្នាក់ឯង ទៅអង្គុយកន្លែងស្ងាត់ ជាមួយនឹងកុមារិកាតែម្នាក់ឯងដដែលនោះ និយាយសមគួរតាមកាល និយាយធម៌សមគួរតាមកាល ។ នាងវិសាខាជាមិគារ-មាតា គេបបួលអញ្ជើញទៅកាន់ត្រកូលនោះ អស់វារៈជាគំរប់ពីរដងទៀត ។ នាងវិសាខាជាមិគារមាតា បានឃើញឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយកន្លែងស្ងាត់ ជាមួយនឹងកុមារិកាម្នាក់ឯងដដែលនោះ លុះឃើញឧទាយិដ៏មានអាយុហើយ បាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន កម្មដែលលោកធ្វើនេះ មិនមែនជាកម្មស្អាតកំបាំងទេ មិនសមគួរទេ លោកម្ចាស់ម្នាក់ឯង ទៅអង្គុយកន្លែងស្ងាត់ ជាមួយនឹងមាតុគ្រាម តែម្នាក់ឯង

កប្បេតិ កិញ្ចាបិ ភន្តេ អយ្យោ អនត្ថិកោ តេន ធម្មេន អបិច ទុស្សទ្ធាបយា អប្បសន្នា មនុស្សាតិ ។ ឯវម្បិ ខោ អាយស្មា ឧទាយី វិសាខាយ មិគារមាតុយា វុច្ចមានោ នាទិយិ ។ អថខោ វិសាខា មិគារមាតា និក្ខមិត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយី មាតុគ្គាមេន សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឧទាយិ មាតុគ្គាមេន សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។ បេ ។ កថំ ហិ នាម ត្វំ មោឃបុរិស មាតុគ្គាមេន សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ ន ហេវ ខោ បន បដិច្ឆន្នំ អាសនំ ហោតិ នាលំកម្មនិយំ អលញ្ច ខោ ហោតិ



បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់មិន(ត្រូវការដោយ(មេថុន)ធម៌នោះក៏ពិតមែន តែជាមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ ។ ព្រះឧទាយីដ៏មានអាយុត្រូវនាងវិសាខាជាមិគារមាតាស្ដីឲ្យយ៉ាងនេះក៏ដោយ ក៏នៅតែមិនអើពើឡើយ ។ គ្រានោះឯង នាងវិសាខាជាមិគារមាតាចេញទៅហើយ ពិតដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរសោះ ព្រះឧទាយីមានអាយុម្នាក់ឯងនឹងនៅអង្គុយកន្លែងស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ។ ហើយភិក្ខុទាំងឡាយនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រះឧទាយី ឮថាអ្នកឯងតែម្នាក់ឯង នៅអង្គុយកន្លែងស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុណ្យសិរី ទ្រង់តិះដៀលថា ។ បេ ។ ម្នាលមោឃបុរស អ្នកតែម្នាក់ឯងមិនសមបើនឹងនៅអង្គុយកន្លែងស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯងសោះ ម្នាលមោឃបុរស កម្មដែលអ្នកធ្វើនេះមិននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះ យ៉ាងនេះថា អាសនៈដែលគេមិនបិទបាំងពិតមែន មិនល្មមធ្វើ(សេវនកិច្ច)បានទេ តែជាគួរអាចនឹងនិយាយ

មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិតុំ ។ យោ បន ភិក្ខុ តថារូបេ អាសនេ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា ទ្វិន្នំ ធម្មានំ អញ្ញតរេន វទេយ្យ សង្ឃាទិសេសេន វា បាចិត្តិយេន វា និសជ្ជំ ភិក្ខុ បដិជានមានោ ទ្វិន្នំ ធម្មានំ អញ្ញតរេន ការេតព្វោ សង្ឃាទិសេសេន វា បាចិត្តិយេន វា យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ តេន សោ ភិក្ខុ ការេតព្វោ ។ អយម្បិ ធម្មោ អនិយតោ ។

[៣៤៩] ន ហេវ ខោ បន បដិច្ឆន្នំ អាសនំ ហោតីតិ អប្បដិច្ឆន្នំ ហោតិ កុដ្ដេន វា កវាដេន វា កិលញ្ជេន វា សាណិបាការេន វា រុក្ខេន វា ថម្ភេន វា កោត្ថឡិយា វា យេន កេនចិ អប្បដិច្ឆន្នំ ហោតិ ។ នាលំកម្មនិយន្តិ ន សក្កា ហោតិ មេថុនំ ធម្មំ បដិសេវិតុំ ។ អលញ្ច ខោ ហោតិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិតុន្តិ សក្កា ហោតិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិតុំ ។



ដែលនឹងមាតុគ្រាមដោយវាចាអាក្រក់បាន ។ ភិក្ខុណាមួយ តែម្នាក់ឯងម្នាក់ អង្គុយក្នុងទីកំបាំងលើអាសនៈមានសភាពយ៉ាងនោះ ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានពាក្យគួរជឿបាន ឃើញភិក្ខុនោះហើយចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះ) ដែលសង្ឃត្រូវធ្វើដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេស ឬបាចិត្តិយ មួយទៀត ឧបាសិកាដែលមានសំដីគួរជឿបាននោះចោទដោយអាបត្តិណា ដែលសង្ឃត្រូវធ្វើដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ សូម្បីធម៌នេះ ក៏ឈ្មោះអនិយតដែរ ។

(៣៤៩) ត្រង់ពាក្យថា អាសនៈដែលគេមិនបានបិទបាំងទុកទេ សេចក្តីថា អាសនៈដែលមិនបិទបាំង ដោយជញ្ជាំងក្តី សន្ទះទ្វារក្តី កន្ទេលវែងក្តី កំពែងធ្វើដោយសំពត់ក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយស្មុកក្តី ឬអាសនៈមិនបានបិទបាំងដោយវត្ថុណាមួយ ។ ពាក្យថា មិនល្មមគួរ (សេពមេថុន) បាន គឺភិក្ខុមិនអាចនឹងសេពមេថុនធម្មបាន ។ ពាក្យថា តែជាល្មមនិយាយបែបនឹងមាតុគ្រាមដោយវាចាអាក្រក់បាន គឺភិក្ខុអាចនិយាយបែបនឹងមាតុគ្រាមដោយវាចាអាក្រក់បាន ។

(៣៦៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ តថារូបេ អាសនេតិ ឋារូបេ អាសនេ ។ មាតុគ្គាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិតទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកោ ឯកាយាតិ ភិក្ខុ ចេវ ហោតិ មាតុគ្គាមោ ច ។ រហោ នាម ចក្ខុស្ស រហោ សោតស្ស រហោ ។ ចក្ខុស្ស រហោ នាម ន សក្កា ហោតិ អក្ខឹ វា និខណិយមានេ ភមុកំ វា ឧក្ខិបិយមានេ សីសំ វា ឧក្ខិបិយមានេ បស្សិតុំ ។ សោតស្ស រហោ នាម ន សក្កា ហោតិ បកតិកថា សោតុំ ។ និសជ្ជំ កប្បេយ្យាតិ មាតុគ្គាមេ និសិន្នេ ភិក្ខុ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា ។ ភិក្ខុ និសិន្នេ មាតុគ្គាមោ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា ។ ឧភោ វា និសិន្នា ហោន្តិ ឧភោ វា និបន្នា ។



[៣៦៦] ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយដូចហើយក្នុងសិក្ខាបទមុន ។ ពាក្យថា លើអាសនៈមានសភាពយ៉ាងនោះ គឺលើអាសនៈដែលមានយ៉ាងនោះ ។ មនុស្សស្រី ហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី សត្វតិរច្ឆានញី មិនហៅថា មាតុគ្រាមទេ គឺស្រីដែលដឹងក្ដី អាចយល់ពាក្យជាសុភាសិតនឹងទុព្ភាសិត ពាក្យគ្រោតគ្រាតនឹងពាក្យល្អបាន ហៅថា មាតុគ្រាម ក្នុងទីនេះ ។ ពាក្យថា ជាមួយគ្នា គឺគង់ទីជាមួយ ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែភិក្ខុនឹងមាតុគ្រាមប៉ុណ្ណោះ ។ ទីកំបាំងភ្នែក ទីស្ដាប់ត្រចៀក ឈ្មោះថា ទីកំបាំង ។ បុគ្គលមិនអាចនឹងមើលឃើញផងទាំងឡាយ កាលបើចាក់ភ្នែកក្ដី ញាក់ចិញ្ចើមក្ដី ងើបក្បាលក្ដី ក្នុងទីណា ទីនោះហៅថា កំបាំងភ្នែក ។ ទីដែលបុគ្គលមិនអាចស្ដាប់ឮពាក្យប្រក្រតីបាន ហៅថា ទីស្ដាប់ត្រចៀក ។ ពាក្យថា នៅអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិតក្ដី ដេកជិតក្ដី ម្យ៉ាង: កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិតក្ដី ដេកជិតក្ដី ម្យ៉ាង អង្គុយទាំងពីរនាក់ក្ដី ដេកទាំងពីរនាក់ក្ដី ។

(៣៤៣) សទ្ធេយ្យវចសា នាម អាគតផលា អភិសមេតាវិនី វិញ្ញាតសាសនា ។ ឧបាសិកា នាម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា ។ ទិស្វាតិ បស្សិត្វា ។

(៣៤៤) ទ្វិន្នំ ធម្មានំ អញ្ញតរេន វទេយ្យ សង្ឃាទិសេ-សេន វា បាចិត្តិយេន វា និសជ្ជំ ភិក្ខុ បដិជានមានោ ទ្វិន្នំ ធម្មានំ អញ្ញតរេន ការេតព្វោ សង្ឃាទិសេសេន វា បាចិត្តិយេន វា យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ តេន សោ ភិក្ខុ ការេតព្វោ ។

(៣៤៥) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ច[1] តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគា-មេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ ឯវំ វទេយ្យ សច្ចាហំ និសិន្នោ នោ ច ខោ កាយសំសគ្គំ សមាបជ្ជឹ និសជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ

១ ម. ច ។



(៣៤៣) ឧបាសិកាដែលមានផលមកហើយ (សោតាបត្តិផល) ត្រាស់ដឹងសច្ចៈ ៤ ស្គាល់សាសនាច្បាស់ ហៅថា ឧបាសិកា មានសំដីគួរជឿបាន ។ ស្រីដែលដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង ហៅថា ឧបាសិកា ។ ពាក្យថា ឃើញ គឺបានប្រទះឃើញ ។

(៣៤៤) ឧបាសិកាពោលដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុកំពុងប្តេជ្ញាការអង្គុយ វិនយធរត្រូវឲ្យធ្វើដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកាមានសំដីគួរជឿបាននោះ ពោលដោយអាបត្តិណា វិនយធរត្រូវឲ្យធ្វើដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។

(៣៤៥) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ អង្គុយប៉ះពាល់កាយមាតុគ្រាម ឯភិក្ខុនោះប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវឲ្យធ្វើតាមអាបត្តិ ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនប៉ះពាល់កាយទេ វិនយធរត្រូវឲ្យធ្វើចំពោះតែការអង្គុយ ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា

អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ ឯវំ វទេយ្យ នាហំ និសិន្នោ អបិច ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និសិន្នោ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ ឯវំ វទេយ្យ នាហំ និសិន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៥០) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ និបន្នោ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោតិ សោ ចេ តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ បេ ។ សច្ចាហំ និបន្នោ ន ច ខោ កាយសំសគ្គំ សមាបជ្ជិន្តិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៥១) សា ចេ ឯវំ វទេយ្យ អយ្យស្ស មយា សុតំ និសិន្នស្ស មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្សាតិ សោ ចេ តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។





ខ្ញុំឃើញលោកម្ចាស់ប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក វិន័យធរត្រូវវិនិច្ឆ័យចំពោះការដេក ។ បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិន័យធរមិនគួរនឹងកាត់ (ឲ្យត្រូវអាបត្តិឡើយ) ។

(៣៥០) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកប៉ះពាល់មាតុគ្រាម បើភិក្ខុនោះប្តេជ្ញាការដេកនោះ វិន័យធរត្រូវកាត់ទោសតាមអាបត្តិ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំបានដេកមែន តែថាខ្ញុំមិនបានប៉ះពាល់កាយមាតុគ្រាមទេ វិន័យធរត្រូវវិនិច្ឆ័យចំពោះការដេក ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ វិន័យធរត្រូវកាត់ទោសចំពោះការអង្គុយ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិន័យធរមិនគួរកាត់ (អាបត្តិឡើយ ។

(៣៥១) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយនិយាយលែបខាយមាតុគ្រាមដោយពាក្យអាក្រក់ បើភិក្ខុនោះប្តេជ្ញាតាមពាក្យពោលនោះ វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។

សោ ចេ ឯវំ វទេយ្យ អយ្យស្ស មយា សុតំ និសិន្នស្ស មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្សាតិ សោ ចេ ឯវំ វទេយ្យ សច្ចាហំ និសិន្នោ នោ ច ខោ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិន្តិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៨៦) សោ ចេ ឯវំ វទេយ្យ អយ្យស្ស មយា សុតំ និបន្នស្ស មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្សាតិ សោ ចេ តំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ បេ ។ សច្ចាហំ និបន្នោ នោ ច ខោ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិន្តិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។



បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយ និយាយប៉ះពាល់មាតុគ្រាមដោយពាក្យអាក្រក់ បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនបាននិយាយប៉ះពាល់មាតុគ្រាមដោយពាក្យអាក្រក់ទេ នោះឲ្យសង្ឃត្រូវធ្វើវិន័យដោយការអង្គុយ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក ឲ្យសង្ឃត្រូវធ្វើវិន័យតាមការដេក ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ ឲ្យសង្ឃមិនត្រូវធ្វើវិន័យ (ឲ្យត្រូវអាបត្តិឡើយ) ។

(៣៨៦) បើឧបាសិកានោះ ពោលយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់ដេកនិយាយប៉ះពាល់មាតុគ្រាមដោយពាក្យអាក្រក់ បើភិក្ខុនោះប្តេជ្ញាតាមពាក្យពោលនោះ ឲ្យសង្ឃត្រូវធ្វើវិន័យដោយអាបត្តិ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំដេកមែន តែថាខ្ញុំមិនបាននិយាយប៉ះពាល់ (មាតុគ្រាម) ដោយពាក្យអាក្រក់ទេ ឲ្យសង្ឃត្រូវធ្វើវិន័យតាមការដេក ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនបានដេកទេ តែថាខ្ញុំអង្គុយ ឲ្យសង្ឃត្រូវធ្វើវិន័យតាមការអង្គុយ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនបានដេកទេ តែថាខ្ញុំឈរ ឲ្យសង្ឃមិនត្រូវធ្វើវិន័យ (ឲ្យត្រូវអាបត្តិឡើយ) ។

(៣៩៣) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសិន្នោតិ សោ ចេ តំ បដិជានាតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ និបន្នោតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និសិន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៩៤) សា ចេ ឯវំ វទេយ្យ អយ្យោ មយា ទិដ្ឋោ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និបន្នោតិ សោ ចេ តំ បដិជានាតិ និបជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ និសិន្នោតិ និសជ្ជាយ ការេតព្វោ ។ បេ ។ នាហំ និបន្នោ អបិច ខោ ឋិតោតិ ន ការេតព្វោ ។

(៣៩៥) អយម្បីតិ បុរិមំ ឧបាទាយ វុច្ចតិ ។ អនិយ-តោតិ ន និយតោ សង្ឃាទិសេសោ វា បាចិត្តិយំ វា ។



(៣៩៣) បើឧបាសិកានោះនិយាយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម គឺស្រីម្នាក់ បើភិក្ខុប្ដេជ្ញាតាមពាក្យនោះមែន ឲ្យសង្ឃត្រូវកាត់អាបត្តិ ចំពោះការអង្គុយ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំដេក ឲ្យសង្ឃត្រូវវិនិច្ឆ័យតាមការដេក ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ ឲ្យសង្ឃមិនត្រូវកាត់ (ឲ្យត្រូវអាបត្តិទៀតឡើយ) ។

(៣៩៤) បើឧបាសិកានោះនិយាយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង ដេកក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាម គឺស្រីម្នាក់ បើភិក្ខុនោះ ប្ដេជ្ញាការដេកនោះ ឲ្យសង្ឃត្រូវវិនិច្ឆ័យដោយការដេក ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ ឲ្យសង្ឃត្រូវកាត់អាបត្តិតាមអង្គុយ ។ បេ ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ ឲ្យសង្ឃមិនត្រូវកាត់ (ឲ្យត្រូវអាបត្តិទៀតឡើយ) ។

(៣៩៥) ត្រង់ពាក្យថា សូម្បីធម៌ គឺតថាគតពោលប្រៀបធៀបនឹងសិក្ខាបទមុន ។ ត្រង់ពាក្យថា អនិយត គឺមិនប្រាកដជាអាបត្តិសង្ឃាទិសេស ឬបាចិត្តិយ ។

[៣៥៦] គមនំ បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ បដិ-ជានាតិ អាបត្តិំ នប្បដិជានាតិ និសជ្ជាយ ការេតព្វោ ។ គមនំ បដិជានាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ នប្បដិជានាតិ ន ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ នប្ប-ដិជានាតិ អាបត្តិំ បដិជានាតិ អាបត្តិយា ការេតព្វោ ។ គមនំ នប្បដិជានាតិ និសជ្ជំ បដិជានាតិ អាបត្តិំ នប្ប-ដិជានាតិ និសជ្ជាយ ការេតព្វោ ។ គមនំ នប្បដិជា-នាតិ និសជ្ជំ នប្បដិជានាតិ អាបត្តិំ នប្បដិជានាតិ ន ការេតព្វោតិ ។

ចតុត្ថោ ខន្ធកោ និដ្ឋិតោ ។





[៣៥៦] ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ ឲ្យ-ធ្វើត្រូវវិន័យដោយអាបត្តិ ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ ឲ្យធ្វើត្រូវវិន័យដោយអាបត្តិ ។ ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ ឲ្យធ្វើត្រូវវិន័យដោយការអង្គុយ ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ ឲ្យធ្វើមិនត្រូវវិន័យអ្វីឡើយ ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ ឲ្យធ្វើត្រូវវិន័យដោយអាបត្តិ ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ ឲ្យធ្វើត្រូវវិន័យដោយអាបត្តិ ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ ឲ្យធ្វើត្រូវវិន័យដោយការអង្គុយ ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ នោះឲ្យធ្វើមិនត្រូវវិន័យ (អ្វីឡើយ) ។

ខន្ធកទី ៤ ចប់ ។

(៣៩៧) ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេ អនិយតា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

អនិយតកណ្ឌំ និដ្ឋិតំ ។

តស្សុទ្ទានំ

អលំកម្មនិយញ្ចេវ តថេវ ច ន ហេវ ខោ

អនិយតា សុបញ្ញត្តា ពុទ្ធសេដ្ឋេន តាទិនា ។

---



(៣៩៧) លោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះអនិយតធម៌ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈពីរដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរលោកម្ចាស់អស់វារៈបីដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ លោកម្ចាស់បរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះ បានជាលោកម្ចាស់ស្ងៀមនៅ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

អនិយតកណ្ឌ ចប់ ។

ឧទ្ទាននៃអនិយតកណ្ឌនោះ

អនិយតាបត្តិ (ពីរ) គឺ អលំកម្មនិយ ១ នាលំកម្មនិយ ១ ដែលព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ មានព្រះគុណធម៌ដ៏មាំមួន ទ្រង់បញ្ញត្តទុកល្អហើយ ។

# សង្ខេបផ្ដុំប្រាប់មាតិកា


| សេចក្ដី | លេខទំព័រ |
|---|---|
| **សង្ក្រាលេខទី ១** | ១ |
| រឿងសេចក្ដីសង្ខេបកិច្ច | ៣ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៦ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ | ៨ |
| បទភាជនីយ សុវត្ថិក | ៩ |
| បទភាជនីយ និយាយអំពីវណ្ណចក្ក | ១៣ |
| បទភាជនីយ និយាយអំពីពន្ធបត្ត | ១៥ |
| បទភាជនីយ និយាយអំពីចក្ខុមានទូលប្រគល់អំណាចសម្រេចដើម | ១៧ |
| ករណីផ្សេងអំពីអាបត្តិ | ៣០ |
| វិធីសត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់អក្សរ) | ៣៤ |
| វិធីសត្ថុ សំនៀងអំពីកិច្ច១ រួមកុលយល់សម្បត្តិជាដើម | ៣៩ |
| **សង្ក្រាលេខទី ២** | ៤៧ |
| រឿងនេតាយកិច្ច | [illegible] |
| សេចក្ដីបញ្ញត្តិ | ៤៨ |
| ចំណែកសិក្ខាបទ | [illegible] |
| បទភាជនីយ និយាយអំពីភិក្ខុបេយ្យាល | ៥៩ |
| បទភាជនីយ និយាយអំពីស្រីតែរគាត់ជាដើម | ៦៣ |
| សំនៀងអំពីករណីដែលមិនត្រូវអាបត្តិ | ៧០ |
| វិធីសត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់អក្សរ) | [illegible] |
| វិធីសត្ថុ រឿងភិក្ខុចាប់គល់ម្ដាយដោយសេចក្ដីស្រឡាញ់ជាដើម | ៧១ |

លេខទំព័រ

## សន្និបាតលេខទី ៣ ៨៦


រឿងរាជកិច្ច . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ . . . . . . . . . . ៩៨
ចំណែកសិក្ខាបទ . . . . . . . . . . 〃
បទភាជនីយ . . . . . . . . . . ៩៩
និយាយអំពីអ្វីៗដែលមិនត្រូវអាបត្តិ . . . . . . . . . . ៩៩
វិធីវត្ថុគាថា (មាតិកាវត្ថុ និងលំដាប់រឿងតាមរបៀបហ្វូវហេ) . . . . . . . . . . ១០០
វិធីវត្ថុ សំដែងអំពីស្រីម្នាក់ណ្ដាំសំពត់ឲ្យលក់ថ្មីជាដើម . . . . . . . . . . ១០១


## សន្និបាតលេខទី ៤ ១០៩


និទានរាជកិច្ច . . . . . . . . . . 〃
សេចក្តីបញ្ញត្តិសិក្ខាបទ . . . . . . . . . . ១០៩
សិក្ខាបទវិភង្គ បទភាជនីយ . . . . . . . . . . ១១១
បទភាជនីយ និយាយអំពីកិច្ចសង្ស័យជាដើម . . . . . . . . . . ១១៣
សំដែងអំពីអ្វីៗដែលមិនត្រូវអាបត្តិ . . . . . . . . . . ១១៦
វិធីវត្ថុគាថា (មាតិកាវត្ថុ និងលំដាប់រឿងតាមរបៀបហ្វូវហេ) . . . . . . . . . . 〃
វិធីវត្ថុ និយាយអំពីស្រីអាងជាដើម . . . . . . . . . . ១១៧


## សន្និបាតលេខទី ៥ ១២០


និទានរាជកិច្ច . . . . . . . . . . 〃
សេចក្តីបញ្ញត្តិជាដំបូង . . . . . . . . . . ១២៨
សេចក្តីបញ្ញត្តិជាបន្ទាប់ . . . . . . . . . . ១៣៣
បទភាជនីយ និយាយអំពីនិក្ខេបបទ . . . . . . . . . . 〃




លេខទំព័រ


ស្រីមាន ១០ ពួក . . . . . . . . . . ១៣៦
ភរិយាមាន ១០ ពួក . . . . . . . . . . 〃
និយាយអំពីវេស្សាបក្ខ . . . . . . . . . . ១៣៧
និយាយអំពីគរុបក្ខ . . . . . . . . . . ១៣៩
និយាយអំពីអ្វីៗដែលមិនត្រូវអាបត្តិ . . . . . . . . . . ១៤១
វិធីវត្ថុគាថា (មាតិកាវត្ថុ និងលំដាប់រឿងតាមលំដាប់ហ្វូវហេ) . . . . . . . . . . 〃
វិធីវត្ថុ និយាយអំពីរឿងស្រីលើកលក់ជាដើម . . . . . . . . . . 〃


## សន្និបាតលេខទី ៦ ១៤២


រឿងភិក្ខុនៅក្នុងដែនអាឡវី . . . . . . . . . . 〃
រឿងមហាកស្សបជាបរាជ . . . . . . . . . . ១៤៣
និយាយអំពីរឿងព្រះសម្ពុទ្ធ . . . . . . . . . . ១៤៨
និយាយអំពីរឿងកុលបុត្តឈ្មោះឥសិទាស . . . . . . . . . . ១៤០
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ១៤៣
សិក្ខាបទវិភង្គ និងសម្មតិវិធី . . . . . . . . . . ១៤៨
និយាយអំពីការសំដែងទីសម្គាល់ . . . . . . . . . . ១៤៧
បទភាជនីយ និយាយអំពីទីមិនមានសេចក្តីគ្រោះថ្នាក់ជាដើម . . . . . . . . . . ១៤៩
សំដែងអំពីអ្វីៗដែលមិនត្រូវអាបត្តិ . . . . . . . . . . ២២២


## សន្និបាតលេខទី ៧ ៦៦៣


រឿងឆន្នត្ថេរ . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ . . . . . . . . . . ២២៩

លេខទំព័រ

សិក្ខាបទវិភង្គ និយាយអំពីការសូមសង្ឃ ឲ្យមើលទីសង់វិហារ.......... ២២៨
សិក្ខាបទវិភង្គ និយាយអំពីវិហារធំ.......................... ២២៩
បទភាជនីយ និយាយអំពីវិហារសង្ឃមិនបានសំដែងទីឲ្យជាដើម.......... ២៣៣
សំដែងអំពីការៈដែលមិនត្រូវអាបត្តិ........................ ២៣៤

## សង្ឃាទិសេសទី ៨ ២៣៩

និទានព្រះទព្វត្ថេរ.......................... ២៣៩
និយាយអំពីការសន្មតិភិក្ខុជាអ្នកចាត់ចែងសេនាសនៈ និងសំពែងឡើងនូវភត្ត ២៤១
និទានមេត្តិយភុម្មជកភិក្ខុ.......................... ២៤៨
និទានមេត្តិយាភិក្ខុនី.......................... ២៥០
សេចក្តីបញ្ញត្តិ.......................... ២៥៥
ចំណែកសិក្ខាបទ.......................... ម
និយាយអំពីអធិករណ៍ ៤ យ៉ាង.......................... ២៥៦
បទភាជនីយ និយាយអំពីការចោទដោយការមិនឃើញជាដើម.......... ២៥៧
និយាយអំពីការៈដែលមិនត្រូវអាបត្តិ.......................... ២៦០

## សង្ឃាទិសេសទី ៩ ២៦១

និទានមេត្តិយភុម្មជកភិក្ខុ.......................... ម
សេចក្តីបញ្ញត្តិ.......................... ២៦៨
សិក្ខាបទវិភង្គ អធិករណ៍ជាចំណែកដទៃ.......................... ៗ
សិក្ខាបទវិភង្គ និយាយអំពីលេស ១០ យ៉ាង.......................... ២៦៩
បទភាជនីយ និយាយអំពីចំណែកនៃដទៃអាបត្តិករណ៍.......... ២៧០
បទភាជនីយ និយាយអំពីចោទអាបត្តិមានមូលមួយ ៗ.......... ២៧៧
សំដែងអំពីការៈដែលមិនត្រូវអាបត្តិ.......................... ២៨១



លេខទំព័រ

## សង្ឃាទិសេសទី ១០ ២៩១

និទានទេវទត្តភិក្ខុ.......................... ម
និយាយអំពីវត្ថុ ៥ យ៉ាង.......................... ២៩២
សេចក្តីបញ្ញត្តិ.......................... ២៩៩
ចំណែកសិក្ខាបទ.......................... ម
ការសូត្រសមនុភាសនកម្ម.......................... ៣០១
បទភាជនីយ.......................... ៣០២
និយាយអំពីអនាបត្តិ.......................... ៣០៣

## សង្ឃាទិសេសទី ១១ ៣០៤

និទានបក្ខានុវត្តកភិក្ខុ.......................... ម
សេចក្តីបញ្ញត្តិ.......................... ៣០៦
សិក្ខាបទវិភង្គ.......................... ៣០៧
ការសូត្រសមនុភាសនកម្ម.......................... ៣០៨
បទភាជនីយ និយាយអំពីការៈដែលត្រូវអាបត្តិ.......................... ៣០៩
សំដែងអំពីការៈដែលមិនត្រូវអាបត្តិ.......................... ៣១២

## សង្ឃាទិសេសទី ១២ ៣១៣

និទានឆន្នភិក្ខុ.......................... ម
សេចក្តីបញ្ញត្តិ.......................... ៣១៦
ការចែកសិក្ខាបទ.......................... ៣១៧
វិធីសូត្រសមនុភាសនកម្ម.......................... ៣១៨
បទភាជនីយ.......................... ៣២០
ការៈដែលមិនត្រូវអាបត្តិ.......................... ៣២១